ទស្សនាវដ្ដីមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៦ ខែតុលា ឆ្នាំ២០០៣

## មាតិកា

◆ សំបុត្រៈ កិច្ចការរៀបចំសាលាក្ដីខ្មែរក្រហមកំពុងតែដើរទៅមុខ..... ១

**ផ្នែកឯកសារ**

◆ ជីង ឈុនលាង អតីតលេខាទីពទូតនៅប្រទេសកូរ៉េ.................. ២

◆ ដូនបង ហែម ជាទីគោរពស្នេហា........................................ ៥

◆ បទខុទ្ទេសនាមរបស់សមមិត្ត ហ៊ុយ........................................ ៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១.......... ១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ជនរងគ្រោះដែលមានជីវិតនៅមន្ទីរស-២១........................ ១២

◆ បដិវត្តន៍បោកប្រាស់...................................................... ១៥

◆ បរាជ័យដោយសារការធ្វេសប្រហែស................................ ១៧

◆ នៅសល់តែបាតដៃទទេ.................................................. ៣៣

**ផ្នែកច្បាប់**

◆ គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌអន្តរជាតិ.......................... ៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ តុលាការប្រជាជននៅប្រទេសរ៉្វាន់ដា.................................. ៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ គ្រួសារខ្ញុំក្រោមរបបអន្ធការ.............................................. ៥៦

◆ សំពះតែរូបថត............................................................. ៥៨

◆ ម្ដាយខ្ញុំ......................................................................... ៦០





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ប៉ាង ពីវីន, ផាន់ សុខជា, លី សុខឃាង, អៀ ម៉េងទ្រី, មាស ប៊ុនថាន, យិន នាន, អ៊ីសា ឧស្មាន, ហ្សាល់ កាការីយ៉ា, និល គន្ធា, ហ៊ីវ៉ាន់ដូ មែនតូវ៉ានី, **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ផាត រចនា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

# *សំបុត្រៈ* កិច្ចការរៀបចំសាលាក្ដីខ្មែរក្រហមកំពុងតែដើរទៅមុខ

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ មានកិច្ចប្រជុំមួយនៅទីស្ដីការគណៈរដ្ឋមន្ត្រី រវាងក្រុមការងាររៀបចំសាលាក្ដីខ្មែរក្រហមនៃរាជរដ្ឋាភិបាលកម្ពុជានិងបណ្ដាប្រទេសដែលមានការចាប់អារម្មណ៍ក្នុងការជួយជាថវិកាដល់សាលាក្ដីនេះ ។ កិច្ចប្រជុំនេះមាន ឯកឧត្ដម ឱម យិនទៀង ជាគណៈអធិបតី ។ មានបញ្ហាជាច្រើនដែលត្រូវបានលើកយកមកពិភាក្សា ប៉ុន្ដែបញ្ហាដែលសំខាន់បំផុតមានចំនួនបីគឺៈ

◆ ទី១ បុគ្គលិកខ្មែរដែលនឹងត្រូវជ្រើសរើសឲ្យបំពេញការងារនៅក្នុងសាលាក្ដីខ្មែរក្រហម ។ ◆ ទី២ តួនាទីរបស់សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលក្នុងដំណើរការកាត់ទោស ។ ◆ ទី៣ ថវិកាសម្រាប់ដំណើរការកាត់ទោស ។

***អំពីបញ្ហាបុគ្គលិកខ្មែរៈ*** ដើម្បីធានាសមត្ថភាពនិងតម្លាភាព និងដើម្បីបង្កើនការទុកចិត្តនៅក្នុងដំណើរការតុលាការ ឯកឧត្ដម ឱម យិនទៀង បានមានប្រសាសន៍ថា “*ខ្មែរណាក៏ដោយមិនគិតថាខ្មែរនៅក្នុងឬក្រៅប្រទេស ឬមកពីគណបក្សនយោបាយណាទេ គឺអាចដាក់ពាក្យសុំធ្វើការនៅក្នុងសាលាក្ដីខ្មែរក្រហមបានដូចគ្នា*” ។ បច្ចុប្បន្នមានខ្មែរជាច្រើនកំពុងរស់នៅបរទេសដែលមានការរៀនសូត្រចេះដឹងគ្រប់គ្រាន់អាចជួយដល់ដំណើរការតុលាការនេះ ។

***ចំពោះបញ្ហាសង្គមស៊ីវិល*** ឯកឧត្ដមបានមានប្រសាសន៍ថា “*តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល គឺមានសារសំខាន់ណាស់*” ។ ម្យ៉ាងវិញទៀតការប្រើប្រាស់សេវាកម្មរបស់អង្គការក្រៅរដ្ឋាភិបាលដែលមានស្រាប់នោះ គឺអាចកាត់បន្ថយការចំណាយ ឧទាហរណ៍ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានសេវាកម្មស្វែងរកឯកសាររួចជាស្រេច ដូច្នេះតុលាការនឹងមិនចាំបាច់បង្កើតសេវាកម្មស្វែងរកឯកសារទាំងស្រុងនោះទេ ពោលគឺអាចកាត់បន្ថយការចំណាយផ្នែកនេះបានមួយចំនួនធំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងប្រគល់ឯកសារជូនដល់តុលាការទៅតាមសំណើនិងការព្រមព្រៀងមួយដ៏ត្រឹមត្រូវ ។

***បញ្ហាថវិកាសម្រាប់បម្រើឲ្យដំណើរការតុលាការៈ*** ឯកឧត្ដម នី តាយី អនុរដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា តុលាការត្រូវការប្រាក់៤០លានដុល្លារអាមេរិកសម្រាប់រយៈពេលបីឆ្នាំ ។ ក្នុងថវិកា៤០លានដុល្លារនេះ គឺខាងរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវ២០លានដុល្លារ ។ អង្គការសហប្រជាជាតិទទួលខុសត្រូវ២០លានដុល្លារ ។ ចំពោះរាជរដ្ឋាភិបាលកម្ពុជាទៅលើទឹកប្រាក់ចំនួន២០លានដុល្លារនេះគឺចំណាយសម្រាប់រយៈពេល៣ឆ្នាំ ។ ដូច្នេះក្នុងមួយឆ្នាំនឹងមានការចំណាយ៧លានដុល្លារ ។

អង្គប្រជុំក៏បានពិភាក្សាអំពីទីតាំងរបស់តុលាការដែលមានជម្រើសបី គឺទី១មជ្ឈមណ្ឌលសន្និសីទអន្ដរជាតិដែលសង់មិនទាន់រួចនៅត្រើយទន្លេខាងកើត ទី២ សាលសន្និសីទចតុមុខដែលជាកន្លែងធ្លាប់កាត់ទោសម្ដងកាលពីឆ្នាំ១៩៧៩ និងទីបីអគារគណៈកម្មការទន្លេមេគង្គដែលនឹងដកចេញពីកម្ពុជានៅក្នុងពេលឆាប់ៗនេះ ។

តំណាងប្រទេសជប៉ុនបាននិយាយថា ជប៉ុនមិនទាន់មានជំហរថានឹងជួយជាថវិកាប៉ុន្មាននៅឡើយទេ ដរាបណារាជរដ្ឋាភិបាលមិនទាន់មានការព្រមព្រៀងជាមួយអង្គការសហប្រជាជាតិអំពីថវិការួមពីព្រោះការពិភាក្សា នៅថ្ងៃនេះគឺជាសេចក្ដីព្រាងថវិកាខាងកម្ពុជា ។ តំណាងប្រទេសអូស្ដ្រាលីបាននិយាយថា អូស្ដ្រាលីបានតម្កល់ប្រាក់រួចជាស្រេចហើយដើម្បីជួយដល់ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ចំណែកតំណាងប្រទេសអង់គ្លេសសន្យាថានឹងជួយប៉ុន្ដែក៏មិនបានបញ្ជាក់អំពីចំនួនទឹកប្រាក់ដែរ ។ ទាំងអស់គ្នាសង្ឃឹមថាពេលប្រជុំខែក្រោយនៅពេលដែលតំណាងអង្គការសហប្រជាជាតិមកប្រទេសកម្ពុជា គឺថ្ងៃទី១០ ខែវិច្ឆិកា ។ រាជរដ្ឋាភិបាលកម្ពុជានឹងមានគម្រោងថវិកាលម្អិតហើយច្បាស់លាស់ជាងនេះទៅទៀត ។ ឯកឧត្ដម ឱម យិនទៀង បានបញ្ជាក់បន្ថែមថា “*នៅពេលដែលសភាថ្មីមានរូបរាងឡើង ច្បាប់ខ្មែរក្រហមគឺជាអាទិភាពទីមួយដែលដាក់ស្នើទៅរដ្ឋសភាដើម្បីសុំសច្ចាប័ន*” ។

មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែមានជំហរមួយថានឹងផ្ដល់ឯកសារជូនទៅគ្រប់ទិសទីទាំងអស់ដើម្បីការពិតនិងយុត្តិធម៌ ។ យើងត្រៀមរួចជាស្រេចចំពោះឯកសារដែលយើងមានសម្រាប់ផ្ដល់ជូនទៅសាលាក្ដី អង្គការផ្សេងៗ ឬអ្នកសារព័ត៌មាន ។ ការបង្ហាញការពិតដល់សាធារណជននោះគឺជាវិធីមួយក្នុងការដោះស្រាយបញ្ហាទំនាស់ដែលមានពីអតីតកាលក៏ដូចជាការផ្ដល់យុត្តិធម៌ជូនដល់ជនរងគ្រោះ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ជីង ឈុនលាង អតីតលេខាទី៣ ទូតប្រទេសកម្ពុជាប្រចាំនៅប្រទេសកូរ៉េ


ជីង ឈុនលាង

ជីង ឈុនលាង ជានិស្សិតខ្មែរមួយរូបដែលបានទទួលអាហារូបករណ៍ទៅរៀននៅសភាពសូវៀត និងក្រោយមកបានក្លាយជាលេខាធិការទី៣នៃស្ថានទូតខ្មែរប្រចាំនៅប្រទេសកូរ៉េ ។ ឈុនលាង បានត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៦ ហើយត្រូវអង្គការចាប់ខ្លួននិងកម្ទេចចោល ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ឈុនលាង ដែលសួរដោយឈ្មោះ ពូល ផាលី នៅមន្ទីរស-២១ ចាប់ពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៧ និងកត់ត្រាចម្លើយដោយឈ្មោះ យីវ ស្រ៊ុ ÷

ឈុនលាង មានស្រុកកំណើតនៅភូមិមេមត់ ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម ។ ឪពុកម្តាយគឺជាម្ចាស់បណ្ណាគារឯកជនមួយនៅផ្សារថ្មីក្រុងភ្នំពេញ ។ ពីឆ្នាំ១៩៥១ រហូតដល់ឆ្នាំ១៩៥៧ ឈុនលាង រៀននៅសាលាហ្វ្រង់ស្វាបូឌ្វាំង និងសាលាព្រះជ័យចេស្តានៅភ្នំពេញ ។ នៅឆ្នាំ១៩៥៨ ឈុនលាង រៀនថ្នាក់ទី៦នៅវិទ្យាល័យស៊ីសុវត្ថិ ។ នៅឆ្នាំ១៩៥៩ ឈុនលាង ផ្លាស់ទៅរៀនថ្នាក់ទី៥នៅវិទ្យាល័យព្រះយុគន្ធរ ។ ចាប់តាំងពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៥ ទម្រាំតែទទួលបានសញ្ញាប័ត្របាក់ឌុប ឈុនលាង ត្រូវប្តូរសាលាជាច្រើនដូចជា អនុវិទ្យាល័យឯកជនប្រសើរសិក្សា វិទ្យាល័យថាច់ង៉ុកក្វាន់ វិទ្យាល័យស៊ីសុវត្ថិ និងសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។

នៅឆ្នាំ១៩៦៥ ឈុនលាង បានទទួលអាហារូបករណ៍ពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំជាតិ ទៅបន្តការសិក្សាផ្នែកសំណង់ទំនប់ទឹកនៅសហភាពសូវៀត ។ នៅខែតុលាឆ្នាំ១៩៦៥ ឈុនលាង បានចេញដំណើរពីភ្នំពេញទៅមូស្គូ ។

**ទំនាក់ទំនងជាមួយអង្គការសហព័ន្ធនិស្សិតកម្ពុជា (អ៊ុយ.អឺ.សេ)**

មកដល់ព្រលានយន្តហោះឈីរីមិនយេវ៉ូនៃសហភាពសូវៀត ឈុនលាង បានទទួលការស្វាគមន៍ពីសំណាក់តំណាងអង្គការសហព័ន្ធនិស្សិតកម្ពុជា ឬហៅថាអង្គការ អ៊ុយ.អឺ.សេ រួមមានឈ្មោះ ១) ហាក់ សៀងឡាយនី ២) ប៉ែន ថុងអាន ៣) ម៉ែន មុនីវ៉ាម ៤) មាស ប៊ុនឈួយ ៥) ជ័យ រ៉េត និង ៦) អៀង សីហា ។ ឈុនលាង ចូលរៀននៅសាលាតាស្កិលានៅក្នុងរដ្ឋអ៊ុយបេគីស្តង់ ។ នៅក្នុងខែ១០ ឆ្នាំ១៩៦៥ ម៉ែន មុនីវ៉ាម, មាស ប៊ុនឈួយ និង ជ័យ រ៉េត ព្យាយាមឃោសនាអូសទាញឲ្យ ឈុនលាង និងនិស្សិតខ្មែរពីររូបទៀតគឺ អ៊ុក ស៊ុក និង ឡាំ វីរី ។ បន្តិចម្តងៗ ឈុនលាង មានការទុកចិត្តនិងស្រឡាញ់អង្គការ អ៊ុយ.អឺ.សេ ។ ខែមិថុនា ឆ្នាំ១៩៦៦គឺជាពេលវិស្សមកាល ឈុនលាង ត្រូវចាកចេញពីសាលាតាស្កិលាដោយមូលហេតុរញ្ជួយដី ហើយទៅបន្តការសិក្សានៅឯប៉ែលឡារុស្ស៊ី ។ ឈុនលាង មិនចង់ទៅទីនោះទេ គឺចង់នៅទីក្រុងមូស្គូដើម្បីបានរស់នៅជួបជុំជាមួយក្រុមគ្រួសារ ។ ឈុនលាង បានទៅសុំជំនួយពីក្រសួងសេនាធិការជាតិសូវៀតនិងបានពឹងពាក់ ជ័យ រ៉េត ជាតំណាងអ៊ុយ.អឺ.សេឲ្យជួយអន្តរាគមន៍ក្នុងរឿងនេះ ហើយក៏បានទទួលសិទ្ធិរស់នៅទីក្រុងមូស្គូ ។ ដោយសារតែហេតុនេះហើយដែលធ្វើឲ្យ ឈុនលាង កាន់តែពេញចិត្តនិងជឿជាក់លើកម្លាំងអ៊ុយ.អឺ.សេ ។

ដោយសារមានការបំពាក់បំប៉នមនោគមន៍វិជ្ជាពីសំណាក់សមាជិកជាច្រើនរបស់ក្រុមអ៊ុយ.អឺ.សេ ឈុនលាង បានសម្រេច

ចិត្តចូលជាសមាជិកក្រុមនេះនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ តាមរយៈ ជ័យ រ៉េត ។ ឈុនលាង បញ្ជាក់ថា អ៊ុយ.អឺ.សេគឺជាអង្គការរបស់កា.ហ្សេ.បេ ។

### ផែនការ

បន្ទាប់ពីចូលជាសមាជិកក្នុងក្រុម អ៊ុយ.អឺ.សេ ក្នុងឆ្នាំ១៩៦៧ ឈុនលាង បានចូលរួមក្នុងអង្គប្រជុំធំៗដែលនិយាយអំពីគម្រោងសកម្មភាពរបស់អង្គការ ។ នៅក្នុងឆ្នាំដដែលនៅសាលា មេអ៊ី នៅទីក្រុងមូស្គូ មានការប្រជុំដាក់ផែនការចំពោះសមាជិកជាភ្នាក់ងារ កា.ហ្សេ.បេ ដែលមាន ជ័យ រ៉េត ជា (ប្រធានអង្គប្រជុំ), យូ ស៊ីមហ៊ុន (និស្សិតវិស្វករកសិកម្ម ជាអនុប្រធាន), ហេង ពេជ្រ (និស្សិតវិស្វករសំណង់) និង ឈុនលាង ជាសមាជិក ។ ជ័យ រ៉េត បានដាក់ផែនការចំនួន៣ឲ្យសមាជិកក្នុងក្រុមអនុវត្ត គឺ១) ទាក់ទាញនិស្សិតកម្ពុជានៅបរទេស ពិសេសនៅសូវៀតឲ្យចូលអង្គការអ៊ុយ.អឺ.សេ ២) ឃោសនាលើកឥទ្ធិពលសូវៀតដូចជាអួតសសើរអំពីការលូតលាស់លើវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយសម្រាប់គំរូកសាងកម្ពុជាទៅថ្ងៃមុខ និង៣) រក្សាសាមគ្គីភាពឲ្យបានក្នុងជួរអង្គការកា.ហ្សេ.បេ នៅក្រៅប្រទេសក៏ដូចនៅក្នុងប្រទេស ។

នៅក្នុងឆ្នាំ១៩៦៨ ឈុនលាង បានអូសទាញឈ្មោះ អួង ខេង (និស្សិតច្បាប់អន្តរជាតិ) និង កែ គីយុន ដែលធ្លាប់រស់នៅប្រទេសសូវៀតស្រាប់ ឲ្យចូលជាសមាជិក ។ ឆ្នាំ១៩៦៩ នៅសាលាមេអ៊ីដដែល ជ័យ រ៉េត បានហៅសមាជិកដែលមានឈ្មោះដូចរាយខាងលើមកប្រជុំដើម្បីទទួលផែនការថ្មីចំនួន៥ទៀតគឺ ១) ស្កាត់រកមិត្តភក្តិតាមខ្សែរយៈចាត់តាំងពីមុនដែលបានចូលមកប្រទេសកម្ពុជាមុន ដើម្បីឲ្យមិត្តទាំងនេះជួយណែនាំបន្ត ។ ២) បើធ្វើការនៅក្រសួងណា ត្រូវបំផុសឲ្យមានចលនាទាមទារសិទ្ធិយុត្តិធម៌ជាប្រាក់ខែនិងជីវភាពរស់នៅ ឲ្យមានការធានាពីរដ្ឋាភិបាល ។ ៣) បង្កប់បក្ខពួកក្រុមកា.ហ្សេ.បេ នៅតាមគ្រប់ក្រសួងសំខាន់ៗក្នុងការប្រមូលកម្លាំងគ្នាទៅអនាគត ដើម្បីផ្លាស់ប្តូរសង្គមកម្ពុជា ដោយមិនបាច់ប្រើអាវុធក្នុងការដណ្តើមអំណាច ។ ៤) រក្សាសាមគ្គីឲ្យបានជិតស្និទ្ធ និងធ្វើសហប្រតិបត្តិការជាមួយសូវៀត វៀតណាម ឡាវ ។ ៥) ក្នុងជួរបក្សក្រុមកា.ហ្សេ.បេត្រូវពង្រីកបន្ថែមទៀត ត្រូវស្តាប់បញ្ជានិងវិន័យឲ្យបានទៀងទាត់តាមលំដាប់លំដោយ ។

នៅខែមិថុនា ឆ្នាំ១៩៧០ នៅឯសណ្ឋាគារ យុយយី នាទីក្រុងប៉េកាំង ហាក់ សៀងឡាយនី (រដ្ឋលេខាធិការក្រសួងការបរទេស) បានកោះហៅសមាជិកពីសហភាពសូវៀត មកប្រជុំជាមួយសមាជិកនៅប៉េកាំងរួមមាន គ្រិន លាន, តាន់ ឆៃហេង (វិស្វករ) ថាច់ សួង (សាស្ត្រាចារ្យផ្នែកភាសា) យូ ស៊ីមហ៊ុន, គាំ លាងហាក់ (វេជ្ជបណ្ឌិត) ហេង ពេជ្រ (រដ្ឋលេខាធិការសព្វាវុធ) និង ជីង ឈុនលាង ។ ហាក់ សៀងឡាយនី បានដាក់ផែនការចំនួន៤គឺ ទី១) ចាត់តាំងភ្នាក់ងារកា.ហ្សេ.បេឲ្យនៅគ្រប់ក្រសួងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប៉េកាំងសម្រាប់ចូលក្នុងប្រទេស ។ ទី២) ទាក់ទាញប្រមូលផ្តុំកម្លាំងបន្ថែមទៀតក្នុងក្រុមកា.ហ្សេ.បេ និងចាត់ឲ្យមានភ្នាក់ងារតូច-ធំ តាមការចេះដឹងនៅក្នុងក្រសួងនីមួយៗ ។ ទី៣) ត្រូវកម្ចាត់ពួកធ្វើការឲ្យរបបចាស់ចោល និង ទី៤) ឃោសនាពន្យល់ឥទ្ធិពលសូវៀតឲ្យអ្នកដទៃយល់ពីសង្គមកម្ពុជាទៅអនាគត ដែលនឹងមានលក្ខណៈសង្គមនិយមដូចនៅសូវៀតដែរ ។

នៅខែសីហា ឆ្នាំ១៩៧០ ប៉ែន វ៉ូសែ បានកោះហៅសមាជិកក្រុមកា.ហ្សេ.បេ មកប្រជុំនៅសណ្ឋាគារ យុយយី នៅទីក្រុងប៉េកាំងម្តងទៀតអំពីសមាជិកដែលត្រូវទៅបំពេញភារកិច្ចនៅក្រៅប្រទេស ។ អ្នកដែលចូលរួមមាន ប៉ែន វ៉ូសែ រដ្ឋលេខាធិការក្រសួងអប់រំជាតិ, ហេង ពេជ្រ រដ្ឋលេខាធិការក្រសួងសព្វាវុធ, យូ ស៊ីមហ៊ុន, គាំ លៀងហាក់ លេខាធិការទី២នៅប៉េកាំង និង ជីង ឈុនលាង លេខាធិការទី៣នៅប្រទេសកូរ៉េ ។ ផែនការថ្មីគឺ១) ជួយបញ្ចុះបញ្ចូលឯកអគ្គរាជទូត អាំង គីមឃន ឲ្យនៅក្រោយឥទ្ធិពលនិងកុំឲ្យជំទាស់ ជួន ម៉ុម ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ២) ទាក់ទងនិស្សិតកម្ពុជានៅកូរ៉េ និងអូសទាញនិស្សិតទាំងនោះឲ្យចូលក្រុម អ៊ុយ.អឺ.សេ ហើយឃោសនាពីឥទ្ធិពលសូវៀត ដែលជួយទំនុកបម្រុងកម្ពុជាតាមរយៈវៀតណាម ៣) លើកឥទ្ធិពលរបស់ក្រុមអ៊ុយ.អឺ.សេ ដែលមាន ជួន ម៉ុម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ជាអ្នកស្នេហាជាតិពិតប្រាកដត្រឹមត្រូវបរិសុទ្ធតស៊ូយូរអង្វែងរហូតមក និង៤) សុំជំនួយពី ប៉ែន វ៉ូសែ

*នៅទីស្នាក់ការកណ្តាលប៉េកាំងបើមានបញ្ហាដោះស្រាយមិនរួច ។ ក្នុងឆ្នាំ១៩៧៣ក្រុមអ៊ីយ.អឺ.សេបានដាក់ផែនការត្រៀមចូលមកកម្ពុជា ។ ប៉ែន នូវែ បានដាក់ផែនការ៤ឲ្យ ជីង ឈុនលាន និង ហេង ពេជ្រ អនុវត្តនៅកម្ពុជាគឺ ១) រៀបចំក្រុមអ៊ីយ.អឺ.សេឲ្យមានគ្រប់ក្រសួងដូចនៅប៉េកាំងជួយអូសទាញគ្នាទៅវិញទៅមកក្នុងការប្រមូលកម្លាំងនៅជុំវិញក្រុម ២) ទាក់ទងនិងសហការជាមួយស្ថានទូតសូវៀតប្រចាំនៅកម្ពុជា ៣) ត្រូវរក្សាការទាក់ទងគ្នាជាផ្លូវការនិងក្រៅផ្លូវការឲ្យបានជិតស្និទ្ធបន្ថែមទៀត ពោលគឺអ្នកដែលចូលមកកម្ពុជាមុន ត្រូវពន្យល់កិច្ចការដល់អ្នកដែលទៅក្រោយ និងត្រូវចេះស្កាត់រកសមាជិកក្រុមរបស់ខ្លួន និង ៤) ត្រូវរង់ចាំបញ្ជាជានិច្ច ព្រោះផែនការថ្មីៗទៀតអាចមានការផ្លាស់ប្តូរច្រើនតាមរយៈសមាជិកក្រុមមាន ដួន ម៉ុម ជាមេធំ អាស្រ័យទៅតាមការដាក់ស្តែងនៅកម្ពុជា ។*

## *ភារកិច្ចរបស់និស្សិតបរទេសដែលជាសមាជិក កា.ហ្វេ.បេ នៅសហភាពសូវៀត*

*សមាជិកទាំងអស់នៅក្នុងក្រុមកា.ហ្វេ.បេត្រូវប្រកាន់ខ្ជាប់នូវភារកិច្ច៤គឺ ទី១) ត្រូវមានជំនឿជឿជាក់លើជ័យជម្នះនៃលទ្ធិម៉ាកឡេនីននិយមក្នុងសាកលលោក ក្នុងការប្រណាំងប្រជែងជាមួយនឹងមូលធននិយមនិងចក្រពត្តិនិយម ២) ជឿជាក់លើភារកិច្ចអន្តរជាតិនិយម វណ្ណៈអធនរបស់គណបក្សកុម្មុយនិស្តសូវៀតដែលដើរជួរមុខគេបង្អស់ក្នុងការរំដោះប្រជាជនសកលលោកទាំងមូលឲ្យផុតពីការជិះជាន់រវាងមនុស្សនិងមនុស្ស ក្នុងការកសាងកុម្មុយនិស្តនិយមនៅក្នុងសាកលលោក ៣) នៅក្នុងសហភាពសូវៀត សមាជិកកា.ហ្វេ.បេមានភារកិច្ចផ្សព្វផ្សាយអំពីវប្បធម៌សូវៀត បញ្ចុះបញ្ចូលនិស្សិតបរទេសឯទៀត បំពាក់នូវមនោគមវិជ្ជាសូវៀត ស្រឡាញ់ចូលចិត្តរបៀបរស់នៅ ស្រឡាញ់ជីវភាពរស់នៅដូចសង្គមរបស់សូវៀត បំពាក់គោលជំហរនយោបាយដូចសូវៀត និង ៤) នៅក្នុងមាតុប្រទេសរបស់ខ្លួន សមាជិកម្នាក់ៗត្រូវធ្វើការឃោសនាផ្សព្វផ្សាយអំពីជីវភាពក្នុងសង្គមសូវៀតបំពាក់នូវគោលនយោបាយសូវៀតទាំងខាងក្នុងប្រទេសទាំងខាងក្រៅប្រទេស ដើម្បីឲ្យមហាជនទទួលយកមនោគមវិជ្ជាសូវៀត ។*

## ទីបញ្ចប់របស់ ជីង ឈុនលាន

*ឈុនលាន បានទទួលបញ្ជាពីអង្គការក្នុងប្រទេសឲ្យវិលត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦ ។ ក្រោយមក ឈុន លាន បានធ្វើដំណើរចាកចេញពីប្រទេសកូរ៉េមកស្នាក់នៅស្ថានទូតកម្ពុជាប្រចាំប្រទេសចិន នៅទីក្រុងប៉េកាំងនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៦ ហើយបានធ្វើដំណើរមកប្រទេសកម្ពុជានៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ។ មកដល់ប្រទេសកម្ពុជា ឈុនលាន ត្រូវបានអង្គការបញ្ជូនមកនៅមន្ទីរក-១៥ ឬហៅថាសាកលវិទ្យាល័យបច្ចេកទេសមិត្តភាពខ្មែរសូវៀតរហូតដល់ថ្ងៃទី២៨ ខែសីហាឆ្នាំ១៩៧៦ ។ ពីមួយថ្ងៃទៅមួយថ្ងៃបន្ទាប់ពីវិលត្រឡប់មកស្រុកវិញ ឈុនលាន ចេះតែនឹកសង្ឃឹមថាអង្គការនឹងចាត់តាំងខ្លួនឲ្យចូលធ្វើការ ប៉ុន្តែផ្ទុយទៅវិញ ឈុនលាន បែរជាត្រូវបញ្ជូនមកមន្ទីរស-២១នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ។*

## ប្រវត្តិរូបសង្ខេបនៃក្រុមគ្រួសាររបស់ ជីង ឈុនលាន

- *ឪពុកឈ្មោះ ជីង អ៊ីវ មានដើមកំណើតនៅព្រែកចង្ក្រាន ខេត្តព្រៃវែង ។*
- *ម្តាយឈ្មោះ ជីង យ៉េត មានដើមកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ។*
- *មុខរបររបស់ឪពុកម្តាយជាអ្នកលក់សៀវភៅបណ្ណាគារឯកជននៅផ្សារថ្មី ក្រុងភ្នំពេញ ។*
- *នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាកសិករនៅភូមិតាឡី ផ្នែកកសិកម្ម ។*
- *មានបងប្អូនប្រាំបីនាក់ (ប្រុស២ ស្រី៦) ។*

**ផាត រចនា**

## ពាក្យស្លោកខ្មែរក្រហម

◆ **ដរាបណាក៏ត្រូវបង្រួបរួមជាស្រេច ផ្តាច់ចិត្តប្រឆាំងនឹងសតិអារម្មណ៍និងការប្រព្រឹត្តិដែលមានមហន្តរាយ ដើម្បីការពារគោលការណ៍របស់បក្ស ដើម្បីពង្រីកជីវភាពសម្ពហភាពរបស់បក្ស ចំណងរវាងបក្សនិងមហាជន។**

*(កំណត់ហេតុលេខ១០១៤)*

*(ឯកសារក្រសួងពាណិជ្ជកម្មខ្មែរក្រហម)៖ លេខ.០១៤,៧៦,KO*

# ជូនបង ហែម ជាធីគោរពស្នេហា

***សេចក្តីរាយការណ៍អំពីមិត្តកូរ៉េស្នើជួបនៅក្រសួងពាណិជ្ជកម្ម ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦ វេលាម៉ោង៨ៈ០០ដល់៨ៈ៤៥ នាទី ។ ខាងយើងមាន សមមិត្តហុង សមមិត្តស៊ូ និង សមមិត្ត ហ៊ីន ។ ខាងមិត្តកូរ៉េមានសមមិត្តលេខាធិការទី២និងទី៣ ។***

**មតិមិត្តកូរ៉េៈ**

១) បញ្ហាចុះហត្ថលេខាស្តីអំពីការដោះដូរពាណិជ្ជកម្មរវាងកម្ពុជា-កូរ៉េសម្រាប់ឆ្នាំ ១៩៧៧ តើចុះនៅប្រទេសកម្ពុជាឬនៅប្រទេសកូរ៉េ យើងចង់ដឹងឆាប់ ។

**មតិយើងៈ**

យើងរាយការណ៍ជូនអង្គការហើយ ដោយអង្គការមានការរវល់ពេកទើបមិនទាន់បានឆ្លើយ ដូច្នេះចាំយើងរាយការណ៍ជូនអង្គការម្តងទៀត ចាំជូនដំណឹងនៅពេលក្រោយ ។

**មតិកូរ៉េៈ**

២) អំពីបញ្ហាម៉ាស៊ីនបូមទឹក១៧៥ គ្រឿងសម្រាប់ឆ្នាំ ១៩៧៧ យើងបានទទួលទូរលេខពីរដ្ឋាភិបាលថាបានរៀបចំក្នុងផែនការស្រេច ។

ក្រោយពីបានជួបពិភាក្សាថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦ ជាមួយមិត្តកម្ពុជាហើយ យើងបានរាយការណ៍ទៅក្នុងប្រទេស ដូច្នេះបញ្ហាម៉ាស៊ីនបូមទឹកនេះគណៈកម្មការរដ្ឋចាត់ចែងខាងផែនការ ហើយគណៈកម្មការនេះក៏បានសម្រេចចំនួន១៧៥ គ្រឿង មានទំហំដូចតទៅៈ

ទំហំៈ ២០០ម.ម ចំនួន ១០០គ្រឿង

៣០០ម.ម ចំនួន ៣៥គ្រឿង

៧០០ម.ម ចំនួន ៤០គ្រឿង

***សរុបៈ*** ចំនួន១៧៥គ្រឿង ដើម្បីយើងរាយការណ៍ទៅក្នុងប្រទេសយើងម្តងទៀត តើមិត្តកម្ពុជាសម្រេចយ៉ាងណា ។

**មតិយើងៈ**

ដូចមិត្តកូរ៉េជ្រាបស្រាប់ហើយ ក្រោយពីសង្គ្រាមដ៏វិនាសកម្មរបស់ចក្រពត្តិប្រទេសយើងមានការខ្វះខាតនូវដើមទុនជាច្រើនដើម្បីទិញសម្ភារស្តារសេដ្ឋកិច្ចនិងកសាងប្រទេស ម្យ៉ាងទៀតផលិតផលរបស់យើងក៏នៅមានការខ្វះខាតច្រើនបើប្រៀបធៀបចំនួនដែលយើងត្រូវការ ។ ពិសេសបញ្ហាពាណិជ្ជកម្មជាបញ្ហាបន្ទាប់បន្សំ ឯបញ្ហានយោបាយយុទ្ធមិត្តកម្ពុជា-កូរ៉េជាបញ្ហាធំ ។

យើងចាំមិនភ្លេចទេដែលប្រទេសកូរ៉េបានជួយយើងក្នុងពេលសង្គ្រាមឈ្លានពានរបស់ចក្រពត្តិ ក៏ដូចក្នុងពេលបច្ចុប្បន្ននេះដែរ ។ បន្ថែមលើនេះប្រជាជនយើង និងបក្សយើងទាំងពីរបានស្គាល់ចិត្តថ្លើមគ្នាយ៉ាងច្បាស់លាស់ ។

សរុបមកវិញ បញ្ហានេះចាំយើងរាយការណ៍ជូនអង្គការម្តងទៀត និងពិគ្រោះគ្នាពេលក្រោយ ។

**មតិកូរ៉េៈ**

ក្នុងឆ្នាំ១៩៧៧ យើងមានគ្រោងការទិញកៅស៊ូពីប្រទេសកម្ពុជាចំនួន១០ពាន់តោន ហើយបើកម្ពុជាផ្តល់ឲ្យយើងរហូត ១៥ពាន់តោន ក៏យើងព្រមទទួលយកដែរ ។

៣) ចំពោះកប៉ាល់ មៀងស៊ីន អាចមកដល់ល្ងាចនេះ ឬស្អែកវិញ ហើយកប៉ាល់ វិនឡា តាមការប៉ាន់ស្មានអាចមកដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ខាងមុខនេះ ។

**មតិយើងៈ**

យើងយកបញ្ហានេះរាយការណ៍ជូនអង្គការ ហើយនឹងបញ្ជាក់អំពីទំនិញដែលត្រូវដុកក្នុងនេះ ។

***សេចក្តីសន្និដ្ឋានៈ***

ការជួបមិត្តកូរ៉េថ្ងៃនេះមានបរិយាកាសរីករាយ ស្និទ្ធស្នាល បញ្ហាម៉ាស៊ីន១៧៥គ្រឿង សមមិត្តកូរ៉េហាក់ដូចជាបង្ខំឲ្យយើងយក ដូច្នេះសុំមតិយោបល់អង្គការ តើសម្រេចយ៉ាងម៉េច ព្រោះយើងបានបញ្ជាក់ប្រាប់កូរ៉េថាមិនយកទេម៉ាស៊ីន១៧៥នេះ យោងតាមសេចក្តីរាយការណ៍ ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦ ។

ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦

ជ.គណៈកម្មាធិការក្រសួងពាណិជ្ជកម្ម

**ឯកសារលេខ (D ២០៥៦១)**

# បទឧទ្ទេសនាមរបស់សមមិត្ត ហ៊ុយៈ ភារកិច្ចនយោបាយរួមរបស់បក្ស ឆ្នាំ១៩៧៧

*ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧*

១) ភារកិច្ចនយោបាយរួមរបស់បក្សក្នុងឆ្នាំ១៩៧៧ឈរលើមូលដ្ឋាននៃមាគ៌ាយុទ្ធសាស្ត្រថ្មីរបស់បក្សដែលបានកំណត់នៅដើមឆ្នាំ១៩៧៦ តាមការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយមនៅកម្ពុជា ។

២) ភារកិច្ចនយោបាយរួមឆ្នាំ១៩៧៧ចាប់ផ្តើមឡើងនៅក្នុងសភាពល្អប្រសើរគ្រប់ផ្នែកជាមូលដ្ឋាន ដោយបក្សបានដឹកនាំបញ្ចប់ភារកិច្ចនយោបាយឆ្នាំ១៩៧៦បានល្អជាមូលដ្ឋានគ្រប់ផ្នែកទាំងអស់ ទាំងការបន្តធ្វើបដិវត្តន៍សង្គមនិយម ទាំងការកសាងសង្គមនិយម ទាំងកិច្ចការពារប្រទេស ការពារជ័យជំនះបដិវត្តន៍របស់យើង ។ ដូច្នេះភារកិច្ចនយោបាយឆ្នាំ១៩៧៧ស្ថិតនៅលើទីតាំងដ៏រឹងមាំ មានលក្ខណៈសម្បត្តិស្ទុះឈានទៅមុខដណ្តើមមហាជ័យជំនះ មហាលោតផ្លោះ មហាអស្ចារ្យថែមទៀតលើគ្រប់ផ្នែកទាំងការបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែជ្រាល-ជ្រៅខ្លាំងឡើងៗ ទាំងការកសាងសង្គម ឲ្យកាន់តែខ្លាំងក្លាឡើងទាំងកិច្ចការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ការពារផលប្រយោជន៍កម្ពុជាបានយ៉ាងរឹងមាំ ។ ចំណុចពិសេសដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ១៩៧៧នេះ ដើម្បីសម្រេចនយោបាយឆ្នាំ១៩៧៧ឲ្យបានជោគជ័យទាំងស្រុងគឺការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់និងជាប់ជានិច្ច ម្ចាស់ការមុនលើខ្មាំងសត្រូវទាំងក្នុងទាំងក្រៅទាំងចំហ ទាំងសម្ងាត់ ដើម្បីការពារប្រទេស ការពារបដិវត្តន៍ការពារប្រជាជនយើង សំខាន់គឺការពារបក្សគ្រប់ថ្នាក់ ។

៣) ការបន្តបដិវត្តន៍សង្គមនិយមត្រូវធ្វើឡើងគ្រប់ផ្នែកទាំងអស់ ខាងសតិអារម្មណ៍ ចាត់តាំងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ចបច្ចេកទេស វិទ្យាសាស្ត្រ ឃោសនាអប់រំ សិក្សាធិការ ។ល ។

***ភារកិច្ចនយោបាយរួមឆ្នាំ១៩៧៧***

១) ភារកិច្ចនយោបាយរួមធ្វើបដិវត្តសង្គមនិយមឲ្យជ្រាលជ្រៅថែមទៀត ។

ក) វិតខំបន្តធ្វើបដិវត្តន៍សង្គមនិយមដោយបន្តគាស់រំលើងឫសគល់ជាសំណល់ផ្សេងៗគ្រប់ប្រភេទរបស់វណ្ណៈនាយទុនសក្តិភូមិ ម្ចាស់ដី និងស្រទាប់វណ្ណៈជិះជាន់ផ្សេងៗទាំងអស់ព្រមទាំងរបបឯកជនរបស់វណ្ណៈទាំងអស់ដែលមិនអធននិងកម្មសិទ្ធិឯកជនទាំងនេះឲ្យកាន់តែជ្រាលជ្រៅជាប់ជានិច្ចក្នុងឆ្នាំ១៩៧៧នេះ ដាច់ខាតកុំឲ្យសំណល់របស់វណ្ណៈជិះជាន់ទាំងអស់របបឯកជនទាំងអស់ហើយនិងកម្មសិទ្ធិឯកជនទាំងអស់ងើបក្បាលឡើងវិញបាន ។

ខ) ការបន្តធ្វើបដិវត្តន៍សង្គមនិយមត្រូវធ្វើឡើងសំខាន់បំផុតនៅក្នុងបក្ស ហើយជាពិសេសក្នុងជួរកម្ពុជាគ្រប់ថ្នាក់ក្នុងអង្គការស្នូលទាំងមូល កងទ័ពបដិវត្តន៍ទាំងមូល យុវជនយុវនារីបដិវត្តន៍យើងទាំងអស់ ក្នុងកម្មករទាំងអស់ ក្នុងសហករណ៍កសិករទាំងអស់ ក្នុងក្រសួងមន្ទីរទាំងអស់ក្នុងសង្គ្រាមជាតិទាំងមូល ។

២) ភារកិច្ចបន្តការកសាងសង្គមនិយមគ្រប់ផ្នែកឲ្យកាន់តែខ្លាំងក្លា និងកាន់តែលោតផ្លោះថែមទៀត ។

ក) បន្តពង្រីកនិងពង្រឹកទីតាំងសមូហភាពឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លា និងជ្រាលជ្រៅគ្រប់ផ្នែកទាំងអស់ខាង សតិអារម្មណ៍ចាត់តាំងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រឃោសនា អប់រំសិក្សាធិការ ។ល ។ ក្នុងពេញមួយឆ្នាំ១៩៧៧នេះ ។

ខ) ផ្នែកកសាងឈរលើទីតាំងសមូហភាពវណ្ណៈអធនកាន់តែរឹងប៉ឹងជាលំដាប់ ត្រូវវិតខំជំរុញដោយខ្សែសង្វាក់មហាលោតផ្លោះមហាអស្ចារ្យ នូវការកសាងសង្គមនិយមគ្រប់ផ្នែកខាង

សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ ឃោសនាអប់រំសិក្សាធិការដោយគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនកម្រិតខ្ពស់បំផុត ។

គ) ភារកិច្ចបន្តកសាងសង្គមនិយមខាងលើនេះត្រូវធ្វើឡើងនៅក្នុងបក្សកម្ពុជាគ្រប់ថ្នាក់ជាសំខាន់បំផុត ធ្វើឡើងនៅក្នុងអង្គការស្នូលទាំងមូល កងទ័ពបដិវត្តន៍ទាំងមូល យុវជនយុវនារីទាំងមូល ក្នុងជួរបដិវត្តន៍យើងទាំងអស់ ក្នុងសហជីពកម្មករ ក្នុងសហករណ៍កសិករទាំងមូល មន្ទីរក្រសួងទាំងមូល និងសង្គមជាតិទាំងមូល ។

៣) ភារកិច្ចបន្តកិច្ចការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ការពារជ័យជំនះបដិវត្តន៍ ការពារបក្សប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា ត្រូវខិតខំយកចិត្តទុកដាក់គ្រប់ពេលវេលា ការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ទាំងដែនគោក ដែនទឹក ដែនអាកាស ការពារជ័យជំនះបដិវត្តន៍ ការពារបក្សប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា ពិសេសគឺការពារបក្សដឹកនាំគ្រប់ផ្នែកឲ្យបានល្អបំផុតក្នុងមួយឆ្នាំ១៩៧៧ ជាក់ស្តែងគឺ ÷

ក) បំពាក់បំប៉នបំផុស ជំរុញនិងកម្តៅឲ្យជាប់នូវស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុតនិងជាប់ជានិច្ច កម្ចាត់គ្រប់បាតុភូតគោលជំហរទស្សនៈសន្តិភាពនិយមទាំងអស់ កុំឲ្យវាកកើតបានក្នុងបក្ស ក្នុងកងទ័ព កម្មករ កសិករ ក្រសួង មន្ទីរ ។

ខ) បន្តជំរុញឲ្យខ្លាំងក្លាពង្រឹងនិងពង្រីកកងទ័ពទាំងបីប្រភេទ និងកងទ័ពគ្រប់ផ្នែក ។

គ) យកចិត្តទុកដាក់ថែមខាងថែរក្សាការពារនិងប្រមូលថែមទៀតនូវសម្ភារយោធាគ្រប់ផ្នែក ទុកដាក់ឲ្យបានល្អ សម្ងាត់យូរអង្វែងច្រើនសិបឆ្នាំ កុំឲ្យខ្មាំងបំផ្លាញបានដាច់ខាត ។

ឃ) បន្តរៀបចំពង្រឹងពង្រីកប្រជាជននៅតាមកន្លែងយុទ្ធសាស្ត្រដាច់ស្រយាលជាបណ្តើរៗថែមទៀត ដោយយកចិត្តទុកដាក់ថែមដោយលក្ខណៈសម្បត្តិជីវភាពរបស់គេ ។

ង) ការយកចិត្តទុកដាក់ពង្រឹងពង្រីករោងជាងរោងចក្រជួសជុលគ្រឿងសាស្ត្រាវុធហើយនិងផលិតសាស្ត្រាវុធ ពិសេសផលិតគ្រឿងសាស្ត្រាវុធដែលឈរលើវត្ថុធាតុដើមនិងលទ្ធភាពសម្ភារបច្ចេកទេសរបស់យើងជាសំខាន់ ។

## ភារកិច្ចស្នូលពីរយ៉ាងប្រចាំឆ្នាំ១៩៧៧

១) ភារកិច្ចស្នូលទីមួយ ខិតខំពង្រឹងពង្រីកសហករណ៍កសិកររបស់យើងឲ្យបានរឹងមាំជាមូលដ្ឋានជាដំបូងដាច់ខាត ដោយពង្រឹងពង្រីកការដឹកនាំនៅគ្រប់សហករណ៍ភូមិឃុំ យកចិត្តទុកដាក់ធ្វើការងារនយោបាយ សតិអារម្មណ៍ ចាត់តាំងលើមូលដ្ឋានបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្សឲ្យបានល្អជាប់ជានិច្ច រៀបចំឲ្យគ្រប់សហករណ៍កសិកររបស់យើង ឈានចូលទៅមានធាតុជាសម្ព័ន្ធភាពកម្មករកសិករដ៏រឹងមាំនៅជនបទ ហើយទៅជាកំពែងដែកពិតប្រាកដរបស់បក្សក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយម ក៏ដូចជាក្នុងកិច្ចការពារប្រទេសកម្ពុជាប្រជាធិបតេយ្យ ។

២) ភារកិច្ចស្នូលទីពីរគឺជំរុញមហាចលនាវាយសម្រុកដោយសន្ធាក់មហាលោតផ្លោះមហាអស្ចារ្យ ផលិតស្រូវក្នុងឆ្នាំ១៩៧៧ ឲ្យបាន៣តោននិង៦តោនក្នុងមួយហិកតាដាច់ខាតជាមធ្យមទូទាំងប្រទេស ដោយឲ្យបានផលស្រូវក្នុងឆ្នាំ១៩៧៧នេះ គឺកើនឡើងជាងឆ្នាំ១៩៧៦ទៀត ដោយវាយសម្រុកដោះស្រាយបញ្ហាទឹកមួយកម្រិតថែមទៀតធ្វើអាង ព្រែក និងប្រព័ន្ធភ្លឺ ប្រឡាយតូចធំ ។ ភារកិច្ចដើម្បីបម្រើនយោបាយរួមឆ្នាំ១៩៧៧ បម្រើភារកិច្ចស្នូលទាំងពីរ ÷

១) ភារកិច្ចពង្រឹងពង្រីកកម្ពុជាដឹកនាំគ្រប់ថ្នាក់ បក្សគ្រប់ថ្នាក់ និងអង្គការស្នូលគ្រប់ប្រភេទឲ្យមានគុណភាពកាន់តែខ្ពស់និងមានបរិមាណល្អ ។

ក) ការកសាងខាងនយោបាយត្រូវខិតខំបំពាក់បំប៉នឲ្យជាប់និងជ្រះស្រឡះនឹងសភាពទំនាស់វណ្ណៈតស៊ូវណ្ណៈស៊ុតស្មាញនៅក្នុងសង្គមកម្ពុជាក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម ឃើញឲ្យច្បាស់យើង-ខ្មាំង ឃើញច្បាស់ទំនាស់ផ្ទៃក្នុងបដិវត្តន៍និងប្រជាជន និងទំនាស់បដិបក្ខជាខ្មាំងមួយក្តាប់តូច ឃើញសភាពទំនាស់ប្រជាជាតិមួយខ្មាំងខាងក្រៅពីទិសផ្សេងៗ ដើម្បីម្ចាស់ការខាងទស្សនៈគោលជំហរនិងជាក់ស្តែងចំពោះប្រភេទទំនាស់ទាំងអស់នេះឲ្យត្រឹមត្រូវ ។

បន្តបំពាក់បំប៉នមាគ៌ាយុទ្ធសាស្ត្រថ្មី ឯការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយមតាមក្តាប់ភារកិច្ចនយោ-

បាយរួម ភារកិច្ចស្នូលទាំងអស់ និងភារកិច្ចគ្រប់ផ្នែកក្នុងឆ្នាំ១៩៧៧ និងអនុវត្តជាបន្តបន្ទាប់ ក្តាប់គោលជំហរជាមូលដ្ឋានរបស់បក្សគ្រប់ផ្នែក ដើម្បីជាត្រីវិស័យក្នុងការពិនិត្យ វិភាគដោះស្រាយបញ្ហានិងចាត់តាំងវិធានការផ្សេងៗឈរលើមូលដ្ឋាននយោបាយរបស់បក្សដាច់ខាត ។

១) ការកសាងខាងសេដ្ឋកិច្ចត្រូវបន្តបំពាក់ឲ្យខ្លាំងនិងជ្រាលជ្រៅថែមនូវសេដ្ឋកិច្ចវណ្ណៈអធនរបស់បក្សឲ្យឃើញសមត្ថភាពវណ្ណៈច្បាស់លាស់ក្នុងសង្គមកម្ពុជាបច្ចុប្បន្នតាមឯកសារយើងរៀនកន្លងមក ។

បំពាក់បំប៉ននូវផ្តាច់ការវណ្ណៈអធនតាមធាតុពិត និងខ្លឹមសារត្រឹមត្រូវរបស់វា បំពាក់បំប៉ននូវស្នេហាជាតិនិយមអធននិងអន្តរជាតិនិយមអធនរបស់បក្សដោយឈរលើស្នេហាជាតិនិយមជាមូលដ្ឋាន បំពាក់បំប៉នឲ្យជ្រួតជ្រាបខ្លាំងក្លាថែមទៀតនូវមោទនភាពបដិវត្តន៍របស់ប្រជាជនកងទ័ពបដិវត្តន៍ និងបក្សរបស់ខ្លួនជឿជាក់លើបក្សកងទ័ព ប្រជាជន និងបដិវត្តន៍របស់ខ្លួនយ៉ាងរឹងមាំ ។ កម្ចាត់ដាច់ខាតនូវសេដ្ឋកិច្ចរណបបរទេស ជឿជាក់លើបរទេស បំពាក់បំប៉នថែមទៀតនូវគោលការណ៍របស់ខ្លួន ប្រជាជនខ្លួន បដិវត្តន៍ខ្លួន កងទ័ពខ្លួន និង បក្សខ្លួន ។

បំពាក់បំប៉នឲ្យខ្លាំងថែមទៀតនូវទស្សនៈប្រជាជនរបស់បក្ស គោរពបម្រើ រាបសា ទទួលខុសត្រូវចំពោះប្រជាជន កម្មករ កសិករយើង កម្ចាត់គ្រប់សតិអារម្មណ៍ទាំងអស់ ដែលផ្ទុយនិងសតិអារម្មណ៍ខាងលើនេះ បំពាក់បំប៉នសីលធម៌កុម្មុយនិស្ត ពិសេសសីលធម៌កុម្មុយនិស្តក្នុងការរស់នៅ និងធ្វើសកម្មភាពតស៊ូប្រយុទ្ធឈានមុខជានិច្ច ។

បំពាក់បំប៉នលទ្ធិម៉ាក្សលេនីនជាមូលដ្ឋាន ពិសេសសម្ភារនិយម និងសម្ភារប្រវត្តិសាស្ត្រ ។

គ) ការកសាងខាងចាត់តាំងបន្តបំពាក់បំប៉នឲ្យខ្លាំង តស៊ូកសាងឲ្យជ្រួតជ្រាបនូវមាគ៌ាដឹកនាំធ្វើការងាររបស់បក្សតាមប្រជាធិបតេយ្យប្រមូលផ្តុំ ពិសេសសមូហភាពដឹកនាំ ។

បន្តពង្រឹងនិងសម្រិតសម្រាំងផ្ទៃក្នុងកងទ័ពឲ្យមានធាតុពិតកាន់តែបរិសុទ្ធឡើងខាងនយោបាយសេដ្ឋកិច្ចចាត់តាំង ត្រូវយកចិត្តទុកដាក់ជាអតិបរមានូវកិច្ចការសម្ងាត់របស់បក្សគ្រប់ផ្នែកទាំងអស់ ទាំងនយោបាយ ទាំងខាងសេដ្ឋកិច្ច ទាំងខាងចាត់តាំង ទាំងកម្មាភិបាលជាក្បាលម៉ាស៊ីនដឹកនាំផ្សេងៗ ទាំងការងារទូទៅៗល ។ ដើម្បីការពារឲ្យបានទាំងស្រុងដាច់ខាត ។

២) ការកសាងពង្រឹងពង្រីកកម្លាំងយោធាបដិវត្តន៍ និងកិច្ចការពារប្រទេសរបស់បក្ស ។

ក) បន្តបំពាក់បំប៉នកងទ័ពបដិវត្តន៍យើងឲ្យកាន់តែជ្រួតជ្រាបជ្រៅជ្រះក្នុងន័យអនុវត្តភារកិច្ចការពារប្រទេសជាភារកិច្ចមូលដ្ឋានរបស់ខ្លួនទាំងស្រុង ក្នុងក្របខ័ណ្ឌភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្ស ។ បន្តបំពាក់បំប៉នថែមទៀតនូវធាតុពិតកងទ័ពបដិវត្តន៍របស់បក្សជាឧបករណ៍ប្រដាប់អាវុធផ្តាច់ការរបស់បក្សបម្រើភារកិច្ចរបស់បក្ស គឺបន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសការពារបក្ស បក្សបដិវត្តន៍ និងប្រជាជន ។ បំពាក់បំប៉នថែមនូវធាតុពិតសមូហភាព វណ្ណៈអធន និងសង្គមនិយម ដើម្បីឲ្យកងទ័ពដែលមានលក្ខណៈចាត់តាំងខ្ពស់ជាងគេមានអង្គការវិន័យខ្ពស់ជាងគេហើយមានការបំពាក់អាវុធខ្ពស់ជាងគេ ទៅជាឧបករណ៍គំរូដ៏ល្អរបស់បក្ស ដូច្នេះត្រូវយកចិត្តទុកដាក់ថែបំប៉នជានិច្ចនូវការងារនយោបាយ សេដ្ឋកិច្ចនៅក្នុងកងទ័ពបដិវត្តន៍យកការងារជាមូលដ្ឋានជាសំខាន់ ។

ទន្ទឹមនេះ ក៏យកចិត្តទុកដាក់ពង្រឹងពង្រីកនិងសម្រិតសម្រាំងកងទ័ពឲ្យជាប់ សម្រិតសម្រាំងសមាសភាពប្រតិកិរិយា និងខ្មាំងបង្កប់នៅក្នុងកងទ័ពក្នុងរង្វង់ក្រុចកមួយក្តាប់តូច ដើម្បីឲ្យកងទ័ពបដិវត្តន៍យើងកាន់តែបរិសុទ្ធនិងកាន់តែខ្លាំងក្លាឡើង ធានាអះអាងក្នុងការរ៉ាប់រងភារកិច្ចរបស់បក្សគ្រប់កាលៈទេសៈ ។

១) បន្តពង្រឹងពង្រីកការចាត់តាំងកងទ័ពគ្រប់ប្រភេទនិងគ្រប់ផ្នែកឲ្យបានឆាប់រហ័ស ដើម្បីម្ចាស់ការជាបន្តបន្ទាប់ដើម្បីមានកម្លាំងការពារប្រទេសដូចជាបំពេញភារកិច្ចផ្សេងៗទៀតត្រូវផ្អែកលើកម្លាំងប្រជាជន កម្មករ កសិករ សមូហភាពទាំងមូល ដូច្នេះត្រូវរួមសុខទុក្ខជាមួយប្រជាជន កម្មករ កសិករសមូហភាព តាមមាគ៌ារបស់បក្ស និងតាមមាគ៌ាសង្គមប្រជាជនរបស់បក្ស ។

កិច្ចការពារប្រទេសត្រូវរួមផ្សំនិងនយោបាយ និងការងារ

បរទេស ។

៣) ការពង្រឹងពង្រីកកម្លាំងលើសកលលោកឈរលើកត្តាអត្តនោម័តិនៃបដិវត្តន៍យើង ដែលខិតខំវាយសម្រុកដណ្តើមជ័យជំនះជាបន្តបន្ទាប់ «បន្តធ្វើបដិវត្តន៍សង្គមនិយម ការកសាងសង្គម និងការប្រទេស» ។

យើងត្រូវយកចិត្តទុកដាក់ ពង្រឹងនិងពង្រីកកម្លាំងមិត្តលើសកលលោកឲ្យកាន់តែបានច្រើនមួយជំហានធំទៀត នៅឆ្នាំ ១៩៧៧នេះ ។ ធ្វើយ៉ាងនេះគឺដើម្បីដំណើរការបន្តធ្វើបដិវត្តន៍សង្គមនិយមរបស់បក្ស និងការពារប្រទេសឲ្យបានល្អ យើងមានមិត្តកាន់តែច្រើនខ្មាំងឯកោយើងមិនបាន ។

៤) បន្តការកសាងពង្រឹងពង្រីកមូលដ្ឋានបផ្អែកបដិវត្តន៍ ត្រូវយកចិត្តទុកដាក់ពង្រឹងពង្រីកមូលដ្ឋានបផ្អែកបដិវត្តន៍ទាំងអស់តទៅទៀត ទាំងព្រៃភ្នំ ទាំងវាលរាប ជនបទ ទីប្រជុំជន ។ល ។ ជាពិសេសសហករណ៍មូលដ្ឋានទាំងអស់ឲ្យទៅជាកំពែងប្តូសំណាញ់ដែករឹងមាំជាបន្តបន្ទាប់ ដោយយកចិត្តទុកដាក់កសាងបក្សកងទ័ពយើង ប្រជាជន កម្មករ កសិករយើងរឹងមាំ និងស្អាតជាបន្តបន្ទាប់ ព្រមទាំងមានសេដ្ឋកិច្ចឧបត្ថម្ភខ្លួនគ្រប់គ្រាន់ហើយ កាន់តែសម្បូរកើនឡើងជានិច្ច ។

៥) អំពីភារកិច្ចទប់ទល់និងកម្ចាត់សកម្មភាពចារកម្មស៊ីរូងរបស់ខ្មាំងគ្រប់ប្រភេទ ដើម្បីការពារបក្សបដិវត្តន៍ ប្រជាជន និងកងទ័ពកម្ពុជា ត្រូវម្ចាស់ការខាងទស្សនៈគោលជំហរនិងវិធានការទប់ទល់កម្ចាត់ក្នុងឋានៈវាយសម្រុកនូវខ្សែចារកម្មចាស់ថ្មីរបស់ខ្មាំង កុំឲ្យវាលូកដៃមកកកូរបដិវត្តន៍យើងបាន ត្រូវយកចិត្តទុកដាក់សំខាន់ពង្រឹងពង្រីកសម្រិតសម្រាំងបក្សឲ្យរឹងនិងឲ្យស្អាតជានិច្ចខាងនយោបាយ សេដ្ឋកិច្ច ចាត់តាំង ព្រមជាមួយកងទ័ព ត្រូវរឹងនិងស្អាតជានិច្ចខាងនយោបាយ សេដ្ឋកិច្ច និងចាត់តាំងជួរបដិវត្តន៍យើងទាំងមូលដ្ឋាន ត្រូវរឹងនិងស្អាតជានិច្ច ប្រជាជន កម្មករ កសិករ សមូហភាព ត្រូវរឹងនិងស្អាតជានិច្ច ដោយយកចិត្តទុកដាក់អប់រំគេជាអប្បបរមា ។

ទន្ទឹមនឹងនេះត្រូវមានវិធានការជាក់ស្តែងមួយចំនួនដើម្បីរាវរក ទប់ទល់និងកម្ចាត់ខ្សែចារកម្មថ្មីចាស់របស់ខ្មាំង ក្នុងនេះត្រូវយកចិត្តទុកដាក់វិធានការរក្សាការសម្ងាត់គ្រប់កាលៈទេសៈ ។

៦) បន្តអនុវត្តឲ្យបានល្អនូវភារកិច្ចការពារបក្សនិងអង្គការដឹកនាំរបស់បក្ស ត្រូវមានទស្សនៈឲ្យច្បាស់ចំពោះគោលបំណងរបស់ខ្មាំងនិងសកម្មភាពបំផ្លិចបំផ្លាញរបស់វាចំពោះបក្សនិងអង្គការដឹកនាំរបស់បក្ស ដូច្នេះត្រូវដុតកម្តៅទស្សនៈនិងគោលជំហរ ហើយមានវិធានការចាត់តាំងជាក់ស្តែងរស់រវើក ម៉ត់ចត់ក្នុងឋានៈម្ចាស់ការជាមុនគ្រប់ពេលវេលា ការពារបក្ស ការពារអង្គការដឹកនាំរបស់បក្សគ្រប់ថ្នាក់ឲ្យបានល្អដាច់ខាត ក្នុងនេះត្រូវយកចិត្តទុកដាក់រក្សាការសម្ងាត់ឲ្យបានល្អដាច់ខាត ។

៧) ពាក្យស្លោកវាយសម្រុកប្រចាំឆ្នាំ១៩៧៧វាយសម្រុកខ្លាំងក្លាបំផុតជាប់ជានិច្ច មហាចលនា មហាជន មហាលោតផ្លោះមហាអស្ចារ្យ ។ មាគ៌ាដំណើរការដឹកនាំអនុវត្តន៍ភារកិច្ចរបស់បក្សឆ្នាំ១៩៧៧ ។

ត្រូវសិក្សាអប់រំបំពាក់បំប៉ន និងក្តាប់ឲ្យជ្រួតជ្រាបជាបន្តបន្ទាប់នូវភារកិច្ចនយោបាយឆ្នាំ១៩៧៧នេះ ក្នុងន័យអនុវត្តជាក់ស្តែងនៅក្នុងចលនារបស់មហាជន ហើយតាមដានពិសោធន៍សាចុះសាឡើងការអនុវត្តន៍ភារកិច្ចនយោបាយឆ្នាំ១៩៧៧ នេះដើម្បីតម្រែតម្រង់ បំពេញ និងកែលម្អជាបន្តបន្ទាប់បានទាន់ពេលវេលា ដោយច្នៃប្រឌិតគំនិតផ្តើមជាប់ជានិច្ច ដើម្បីជំរុញចលនាឲ្យខ្លាំងក្លា សម្រេចភារកិច្ចនយោបាយឆ្នាំ១៩៧៧ឲ្យបានទាំងស្រុងតាមសំណូមពររបស់បក្សភារកិច្ចនយោបាយនេះត្រូវរក្សាការសម្ងាត់ដាច់ខាត ។ល ។

***ឯកសារខ្មែរក្រហម D២១៩០៥***

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទីតាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | |
|---|---|---|---|---|---|---|
| ៩៤៨ | ផាត សាងឹម | យុទ្ធជន | កងពល៥០២ | ២៤-៩-៧៦ | ២៩-៩-៧៦ | |
| ៩៤៩ | ពុធ កែវ | មេពួក | កងពល៥០២ | ២៤-៩-៧៦ | ២៩-៩-៧៦ | |
| ៩៥០ | ខៀវ ថា | យុទ្ធជន | រោងចក្រភ្លើង | ៣០-៧-៧៦ | ៣០-៩-៧៦ | ឈឺស្លាប់ |
| ៩៥១ | អ៊ុយ ប៊ុនហាក់ | កម្មករ | រោងចក្រភ្លើង | ៧-៨-៧៦ | ៣០-៩-៧៦ | ឈឺស្លាប់ |
| ៩៥២ | ហ៊ា ឆេន | កម្មករ | អគ្គិសនីចាក់អង្រែ | ៤-៨-៧៦ | ១-១០-៧៦ | ឈឺស្លាប់ |
| ៩៥៣ | ឡុង សាគុណ | កម្មករ | អគ្គិសនី | ៤-៨-៧៦ | ១-១០-៧៦ | ឈឺស្លាប់ |
| ៩៥៤ | ឈិន លុន | វរសេនាតូច | កងពល១៦៤ | ២៩-៦-៧៦ | ១-១០-៧៦ | ឈឺស្លាប់ |
| ៩៥៥ | ស៊ុម ស៊ីង ហៅ ឡឿន | កងហ | ពាណិជ្ជកម្ម | ៣-៨-៧៦ | ២-១០-៧៦ | ឈឺស្លាប់ |
| ៩៥៦ | កេង នឿន | អនុក្រុម | កងពល២៩០ | ២២-៨-៧៦ | ២-១០-៧៦ | ឈឺស្លាប់ |
| ៩៥៧ | ជា យឹន ហៅ ដែក | យុទ្ធជន | ពាណិជ្ជកម្ម | ៨-៧-៧៦ | ២-១០-៧៦ | ឈឺស្លាប់ |
| ៩៥៨ | អ៊ុម ហ៊ន ហៅ ណារ៉ាត | កងហ | កងពល២៩០ | ២២-៨-៧៦ | ២-១០-៧៦ | ឈឺស្លាប់ |
| ៩៥៩ | ដេង គា | បើកឡាន | ដឹកជញ្ជូន | ១៨-៧-៧៦ | ២-១០-៧៦ | ឈឺស្លាប់ |
| ៩៦០ | កែវ ហួន | យុទ្ធជន | រោងចក្រភ្លើង | ៣០-៧-៧៦ | ២-១០-៧៦ | |
| ៩៦១ | អ៊ិន សាង៉ូត | ឈ្លបឃុំ | តំបន់៣១ | ៥-៩-៧៦ | ២-១០-៧៦ | |
| ៩៦២ | យាង បួយ ហៅ ស្មី | មេពួក | ថាមពល | ១៤-៧-៧៦ | ២-១០-៧៦ | |
| ៩៦៣ | ម៉ែន ឌឹម | យុទ្ធជន | កង៤៨៨ | ២៩-៧-៧៦ | ២-១០-៧៦ | |
| ៩៦៤ | ញ៉ែម ស៊ឹម | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ២-១០-៧៦ | |
| ៩៦៥ | ចាន់ សុង | ប្រជាជន | តំបន់៣៣ | ២៨-៨-៧៦ | ២-១០-៧៦ | |
| ៩៦៦ | សុក សារ៉ែន | ទាហានពលទោ | កំពង់ស្ពឺ | ១៦-៩-៧៦ | ២-១០-៧៦ | |
| ៩៦៧ | អៀង សុង ហៅ ស្រ៊ាង | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ២-១០-៧៦ | |
| ៩៦៨ | ណុប អ៊ឹម | ប្រជាជន | តំបន់៣៣ | ៥-៩-៧៦ | ២-១០-៧៦ | |
| ៩៦៩ | សេក សុផល | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ២-១០-៧៦ | |
| ៩៧០ | វ៉ត់ វីន | យុទ្ធជន | កងពល៤៥០ | ៩-៧-៧៦ | ២-១០-៧៦ | |
| ៩៧១ | ហួត ផល | អនុក្រុម | ស-២១យ | ១-១០-៧៦ | ២-១០-៧៦ | |
| ៩៧២ | ឈុន ហ៊ាង | យុទ្ធជន | ស-២១យ | ១-១០-៧៦ | ២-១០-៧៦ | |
| ៩៧៣ | យឹម ណាក់ | យុទ្ធជន | ស-២១យ | ១-១០-៧៦ | ២-១០-៧៦ | |
| ៩៧៤ | សន លន | យុទ្ធជន | ស-២១យ | ១-១០-៧៦ | ២-១០-៧៦ | |
| ៩៧៥ | លឹម ហួត | យុទ្ធជន | កងពល១៦៤ | ២៨-៨-៧៦ | ៣-១០-៧៦ | ឈឺស្លាប់ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩៧៦ | អោ ជី | មេក្រុម | តំបន់១៥ | ៤-៧-៧៦ | ៣-១០-៧៦ | ឃើស្លាប់ |
| ៩៧៧ | ឃឹម ណាក់ | កងហា | តំបន់១៥ | ៤-៧-៧៦ | ៣-១០-៧៦ | ឃើស្លាប់ |
| ៩៧៨ | ចាន់ ស៊ីណាត ហៅ កុន | កម្មករ | រដ្ឋករទឹក | ៤-៨-៧៦ | ៤-១០-៧៦ | ឃើស្លាប់ |
| ៩៧៩ | ជា កង ហៅ សៀន | យុទ្ធជន | កង៤៥០ | ២៩-៧-៧៦ | ៤-១០-៧៦ | ឃើស្លាប់ |
| ៩៨០ | សឿន សាគុណ | វរសេនាតូច | វរសេនាធំ១៥២ | ២-៨-៧៦ | ៥-១០-៧៦ | |
| ៩៨១ | អ៊ិន សារឿន ហៅ ផុំ | កម្មករ | រដ្ឋករទឹកភូមិព្រែក | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨២ | ណន រឿន | កម្មករ | រដ្ឋករទឹកភូមិព្រែក | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៣ | សៀង វ៉ាន់ថន | កម្មករ | រដ្ឋករទឹកភូមិព្រែក | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៤ | សូ គា | កម្មករ | រដ្ឋករទឹកភូមិព្រែក | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៥ | សូត្រ យុទ្ធ | បើកឡាន | មន្ទីរស-៨ | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៦ | កៀត សំអាន | ពលកម្ម | អគ្គិសនីទី១ | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៧ | ស្រ៊ុន សុកជា | ពលកម្ម | អគ្គិសនីទី២ | ៤-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៨ | អ៊ឹម ខុន ហៅ ទិត | យុទ្ធជន | តំបន់២៤ | ២០-៨-៧៦ | ៥-១០-៧៦ | |
| ៩៨៩ | សោម សុទ្ធា | យុទ្ធជន | ភូមិភាគបូព៌ា | ២០-៨-៧៦ | ៥-១០-៧៦ | |
| ៩៩០ | ហន់ សារិន ហៅ ប៉ក់ប៉ូច | កងហា | កងស្រុកបូព៌ា | ២០-៨-៧៦ | ៥-១០-៧៦ | |
| ៩៩១ | កែន ឈុំ | កងរយ | ទូរពុម្ព | ២-៩-៧៦ | ៥-១០-៧៦ | |
| ៩៩២ | សឹម ស៊ុត | យុទ្ធជន | វរសេនាធំ១៥២ | ៥-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៣ | ស្វាយ គឹមអេង | និសាកងរយ | វរសេនាធំ១៥២ | ៥-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៤ | អែម សឿន ហៅ ណែវ | កម្មករ | កំពង់ឆ្នាំង | ១៣-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៥ | នុប សុផល | កម្មករ | កំពង់ឆ្នាំង | ១៣-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៦ | ស៊ុ សេង | ១៣អនុក្រុម | ២១យ | ១៣-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៧ | ព្រះ បៀង | យុទ្ធជន | កងពល៤៥០ | ១៦-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៨ | ឈឹម ឌុក | យុទ្ធជន | កងពល១៧០ | ២២-៩-៧៦ | ៥-១០-៧៦ | |
| ៩៩៩ | ចាយ ម៉េង | កម្មករអគ្គិសនី | មន្ទីរទឹកថ្វា | ២៥-៩-៧៦ | ៥-១០-៧៦ | |
| ១០០០ | គ្រី ជា | អនុក្រុម | មន្ទីរពិការ ៦២ | ២៩-៩-៧៦ | ៥-១០-៧៦ | |
| ១០០១ | អែម វ៉ាន់លី | មេក្រុម | កងពល១៧០ | ៣-១០-៧៦ | ៥-១០-៧៦ | |
| ១០០២ | យិន ឡោម | កម្មករ | អគ្គិសនីចាក់អង្រែ | ៤-៨-៧៦ | ៥-១០-៧៦ | |
| ១០០៣ | កែប សារឿន | កម្មករ | អគ្គិសនីចាក់អង្រែ | ៤-៨-៧៦ | ៥-១០-៧៦ | |
| ១០០៤ | ជុំ សារ៉ែន | យុទ្ធជន | ២១យ | ១៦-៩-៧៦ | ៥-១០-៧៦ | |
| ១០០៥ | ភោគ ស៊ឹន | កម្មករ | អគ្គិសនីផ្សារតូច | ៤-៨-៧៦ | ៥-១០-៧៦ | |
| ១០០៦ | អ៊ា ពុធ | កម្មករ | អគ្គិសនីផ្សារតូច | ៤-៨-៧៦ | ៥-១០-៧៦ | |
| ១០០៧ | គុង គុណ | យុទ្ធជន |ឃ្លាំងរដ្ឋ | ២៨-៨-៧៦ | ៥-១០-៧៦ | |
| ១០០៨ | នូ ឈុនលី | ពេទ្យ | កងពល២៩០ | ២២-៨-៧៦ | ៥-១០-៧៦ | **(នៅមានត)** |

# រកឃើញជនរងគ្រោះពីរនាក់ទៀត ដែលជាអតីតអ្នកទោសនៅមន្ទីរ ស-២១

ក្នុងចំណោមអ្នកទោសជាងមួយម៉ឺនបួនពាន់នាក់ដែលខ្មែរក្រហមបានធ្វើទារុណកម្មជម្រិតយកចម្លើយនិងសម្លាប់ចោលនៅមន្ទីរស-២១ មានជនរងគ្រោះតែ៧នាក់ប៉ុណ្ណោះដែលត្រូវបានដឹងឮជាសាធារណៈថានៅរស់រានមានជីវិតពីទីតាំងពិឃាតដ៏សាហាវនេះ ។ ថ្មីៗនេះ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្រាវជ្រាវរកឃើញជនរងគ្រោះចំនួនពីរនាក់ទៀតដែលជាអតីតអ្នកទោសនៅមន្ទីរ ស-២១ ។ ជនរងគ្រោះទាំងពីរនាក់ឈ្មោះ ញ៉ែម សល់ និង តូច តែម បច្ចុប្បន្នជាកសិករនៅខេត្តតាកែវ ។

ញ៉ែម សល់ ឆ្នាំ១៩៧៦



នៅមុនពេលដែលត្រូវខ្មែរក្រហមចាប់ខ្លួន ញ៉ែម សល់ និង តូច តែម គឺជាយុទ្ធជនខ្មែរក្រហមនៅក្នុងអង្គភាពជាមួយគ្នា ហើយបានរត់គេចចេញពីអង្គភាពជាមួយគ្នា ។ នៅក្នុងប្រវត្តិរូបរបស់អ្នកទាំងពីរដែលធ្វើនៅមន្ទីរស-២១ ញ៉ែម សល់ និង តូច តែម ត្រូវបានចាប់ខ្លួននៅក្នុងពេលជាមួយគ្នា គឺថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៦ ។ នៅក្នុងមន្ទីរស-២១ អ្នកទាំងពីរជាប់នៅក្នុងបន្ទប់ធំជាមួយគ្នា គឺបន្ទប់លេខ១០៧ ប៉ុន្តែនៅក្នុងបន្ទប់តូចផ្សេងពីគ្នា ។ ញ៉ែម សល់ ជាប់នៅក្នុងបន្ទប់តូចលេខ១១៦ តូច តែម ជាប់នៅក្នុងបន្ទប់តូចលេខ១១៨ ។

ញ៉ែម សល់ បានរៀបរាប់អំពីដំណើររឿងរបស់គាត់ប្រាប់ក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដូចខាងក្រោម៖

ខ្ញុំបានចូលធ្វើកងទ័ពស្រុកនៅក្នុងឆ្នាំ១៩៧២ ដោយសាររណសិរ្សខ្មែរក្រហមបង្ខំខ្ញុំ ។ ឪពុកម្តាយខ្ញុំក៏មិនចង់ឲ្យខ្ញុំបែកឆ្ងាយពីគាត់ដែរ ព្រោះខ្ញុំទើបតែមានអាយុ១៦ឆ្នាំប៉ុណ្ណោះ ។ គាត់បារម្ភក្រែងខ្ញុំស្លាប់ឬរបួសនៅក្នុងសមរភូមិ ។

នៅខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅភូមិភាគឦសាន ។ ខ្ញុំចេញដំណើរពីស្រុកជាមួយមិត្តភក្តិរបស់ខ្ញុំម្នាក់ទៀតដែលនៅក្នុងអង្គភាពជាមួយគ្នា ។ ទៅដល់ភ្នំពេញខ្ញុំបានជួបនឹងមនុស្សជាច្រើនទៀតដែលខ្ញុំពុំធ្លាប់ស្គាល់ពីមុនមក ។ អ្នកទាំងអស់នេះសុទ្ធតែត្រូវរួមដំណើរទៅជាមួយខ្ញុំដែរ ។ កប៉ាល់ធំៗចំនួនពីរបានដឹកយើងចេញពី ភ្នំពេញតាមទន្លេមេគង្គឆ្ពោះទៅទិសខាងជើង ។ នៅពេលទៅដល់ទីរួមខេត្តកំពង់ចាម កប៉ាល់បានចូលចតនៅមាត់ច្រាំង ។ ខ្មែរក្រហមបានបញ្ជាឲ្យយើងទៅស្នាក់នៅផ្ទះថ្មមួយក្នុងទីរួមខេត្ត ដើម្បីហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ព ។

មួយខែក្រោយមក ខ្មែរក្រហមដឹកពួកខ្ញុំតាមកប៉ាល់ពីរគ្រឿងដដែលបន្តដំណើរទៅទៀត ។ ទីកន្លែងដែលកប៉ាល់ឈប់ ខ្ញុំស្គាល់ថាជាទីរួមខេត្តក្រចេះ ។ ដូចលើកមុនទៀតដែរ យើងត្រូវស្នាក់នៅតាមផ្ទះថ្មដើម្បីបន្តហាត់រៀនក្បួនយុទ្ធសាស្ត្រ ។

ចូលដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានដឹកយើងតាមរថយន្តទៅស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគិរី ដែលនៅទីនោះយើងមានភារកិច្ចការពារទឹកដីកម្ពុជាដែលនៅជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ។ នៅទីនោះខ្ញុំមានអារម្មណ៍ភ័យខ្លាចជាប្រចាំ ។ ថ្ងៃមួយខ្ញុំបានប្រទះឃើញសាកសពជាច្រើននៅក្នុងជ្រោះ ។ ខ្ញុំស្គាល់ច្បាស់ថាសាកសពទាំងនោះសុទ្ធតែជាអ្នកធ្លាប់នៅក្នុងអង្គភាពជាមួយខ្ញុំ ដែលប៉ុន្មានថ្ងៃមុនត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅទីកន្លែងផ្សេងទៀត ។

ដោយហេតុតែភ័យខ្លាចខ្មែរក្រហមយកខ្ញុំទៅសម្លាប់ចោលដូចអ្នកទាំងនោះ ខ្ញុំក៏សម្រេចចិត្តរត់គេចចេញពីអង្គភាព ។ អ្នក

រួមដំណើរជាមួយខ្ញុំមានគ្នាបីនាក់គឺៈ សឿន, វ៉ន និង វឿន ។ នៅពេលរត់គេចផុតពីអង្គភាពចំនួនមួយថ្ងៃ ខ្ញុំបានជួបជាមួយក្រុមអ្នករត់ផ្សេងទៀតដែលមានគ្នាចំនួនបីនាក់ដែរគឺ តែម, ផល និង ហួត ។ ដូច្នេះក្រុមរបស់យើងមានសមាជិករហូតដល់ប្រាំពីរនាក់ ។ នៅជាប់នឹងខ្លួនយើងម្នាក់ៗសុទ្ធតែមានអង្ករដែលស្ពាយយកមកជាមួយនិងមានឆ្នាំងសម្រាប់ដាំបាយ ។ ថ្ងៃមួយ យើងធ្វើដំណើរក្នុងព្រៃពេញមួយថ្ងៃដោយពុំប្រទះឃើញទឹកបន្តិចសោះឡើយ ។ ម្នាក់ៗអស់កម្លាំងស្ទើរដាច់ខ្យល់ស្លាប់ ហើយក៏នាំគ្នាប្រះខ្លួនដេកនៅក្នុងគុម្ពោតព្រៃ រហូតដល់រំលងអគ្រាត្រ យើងអាចស្រូបបាននូវភាពត្រជាក់ខ្លះៗនៃទឹកសន្សើម ធ្វើឲ្យយើងមានកម្លាំងល្មមអាចបន្តដំណើរតទៅមុខទៀត ។


ញ៉ែម សល់ ឆ្នាំ២០០៣

ធ្វើដំណើរអស់រយៈពេលប្រហែលមួយខែយើងមកជិតដល់ទីរួមខេត្តស្ទឹងត្រែង ។ ពីដំបូងយើងហាក់ដូចជាមានអារម្មណ៍ធូរស្រាលដោយបានមកដល់ភូមិដែលមានប្រជាជនរស់នៅ ប៉ុន្តែភ្លាមៗនោះមានឈ្លបមួយក្រុមបានមកចាប់យើងទាំងអស់គ្នាយកទៅឃុំឃាំង ។ នៅក្នុងយប់នោះយើងបាននាំគ្នាលួចរត់ចេញពីមន្ទីរឃុំឃាំង ហើយក៏បន្តដំណើរឆ្ពោះមកខេត្តក្រចេះ ។ ការធ្វើដំណើរគឺត្រូវកាត់ព្រៃភ្នំដូចលើកមុនដែរ ។ មួយសប្តាហ៍ក្រោយមក យើងបានមកដល់ទីរួមខេត្តក្រចេះ ។ នៅពេលមកដល់ទីនេះ យើងត្រូវខ្មែរក្រហមឃាត់ដំណើរយើងជាលើកទីពីរ ប៉ុន្តែម្តងនេះយើងបានរួចខ្លួន ពីព្រោះយើងបានក្លែងបន្ទំលិខិតធ្វើដំណើរ ។

អង្ករដែលយើងយកមកគ្រប់គ្នានោះបានអស់ទៅហើយ ។ សំណាងល្អដែរដែលការធ្វើដំណើរបន្តមកទៀតយើងដើរកាត់តាមស្រែចម្ការរបស់សហករណ៍ ។ នៅពេលថ្ងៃយើងតែងតែសម្ងំលាក់ខ្លួនក្នុងគុម្ពពោតឬគុម្ពដំឡូង ហើយហូបពោតឬដំឡូងឆៅនៅទីនោះ ។ លុះដល់ពេលយប់ទើបយើងបន្តដំណើរទៅទៀត ។ ជួនពេលខ្លះ យើងក៏បានជួបជាមួយប្រជាជននៅតាមសហករណ៍ ប៉ុន្តែគ្មានអ្នកណាហ៊ានសួរដេញដោលយើងទេ ដោយសារតែឃើញយើងទាំងអស់គ្នាស្លៀកពាក់ឯកសណ្ឋានជាកងទ័ព ។

អស់រយៈពេលជាច្រើនសប្តាហ៍កន្លងមក យើងបានឆ្លងកាត់ទីរួមខេត្តកំពង់ចាម ហើយបានមកដល់ទីប្រជុំជនព្រែកក្តាម ។ ប្រធានឃុំគ្រប់គ្រងនៅទីនេះឈ្មោះ វ៉ាន់ ។ បងផល (អ្នករួមដំណើរជាមួយខ្ញុំ) ស្គាល់ វ៉ាន់ យ៉ាងជិតស្និទ្ធតាំងពីមុនឆ្នាំ១៩៧៥ម្ល៉េះ នៅពេលដែលគាត់ធ្វើកងទ័ពក្នុងអង្គភាពជាមួយគ្នា ។ វ៉ាន់ បានឃាត់យើងទាំងអស់គ្នាឲ្យស្នាក់នៅមន្ទីររបស់គាត់មួយយប់ ហើយទទួលយើងដោយម្ហូបអាហារយ៉ាងឆ្ងាញ់ពិសាដែលយើងខានស្គាល់រសជាតិជាយូរមកហើយ ។ បន្ទាប់ពីទទួលទានបាយល្ងាចរួច ម៉ោងប្រហែល១០យប់ ឈ្លបមួយក្រុមបានមកព័ទ្ធចាប់យើង ។ យើងគ្មានផ្លូវណាដែលអាចដោះសាបានទៀតឡើយ ។ ឈ្លបបានបញ្ជូនយើងទៅដាក់ឃុំឃាំងនៅក្នុងគុកមួយនៅក្បែរនោះ ហើយស្អែកឡើងបញ្ជូនមកឃុំឃាំងនៅគុកវត្តចំពុះក្អែកដែលស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ។ គុកវត្តចំពុះក្អែកឃុំឃាំងអ្នកទោសរាប់រយនាក់ ។ ពេលថ្ងៃ អ្នកទោសទាំងអស់ត្រូវបានដោះលែងឲ្យទៅធ្វើការងារនៅខាងក្រៅ លើកលែងតែក្រុមខ្ញុំចំនួន៧នាក់ដែលត្រូវប្រធានគុកប្រើឲ្យសែងលាមកនៅក្នុងគុក ។

មួយសប្តាហ៍ក្រោយមក យើងត្រូវបានបញ្ជូនទៅដាក់នៅមន្ទីរឃុំឃាំងកោះថ្មី ក្នុងស្រុកស្អាង បន្ទាប់មកបញ្ជូនយើងបន្តទៅមន្ទីរឃុំឃាំងកោះគរទៀត ។ នេះជាលើកទីមួយដែលខ្ញុំក៏ដូចអ្នកនៅក្នុងក្រុមជាមួយខ្ញុំទាំងអស់ត្រូវសួរចម្លើយ ។ ខ្មែរក្រហមបានសួរចម្លើយខ្ញុំស្ទើរតែគ្មានលោះថ្ងៃ ។ ពេលហៅទៅសួរម្តងៗ ខ្ញុំត្រូវឈ្លបចងមុខនឹងក្រណាត់ខៅស៊ូដ៏ក្រាស់ជិតឈឹង ហើយដៃទាំងពីររបស់ខ្ញុំត្រូវចងរឹតមកក្រោយខ្នងយ៉ាងតឹង ។

ឈ្លបម្នាក់បានទាញខ្ញុំឲ្យដើរបត់ចុះបត់ឡើងៗ មួយសន្ទុះធំទើបទៅដល់កន្លែងសួរចម្លើយ ។ ឈ្លបបានបើកក្រណាត់បង់មុខខ្ញុំចេញ ។ ខ្ញុំមើលឃើញអ្នកសួរចម្លើយម្នាក់អង្គុយនៅលើកៅអីក្បែរខ្ញុំ និងមានតុមួយនៅទីនោះ ។ នៅជុំវិញខ្លួន ខ្ញុំឃើញឧបករណ៍សម្រាប់ធ្វើទារុណកម្មជាច្រើនមុខ ប៉ុន្តែអ្នកសួរមិនបានប្រើប្រាស់ឧបករណ៍ទាំងនោះសម្រាប់ធ្វើទារុណកម្មលើខ្ញុំឡើយ ។ អ្នកសួរបានសួរខ្ញុំជីកប្ញសគល់អំពីរឿងរ៉ាវពាក់ព័ន្ធទៅនឹងខ្មែរស ប៉ុន្តែខ្ញុំនៅតែឆ្លើយថា «ខ្ញុំរត់ចេញពីអង្គភាពមកពីខ្ញុំនឹកផ្ទះ» ។

មួយសប្តាហ៍ក្រោយមក ខ្ញុំរួមជាមួយមិត្តភក្តិទាំងអស់ត្រូវបានដឹកចេញពីកោះគរតាមទូក រួចដឹកតាមរថយន្តមួយដែលបិទជិតឈឹង មកទីក្រុងភ្នំពេញ ។ នៅពេលមកដល់ទីក្រុងភ្នំពេញ រថយន្តនោះបានទម្លាក់ពួកខ្ញុំចុះទាំងអស់គ្នាហើយ មានអ្នកយាមមកបណ្តើរយើងចូលទៅបរិវេណដីធំមួយ ។ នៅក្នុងបរិវេណនោះ ខ្ញុំឃើញអគារជាច្រើន ហើយអគារនីមួយៗមានច្រើនជាន់ ។ ពួកខ្ញុំត្រូវបានបំបែកចេញពីគ្នា ។ ខ្ញុំត្រូវបានអ្នកយាមនាំដើរបត់ចុះបត់ឡើងតាមជណ្តើរអគារមួយឡើងទៅជាន់លើ ។ ខ្ញុំមិនអាចដឹងឈ្មោះរបស់មន្ទីរ ហើយក៏មិនអាចចាំបានអំពីទីតាំងនៃអគារទាំងនោះដែរ ព្រោះខ្ញុំមិនអាចមើលឃើញផ្លូវដែលខ្ញុំធ្វើដំណើរទៅ ។

នៅក្នុងបន្ទប់ដែលខ្ញុំជាប់ឃុំឃាំង មានអ្នកទោស៤ឬ៥នាក់ផ្សេងទៀតនៅជាប់ទីនោះជាមួយខ្ញុំដែរ ប៉ុន្តែយើងមិនអាចមើលឃើញគ្នាទៅវិញទៅមកបានទេ ព្រោះមានជញ្ជាំងបាំងពីម្នាក់ទៅម្នាក់ ។ ខ្ញុំត្រូវអ្នកយាមចាក់សោច្រវាក់ភ្ជាប់នឹងកជើង ហើយបន្ធាយច្រវាក់បន្តិចដែលអាចឲ្យខ្ញុំរំកិលខ្លួនបានប្រហែលមួយម៉ែត្រ ។ នៅក្បែរខ្ញុំគ្មានអ្វីក្រៅពីគ្រែមួយ មុងមួយ ភួយមួយ និងកេសគ្រាប់មួយសម្រាប់បត់ជើង ។ ខ្ញុំត្រូវសួរចម្លើយជាបន្តបន្ទាប់ថែមទៀត ។ មុននឹងនាំខ្ញុំយកទៅសួរចម្លើយម្តងៗ អ្នកយាមបានបង់មុខខ្ញុំជិតឈឹង និងចងស្លាបសេកខ្ញុំ រួចប្រាប់ឲ្យខ្ញុំដើរទៅមុខដោយគ្មានដឹងទិសតំបន់ ។ អ្នកយាមដើរពីក្រោយស្រែកប្រាប់ខ្ញុំថា ត្រូវបត់ឆ្វេង បត់ស្តាំ ឬត្រូវចុះកាំជណ្តើរ ។ ខ្ញុំដើរស្ទាបៗទៅមុខយ៉ាងយឺត ។

កន្លែងសួរចម្លើយមិនមែននៅជិតបន្ទប់ឃុំឃាំងរបស់ខ្ញុំទេ ។ យ៉ាងហោចណាស់ ខ្ញុំត្រូវចំណាយពេលប្រហែលមួយម៉ោងទើបអាចទៅដល់ ។ នៅពេលទៅដល់ក្នុងបន្ទប់សួរចម្លើយភ្លាមអ្នកសួរបានដាក់ខ្នោះដៃខ្នោះជើងខ្ញុំភ្ជាប់ទៅនឹងតុ ទើបស្រាយចំណងមុខនិងដៃរបស់ខ្ញុំ ។ ដំបូងបង្អស់ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលឃើញកន្លែងសួរចម្លើយនោះស្អាតហាក់ដូចជាការិយាល័យមួយ ប៉ុន្តែខ្ញុំមានអារម្មណ៍ភ័យខ្លាចទៅវិញនៅពេលដែលក្រឡេកឃើញឧបករណ៍ធ្វើទារុណកម្មដូចជា ប្រដាប់ដកក្រចកដៃជើង រំពាត់ខ្សែតី ឧបករណ៍ឆក់ខ្សែភ្លើងនៅក្បែរៗខ្លួនខ្ញុំ ។ រាល់លើកដែលខ្ញុំត្រូវនាំយកទៅសួរចម្លើយ អ្នកយាមតែងតែពាក់ផ្លាកលេខឲ្យខ្ញុំជានិច្ច ។ ផ្លាកលេខនេះនឹងត្រូវដោះចេញវិញនៅពេលណាដែលខ្ញុំមកដល់ក្នុងបន្ទប់ ។ តាមខ្ញុំដឹងលេខនេះគឺដើម្បីជៀសវាងកុំឲ្យច្រឡំបន្ទប់ ។ ខ្ញុំនៅចាំបានថាមានម្តងនោះ គ្រាន់តែអ្នកសួរស្រាយមុខខ្ញុំចេញភ្លាម ខ្ញុំត្រូវគេថតរូបមួយប៉ុស្តិ៍ភ្លាមដែរ ។ ខ្ញុំត្រូវនាំយកទៅសួរចម្លើយជាច្រើនដង ប៉ុន្តែខ្ញុំមិនអាចចាំបានប្រាកដឡើយ ។ រាល់លើក អ្នកសួរបានផ្លាស់ប្តូរវេនគ្នា ។ ជួនពេលខ្លះអ្នកសួរចម្លើយគឺក្មេងដែលមានអាយុតិចជាងខ្ញុំ ។ ចម្លើយរបស់ខ្ញុំនៅតែឆ្លើយដដែល គឺថា «ខ្ញុំរត់ចោលជួរមកពីខ្ញុំនឹកផ្ទះ» ។ សំណាងល្អណាស់ដែលអ្នកសួរមិនបានធ្វើទារុណកម្មអ្វីមកលើខ្ញុំ ហើយថែមទាំងឲ្យពេទ្យមកពិនិត្យសុខភាពរបស់ខ្ញុំរៀងរាល់បីឬបួនថ្ងៃម្តង ។

មួយខែក្រោយមក ខ្ញុំក៏ត្រូវបញ្ជូនចេញពីទីនោះទៅគុកមួយទៀតនៅតាខ្មៅ ។ មិត្តភក្តិទាំង៦នាក់របស់ខ្ញុំក៏ត្រូវបានបញ្ជូនទៅជាមួយគ្នាទាំងអស់ ។ យើងបានជួបជុំគ្នាឡើងវិញ ។ ខ្ញុំដឹងថាគុកដែលនៅតាខ្មៅនោះកាលពីរបបមុនជាមន្ទីរពេទ្យឆ្កួត ។ នៅកន្លែងថ្មីនេះ ខ្ញុំក៏ដូចអ្នកទោសដទៃទៀតដែរ លែងត្រូវចងបិទមុខឬសួរចម្លើយទៀតហើយ ។ ពេលយប់ខ្ញុំត្រូវដាក់ខ្នោះ ប៉ុន្តែដោះលែងឲ្យទៅជីកដីនៅពេលថ្ងៃ ។ មានឱកាសខ្លះយើងអាចលួចពិភាក្សាគ្នាស្ងាត់ៗជាមួយមិត្តភក្តិ ។ នៅពេលរំឭកដល់គុកដែលយើងធ្លាប់បានជាប់នៅក្នុងទីក្រុងភ្នំពេញ គ្មាននរណាម្នាក់ស្គាល់ទីនោះច្បាស់លាស់ឡើយ ។ បងវឿន ដែលធ្លាប់ធាក់ស៊ីក្លូនៅក្រុងភ្នំពេញកាលពីរបបមុន បានប្រាប់ថា កន្លែងនោះនៅជិត

វត្តខណ្ឌលោម ប៉ុន្តែ បងផល ស្គាល់កន្លែងនោះថាជាសាលារៀនទួលស្វែង ។ ខ្ញុំគិតថាគឺទីនោះហើយដែលហៅថា គុកទួលស្វែង ។

យើងនៅគាខ្មៅបានប្រហែលជា១០ថ្ងៃ បន្ទាប់មកខ្ញុំនិងមិត្តភក្តិទាំងអស់ត្រូវបានបញ្ជូនបន្តមកគុកព្រៃស ។ នៅឯព្រៃស យើងត្រូវធ្វើការកាប់ដីទាំងយប់ទាំងថ្ងៃនិងធ្វើស្រែជាមួយអ្នកទោសរាប់រយនាក់ផ្សេងទៀត ។ យើងគ្មានកម្លាំងកំហែងដើម្បីធ្វើការទាំងនេះឡើយ ព្រោះហូបបាយមិនគ្រប់គ្រាន់ ។ នៅបានតែចំនួនបីថ្ងៃ ខ្ញុំ បងតែម បងវឿន និងបងផល បានសម្រេចចិត្តរត់ម្តងទៀត ។ រីឯមិត្តភក្តិបីនាក់ទៀតពុំបានរួមដំណើរជាមួយគ្នាទៀតទេ ពីព្រោះផ្ទះរបស់គាត់នៅកន្លែងខុសគ្នា ។ នៅថ្ងៃនោះ បន្ទាប់ពីបាយល្ងាចរួចគឺដល់ពេលដែលរៀបចេញទៅធ្វើការម្តងទៀត ខ្ញុំនិងមិត្តភក្តិទាំងបីនាក់បានឆក់ឱកាសលួចរត់ចេញពីគុកព្រៃស ។ យើងបានប្រទះឃើញផ្លូវរថភ្លើង ហើយក៏ដើរតាមបណ្តោយផ្លូវរថភ្លើងរហូតពេញមួយយប់ ពីព្រោះយើងជឿជាក់ថាផ្លូវរថភ្លើងនេះប្រាកដជានាំយើងទៅដល់ស្រុកកំណើតនៅក្នុងខេត្តតាកែវ ។ ពេលថ្ងៃរះ យើងនាំគ្នាពួនសម្ងំនៅក្នុងគុម្ពស្រូវរង់ចាំទម្រាំដល់ពេលយប់ទើបបន្តដំណើរទៅមុខទៀត ។ ទីបំផុតខ្ញុំបានមកដល់ផ្ទះ ហើយបានជួបជុំឪពុកម្តាយបងប្អូនរបស់ខ្ញុំវិញរហូតមកដល់សព្វថ្ងៃនេះ ។

**អ៊ីសា ឧស្មាន**

# បដិវត្តន៍បោកប្រាស់


ឡាយ អ៊ាន

ឡាយ អ៊ាន ជាអតីតក្មេងម្នាក់ដែលមានមាឌតូចល្អិត សកម្មរហ័សរហួននិងគួរឲ្យទុកចិត្តបាន ។ ឡាយ អ៊ាន ត្រូវបានប្រធានសង្កាត់ឈ្មោះ ហ៊ឹម ជ្រើសរើសឲ្យបម្រើតួនាទីជានិរសាក្នុងជួរកងទ័ពបដិវត្តន៍ខ្មែរក្រហម នៅចុងឆ្នាំ១៩៧៣ ។ ឡាយ អ៊ាន បានចូលក្នុងចលនាតស៊ូតាមការឃោសនាថា ដើម្បីវាយកម្ទេចពួកចក្រពត្តិអាមេរិកកាំងឈ្លានពានទឹកដីនិងរំដោះប្រទេសជាតិ ។ ឡាយ អ៊ាន បានចូលទៅហាត់បច្ចេកទេសយោធានៅសាលាស្រុកតាអោង ឬហៅថាសាលាស្រុក៧៣ ខេត្តកំពង់ធំ អស់រយៈពេលជិតពីរខែ ហើយក្រោយមកត្រូវបានបញ្ចូលទៅក្នុងកងទ័ពចល័តក្រោមការគ្រប់គ្រងរបស់ឈ្មោះ អឿន ។ ឡាយ អ៊ាន បានចូលប្រយុទ្ធនៅសមរភូមិមុខកំពូល ព្រែកអញ្ចាញ ព្រែកក្តាម កំពង់ចាម សៀមរាប កំពង់ធំ និងកំពង់ស្ពឺ ។ បន្ទាប់ពីបម្រើការជាកងទ័ពថ្មើរជើង ឡាយ អ៊ាន បានត្រូវជ្រើសរើសជានិរសាផ្ទាល់របស់ ស្រួយ ជាអនុ-ប្រធានកងវរ សេនាតូចលេខ២០២ ។

ក្នុងប្រតិបត្តិការវាយលុកចូលទីក្រុងភ្នំពេញពីខាងព្រែកព្នៅនិងទំនប់កប់ស្រូវ ឡាយ អ៊ាន បានបម្រើការជានិរសានាំពត៌មានរវាងសមរភូមិមុខនិងសមរភូមិក្រោយ ។ ក្រោយពេលបានទទួលជ័យជម្នះកាន់កាប់ក្រុងភ្នំពេញ ឡាយ អ៊ាន បាន និយាយថា ប្រធានកងវរសេនាតូចលេខ២០២ឈ្មោះ ឃាង បានបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ការជម្លៀសប្រព្រឹត្តទៅអស់រយៈពេលកន្លះខែ ។

នៅពេលដែលសង្គ្រាមបានបញ្ចប់ កងទ័ពទាំងអស់បានទទួលការចាត់តាំងឲ្យចុះជួយធ្វើស្រែជាមួយប្រជាជន ។ ឡាយ អ៊ាន បានត្អូញត្អែរថា «វាសមតែកងទ័ពដែលឆ្លងផុតសេសសល់ពីស្លាប់បានរស់នៅសុខស្រួល ប៉ុន្តែមិនទាន់ទាំងបាត់ញើសផ្សែងរំសេវផង ឲ្យកងទ័ពទៅធ្វើស្រែ» ។ ក្រោយពីទទួលបានជ័យជម្នះ ទូទាំងប្រទេសកងពលលេខ៣១០ដែលមានបីវរសេនាធំត្រូវបានបង្កើតឡើង មានទីតាំងនៅខាងជើងវត្តភ្នំ និងត្រូវបានប្រើប្រាស់ជាកន្លែងប្រជុំរៀនសូត្រសម្រាប់ក្រុមស្នូល បក្សជនត្រៀម និងបក្សជនពេញសិទ្ធ ។ សុន សេន និង នួន ជា តែងតែបានចូលរួមនិងមានមតិផ្តែផ្តាំញឹកញាប់នៅពេលបើកបុរិវគ្គ

រៀនសូត្រម្តងៗ ។ នៅក្នុងឆ្នាំ១៩៧៦ នៅក្នុងសាលាកងពលលេខ៣១០របស់ តា អឿន សិក្ខាកាមចំនួន៨០០នាក់បានចូលរៀនតាមឯកសារទង់បដិវត្តន៍ ដោយមានការបង្រៀនផ្ទាល់ពី សុន សេន ។

ឡាយ អ៊ាន នៅតែជានិរសាដដែលរហូត ដល់ឆ្នាំ១៩៧៧ គាត់ត្រូវអង្គការចាត់តាំងទៅរៀនបច្ចេកទេសបើកបររថយន្តនៅសេនាធិការរយៈពេល៣ខែ ដោយមានឈ្មោះ តាទុម ជាប្រធាន ។ ចប់វគ្គរៀនបើកបរ អង្គការចាត់តាំង ឡាយ អ៊ាន ជាក្រុមដឹកជញ្ជូន ។ ក្រុមដឹកជញ្ជូនមានរថយន្តហ្ស៊ីប៦០គ្រឿង ផលិតនៅប្រទេសចិន និងពាក់ផ្លាកកងទ័ព បានដើរប្រមូលស្រូវនៅកំពង់ស្ពឺ និងកំពង់ឆ្នាំងយកទៅដាក់ក្នុងឃ្លាំងនៅទីក្រុងភ្នំពេញ ។ ក្រៅពីនេះទៀត ឡាយ អ៊ាន ធ្លាប់បានចូលរៀនវគ្គនយោបាយជាញឹកញាប់តាមសៀវភៅដែលមានក្របពណ៌ខៀវមានរូបទង់១ ទង់២ និងទង់៣ ។ ឡាយ អ៊ាន បាននិយាយថា សៀវភៅទាំងនោះបង្ហាញអំពីគំនិតផ្តួចផ្តើមរបស់លទ្ធិម៉ាក្សលេនីន ។ ឡាយ អ៊ាន នៅចាំបានខ្លឹមសាររបស់សៀវភៅសរសេរថា «ធ្វើកុម្មុយនិស្តទាល់តែចំណាយមនុស្សខ្លះបានធ្វើទៅកើត បើអត់ចំណាយធ្វើទៅអត់កើតទេ» ។

នៅក្នុងឆ្នាំ១៩៧៦ អង្គការបានចាប់ខ្លួន អឿន ប្រធានកងពលលេខ៣១០នៅភូមិភាគឧត្តរ ។ ចំណែកថ្នាក់ក្រោមរបស់ អឿន ត្រូវបញ្ជូនទៅសមរភូមិប្រយុទ្ធជាមួយយួន ។ យុទ្ធជនដឹកជញ្ជូនចំនួន៦០នាក់បានត្រូវបញ្ជូនទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំង លើកលែងតែ ឡាយ អ៊ាន និងគ្នីគ្នា៣នាក់ទៀតដែលត្រូវដកទៅកងវរសេនាតូចលេខ១៧គ្រប់គ្រងដោយឈ្មោះ សែន ។ ឡាយ អ៊ាន បាននិយាយថា គាត់ស្ថិតក្នុងចំណោមមនុស្ស៤០នាក់ដែលអង្គការចោទថាក្បត់ ។ រថយន្តរបស់អង្គការបានមកដឹកមនុស្សចេញមួយថ្ងៃបន្តិចៗតាំងពីចំនួន៤០នាក់រហូតនៅសល់តែ៦នាក់ ។ សំណាងល្អ ឡាយ អ៊ាន មិនត្រូវបានដឹកទៅទេ គាត់ត្រូវបានបញ្ជូនមកកងវរសេនាតូចលេខ១៨នៅក្នុងចំណោមកងទ័ពចំនួន២០០នាក់ដែលជាប់ឈ្មោះទៅវាយយួននៅឆ្នាំ១៩៧៨ ។ ឡាយ អ៊ាន បាននិយាយថា កងទ័ពមជ្ឈិមបានវាយយួនចាប់ដៃជាមួយកងពលទី៤របស់លោក ហេង សំរិន នៅឈើទាលអំពុក ។ ឡាយ អ៊ាន បាននិយាយថា កងទ័ពបានវាយចូលទៅក្នុងទឹកដីវៀតណាមព្រមទាំងចាប់បានឈ្លើយសឹកវៀតណាមជាច្រើននាក់ ។ វិទ្យុផ្សាយសំឡេងពីទីក្រុងភ្នំពេញក៏បានផ្សាយអំពីការចាប់ឈ្លើយសឹកវៀតណាមនៅក្នុងសមរភូមិ ។ ក្នុងខណៈដែលកងទ័ពរបស់ភូមិភាគកណ្តាលនិងទ័ពស្រួចខំប្រឹងវាយយួន អង្គការបានបញ្ជាឲ្យចាប់កម្លាំងភូមិភាគបូព៌ាដោយចោទថាក្បត់ ។ នៅក្នុងជួរកងទ័ពភូមិភាគឧត្តរ តាំងពីប្រធានកងពល ប្រធានក្រុម ប្រធានកងធំ ប្រធានកងតូច និងប្រធានវរសេនាតូច គឺគ្រប់គ្រងដោយកម្លាំងមកពីភូមិភាគមជ្ឈិមទាំងអស់ ។ រីឯភូមិភាគកណ្តាល តាំងពីទ័ពស្រួចរហូតដល់ទ័ពភូមិភាគ គឺស្ថិតក្រោមការក្តោបក្តាប់ដោយភូមិភាគនិរតី ។ ដោយអស់សង្ឃឹមចំពោះការគ្រប់គ្រងរបស់ខ្មែរក្រហម កងទ័ពមួយចំនួនបានរត់ទៅស្រុកយួនតាមការអំពាវនាវដោយគ្រាក់ ប៉ុន្តែ ឡាយ អ៊ាន មិនអាចទៅបានដោយសារគាត់មានរបួស ។

បន្ទាប់ពីរបបខ្មែរក្រហមត្រូវផ្តួលរំលំ ឡាយ អ៊ាន បានវិលត្រឡប់មកស្រុកកំណើតវិញ ។ ឡាយ អ៊ាន បាននិយាយពីប្រវត្តិតស៊ូរបស់គាត់ប្រាប់ក្រុមគ្រួសារនិងអ្នកភូមិ ហើយអ្នកភូមិក៏រំឭកអំពីការលំបាកវេទនាដែលបានជួបនៅមូលដ្ឋានឲ្យគាត់ស្តាប់វិញ ។ ដល់ពេលនោះទើប ឡាយ អ៊ាន ដឹងថានៅក្នុងរបបខ្មែរក្រហមប្រជាជនកម្ពុជាទាំងអស់មិនថាកងទ័ពឬប្រជាជននៅតាមមូលដ្ឋានសុទ្ធតែជួបការលំបាកដូចៗគ្នា ។ ពីមុន អ៊ាន តែងតែគិតថា មានតែគាត់ទេដែលជួបការលំបាកវេទនា ហើយគិតថាបងប្អូននៅតាមមូលដ្ឋានមានជីវភាពរស់នៅប្រសើរជាងគាត់ ព្រោះស្តាប់តាមវិទ្យុតែសម្បូរសប្បាយ មិនដឹងថាពត៌មានទាំងនោះជាការកុហកបោកប្រាស់សោះ ។

បច្ចុប្បន្ន ឡាយ អ៊ាន មានអាយុ៤៧ឆ្នាំ រស់នៅជាមួយប្រពន្ធឈ្មោះ ជា ហ៊ឹម និងកូន៦នាក់ នៅភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ប្រកបរបរធ្វើស្រែចម្ការ ។ ឡាយ អ៊ាន បានសម្តែងការមិនពេញចិត្តចំពោះការដឹកនាំនៅរបបខ្មែរក្រហម ហើយគាំទ្រឲ្យមានការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះរឿងរ៉ាវដែលកើតក្នុងរបបនោះ ។ ឡាយ អ៊ាន សន្យាថានឹងផ្តល់ពត៌មានដល់តុលាការប្រសិនបើមានតម្រូវការចាំបាច់ ។ **លី សុខឃាង**

# បរាជ័យដោយការធ្វេសប្រហែសៈ នយោបាយខ្មែរក្រហមចំពោះស្ត្រីខ្មែរ

## *សេចក្តីផ្តើម*

*«នៅក្នុងអំឡុងពេលតស៊ូ យើងជួបការលំបាកជាច្រើន ។ ឧទាហរណ៍ដូចជា កម្មាភិបាលត្រូវព្រាត់ប្រាសពីក្រុមគ្រួសារ ហើយដោយគ្មានសតិអារម្មណ៍នឹងនរ ដូនកាលក៏សម្រេចចិត្តរត់ចោលបដិវត្តន៍ទៅរស់នៅជាមួយគ្រួសារវិញ» ។ នេះជាសម្តីរបស់ នួន ជា ឬ «បងទី២» នាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិប-តេយ្យ) នៅឆ្នាំ១៩៧៨ ។*

*«ដោយនឹកផ្ទះពេក ខ្ញុំរត់ទៅផ្ទះឪពុកម្តាយជាញឹកញយ ។ ខ្ញុំតែងតែនឹកដល់ឪពុកម្តាយ ហើយតែងតែចង់រត់គេចទៅផ្ទះ ។ ខ្ញុំមកផ្ទះប្រាំដង ។ មានម្តងនោះ ខ្ញុំឈឺញ័រចំប្រប់គ្រដាក់ក្តៅៗ ។ គេ (ខ្មែរក្រហម) ដាក់អង្រឹងសែងខ្ញុំត្រឡប់មកវិញ» ។ នេះជាសម្តីរបស់ ស៊ុម ស្រេង (អតីតកម្មាភិបាលនារីខ្មែរក្រហម) នៅឆ្នាំ២០០២ ។*

បដិវត្តន៍កម្ពុជាគួរឲ្យកត់សម្គាល់ដោយសារមូលហេតុអកុសលច្រើនយ៉ាង ហើយអ្វីដែលលេចធ្លោបផុតនោះគឺអំពើឃោរឃៅនិងការបំផ្លិចបំផ្លាញជីវិតមនុស្ស ។ ចាប់តាំងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជារាប់មិនអស់ត្រូវរងទុក្ខវេទនា ហើយជាច្រើនលាននាក់បានបាត់បង់ជីវិត ដោយសារប្រទេសនេះពោរពេញទៅដោយអំពើឃោរឃៅដែលដំណាក់កាលទីមួយគឺនៅក្នុងអំឡុងសង្គ្រាមស៊ីវិលឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ហើយក្រោយមកទៀតសង្គ្រាមរបស់កម្ពុជាប្រជាធិបតេយ្យជារបបកុម្មុយនិស្តជ្រុលនិយមដែលកាន់កាប់អំណាចពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យគឺ សាឡុត ស ដែលហៅជាទូទៅថា ប៉ុល ពត ។

អ្វីដែលគួរឲ្យកត់សម្គាល់មួយទៀតគឺកង្វះការគាំទ្រទៅលើមនោគមវិជ្ជាបដិវត្តនៅក្នុងចំណោមប្រជាកសិករដែលមានចំនួនពី៨៥ទៅ៩០ភាគរយនៃប្រជាជនកម្ពុជាទាំងអស់ ។ មេដឹកនាំខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាពិភពសុក្រឹតឥតខ្ចោះមួយដែលប្រជាជនមានសិទ្ធិស្មើៗគ្នា ។ ទោះបីជារបបនេះយល់ថា ផែនការបដិវត្តន៍របស់ខ្លួននឹងមានការគាំទ្រពីសំណាក់ប្រជាកសិករក៏ដោយ ប៉ុន្តែផែនការទាំងនេះក៏អាស្រ័យទៅលើការយល់ឃើញជាក់ស្តែងរបស់ប្រជាជនកម្ពុជានៅតាមជនបទដែរ ។ ដូចដែល ហ្វ្រង់ ហ្សាណុន បានសរសេរថា ខ្មែរក្រហមបានលួងលោមប្រជាកសិករដោយលើកសរសើរនូវការងារដែលគាត់បានធ្វើ និងសីលធម៌រស់នៅស្អាតស្អំរបស់គាត់ ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមថែមទាំងបំប៉ោងនូវទុក្ខព្រួយរបស់ប្រជាកសិករ បំផ្ទើសការជិះជាន់កេងប្រវ័ញ្ច និងបំប៉ោងសក្តានុពលដែលប្រជាកសិករមានចំពោះបដិវត្តន៍ ។ ខ្មែរក្រហមបានធ្វើដូចជាការលើកឡើងរបស់ ហ្សាណុន គឺប្រើអំពើឃោរឃៅដើម្បីជម្រះចោលនូវការគោរពអំណាច ប៉ុន្តែប្រជាកសិករកម្ពុជាមិនបានធ្វើដូចជាអ្វីដែល ហ្សាណុន បានលើកឡើងជាទូទៅចំពោះសង្គមខ្មែរនៅតាមជនបទនោះទេដែលថា «ប្រជាកសិករគិតអំពីបញ្ហារំដោះ លើកលែងតែក្នុងន័យប្រើអំពើឃោរឃៅ...ការតស៊ូជាតិ និងការបះបោរដោយអាវុធ» ។ ផ្ទុយទៅវិញ ប្រជាកសិករខ្មែរមិនធ្វើដូចនេះឡើយ ដូចអ្វីដែល ចេមស៍ ស្កុត បានលើកឡើងថា «ប្រជាកសិករខ្មែរមិនប្រឆាំងទៅនឹងអំពើជិះជាន់កេងប្រវ័ញ្ចទេ ឲ្យតែអំពើនោះស្របទៅតាមការរកស៊ីត្រឹមត្រូវ យុត្តិធម៌ និងត្រូវតាមនិយមន័យនៃការជិះជាន់កេងប្រវ័ញ្ច ព្រមទាំងស្របទៅតាមតម្រូវការចាំបាច់មានហូបចុកគ្រប់គ្រាន់» ។ នេះគឺជាការយល់ឃើញរបស់ប្រជាកសិករភាគច្រើននៅតាមជនបទមុនពេលមានសង្គ្រាម ដែលជីវិតប្រជាកសិករទាំងនោះរស់នៅដោយលំបាកលំបិនមែន ប៉ុន្តែមិនដល់ថ្នាក់ខ្វះមុខខ្វះក្រោយនោះទេ ។

តាមការពិត ប្រជាកសិករត្រូវបានអូសទាញឲ្យធ្វើបដិវត្តន៍ដោយសារការគោរពដ៏ជ្រាលជ្រៅរបស់ខ្លួនចំពោះសម្តេច សីហនុ នៃប្រទេសកម្ពុជា ។ ក្រោយថ្ងៃរដ្ឋប្រហាររបស់ពួកស្តាំនិយមទម្លាក់ព្រះអង្គនៅខែមីនា ឆ្នាំ១៩៧០ សម្តេច សីហនុ និងអ្នកគាំទ្រព្រះអង្គ បានបង្កើតសម្ព័ន្ធភាពជាមួយក្រុមមួយដែលព្រះអង្គធ្លាប់បានហៅថា «ខ្មែរក្រហម» ជាជនកុម្មុយនិស្តកម្ពុជា

ដែលជាអតីតសត្រូវរបស់ព្រះអង្គ ។ រដ្ឋប្រហារនោះបានបញ្ចប់ការគ្រប់គ្រងអំណាចដ៏យូរលង់របស់ព្រះអង្គ ហើយនាំយកសេនាប្រមុខ លន់ ណុល ដែលគាំទ្រដោយសហរដ្ឋអាមេរិក មកកាន់អំណាចវិញម្តង ។ សម្ព័ន្ធភាពរវាងព្រះអង្គនិងខ្មែរក្រហមមានឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា ។ នៅក្នុងសង្គ្រាមស៊ីវិលបន្ទាប់ពីព្រឹត្តិការណ៍នោះ ប្រជាកសិករភាគច្រើនបានប្រយុទ្ធដើម្បីស្តារឡើងវិញនូវសណ្តាប់ធ្នាប់មុនពេលមានសង្គ្រាមដែលមានសម្តេច សីហនុ ជាព្រះប្រមុខរដ្ឋ មិនមែនដើម្បីធ្វើការផ្លាស់ប្តូរបដិវត្តន៍ឡើយ ។ តាមការពិត ប្រជាកសិករមានការច្របូកច្របល់ដោយសារកម្មវិធីខុសធាតុពិតរបស់កុម្មុយនិស្តខ្មែរក្រហមដែលចាត់ទុកសក្តិភូមិម្ចាស់ដីជាបញ្ហាធំបំផុតរបស់ប្រជាកសិករ ។ ប្រជាកសិករភាគច្រើនមានដីធ្លីរបស់ខ្លួន ។ មានតែប្រជាកសិករភាគតិច ប្រជាកសិករដែលគ្មានដីធ្លីប៉ុណ្ណោះ ដែលប្តេជ្ញាដាច់ខាតបម្រើបុព្វហេតុបដិវត្តន៍របស់ខ្មែរក្រហម ហើយភាគច្រើនមិនច្បាស់ក្នុងចិត្តថាតើត្រូវតែគាំទ្រគោលការណ៍បដិវត្តន៍របស់ខ្មែរក្រហមដែរឬក៏យ៉ាងណាឡើយ ។ ប្រការនេះបានធ្វើឲ្យខ្មែរក្រហមប្រើអាវុធដើម្បីទាញយកនូវការលះបង់ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនៃសង្គ្រាម នៅពេលដែលខ្មែរក្រហមគ្រប់គ្រងសម្ព័ន្ធភាព ព្រមទាំងចាប់ផ្តើមប្រមាថបង្ខូចព្រះកិត្តិនាមសម្តេចសីហនុ នៅក្នុងការឃោសនារបស់ខ្លួន ព្រមទាំងលែងឲ្យតម្លៃទៅលើឥទ្ធិពលរបស់ព្រះអង្គនៅក្នុងរណសិរ្សរួបរួមជាតិតទៅទៀត ។ ប្រជាកសិករត្រូវបានគំរាមកំហែងបង្ខំឲ្យចូលបម្រើកងទ័ពខ្មែរក្រហម ដែលកាន់តែធ្វើឲ្យថមថយនូវការសាទររបស់គាត់ចំពោះបដិវត្តន៍ ។ បដិវត្តន៍ផ្តល់ផលប្រយោជន៍ឲ្យប្រជាកសិករតិចតួចណាស់ គឺគ្មានអ្វីក្រៅពីការធ្វើឲ្យនិរាសព្រាត់ប្រាសគ្រួសារ អំពើឃោរឃៅ និងការប្រើប្រាស់ភេរវកម្មនៅគ្រប់ទីកន្លែងឡើយ ។

ចំណុចដែលលើកឡើងទាំងនេះគឺជាការពិតសម្រាប់ស្ត្រីកសិករកម្ពុជាដែលធ្លាប់ទទួលរងនូវការប៉ុនប៉ងរបស់ខ្មែរក្រហមក្នុងការកំណត់តួនាទីសាជាថ្មីរបស់ស្ត្រី និងធ្វើឲ្យទំនាក់ទំនងសង្គមរបស់ស្ត្រីមានភាពច្របូកច្របល់ ។ និក្ខេបបទនេះនឹងបង្ហាញថាជនកុម្មុយនិស្តកម្ពុជាខកខានមិនបានទាក់ទាញស្ត្រីឲ្យបានច្រើនដោយធ្វើឲ្យស្ត្រីលែងមានភាពជិតស្និទ្ធជាមួយបុព្វហេតុដិវត្តន៍តាមរយៈល្បិចជ្រើសរើសឲ្យចូលបដិវត្តន៍ ការបំពាក់បំប៉នមនោគមវិជ្ជានៅខ្សោយ និងការបង្ខំឲ្យព្រាត់ប្រាសពីក្រុមគ្រួសារ ។ តាមការពិតខ្មែរក្រហមមិនយកចិត្តទុកដាក់ចំពោះបញ្ហាស្ត្រីស្ទើរតែទាំងអស់ ដោយខកខានមិនបានកំណត់តួនាទីបដិវត្តន៍គួរឲ្យជឿបានរបស់ស្ត្រីកម្ពុជា ។ ជាលទ្ធផល ស្ត្រីទាំងនោះមានហេតុផលតិចតួចណាស់ក្នុងការគាំទ្រខ្មែរក្រហម ។

មុនពេលកើតមានខ្មែរកុម្មុយនិស្ត ស្ត្រីជាកសិករនៅប្រទេសកម្ពុជារក្សានូវឥទ្ធិពលដ៏សំខាន់និងស្វ័យភាពនៅក្នុងផ្ទះសម្បែងព្រមទាំងនៅក្នុងភូមិដ្ឋានដែលខ្លួនរស់នៅទៀតផង គ្រាន់តែឥទ្ធិពលនោះស្ថិតក្នុងកម្រិតទាបប៉ុណ្ណោះ ។ ស្ត្រីគ្រប់គ្រងប្រាក់កាសក្នុងផ្ទះ និងចូលរួមប្រតិបត្តិការនៅក្នុងទីផ្សារយ៉ាងសកម្ម ដែលជាការរួមវិភាគទានយ៉ាងសំខាន់នៅក្នុងផលិតកម្មក្នុងផ្ទះ ។ ស្ត្រីទទួលបានសិទ្ធិក្នុងការបោះឆ្នោតនៅឆ្នាំ១៩៥៦ ហើយបានអនុវត្តសិទ្ធិនេះយ៉ាងសកម្មទៀតផង ។ ស្ត្រីក៏អាចធ្វើកិច្ចការនយោបាយទោះបីជាតួនាទីនេះមានបុរសចូលរួមច្រើនជាងទាំងនៅក្នុងថ្នាក់ជាតិនិងថ្នាក់ភូមិ-ឃុំក៏ដោយ ។ ប្តីនិងប្រពន្ធរក្សាតួនាទីសមភាព ហើយការសិក្សាជាច្រើនបានកត់សម្គាល់អំពីតុល្យភាពដ៏ប្រពៃដែលជាការចង្អុលលក្ខណៈអាពាហ៍ពិពាហ៍របស់កសិករកម្ពុជា ។ ទន្ទឹមគ្នានេះដែរ ស្ត្រីទទួលបាននូវភាពងាយស្រួលក្នុងការប្រើសិទ្ធិលែងលះ ហើយអ្នកដែលបានលែងលះគ្នាថែមទាំងគ្មានស្លាកស្នាមទុយ៌សទៀតផង ។ មិនតែប៉ុណ្ណោះ ស្ត្រីមានសិទ្ធិកាន់កាប់និងទទួលមរតកដីធ្លីថែមទៀត ។ ក្នុងខណៈដែលស្ត្រីជនបទភាគច្រើនមិនចេះអក្សរ ការអប់រំបណ្តុះបណ្តាលសម្រាប់ស្ត្រីមានការកើនឡើងនៅប៉ុន្មានឆ្នាំមុនពេលជម្លោះកើតឡើង ។ កុមារីជំទង់ៗធ្វើស្រែចម្ការច្បារដំណាំ និងមើលថែទាំប្អូនៗ ។ ភាគច្រើននៃកុមារីវ័យជំទង់ចូលបម្រើការងារពាក់កណ្តាលម៉ោង ព្រមទាំងរក្សាទុកនូវប្រាក់កម្រៃដែលខ្លួនរកបាន ។ ទោះបីជាមានការទទួលខុសត្រូវច្រើនយ៉ាងក៏ដោយ ក៏កុមារីវ័យជំទង់ទាំងនេះនៅតែមានពេលវេលាលម្ហែកាយសមស្រប ហើយអាចសេពគប់បានទាំងមិត្តភក្តិស្រីនិងមិត្តភក្តិប្រុស ។ នៅក្នុងអំឡុងពេលបដិវត្តន៍ តួនាទីស្ត្រីមិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ទាល់តែសោះ ហើយការងារដែលស្ត្រីទទួលវិញគឺសឹងតែជាការងារពិបាកៗរាប់មិនអស់ ។ បដិវត្តន៍ខ្មែរក្រហមបានកេងប្រវ័ញ្ចលើការងារ

របស់ស្ត្រី នៅអំឡុងពេលសង្រ្គាមនិងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខណៈពេលដែលខ្លួនអះអាងដោយភាពមន្ទិលសង្ស័យថា ខ្លួនបានធ្វើឲ្យបុរសនិងស្ត្រីមានភាពស្មើគ្នា ។ ទន្ទឹមពេលនេះដែរ ខ្មែរក្រហមបន្ទាប់តម្លៃ "គ្រួសារនិយម" ហើយវាយប្រហារមកលើរចនាសម្ព័ន្ធគ្រួសារដែលជាប្រពៃណីរបស់ខ្មែរ ដោយមានចេតនាបំបែកចំណងដ៏ស្អិតល្មួតរវាងឪពុកម្តាយនិងកូន ហើយបង្វែរចំណងភក្តីភាពនេះឲ្យងាកទៅរកអង្គការវិញ ។ គោលនយោបាយនេះគ្មានតម្លៃសម្រាប់ប្រជាកសិករទេ (ជាពិសេសស្ត្រី) ដោយសារថា គ្រួសារគឺជាក្រុមដ៏សំខាន់មួយនៃសង្គមប្រជាកសិករកម្ពុជា ។ ការរំលោភមកលើគ្រួសារមានដើមកំណើតនៅក្នុងទ្រឹស្តីស្តីអំពីគ្រួសារនិងសមភេទរបស់ ហ្វ្រេដរិក អ៊ែងដែល ។ ទោះបីជាខ្មែរក្រហមអនុវត្តនូវគំនិតរបស់ អ៊ែងដែល ដូចជានយោបាយរបស់ខ្លួនចំពោះស្ត្រីក៏ដោយ ក៏មានលក្ខណៈគ្រោតគ្រាតបំផុតដែរ ។

ផ្ទុយមកវិញ អ្នកប្រកាន់លទ្ធិកុម្មុយនិស្តដូចជាខ្មែរក្រហមមួយចំនួននៅអាស៊ី បានអភិវឌ្ឍកម្មវិធីទំនើបៗសម្រាប់ស្ត្រី ហើយបានប្រើប្រាស់ដោយមានប្រសិទ្ធភាពនៅអំឡុងពេលនៃបដិវត្តន៍របស់ខ្លួន ។ ជនកុម្មុយនិស្តចិននិងវៀតណាមបានទាក់ទាញស្ត្រីឲ្យចូលបម្រើបុព្វហេតុបដិវត្តន៍របស់ខ្លួនតាមរបៀបវារៈបដិរូបនិយម (លទ្ធិនយោបាយដែលនិយមថាអាចកែប្រែសង្គមបានដោយកែប្រែច្បាប់ដែលផ្ទុយនឹងបដិវត្តន៍) ដែលវាយប្រហារទៅលើប្រព័ន្ធគ្រប់គ្រងដោយព្រឹទ្ធាចារ្យ ។ ជនកុម្មុយនិស្តទាំងនោះបានសន្យាថានឹងលើកកម្ពស់ស្ត្រីតាមរយៈការងាររបដិវត្តរបស់ខ្លួន និងផ្តល់នូវផលប្រយោជន៍ស្របច្បាប់រួមទាំងសិទ្ធិកាន់កាប់ដីធ្លី សិទ្ធិបោះឆ្នោត សិទ្ធិអាពាហ៍ពិពាហ៍ និងសិទ្ធិលែងលះ ។ ស្ត្រីត្រូវបានផ្តល់នូវតួនាទីសំខាន់ៗនៅក្នុងការតស៊ូដណ្តើមអំណាចដែលស្ត្រីទាំងនោះធ្វើឡើងដោយស្ម័គ្រចិត្ត និងប្រកបដោយមោទកភាព ។ កូរ៉េខាងជើងហាក់ដូចជាប្រើប្រាស់ស្ត្រីតាមវិធីស្រដៀងគ្នានេះដែរ ទោះបីជាគោលនយោបាយរបស់កូរ៉េខាងជើងចំពោះស្ត្រីមិនសូវពុទ្ធរខ្ចាយក៏ដោយ ។ ក្នុងខណៈដែលប្រទេសទាំងពីរប្រកាន់ប្រពៃណីគ្រួសារដែលបិតាមានអំណាចលើសសមាជិកគ្រួសារ ដែលជាមូលហេតុធ្វើឲ្យកំណែទម្រង់ស្ត្រីមានល្បឿនយឺតនោះ វាច្បាស់ណាស់ថា បក្សកុម្មុយនិស្តរបស់ប្រទេសទាំងពីរនេះចាត់ទុកបញ្ហាស្ត្រីជាបញ្ហាសំខាន់ដូចៗគ្នា មិនដូចជាបក្សកុម្មុយនិស្តកម្ពុជាទេ ។ បក្សកុម្មុយនិស្តកម្ពុជាគឺជាឧបករណ៍នយោបាយរបស់ខ្មែរក្រហមដែលធ្វើមិនដឹងមិនឮអំពីតម្រូវការចាំបាច់ស្ទើរតែទាំងអស់របស់ស្ត្រីកម្ពុជា ។

ការធ្វេសប្រហែសរបស់ខ្មែរក្រហមទៅលើបញ្ហាស្ត្រីបានឆ្លុះបញ្ចាំងនៅក្នុងសំណេរប្រវត្តិសាស្ត្រកម្ពុជា ។ អ្នកសិក្សាស្រាវជ្រាវមួយចំនួនតូចបានសិក្សាជាពិសេសទៅលើតួនាទីរបស់ស្ត្រីកម្ពុជាក្រោមរបបខ្មែរក្រហម ហើយកិច្ចការស្រាវជ្រាវជាច្រើនដែលពិនិត្យទៅលើចលនាជាប្រវត្តិសាស្ត្ររបស់ខ្មែរ-ក្រហម បានយកចិត្តទុកដាក់តិចតួចណាស់ទៅលើស្ត្រីកម្ពុជា ។ ប្រការនេះអាចពន្យល់បានថា មួយផ្នែកគឺដោយសារភាពកម្រឯកសារភ័ស្តុតាងទាក់ទងនឹងចំណាប់អារម្មណ៍របស់បក្សកុម្មុយនិស្តកម្ពុជាទៅលើបញ្ហាស្ត្រី ។ សូម្បីតែឯកសារបក្សដែលគេដឹងថាមាននោះ ក៏ទាក់ទងនឹងបញ្ហានេះតិចតួចដែរ ។ គ្មានអ្នកសិក្សាស្រាវជ្រាវណាម្នាក់ស្វែងយល់ឲ្យបានលម្អិតនោះទេ ហើយក៏គ្មានកន្លែងណាដែលកំណត់ឲ្យបានច្បាស់លាស់អំពីគោលនយោបាយចំពោះស្ត្រីដែរ ។ ប្រការនេះពិបាកនឹងទាញថាស្ត្រីមិនបានទទួលផលប៉ះពាល់ពីទង្វើរបស់ខ្មែរក្រហមនៅក្នុងអំឡុងពេលបដិវត្តនោះទេ មានន័យថា ការធ្វេសប្រហែសពិតៗដែលជាជីហានរបស់ជនកុម្មុនិស្តចំពោះស្ត្រីមានផលវិបាកធ្ងន់ណាស់សម្រាប់ជនកុម្មុយនិស្តខ្លួនឯង ហើយបានកំណត់នូវការយល់ឃើញរបស់ស្ត្រីចំពោះរបបនោះ ។ និក្ខេបបទនេះមានបំណងចង់បំពេញនូវចន្លោះប្រហោងសំណេរប្រវត្តិសាស្ត្រទាក់ទងនឹងស្ត្រីកម្ពុជាក្រោមរបបខ្មែរក្រហម ។

និក្ខេបបទនេះចែកចេញជាបីជំពូក ។ ជំពូកទី១និយាយអំពីទិដ្ឋភាពទូទៅនៃការសរសេរប្រវត្តិសាស្ត្រទូទៅទាក់ទងនឹងប្រធានបទនេះ ។ ដំបូងខ្ញុំធ្វើការវិភាគទៅលើសំណេរតូច ប៉ុន្តែមានសារសំខាន់ស្តីអំពីស្ត្រីនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់និក្ខេបទបទនេះ ។ បន្ទាប់មកមានការប្រមូលដោយមានការសង្កត់ធ្ងន់ទៅលើការវិភាគអំពីការគាំទ្ររបស់ប្រជាកសិករមកលើបដិវត្តន៍ វិធីសាស្ត្រក្នុងការជ្រើសរើសរបស់ខ្មែរក្រហមនិងស្នាដៃស្រាវជ្រាវនានាដែលមានពីមុនមក ទាក់ទងនឹងខ្មែរកុម្មុយនិស្ត ។ ចុងបញ្ចប់ ខ្ញុំពិនិត្យទៅលើសំណេរប្រវត្តិសាស្ត្រ

ទាក់ទងនឹងតួនាទីរបស់ស្ត្រីនៅក្នុងបដិវត្តន៍ប្រទេសចិននិងប្រទេសវៀតណាម ។ ចំណុចចុងក្រោយនេះនាំដោយផ្ទាល់ដល់ទ្រឹស្តីប្រៀបធៀបដែលបានប្រើនៅក្នុងជំពូកទី២ ។ នៅទីនេះ នយោបាយទំនើបរបស់ចិន វៀតណាម និងកូរ៉េខាងជើង ចំពោះស្ត្រី មានលក្ខណៈផ្ទុយគ្នាទៅនឹងនយោបាយអរូបរបស់ខ្មែរក្រហមចំពោះស្ត្រី ។ តាមពិត ការវិភាគទៅលើឯកសារបក្សកុម្មុយនិស្តកម្ពុជានៅក្នុងជំពូកនេះបង្ហាញថា ខ្មែរក្រហមមានការជឿជាក់ទៅលើលក្ខណៈពិសេសនៃបដិវត្តន៍របស់ខ្លួន ហើយប្តេជ្ញាចិត្តធ្វើឲ្យចម្រើនទៅមុខដោយឯករាជ្យម្ចាស់ការ ។ នៅក្នុងជំហរនេះ ខ្ញុំចោទជាសំណួរថា តើខ្មែរក្រហមយកគំរូតាមរដ្ឋកុម្មុយនិស្តនានាដែលមានឥទ្ធិពលលើជនកុម្មុយនិស្តកម្ពុជានៅពេលតែមួយឬដោយឡែកៗពីគ្នា ជាពិសេសឥទ្ធិពលពីប្រទេសចិននិងវៀតណាម?

ជំពូកទី៣លើកឡើងអំពីទឡ្ហីករណ៍បីអំពីនិក្ខេបបទនេះ ។ នៅក្នុងទឡ្ហីករណ៍នេះ ខ្ញុំបង្ហាញជូនហេតុផលបួនយ៉ាងដែលបណ្តាលឲ្យខ្មែរក្រហមទទួលបរាជ័យក្នុងការទាក់ទាញស្ត្រីឲ្យជឿជាក់ទៅលើបុព្វហេតុបដិវត្តន៍របស់ខ្លួន ។ ទី១) យុទ្ធសាស្ត្រទន់ខ្សោយក្នុងការជ្រើសរើសឲ្យចូលបដិវត្តន៍ ២) ការពង្រាត់ក្រុមគ្រួសារ ៣) ការបញ្ចូលមនោគមវិជ្ជាមិនគ្រប់គ្រាន់ និងទី៤) ការខកខានក្នុងការបង្កើតឡើងនូវតួនាទីដ៏មានប្រសិទ្ធភាពរបស់ស្ត្រីនៅក្នុងបដិវត្តន៍កុម្មុយនិស្ត ។

ការរកឃើញរបស់ខ្ញុំគឺផ្អែកទៅលើការពិនិត្យទៅលើស្នាដៃនិពន្ធនានានិងកិច្ចសម្ភាសន៍ដែលធ្វើឡើងជាមួយនារីកសិករកម្ពុជាចំនួន២០នាក់ នៅក្នុងអំឡុងខែកក្កដានិងខែសីហា ឆ្នាំ២០០២ ។ វាគឺជាប្រវត្តិសាស្ត្រដែលថតជាប់នឹងខួរក្បាល ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃនិក្ខេបបទនេះ ។ ការសិក្សានេះបង្ហាញនូវលំហាត់ដំបូងទាក់ទងនឹងប្រវត្តិសាស្ត្រថតទុកក្នុងខួរក្បាល និងការចាប់ផ្តើមសមល្មមនូវការសិក្សាទៅលើយុទ្ធសាស្ត្ររបស់ខ្មែរក្រហមចំពោះការជ្រើសរើសនិងប្រើប្រាស់កម្មាភិបាលនារី ។ មានស្ត្រីពីរនាក់ដែលរស់នៅភូមិឆ្ងាយពីគ្នាពីរបីគីឡូម៉ែត្រ បានផ្តល់កិច្ចសម្ភាសន៍ ។ ស្ត្រីពីរនាក់ទៀតរស់នៅស្រុកជិតខាងគ្នា ។ តំបន់ទាំងមូលនេះត្រូវបានកាន់កាប់ដោយក្រុមបះបោរចាប់តាំងពីឆ្នាំ១៩៧០ ដែលដំបូងឡើយគ្រប់គ្រងដោយជនកុម្មុយនិស្តវៀតណាម និងសម្តេច សីហនុ ហើយបន្តបន្ទាប់មកទៀតដោយសង្គ្រាមចេះតែអូសបន្លាយ ទីនេះក៏ត្រូវកាន់កាប់ដោយខ្មែរក្រហម ។ តំបន់នេះក៏ជាសមរភូមិទម្លាក់គ្រាប់បែកដ៏ធ្ងន់ធ្ងរពេញអំឡុងពេលសង្គ្រាមពីសំណាក់កងទ័ពនៃរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយ លន់ ណុល និងកងទ័ពសម្ព័ន្ធមិត្តគឺអាមេរិក ។ ស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហម ភូមិដែលស្ត្រីទាំងនេះរស់នៅគឺស្ថិតនៅក្នុងតំបន់២៥ដែលជាផ្នែកមួយនៃភូមិភាគនិរតី ។ ប្រវត្តិវិទូ ម៉ៃឃើល វីកឃ័រី ហៅតំបន់នេះថា«តំបន់ប៉ុលពតនិយម» ដែលជាមូលដ្ឋានអំណាចរបស់រដ្ឋាភិបាលប៉ុលពត ។ អ្វីដែលគួរឲ្យសង្កត់ធ្ងន់នោះគឺ វីកឃ័រី បានកត់សម្គាល់ថា ស្ថានភាពជាក់ស្តែងមានលក្ខណៈខុសប្លែកពីគ្នាច្រើនក្នុងទូទាំងប្រទេសកម្ពុជានៅអំឡុងឆ្នាំ១៩៧០ គឺគោលនយោបាយចេញពីមជ្ឈិមត្រូវបានអនុវត្តផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា ។

យ៉ាងណាក៏ដោយ ដោយសារស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម អតីតតំបន់២៥បង្ហាញអំពីកន្លែងពិសេសដើម្បីកំណត់នូវជំហររបស់ខ្មែរក្រហមចំពោះស្ត្រី ។ បទពិសោធន៍នៃអ្នកផ្តល់កិច្ចសម្ភាសន៍មិនអាចតំណាងឲ្យស្ត្រីកម្ពុជាទាំងអស់បានទេ ប៉ុន្តែបទពិសោធន៍ទាំងនេះបញ្ជាក់នូវគំនិតទាក់ទងទៅនឹងស្ត្រីដែលមានប្រភពចេញពីមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត ។ លទ្ធផលចុងក្រោយគឺភាពទទេស្អាតដែលបង្កើតចេញនូវភាពច្របូកច្របល់ ភាពឯកា និងការឈឺចាប់ សម្រាប់ស្ត្រីកម្ពុជា ។

## ជំពូក១

## ស្ត្រីនៅក្នុងបដិវត្តន៍កម្ពុជា វៀតណាម និងចិនៈ ការពិនិត្យលើទិដ្ឋភាពប្រវត្តិសាស្ត្ររួម

*«យើងធ្វើបដិវត្តន៍ ។ បដិវត្តន៍នៅប្រទេសវៀតណាមនិងបារាំងក៏មានកំហុសជាច្រើនដែរ ។ ធ្វើត្រូវច្រើនហើយខុសក៏ច្រើន ។ យើងព្យាយាមធ្វើ ។» នេះជាសម្តីរបស់ អៀង សារី (អតីតរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ) នៅឆ្នាំ១៩៨០ ។*

នយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រីកសិករកម្ពុជាបានបង្ហាញអំពីការបំបាក់ប្រពៃណីដ៏គំហុក ក៏ដូចជាសកម្មភាពបដិវត្តន៍របស់ខ្លួននៅស្ទើរគ្រប់វិស័យ ។ ខ្មែរក្រហមព្យាយាមធ្វើឲ្យទន់ខ្សោយចំណងគ្រួសារ ហើយជំនួសវិញដោយចំណង

អង្គការ ។ ការវាយប្រហារទៅលើគ្រួសារនៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមទាំងនេះ ចាប់ផ្ដើមនៅអំឡុងពេលសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ដែលក្រៅពីសកម្មភាពផ្សេងៗទៀត ខ្មែរក្រហមក៏បានជ្រើសរើសស្ត្រីឲ្យចូលបម្រើកងទ័ពដែរ ។

តួនាទីរបស់ស្ត្រីនៅក្នុងបដិវត្តន៍កម្ពុជាភាគច្រើនមិនត្រូវបានអ្នកសិក្សាស្រាវជ្រាវអើពើឡើយ ។ អ្នកស្រាវជ្រាវភាគច្រើនកត់សម្គាល់ឃើញថា ខ្មែរក្រហមបានកេណ្ឌប្រជាជនទាំងប្រុសទាំងស្រីនៅក្នុងតំបន់នានាដែលខ្លួនគ្រប់គ្រង ។ មានតែអ្នកស្រាវជ្រាវមួយចំនួនតូចប៉ុណ្ណោះ ដែលបានពិនិត្យយ៉ាងដិតដល់អំពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រីខ្មែរ ព្រមទាំងអំពីការយល់ឃើញរបស់ស្ត្រីខ្មែរទៅលើគោលនយោបាយទាំងនោះ ។ ជាលទ្ធផលឃើញថា តួនាទីរបស់ស្ត្រីទាក់ទងនឹងនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងយោធា ប្រមូលផ្ដុំត្រឹមតែទៅលើសំណេរជាប្រវត្តិសាស្ត្រអំពីកម្ពុជាតែប៉ុណ្ណោះ ។ ការសិក្សាជាច្រើនបានលើកឡើងអត្ថិភាពនៃ «សមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យ» និង «សមាគមស្ត្រីខ្មែរប្រជាធិបតេយ្យ» ការសិក្សាស្រាវជ្រាវជាច្រើនអំពីការរីកធំធាត់និងសារជាតិបដិវត្តន៍កម្ពុជា ឃើញមាននៅក្នុងស្នាដៃនិពន្ធជាច្រើន ។ ការសិក្សាជាន់ខ្ពស់អំពីការគាំទ្រពីសំណាក់ប្រជាកសិករទៅលើខ្មែរក្រហម ស្នាដៃបញ្ញវ័ន្តដែលមានពីមុនៗមកនិងប្រវត្តិនយោបាយ ការប្រើប្រាស់យុវជនយុវនារីកសិករ និងវិធីសាស្ត្រជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍ យុទ្ធនាការបដិវត្តន៍ និងការបញ្ចូលមនោគមវិជ្ជា សុទ្ធតែបានសរសេរចេញអស់ហើយ ។ ការពិនិត្យទៅលើការសិក្សាទាំងនេះអាចឃើញអំពីជំហររបស់ខ្មែរក្រហមចំពោះស្ត្រីនៅក្នុងបរិបទស្រាវជ្រាវនិងប្រវត្តិសាស្ត្រ ។

មិនតែប៉ុណ្ណោះក៏មានស្នាដៃសិក្សាស្រាវជ្រាវដែលចេះតែកើនឡើងនិងមានប្រយោជន៍ ស្ដីអំពីតួនាទីរបស់ស្ត្រីនៃសតវត្សរ៍ទី២០ នៅក្នុងចលនាបដិវត្តន៍នៅប្រទេសចិននិងវៀតណាម ។ ចលនាបដិវត្តន៍ទាំងពីរនេះមានយុទ្ធសាស្ត្រល្អៗសម្រាប់ទាក់ទាញការគាំទ្រពីស្ត្រីកសិករ ដោយប្រើប្រាស់អង្គការស្ត្រីនានាដែលគ្រប់គ្រងយ៉ាងហ្មត់ចត់ ។ លទ្ធផលគឺថា ស្ត្រីចូលរួមវិភាគទានយ៉ាងសំខាន់ដល់ជ័យជម្នះរបស់ចលនាទាំងពីរនេះ ទោះបីជាផលប្រយោជន៍សម្រាប់រយៈពេលវែងនៃគោលនយោបាយកុម្មុយនិស្តចំពោះស្ត្រីនៅក្នុងប្រទេសទាំងនេះត្រូវបានសិក្សាវែកញែកយ៉ាងខ្លាំងពីសំណាក់អ្នកស្រាវជ្រាវក៏ដោយ ជាពិសេសអ្នកសិក្សាស្រាវជ្រាវអំពីប្រទេសចិន ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយទំនើបរបស់ចិននិងវៀតណាមចំពោះស្ត្រី មានលក្ខណៈផ្ទុយស្រឡះពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រីដែលនាំទៅកាន់ផ្លូវខុសនិងគ្មានប្រជាប្រិយភាព ។ ភាពផ្ទុយគ្នានេះធ្វើឲ្យមានការកត់សម្គាល់នូវទំនាក់ទំនងដែលតែងតែមានលក្ខណៈជិតស្និទ្ធរវាងខ្មែរក្រហមជាមួយនឹងជនកុម្មុយនិស្តវៀតណាមនិងចិន ហើយបង្ហាញឲ្យឃើញថា ជនកុម្មុយនិស្តខ្មែរក្រហមបដិសេធមិនព្រមចម្លងមេរៀនតាមសម្ព័ន្ធមិត្តរបស់ខ្លួនឡើយនៅក្នុងការគ្រប់គ្រងលើស្ត្រី ។ កូរ៉េខាងជើងក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងខ្មែរក្រហមដែរ ហើយគោលនយោបាយរបស់ស្ត្រីត្រូវបានលើកយកមកពិនិត្យនៅក្នុងជំពូកទី២ ។ ការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះមានកម្រិតតិចពេក ហេតុដូចនេះហើយបានជាមិនបានលើកមកពិភាក្សានៅក្នុងជំពូកសំណេរប្រវត្តិសាស្ត្រនេះ ។

ជំពូកនេះនឹងផ្ដល់នូវការពិនិត្យដោយលក្ខណៈរិះគន់ទៅលើការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធជាបីផ្នែកៈ ទី១) គោលនយោបាយខ្មែរក្រហមចំពោះស្ត្រីនិងគ្រួសារ ទី២) ការរីកធំធាត់និងសារជាតិបដិវត្តន៍កម្ពុជា ទី៣) តួនាទីរបស់ស្ត្រីនៅក្នុងបដិវត្តន៍ចិននិងវៀតណាម ។

ដើម្បីបំពេញនូវចន្លោះប្រហោងដ៏ធំនៃនយោបាយខ្មែរក្រហមចំពោះស្ត្រីនិងគ្រួសារ សំខាន់គឺត្រូវស្វែងយល់អំពីតួនាទីរបស់ស្ត្រីនៅក្នុងជីវិតកសិករកម្ពុជានៅអំឡុងពេលមុនឆ្នាំ១៩៧០ ។ នៅក្នុងសំណេរអំពីស្ត្រីកម្ពុជានៅតាមភូមិដ្ឋានក្នុងប្រទេសកម្ពុជា នរវិទូ ម៉េ អេប៊ីហ៊ារ៉ា ដែលចំណាយពេលពេញមួយឆ្នាំ (ពីឆ្នាំ១៩៥៩ដល់ឆ្នាំ១៩៦០) រស់នៅក្នុងភូមិមួយនៅជនបទ ប្រទេសកម្ពុជាដើម្បីស្រាវជ្រាវនោះ បានសង្កត់ធ្ងន់អំពីសារសំខាន់របស់គ្រួសារថា «គ្រួសារគឺជាក្រុមសង្គមមានលក្ខណៈគ្រឹះនៅក្នុងជីវិតនៅតាមភូមិដ្ឋាន» ។ គ្មានក្រុមសាច់ញាតិណាដែលរៀបចំឡើងឲ្យហួសពីផ្ទះសម្បែងឡើយ គ្មានក្លិប គ្មានគណបក្សនយោបាយ ឬសមាគមជាផ្លូវការឡើយ ។ ចំណងទាក់ទងរវាងឪពុកម្ដាយនិង

កូនមានសភាពរឹងមាំណាស់ ជាពិសេសរវាងម្តាយនិងកូនស្រី ។ ស្ត្រីចង់នៅជិតឪពុកម្តាយ សូម្បីតែក្រោយពេលរៀបការហើយក៏ដោយ ។ យោងតាម អេប៊ីហ៉ារ៉ា ស្ត្រីខ្មែរ «មានអំណាចច្រើន មានឯករាជ្យភាព និងមានសេរីភាព» ។ ឧទាហរណ៍ស្ត្រីខ្មែរដើរតួនាទីខាងសេដ្ឋកិច្ចគ្រួសារ «ដែលមិនអាចអត់បាន» ដោយគ្រប់គ្រងនូវរាល់ហិរញ្ញវត្ថុនិងប្រតិបត្តិការទីផ្សារយ៉ាងសកម្ម ។

នៅក្នុងអត្ថបទមួយក្រោយសម័យកម្ពុជាប្រជាធិបតេយ្យស្តីអំពី «បដិវត្តន៍និងកំណែទម្រង់នៅក្នុងវប្បធម៌ភូមិខ្មែរ» អេប៊ីហ៉ារ៉ា បានពិពណ៌នាអំពីរបៀបដែលកម្ពុជាប្រជាធិបតេយ្យវាយប្រហារទៅលើគ្រួសារនិងទំនាក់ទំនងជាមួយសាច់ញាតិនៅក្នុងកិច្ចខិតខំប្រឹងប្រែងទាក់ទាញស្ត្រីឲ្យចូលបម្រើបដិវត្តន៍ ។ ខ្មែរក្រហមខិតខំរិះរកមធ្យោបាយលុបបំបាត់គ្រួសារ ភូមិ និងព្រះពុទ្ធសាសនា ដោយចាត់ទុកថាប្រការទាំងនេះគឺជាភក្តីភាពដែលប្រកួតប្រជែងជាមួយបដិវត្តន៍ ។ ចំណុចគួរឲ្យកត់សម្គាល់មួយទៀតនោះគឺ យោងតាម អេប៊ីហ៉ារ៉ា ការវាយប្រហារដ៏ខ្លាំងក្លាបំផុតរបស់កម្ពុជាប្រជាធិបតេយ្យមកលើទំនាក់ទំនងគ្រួសារកសិករ គឺទំនាក់ទំនងរវាងឪពុកម្តាយនិងកូន ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុមារដែលមានអាយុលើសពី៧ឆ្នាំកម្រនឹងបានជួបមុខឪពុកណាស់ ហើយតែងតែត្រូវយកទៅអប់រំបំពាក់បំប៉នមនោគមវិជ្ជាបដិវត្ត ។ ការលះបង់អ្វីៗសម្រាប់អង្គការបានចូលមកជំនួសភក្តីភាពរបស់ខ្លួនជាមួយគ្រួសារ ហើយអំណាចជាឪពុកក៏ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការតែមួយ ។ ក៏ប៉ុន្តែ អេប៊ីហ៉ារ៉ា បានបំផ្លើសករណីរបស់ខ្លួនពីព្រោះមិនមែនគ្រប់កុមារទាំងអស់សុទ្ធតែត្រូវបានបញ្ចុះបញ្ចូលឲ្យប្តូរគំនិតដូចដែលអ្នកស្រីបានលើកឡើងនោះទេ ។ ការបញ្ចូលមនោគមវិជ្ជារបស់ខ្មែរក្រហមដូចដែលនឹងបង្ហាញជូននៅក្នុងជំពូក៣ គឺតែងតែគ្មានប្រសិទ្ធភាពនិងត្រូវបានជំទាស់ ។

ម៉ម កល្យានី ដែលសរសេរអត្ថបទមួយមានចំណងជើងថា «កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ ស្ត្រីគឺជាឧបករណ៍សម្រាប់ផ្លាស់ប្តូរសង្គម» បានដោយកកន្លែងដែល អេប៊ីហ៉ារ៉ា មិនបានបញ្ចូលនៅក្នុងស្នាដៃនិពន្ធទីពីររបស់ខ្លួន ។ សំណេររបស់ កល្យានី ផ្តោតកាន់តែខ្លាំងថែមទៀតទៅលើការវាយប្រហារមកលើគោលនយោបាយសង្គមរបស់កម្ពុជាប្រជាធិបតេយ្យ ហើយបង្ហាញការសិក្សាដែលមានតែមួយទាក់ទងនឹងស្ថានភាពស្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ផ្អែកលើកិច្ចសម្ភាសន៍ជាមួយស្ត្រីកសិករកម្ពុជា កល្យានី ទាញហេតុផលថាខ្មែរក្រហមប្រើប្រាស់វោហារសាស្ត្រទាក់ទាញដែលនិយាយអំពីសមភេទ ក្នុងគោលបំណងកេងយកផលប្រយោជន៍ពីពលកម្មស្ត្រីនៅក្នុងការបង្កបង្កើនផល បំផ្លាញនូវគ្រួសារសមាជិកតិចព្រមទាំង«ចងភ្ជាប់ស្ត្រីយ៉ាងតឹងទៅនឹងបំណងរបស់អង្គការ» ។ ការរៀបចំគោលនយោបាយនិយាយអំពីសិទ្ធិដោយផ្តោតសំខាន់ទៅលើសមភេទ គឺជាឧបករណ៍ដែលខ្មែរក្រហមប្រើប្រាស់ដើម្បីប្រមូលពលកម្មស្ត្រីតែប៉ុណ្ណោះ ដោយនិយាយតែមាត់ក្រៅថាវាជាការរំដោះស្ត្រីឲ្យចាកផុតពីគំនិតដែលថាស្ត្រីបង្វិលចង្ក្រានមិនជុំ ។ តាមការពិត ការកម្ចាត់មិនឲ្យស្ត្រីធ្វើការងារក្នុងផ្ទះដូចជាការចម្អិនអាហារនិងចិញ្ចឹមកូន គឺ «បានរំលោភសិទ្ធិរបស់នារីក្នុងការចិញ្ចឹមបីបាច់បុត្រធីតានិងគ្រួសារ» ហើយវាជាការប៉ុនប៉ងដ៏ឃោរឃៅក្នុងការលុបបំបាត់តួនាទីរបស់ស្ត្រីក្នុងនាមជាម្តាយ ពោលគឺជាអ្វីដែលទទួលនូវការមិនពេញចិត្តនិងបដិសេធយ៉ាងខ្លាំង បើតាមដែល កល្យានី បានលើកឡើង ។ កម្ពុជាប្រជាធិបតេយ្យថែមទាំងបានបំបាត់នូវសិទ្ធិនារីក្នុងការរកការងារធ្វើដោយខ្លួនឯង ដោយបង្ខំឲ្យស្ត្រីទៅធ្វើការស្រែចម្ការដើម្បីបម្រើបដិវត្តន៍ ។ ការកម្ចាត់បែបនេះបង្ហាញអំពីការមិនប្រើប្រាស់គ្រួសារកម្ពុជាជាស្ថាប័នសង្គម ប៉ុន្តែបែរជាចាត់ទុកថា ភក្តីភាពរបស់បុគ្គលត្រូវផ្ទេរទៅឲ្យអង្គការទៅវិញ ។

នៅក្នុងសៀវភៅដែលមានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ដែលជាការពិភាក្សាយ៉ាងទូលំទូលាយនិងលម្អិតទៅលើបដិវត្តន៍ខ្មែរក្រហម អ្នកកាសែត អេលីហ្សាប៊ែត ប៊ែកឃ័របានសង្កត់ធ្ងន់ទៅលើផលវិបាករបស់បដិវត្តន៍មកលើគ្រួសារខ្មែរ ដោយសារការគំរាមកំហែងថាវាតំណាងឲ្យខ្មែរក្រហម ។ ការរកឃើញរបស់ អេលីហ្សាប៊ែត គឺផ្អែកលើប្រភពឯកសារដើមជាច្រើនដូចជា៖ ឯកសារបក្សកុម្មុយនិស្តកម្ពុជា ចម្លើយសារភាពរបស់អ្នកទោស កិច្ចសម្ភាសន៍ជាមួយមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា (រួមទាំង ប៉ុល ពត ផ្ទាល់) និងកិច្ចសម្ភាសន៍ជាមួយប្រជាជនកម្ពុជាដែលរស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ អេលីហ្សាប៊ែត កត់សម្គាល់ថា ជំងឺ ការបំផ្លិច

បំផ្លាញ និងការស្លាប់ដែលបណ្តាលមកពីបដិវត្តន៍ គឺជាការវាយសំពងយ៉ាងធ្ងន់ធ្ងរមកលើក្រុមគ្រួសារតាំងពីមុនពេលដែលគោលនយោបាយឆាឆៅបង្អាក់របស់ជនកុម្មុយនិស្តត្រូវបានអនុវត្តទៅទៀត។ អេលីហ្សាប៊ែត បានសរសេរចំណុចក្តៅនៅក្នុងសំណេរនេះថា ស្ទើរតែគ្រប់គោលនយោបាយទាំងអស់នៅក្នុងផ្លូវខ្វះបាននាំដល់ការបែកខ្ញែកក្រុមគ្រួសារ ដោយសារភក្តីភាពចំពោះគ្រួសារគឺជាការគំរាមកំហែងធំបំផុតចំពោះអង្គការ ដែលអង្គការនេះមានអំណាចនិងគួរឲ្យភ័យខ្លាចបំផុតចំពោះទំនាក់ទំនងទាំងអស់នៅក្នុងរបបចាស់» ។ ហេតុដូចនេះ ការលុបបំបាត់ជីវិតគ្រួសារមានសារសំខាន់ចំពោះការរស់ឡើងវិញរបស់រដ្ឋ និងសំខាន់ក្នុងការប្រឆាំងតបនឹងការគំរាមកំហែងដល់គ្រួសារ ។ ខ្មែរក្រហមប្រឌិតឡើងនូវប្រព័ន្ធបែងចែកវណ្ណៈក្នុងគោលបំណងប្តូរទិសភក្តីភាពឲ្យទៅរកបដិវត្តន៍វិញ ។ អេលីហ្សាប៊ែត សរសេរថា ខ្មែរក្រហមមិនដែលហាមឃាត់ជាផ្លូវការទេ ប៉ុន្តែការដែលមានបញ្ជាចេញពីបក្សកុម្មុយនិស្តកម្ពុជាឲ្យមានការហូបរួមជាជាងហូបជាលក្ខណៈគ្រួសារ ឲ្យមានគ្រែដេកផ្សេងគ្នារវាងបុរសនិងស្ត្រី និងការបំបែកកុមារដែលមានអាយុលើសពី៦ឆ្នាំចេញពីឪពុកម្តាយ គឺត្រូវបានរៀបចំឡើងជាពិសេសដើម្បីបំបែកគ្រួសារ ។ ខ្មែរកុម្មុយនិស្តសង្ឃឹមថា បុគ្គលអាចគិតទំធ្វើការទាំងរីករាយក្រោមប្រព័ន្ធសង្គមនិយមដែលរំដោះអ្នកទាំងនោះ ឲ្យចាកផុតពីកាតព្វកិច្ចជីវិតជាកសិករ ដូចជាដើរទៅផ្សារ ថែទាំផ្ទះសម្បែងនិងចិញ្ចឹមកូន ។ ផ្ទុយមកវិញ ប្រជាជនកម្ពុជាយល់ឃើញថា «ការវាយប្រហាររបស់បដិវត្តន៍មកលើគ្រួសារ គឺមានលក្ខណៈធ្ងន់ធ្ងរមិនអាចអត់ទ្រាំបាន» ។

សៀវភៅ «ពេលសង្គ្រាមផុតរលត់ទៅ» ក៏បានផ្តល់នូវទិដ្ឋភាពកម្រមួយនៃទស្សនៈរបស់បក្សកុម្មុយនិស្តទៅលើស្ត្រីនៅក្នុងប្រទេសកម្ពុជា ។ នៅឆ្នាំ១៩៨០ អេលីហ្សាប៊ែត បានធ្វើសម្ភាសន៍ អៀង ធីរិទ្ធ ដែលជារដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជា«ស្ត្រីទីមួយ»របស់បដិវត្តន៍ ។ ធីរិទ្ធ អះអាងថា ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ កសិកររស់នៅស្រួល «កសិករត្រូវបានបដិវត្តន៍បម្រើត្រឹមត្រូវ» ។ ធីរិទ្ធ ពន្យល់ទៀតថា «កាលពីមុនស្ត្រីត្រូវចេញទៅធ្វើការ វិលត្រឡប់មកផ្ទះវិញដើររកត្រីអង្ករបានហើយចម្អិនធ្វើជាអាហារ មើលថែទាំកូនទៅ ជីវិតពិបាកណាស់ ។ ផ្ទុយទៅវិញ ការរស់នៅជាសហករណ៍ក្រោយពីត្រឡប់មកពីធ្វើការវិញស្ត្រីមានបាយហូបស្រាប់» ។ អេលីហ្សាប៊ែត បានផ្ទាញ់សម្តីរបស់ អៀង ធីរិទ្ធ ដោយលើកឡើងអំពីភាពគ្មានទំនាក់ទំនងរវាងរដ្ឋមន្ត្រីសង្គមកិច្ចរូបនេះទៅនឹងសភាពជាក់ស្តែងរបស់ប្រជាកសិករ ។ អេលីហ្សាប៊ែត បានកត់សម្គាល់ថា អ្វីដែល «យ៉ាប់» សម្រាប់ ធីរិទ្ធ គឺ «ការសប្បាយរីករាយនឹងជីវិតរបស់បុរសស្ត្រីចិញ្ចឹមកូនដោយខ្លួនឯង មើលខុសត្រូវក្នុងផ្ទះ រៀបចំចំណីអាហារ ដែលទាំងអស់នេះគឺពិតជាជីវិតប្រចាំថ្ងៃរបស់ខ្មែរពិតប្រាកដ» ។

អេប៊ីហារ៉ា, កល្យាន៊ី និង អេលីហ្សាប៊ែត សុទ្ធតែទាញហេតុផលប្រឆាំងនឹងការអះអាងតែមួយគត់របស់ ម៉ៃឃើល វីកឃ័រី ដែលថា កម្ពុជាប្រជាធិបតេយ្យចូលចិត្តថែរក្សាគ្រួសារដែលមានសមាជិកតិច ប្រសិនបើគ្មានហេតុផលផ្សេងទៀតទេ គឺជាជាងបង្កើនចំនួនប្រជាជននៅក្នុងប្រទេសដែលជាគោលដៅមួយក្នុងចំណោមគោលដៅដែលរបបកម្ពុជាប្រជាធិបតេយ្យបានលើកឡើង ។ នៅក្នុងសៀវភៅដែលមានចំណងជើងថា «កម្ពុជាៈ ១៩៧៥-១៩៨២» វីកឃ័រី សរសេរថា ការបំបែកប្តីប្រពន្ធ ឪពុកម្តាយនិងកូន គឺជាករណីខុសពីធម្មតានិងឥតគ្រោងទុកក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឬដោយសារការធ្វើឲ្យឯកោពីសំណាក់កម្មាភិបាលដែលមានចរិតឃោរឃៅនិងមានការបណ្តុះបណ្តាលទាប ។ ភស្តុតាងរបស់ វីកឃ័រី គឺផ្អែកលើ «បទពិសោធន៍ទាំងឡាយដែលលើកឡើងដោយសហគមន៍ជនភៀសខ្លួនទាំងមូល» តាមរយៈកិច្ចសម្ភាសន៍ដែលលោកបានធ្វើឡើងក្នុងជំរំជនភៀសខ្លួននៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក៏ដូចជាការសង្កេតខុសនិងមិនស័ក្តិសិទ្ធិរបស់លោកដែលថា គ្រួសារគ្មានទទួលផលប៉ះពាល់ទេនៅជំរំជនភៀសខ្លួន ពោលគឺក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមកទៀត ជនភៀសខ្លួនអាចរួមរស់ជាមួយអ្នកដែលជាទីស្រលាញ់របស់ខ្លួនវិញ ។ កិច្ចសម្ភាសន៍របស់ កល្យាន៊ី និងកិច្ចសម្ភាសន៍ផ្សេងៗទៀតដែលធ្វើឡើងសម្រាប់សរសេរនិក្ខេបបទនេះ ជំទាស់ទៅនឹងការរកឃើញរបស់ វីកឃ័រី ហើយឯកសារខ្មែរក្រហមនានានិងសម្តីរបស់អ្នកស្រាវជ្រាវខាងក្រោម ក៏មានលក្ខណៈផ្ទុយទៅនឹងការអះអាងរបស់ វីកឃ័រី ដែរ ។

ដូចដែលបានកត់សម្គាល់ខាងលើរួចមកហើយ ការសិក្សាស្រាវជ្រាវអំពីសារជាតិនិងរចនាសម្ព័ន្ធនៃបដិវត្តន៍កម្ពុជាមានលក្ខណៈទូលំទូលាយនិងមានតម្លៃខ្ពស់ ហើយគំនិតអ្នកសិក្សាស្រាវជ្រាវជាច្រើនត្រូវបានលើកឡើងមកបង្ហាញជូននៅទីនេះ ។ ក្រុមអ្នកស្រាវជ្រាវទីមួយ ហើយជាក្រុមដែលធំបំផុត បានចាត់ទុកមនោគមវិជ្ជាខ្មែរក្រហមក្នុងក្របខ័ណ្ឌប្រពៃណីកុម្មុយនិស្ត



ដោយបង្ហាញនូវឥទ្ធិពលលទ្ធិ ម៉ាក្សលេនីន, ម៉ៅ និង ស្តាលីន មកលើចរិតខ្មែរក្រហម ។ ក្រុមអ្នកស្រាវជ្រាវទីពីរបានច្រានចោលសម្មតិកម្មនេះ ហើយអះអាងថា មានមនោគមវិជ្ជាផ្សេង



អំពីក្រុមទីមួយដែលជំរុញឲ្យមានបដិវត្តន៍ខ្មែរក្រហម ។ ប៉ុន្តែទោះជាស្ថិតនៅក្នុងប្រភេទគំនិតទីពីរក៏ដោយ ក៏មានការខ្វែងគំនិតគ្នាទៅលើការសិក្សាស្រាវជ្រាវមូលហេតុដើមដែលនាំឲ្យមានបដិវត្តន៍នេះ ។ តាមរយៈការពិនិត្យរួមទៅលើប្រភេទគំនិតទាំងនេះដែលចាប់ផ្តើមពីប្រភេទគំនិតទីមួយ នឹងបង្ហាញជូននូវស្នាដៃនិពន្ធរបស់អ្នកសិក្សាក្នុងក្រុមទីមួយថាមាន លក្ខណៈគួរឲ្យជឿទុកចិត្តជាទីបំផុត ហើយថែមទាំងទាក់ទងនឹងប្រធានបទនេះទៀតផង ។

ឯកសារភាគច្រើនដែលយកមកសរសេរអំពីបដិវត្តន៍កម្ពុជា គឺផ្អែកទៅលើការសង្កេតរបស់ អ៊ិត សារិន ដែលជាឯកសារដើម និងមានតម្លៃមិនអាចកាត់ថ្លៃបាន ។ អ៊ិត សារិន គឺជាអតីតសមាជិកនៃចលនាកុម្មុយនិស្តខ្មែរដែលចុះចូលជាមួយសាធារណរដ្ឋខ្មែរនៅឆ្នាំ១៩៧៣ ក្រោយពីស្រង៉ាកចិត្តចំពោះខ្មែរក្រហម ។ សៀវភៅរបស់ អ៊ិត សារិន ដែលមានចំណងជើងថា "ស្រណោះព្រលឹងខ្មែរ" និងរបាយការណ៍របស់លោកដែលមានចំណងជើងថា "ប្រាំបួនខែនៅក្នុងព្រៃម៉ាគី" ត្រូវបាន ទីម៉ូធី ម៉ៃឃើលខានី មន្ត្រីបរិច្ចារកិច្ចបរទេសរបស់សហរដ្ឋអាមេរិកដកស្រង់ជាឯកសារសម្រាប់សរសេរសៀវភៅសិក្សាស្រាវជ្រាវទីមួយដែលនិយាយអំពីកុម្មុយនិស្តកម្ពុជា ។ ស្នាដៃនិពន្ធរបស់លោកនៅឆ្នាំ១៩៧៧ មានចំណងជើងថា "អំណាចរបស់បក្សកុម្មុយនិស្តកម្ពុជាៈ ឯកសារនិងការពិភាក្សា" ។ របាយការណ៍របស់ ទីម៉ូធី បង្ហាញថា ខ្មែរក្រហមមានការគាំទ្រពីជនបទតិចជាងអ្វីដែលធ្លាប់តែបានអះអាងពីមុនៗ ។ ខ្មែរក្រហមខ្វះកម្មាភិបាលដែលមានការបណ្តុះបណ្តាលត្រឹមត្រូវនិងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ លទ្ធផលគឺថា "បក្សបង្ខំឲ្យទទួលយកនូវតម្លៃថ្មីរបស់ខ្លួនប្រហែលដោយសារថា សូម្បីតែកម្មាភិបាលជាន់ខ្ពស់ក៏ខ្វះបទពិសោធន៍ក្នុងការជឿជាក់លើខ្លួនឯង ដែលជាមូលដ្ឋានគ្រឹះនៃគោលការណ៍អនុវត្តប្រកបដោយភាពឆាយបត់បែនបាននិងសំអាងលើហេតុការណ៍ជាក់ស្តែង" ។ បក្សទទួលបានការគាំទ្រដោយសារតែបានចុះជួយកិច្ចការប្រជាកសិករច្រើន ជាងការគាំទ្រពីកសិករតាមរយៈការប្រើមនោគមវិជ្ជាដែលខ្លួនរៀបចំឡើង ។ សារិន បង្ហាញថា សម្ព័ន្ធភាពរវាង សម្តេច សីហនុ និងបក្សកុម្មុយនិស្តកម្ពុជា (ក្រោមរូបភាពរណសិរ្សរួបរួមជាតិកម្ពុជា) គឺជាការបោក

បញ្ឆោត ពីព្រោះជនកុម្មុយនិស្តបានកម្ចាត់កម្មាភិបាលដែលគាំទ្រព្រះអង្គជាបន្តបន្ទាប់ ។ ផ្ទុយទៅវិញ ប្រជាកសិករភាគច្រើននៅតែរក្សាភក្តីភាពចំពោះ សម្តេច សីហនុ ហើយមានទំនាក់ទំនងតិចតួចជាមួយលទ្ធិកុម្មុយនិស្ត ។ មានន័យថា ប្រជាកសិករគ្រាន់តែចង់បានសន្តិភាព និងវិលមករួមរស់ជាមួយសង្គមជាតិតាមធម្មតាតែប៉ុណ្ណោះ ។

ខេណេត ឃ្វីន បានតាមដានការវិវឌ្ឍន៍របស់ចលនាកុម្មុយនិស្តខ្មែរ ដោយសរសេរនូវការសិក្សាស្រាវជ្រាវចំនួនពីរ ។ ស្នាដៃទីមួយបោះពុម្ពនៅឆ្នាំ១៩៧៦ ដែលផ្តោតសំខាន់ទៅលើសម័យកាលសង្គ្រាមស៊ីវិល និងស្នាដៃទីពីរគឺនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោក បោះផ្សាយនៅឆ្នាំ១៩៨២ ដែលពិនិត្យទៅលើប្រវត្តិរបស់ចលនានេះកាន់តែទូលំទូលាយថែមទៀត ។ ដូចជា ទីម៉ូធី ដែរ ខេណេត គឺជាមន្ត្រីបរិច្ចារកិច្ចបរទេសរបស់សហរដ្ឋអាមេរិកប្រចាំនៅប្រទេសវៀតណាមនៅអំឡុងសង្គ្រាម ហើយក៏ជាសមាជិកមួយរូបនៅក្នុងក្រុមប្រឹក្សាសន្តិសុខជាតិ ។ ក្រោយមក ខេណេត បានក្លាយជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា ។ នៅក្នុងនិក្ខេបបទរបស់ខ្លួន ខេណេត បានលើកឡើងថា បដិវត្តន៍ខ្មែរក្រហមគឺស្ថិតនៅក្នុងក្របខ័ណ្ឌកុម្មុយនិស្តសុទ្ធសាធ ។ លោកទាញហេតុផលថា ប៉ុល ពត ទទួលឥទ្ធិពលយ៉ាងជោកជាំពីលទ្ធិម៉ៅនិយម ទាំងគំនិតមហាលោតផ្លោះមហាអស្ចារ្យទាំងបដិវត្តន៍ វប្បធម៌ចិន ហើយបានបញ្ចូលភេរវកម្មតាមរបៀប ស្តាលីន មកក្នុងប្រទេសកម្ពុជា ។ ដោយយកគំរូពីចិននិងសូវៀត ប៉ុល ពត បានរិះរកមធ្យោបាយដើម្បីកែតម្រូវភាពទន់ខ្សោយដែលខ្លួនយល់ឃើញក្រោយពីទទួលបានលទ្ធផលបដិវត្តន៍តាមរយៈការប្រើប្រាស់នូវអំពើឃោរឃៅនិងភេរវកម្ម ដើម្បីឈានទៅសម្រេចបាននូវ«លទ្ធិកុម្មុយនិស្តបរិសុទ្ធមួយរយភាគរយ» ។ ខេណេត ក៏ជឿដែរថា ជនកុម្មុយនិស្តខ្មែរមិនបានទទួលការគាំទ្រទូលំទូលាយនិងយូរអង្វែងពីសំណាក់ប្រជាកសិករខ្មែរទេ ដោយធ្វើខ្លួនឲ្យលែងជិតស្និទ្ធនឹងប្រជាកសិករនៅតាមជនបទតាមរយៈកម្មវិធីភេរវកម្មដែលអនុវត្តដោយកម្មាភិបាលក្មេងៗមានវិន័យម៉ឺងម៉ាត់និងជ្រុលនិយមដែលជ្រើសរើសចេញមកពីក្មេងជំទង់ដែលត្រូវបំបែកចេញពីក្រុមគ្រួសារដើម្បីមកបំពាក់បំប៉ននិងហ្វឹកហ្វឺន ។

នៅខាងដើម ខេណេត សរសេរថា ភ្លាមៗបន្ទាប់ពីការទម្លាក់សម្តេច សីហនុ ចេញពីតំណែងនៅខែមីនាឆ្នាំ១៩៧០ ប្រជាកសិករបានគាំទ្រអ្នកបះបោរកុម្មុយនិស្តដោយសារឃើញជនកុម្មុយនិស្តទាំងនេះធ្វើល្អចំពោះខ្លួន ដែលនេះគឺជាផ្នែកមួយនៃការទាញយកអំណាចរបស់កងកម្លាំងរ៉ាឌីកាល់និយមជ្រុលពីរណសិរ្សរួបរួមជាតិកម្ពុជា ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនៅក្នុងយុទ្ធនាការឃោសនារបស់រណសិរ្សរួបរួមជាតិ គឺមេដឹកនាំមួយរូបដែលមានឋានៈខ្ពង់ខ្ពស់គឺ សម្តេច សីហនុ ។ ដោយមានប្រជាប្រិយភាពដ៏លើសលប់ក្នុងចំណោមប្រជាកសិករដែលសម្តេចជាមេដឹកនាំនយោបាយផងនិងមេដឹកនាំសាសនាផងនោះ ការផ្តួលរំលំ សម្តេច សីហនុ គឺជាកាតាលីករជំរុញឲ្យមានការកសាងលក្ខណៈជាតិនិយម ជំរុញឲ្យមានការស្តារឡើងវិញនូវរាជាធិបតេយ្យ នេះហើយដែលបង្កើតនិងធ្វើឲ្យការបះបោររបស់ប្រជាកសិករមានសន្ទុះឡើង ដែលប្រការនេះ ខេណេត បដិសេធថាវាមិនមែនជាមនោគមវិជ្ជាកុម្មុយនិស្តទេ ។ នៅពេលដែលក្រុមកុម្មុយនិស្ត ប៉ុល ពត ចាប់ផ្តើមគ្រប់គ្រងទៅលើរណសិរ្សរួបរួមជាតិនៅពាក់កណ្តាលឆ្នាំ១៩៧១មក ប្រជាកសិករចាប់ផ្តើមដកខ្លួនថយពីបដិវត្តន៍ ដែលជាការបង្កើតឲ្យមានការកេណ្ឌឲ្យធ្វើកងទ័ពដោយបង្ខំនិងអំពើភេរវកម្ម ។ ដោយទទួលការដុសខាត់ស្មារតីយ៉ាងជោកជាំ យុវជនវ័យក្មេងបានផ្តាច់ចិត្ត ប៉ុល ពត ដោយធ្វើតាមផែនការកុម្មុយនិស្តដ៏តឹងរ៉ឹងគួរឲ្យរន្ធត់ញាប់ញ័រ ។

ខេណេត បានលើកឡើងដោយត្រឹមត្រូវអំពីការបង្ខិតបង្ខំពីសំណាក់កងទ័ពកុម្មុយនិស្តដើម្បីធានាឲ្យមានការសហប្រតិបត្តិការជាមួយខ្លួន ។ ប៉ុន្តែ ខេណេត មិនបានលើកឡើងអំពីសកម្មភាពរបស់ខ្មាំង ដែលបានធ្វើឲ្យការជ្រើសរើសប្រជាកសិករចូលបម្រើរណសិរ្សរួបរួមជាតិកាន់តែមានលក្ខណៈងាយស្រួលនោះទេ ។ សកម្មភាពនោះគឺការទម្លាក់គ្រាប់បែកបំផ្លិចបំផ្លាញមកលើជនបទប្រទេសកម្ពុជាពីសំណាក់សហរដ្ឋអាមេរិក ដែលជួយជំរុញឲ្យចំនួនជនបដិវត្តន៍កើនឡើង ដែលមានចរិតជាជនកុម្មុយនិស្ត ឬជនដែលមិនមែនសល់ពីការបំផ្លិចបំផ្លាញនេះ ។

និក្ខេបបទថ្នាក់បណ្ឌិតរបស់ ខេត ហ្វ្រីសុន ដែលសិក្សាអំពីនយោបាយ មានចំណងជើងថា «ឥទ្ធិពលរបស់បដិវត្តន៍មកលើប្រជាកសិករកម្ពុជាៈ ១៩៧០-១៩៧៥» និយាយជ្រៅ

ជាងអ្វីដែល ខេណេត ឃ្វីន បានលើកឡើង ដោយសង្កត់ធ្ងន់ទៅលើកត្តាៈនូវការគាំទ្រប្តូរផ្តាច់របស់ប្រជាកសិករមកលើបដិវត្តន៍របស់ប៉ុល ពត ។ ខេត ហ្វ្រីសុន ទាញសេចក្តីសន្និដ្ឋានថា «ប្រជាកសិករខ្មែរភាគច្រើនលើសលប់មិនយល់អំពីន័យបដិវត្តន៍សង្គមនិយម និងមិនរៀបចំខ្លួនសម្រាប់ប្រយុទ្ធដើម្បីឈានទៅដល់គោលដៅនោះឡើយ» ។ ហ្វ្រីសុន ទាញហេតុផលថា ដោយសារភាពតឹងតែងនៃសង្គ្រាម និងដើម្បីរស់ ប្រជាកសិករត្រូវតែគាំទ្រខ្មែរក្រហម ។ ហ្វ្រីសុន សង្កត់ធ្ងន់ថា ភាពក្រីក្ររបស់ប្រជាកសិករមិនមានសភាពធ្ងន់ធ្ងររហូតដល់បង្កឲ្យមានសកម្មភាពបដិវត្តន៍នោះទេ ។ ជាលទ្ធផល កម្មវិធីរបស់ខ្មែរក្រហមបានអំពាវនាវដល់ក្រុមប្រជាកសិករមួយចំនួនតូចតែប៉ុណ្ណោះ ។ ឆ្លងតាមបទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅអាមេរិកខាងជើង និងអូស្ត្រាលី ព្រមទាំងកិច្ចសម្ភាសន៍ផ្សេងៗទៀតដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ហ្វ្រីសុន យល់ឃើញថា ភាគច្រើននៃប្រជាកសិករខ្មែរ «មានមូលដ្ឋានសង្គមឬសេដ្ឋកិច្ចតិចតួចណាស់» ក្នុងការគាំទ្របដិវត្តន៍ ។ ចំណង់របស់ប្រជាកសិករក្នុងការចូលបម្រើបដិវត្តន៍តាមតែអ្នកស្រីគិត គឺមានលក្ខណៈបុរាណជាជាងមានលក្ខណៈជាបដិវត្តន៍ ពោលគឺភាគច្រើនចូលបម្រើរណសិរ្សដូចដែល ខេណេត ឃ្វីន បានលើកឡើងពីខាងដើម ដើម្បីឲ្យបានរបបសង្គមរាស្ត្រនិយមរបស់ សម្តេច សីហនុ មកវិញ មិនមែនដើម្បីបង្កើតរបបថ្មីមួយទៀតនោះទេ ។ ដោយបូកផ្សំគ្នាជាមួយនឹងបរិយាកាសមិនបដិវត្តន៍នៅតាមជនបទបែបនេះគឺជាការហ៊ឺកហ៊ឺននយោបាយមិនមានប្រសិទ្ធភាពរបស់ខ្មែរក្រហម ពោលគឺជនកុម្មុយនិស្តខ្វះកម្មាភិបាលដែលមានការបណ្តុះបណ្តាលត្រឹមត្រូវដើម្បីបំពាក់បំប៉នដល់ប្រជាកសិករ និងធ្វើឲ្យប្រជាកសិករជឿជាក់ដល់ភាពចាំបាច់របស់បដិវត្តន៍ ។ ដូចនេះការបង្ខិតបង្ខំក្លាយជាវិធីសាស្ត្រចម្បងសម្រាប់ជ្រើសរើសនិងការប្រព្រឹត្តិតាម ។ នយោបាយរបស់ខ្មែរក្រហមដែលបង្ខំទៅលើប្រជាកសិករភាគច្រើនមិនមានប្រជាប្រិយភាពឡើយ ដូចដែល ហ្វ្រីសុន បានទាញសេចក្តីសន្និដ្ឋានថា «នយោបាយទាំងនោះបង្កការលំបាក និងមានភាពឃោរឃៅចំពោះប្រជាជន» ។

ក្រេក អិចឆេសាន់ ក៏ដូចជា ខេត ហ្វ្រីសុន ដែលជាអ្នកវិទ្យាសាស្ត្រនយោបាយ បានលើកឡើងជាសំខាន់អំពីបែបបទចិត្តសាស្ត្ររបស់ប្រជាកសិករដែលជួយពន្យល់អំពីជោគជ័យនិងបរាជ័យរបស់ខ្មែរកុម្មុយនិស្ត ។ នៅក្នុងសៀវភៅដែលមានចំណងជើងថា «ការកើតនិងស្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យ» ដែលជាការផ្តុំចូលគ្នារាល់ស្នាដៃនិពន្ធអំពីបដិវត្តន៍កម្ពុជា អិចឆេសាន់ បានទាញសេចក្តីសន្និដ្ឋានដ៏លេចធ្លោនិងមានតម្លៃមួយចំនួន ។ ដូចជាអ្នកសិក្សាស្រាវជ្រាវដទៃទៀតដែរ អិចឆេសាន់ បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការគាំទ្ររបស់ប្រជាកសិករចំពោះវត្តមានរបស់សម្តេច សីហនុ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ប៉ុន្តែលោកក៏បានសង្កត់ធ្ងន់នូវសញ្ញាណមួយទៀតនៅក្នុងវង្វង់ស្មារតីជារួមរបស់ប្រជាកសិករដែលខ្មែរក្រហម បានប្រឹងតទំនាក់ទំនងមួយពោលគឺ អ្នកកាន់អំណាចសាសនា ឬបព្វជិតនិយមភាគច្រើនជាព្រះសង្ឃ ។ ក្រោយពីបង្កើតបាននូវចំណងដ៏មានសារសំខាន់ជាមួយនឹងស្ថាប័នរាជាធិបតេយ្យនិងបព្វជិតនិយម ខ្មែរក្រហមក៏ដណ្តើមអំណាចពីស្ថាប័នទាំងនេះ ។ អិចឆេសាន់ ក៏បានកត់សម្គាល់អំពីការពឹងផ្អែករបស់ជនកុម្មុយនិស្តមកលើកម្មាភិបាលវ័យក្មេងឲ្យដឹកនាំបដិវត្តន៍របស់ខ្លួន ដោយទាញយកប្រយោជន៍ពី «ប្រព័ន្ធសមាហរណកម្មលើជំនឿដែលមានលក្ខណៈបន្ទាប់បន្សំ» តាមរយៈ «រៀបចំឡើងនូវកម្មវិធីបំពាក់បំប៉ននិងជ្រើសរើសដោយបង្ខំ» ។ ស្តែងចេញពីកម្មវិធីនេះបង្កើតបានជា «កងឈ្លបកុមារដែលមានចិត្តដាច់ខាតចំពោះអង្គការ» ។ អិចឆេសាន់ បានលើកឡើងថា ប្រជាកសិករភាគច្រើនមិនបានបញ្ចូលមនោគមវិជ្ជាកុម្មុយនិស្តដោយការរៀនសូត្រទេ ពោលគឺជាដំណើរការដែល «បុព្វហេតុបដិវត្តន៍មានលក្ខណៈចំៗមិនលម្អៀងជាមួយប្រព័ន្ធដែលឲ្យតម្លៃទៅលើខ្លួនឯង» ហើយជនបដិវត្តន៍នោះ «ជឿទៅលើភាពត្រឹមត្រូវនៃបុព្វហេតុរបស់ខ្លួន ។ អិចឆេសាន់ សរសេរថា «កម្មាភិបាលដែលមានចិត្តដាច់ខាត» បែបនេះ «នៅតែជាប្រភពដ៏មានតម្លៃពេញអំឡុងពេលនៃការតស៊ូអាវុធ» ។ ក៏ដូចជា ហ្វ្រីសុន ដែរ អិចឆេសាន់ បានកត់សម្គាល់ទៅលើចរិតលក្ខណៈបុរាណនិងប្រឆាំងបដិវត្តន៍របស់ប្រជាកសិករកម្ពុជានិងការយល់ដឹងតិចតួចនិងការប្តេជ្ញាចិត្តដ៏ស្តួចស្តើងចំពោះមនោគមវិជ្ជារបស់ខ្មែរក្រហម ។

អិចឆេសាន់ ក៏បានអត្ថាធិប្បាយអំពីដើមកំណើតនៃការប្រកាន់ខ្ជាប់របស់ខ្មែរក្រហមទៅនឹងនយោបាយខ្លួនទុកខ្លួនដែលជាកត្តាដ៏សំខាន់សម្រាប់ឲ្យមានការពិភាក្សាទាក់ទងនឹងការ

មិនយកចិត្តទុកដាក់របស់ខ្មែរក្រហមចំពោះពិសោធន៍បដិវត្តន៍និងបទពិសោធន៍នយោបាយរបស់ប្រជាជាតិជិតខាងដែលកាន់លទ្ធិកុម្មុយនិស្ត ។ អិចឆេសាន់ សរសេរថា ការមិនទុកចិត្តរបស់ខ្មែរក្រហមទៅលើជំនួយនិងយោបល់របស់ពួកបរទេស បណ្តាលមកពីកង្វះនូវការគាំទ្រដែលខ្លួនធ្លាប់ឆ្លងកាត់ពីបងប្អូនកុម្មុយនិស្តចិន និងវៀតណាមនៅអំឡុងឆ្នាំបង្កើតបក្សកុម្មុយនិស្តកម្ពុជា នៅពេលនោះប្រទេសកុម្មុយនិស្តជិតខាងទាំងពីរបានគាំទ្រសម្តេច សីហនុ និងនយោបាយអព្យាក្រឹតរបស់ព្រះអង្គនៅក្នុងសង្គ្រាមវៀតណាម ។ ប្រការនេះគឺជាមេរៀនប្រាប់ខ្មែរក្រហមថា «វណ្ណៈអធនអន្តរជាតិនិយមគឺជាការបោកបញ្ឆោត» ហើយថា «ខ្លួនត្រូវតែប្រុងប្រយ័ត្នចំពោះការសន្យាទុកមុនរបស់ភាគីបរទេសដែលអះអាងថាជាបងប្អូននឹងខ្លួន ។ គ្មានអ្នកណាគួរឲ្យជឿទុកចិត្តបានឡើយ ។ គ្មានទាល់តែសោះ» ។

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជនជាតិហុល្លង់ឈ្មោះ រ៉ូល ប៊ីកល័រ បាននិពន្ធសៀវភៅមួយក្បាលមានចំណងជើងថា «ភ្នែកម្ចាស់» ។ សៀវភៅនេះគឺជាការវិភាគប្រកបដោយន័យស្ថាបនាចំពោះកម្ពុជាប្រជាធិបតេយ្យ មានប្រយោជន៍ចំពោះការប្រមូលផ្តុំស្នាដៃនិពន្ធពីមុនៗសម្រាប់គំនិតប្រៀបធៀបចង់ពិនិត្យទៅលើបដិវត្តន៍ខ្មែរក្រហម ការសង្កត់ធ្ងន់ទៅលើមនោគមវិជ្ជា និងការគិតគាលពីដំបូងអំពីខ្មែរក្រហម ព្រមទាំងការពិនិត្យពិច័យទៅលើទំនាក់ទំនងរវាងមេដឹកនាំខ្មែរក្រហម កម្មាភិបាលបក្ស និងមហាជនកម្ពុជា ។ ដោយលើកឡើងនូវអ្វីដែល ហ្វ្រឺសុន, ទីម៉ូធី និង ខេណេត ឃ្វីន បានសរសេរ អ្នកស្រាវជ្រាវឈ្មោះ ប៊ីកល័រ មានការសង្ស័យទៅលើភក្តីភាពប្រកបដោយប្រាជ្ញារបស់ប្រជាកសិករភាគច្រើនចំពោះបដិវត្តន៍កុម្មុយនិស្តខ្មែរក្រហម ហើយបានលើកឡើងនូវកង្វះខាតកម្មាភិបាលដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានលទ្ធភាពអាចបំពាក់បំប៉នដល់ប្រជាកសិករដែលមានលក្ខណៈបុរាណ ។

ប៊ីកល័រ សរសេរថា ខ្មែរក្រហមគិតមមៃតែអំពីការថែរក្សារដ្ឋមួយដែលឯករាជ្យម្ចាស់ការលើខ្លួនឯង ប៉ុន្តែបានប្រកាសខុសថា ខ្លួនទទួលបានជោគជ័យនៅក្នុងសង្គ្រាមស៊ីវិលរបស់ខ្លួនដែលគ្មានអ្នកណាជួយ និងមានតែមួយគត់នៅក្នុងប្រវត្តិសាស្ត្រ ។ សៀវភៅ «ភ្នែកម្ចាស់» បាននិយាយអំពីអ្វីៗដែលមានពីមុនគួរឲ្យចង់ដឹងនិងកម្រមាន ដែលនាំឲ្យមានសកម្មភាពនិងចរិតលក្ខណៈរបស់ខ្មែរក្រហម ហើយដែលប្រការទាំងនេះប្រហែលជាមានឥទ្ធិពលទៅលើថ្នាក់ដឹកនាំនៃចលនានេះ ។ ក៏ដូចជា ខេណេត ឃ្វីន ដែរ ប៊ីកល័រ បានលើកឡើងនូវបែបផែនស្តាលីននិងម៉ៅនិយមរបស់ខ្មែរក្រហម ដោយបន្ថែមនូវជាតិនិយមជ្រុលរបស់ជនជាតិកម្ពុជាទៅលើធាតុមនោគមវិជ្ជាស្តាលីននិងម៉ៅ ។ ប៊ីកល័រ ក៏បានមើលទៅលើឥទ្ធិពលរបស់ពួករ៉ាឌីកាល់មកពីអឺរ៉ុប ។ ប៊ីកល័រ បានសរសេរថា អនាគតមេដឹកនាំខ្មែរក្រហមមួយចំនួន (រួមទាំងប៉ុលពតផង) បានក្លាយទៅជាសមាជិកបក្សកុម្មុយនិស្តបារាំងដែលធ្វើឲ្យមេដឹកនាំទាំងនោះស្រូបយកនូវសម្ព័ន្ធមិត្តដែលមានភក្តីភាពនិងធាតុប្រតិកិរិយាបំផុតចំពោះលទ្ធិស្តាលីនរបស់ទីក្រុងមូស្គូ ។ ទន្ទឹមពេលនេះដែរ ភាពលម្អៀងរបស់ជនកុម្មុយនិស្តជាតិនិយមខ្មែរក្រហមអាចត្រូវបានជំរុញដោយដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ឆ្នាំ ១៩៥០ នៅប្រទេសយូហ្គោស្លាវីដែលជាប្រទេសកុម្មុយនិស្តស្ថិតក្រោមការដឹកនាំរបស់លោក ទីតូ ។ ប្រការនេះធ្វើឲ្យជនកុម្មុយនិស្តលែងអនុវត្តដោយងងឹតងងល់តាមបញ្ជារបស់សូវៀត ។ ប៊ីកល័រ ក៏បានសង្កត់ធ្ងន់ទៅលើឥទ្ធិពលជាក់ស្តែង ប៉ុន្តែគេតែងតែមើលរំលងទៅលើមេដឹកនាំខ្មែរក្រហមៈ គឺបដិវត្តន៍បារាំង ជាពិសេសគំនិតរ៉ាឌីកាល់របស់ ក្រាឈូស បាប៊ីវ ដែល ប៊ីកល័រ ហៅថាមានលក្ខណៈដូចគ្នា «មែនទែន» ទៅនឹងការអនុវត្តន៍ជាក់ស្តែងរបស់ខ្មែរក្រហម ។ ភាពដូចគ្នាទាំងនេះរួមមានដូចជាៈ ការបណ្តុះឧត្តមគតិប្រជាកសិករ ការប្រឆាំងនឹងទីក្រុងនិយម ការហូបបាយរួម ការមិនពាក់ព័ន្ធរបស់ឪពុកម្តាយជាមួយនឹងការរៀនសូត្ររបស់កូន ការបំបែកស្ត្រីនិងបុរស និងការធ្វើឲ្យជាតិមានលក្ខណៈដាច់ដោយឡែកពីអន្តរជាតិ ។ ប៊ីកល័រ ក៏បានបញ្ជាក់ដែរថា អនាគតមេដឹកនាំខ្មែរក្រហមពេលនោះ អាចត្រូវដាក់ឲ្យពិភាក្សាជាមួយបញ្ញវន្តបារាំងស្តីអំពីការប្រើអំពើឃោរឃៅនៅក្នុងការធ្វើបដិវត្តន៍នៅប្រទេសអាល់ហ្សេរី ។ បន្ទាប់មក ប៊ីកល័រ ស៊ង់មើលថា មេដឹកនាំខ្មែរក្រហមទាំងនោះអាចស្រូបយកនូវគំនិតរបស់ ហ្វ្រង់ ហ្វាណុង ទាក់ទងនឹងចរិតលក្ខណៈបដិវត្តរបស់ប្រជាកសិករនិងសក្តានុពលភាពជាវិជ្ជមាននៃអំពើឃោរឃៅ ។

រួចហើយ ប៊ីកល័រ ប្រៀបធៀបបដិវត្តន៍កុម្មុយនិស្តកម្ពុជាទៅនឹងបដិវត្តន៍របស់ចិននិងវៀតណាម ។ ប៊ីកល័រ សង្កត់ធ្ងន់ជា

ពិសេសទៅលើភាពខុសគ្នារវាងកម្រិតនៃការប្រើអំពើភេរវកម្មពីសំណាក់ចលនាទាំងពីរនេះ និងអំពើឃោរឃៅជាទ្រង់ទ្រាយធំបង្កើតឡើងដោយខ្មែរក្រហម ។ ប៊ីកល័រ បានសរសេរថា ជនកុម្មុយនិស្តចិននិងវៀតណាមមានការរៀបចំយ៉ាងត្រឹមត្រូវនិងទទួលបាននូវការគាំទ្រយ៉ាងទូលំទូលាយពីសំណាក់ប្រជាកសិករ ។ ខ្មែរក្រហមក៏មានពេលជាច្រើនឆ្នាំក្នុងការសំលៀងជំនាញដឹកនាំរបស់ខ្លួននៅក្នុងសង្គ្រាមអូសបន្លាយដ៏យូរ ហើយបានសង្កត់ធ្ងន់ទៅលើការតស៊ូខាងនយោបាយខ្លាំងជាងការតស៊ូដោយអាវុធ ។ នៅក្នុងដំណើរការនេះ មេដឹកនាំខ្មែរក្រហមទទួលបាននូវជំនឿមកលើជាតិនិយមដ៏សន្ធឹកសន្ធាប់ ។ ផ្ទុយទៅវិញ ខ្មែរក្រហមយល់ឃើញថា ខ្លួនឈានមកគ្រប់គ្រងប្រទេសកម្ពុជាដោយជោគជ័យយ៉ាងឆាប់រហ័ស ប៉ុន្តែក្នុងលក្ខណៈឃោរឃៅក្រោយពីសង្គ្រាមស៊ីវិលរយៈពេលប្រាំឆ្នាំ ។ ខ្មែរក្រហមបានប្រើប្រាស់លទ្ធិរបស់ខ្លួន ប៉ុន្តែមានតែកម្មាភិបាលដែលមានការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ប៉ុណ្ណោះដែលមកដឹកនាំបដិវត្តន៍ ។ ជាលទ្ធផលឃើញថាមានការប្រើកម្លាំងបាយជាជាងការអនុវត្តន៍តាមនយោបាយមកលើមហាជន ដែលមកដល់ចំណុចនេះ ប៊ីកល័រ សរសេរថា «អំពើភេរវកម្មហាក់ដូចជាកើតឡើងនិងបញ្ចប់ដោយខ្លួនឯង» ។

នៅក្នុងស្នាដៃនិពន្ធរបស់លោកមានចំណងជើងថា «សោកនាដកម្មនៃប្រវត្តិសាស្ត្រខ្មែរៈ នយោបាយ សង្គ្រាមនិងបដិវត្តន៍តាំងពីឆ្នាំ១៩៤៥» ប្រវត្តិវិទូ ដេវីដ ឆេនដ័ល័រ បានបង្ហាញថាបដិវត្តន៍កម្ពុជាគឺជាឧទាហរណ៍មួយបញ្ជាក់អំពីការអនុវត្តន៍ខុសពីគំរូនិងទ្រឹស្តីបដិវត្តន៍នៅក្រៅប្រទេស ។ ឆេនដ័ល័រ យល់ឃើញថា ខ្មែរក្រហមបានប្រើប្រាស់លទ្ធិម៉ាក្សលេនីនជា «ឧបករណ៍គំរិលនិងជាអាវុធមហាប្រល័យ» ហើយបានប្រើប្រាស់មេរៀនពីបរទេស ។ គំរូគ្រប់យ៉ាងបានមកពីបដិវត្តន៍បារាំងនិងសូវៀតគួបផ្សំជាមួយបដិវត្តន៍វប្បធម៌ចិន និងភាពឯករាជ្យម្ចាស់ការរបស់កូរ៉េខាងជើងជាមួយនឹង «ការធ្វើត្រង់ៗតាមបញ្ជា»និង «ល្បឿនដែលធ្វើឲ្យឧបករណ៍និងអាវុធទាំងនេះមានលក្ខណៈមហាប្រល័យ» ។ កន្ទុះនូវបុព្វលក្ខខណ្ឌបដិវត្តន៍នៅកម្ពុជា ដូចជាប្រជាកសិករដែលមានលក្ខណៈអធននិងដាច់ខាត មិនបានធ្វើឲ្យមេដឹកនាំប្រទេសញញើតញញើមឡើយ ពីព្រោះមេដឹកនាំទាំងនោះជឿថា កន្ទុះខាតទាំងនេះអាចជម្នះបានតាមរយៈការខិតខំប្រឹងប្រែង ។ បក្សកុម្មុយនិស្តកម្ពុជាគ្មានលទ្ធភាពក្នុងការដោះស្រាយទំនាស់រវាង «លក្ខណៈប្លែក» ដែលយល់ឃើញដោយខ្លួនឯងនៃបដិវត្តន៍និងទិសដៅសង្គមនិយមរបស់ខ្លួន ពីព្រោះបំណងឈានទៅសម្រេចទិសដៅសង្គមនិយមបង្ហាញឲ្យឃើញថាបដិវត្តន៍កម្ពុជា គឺជាប្រពៃណីសង្គមនិយមអន្តរជាតិ ហើយឆ្លើយតបនឹងច្បាប់រឹងមួយចំនួននៃប្រវត្តិសាស្ត្រ ។ ចុងបញ្ចប់ ឆេនដ័ល័រ ទាញសេចក្តីសន្និដ្ឋានថា «បដិវត្តន៍កម្ពុជាបានឈានដល់ទីបញ្ចប់ដោយសារមានគំនិតជាច្រើនជំទាស់នឹងបដិវត្តន៍ក្នុងជួរដឹកនាំរបស់ខ្លួន និងអាកប្បកិរិយាប្រឆាំងនឹងបដិវត្តន៍ច្រើនពេក ។ និយាយឲ្យស្រួលស្តាប់ បដិវត្តន៍ខ្វះនូវការគាំទ្រ» ។

នៅក្នុងស្នាដៃនិពន្ធរបស់ អេលីហ្សាប៊ែត មានចំណងជើងថា «ក្រោយសង្គ្រាមផុតរលត់ទៅ» អ្នកស្រីក៏បានលើកឡើងថាបដិវត្តន៍ខ្មែរក្រហមស្ថិតនៅក្នុងក្របខណ្ឌកុម្មុយនិស្តហើយបញ្ជាក់អំពីគោលការណ៍ «មហាលោតផ្លោះមហាអស្ចារ្យ» សមូហភាវូបនីយកម្មតាមបែបស្តាលីននិងអំណាចផ្តាច់ការរបស់កូរ៉េខាងជើង គឺកម្ពុជាប្រជាធិបតេយ្យបានចម្លងយកមកធ្វើជាគំរូដើម្បីអនុវត្តតាម ។ អ្នកស្រីក៏បានគូសបញ្ជាក់អំពីការអះអាងរបស់ខ្មែរក្រហមថា បដិវត្តន៍របស់ខ្លួនមានភាពផ្ទុយគ្នាពីគំរូនិងគំនិតរបស់បរទេស ។ ក៏ប៉ុន្តែការនិយាយរបស់អ្នកស្រីទៅលើការគាំទ្រពីសំណាក់ប្រជាកសិករចំពោះបដិវត្តន៍ ថាមិនបានធ្វើឡើងដោយលក្ខណៈបន្ទំទេ ។ ការអះអាងរបស់ អេលីហ្សាប៊ែត ដែលថាសេចក្តីមិនទុកចិត្តតាំងពី «យូរណាស់មកហើយ» ទៅលើទីក្រុង ទៅលើអ្នកប្រមូលពន្ធអាករនិងបញ្ញវន្ត មានលក្ខណៈស្ទើរតែដូចគ្នាទៅនឹងលទ្ធិប្រឆាំងនឹងចក្រពត្តិនិយមរបស់ខ្មែរក្រហមនោះគឺមានន័យទូលំទូលាយនិងមិនមានគុណសម្បត្តិគ្រប់គ្រាន់ទេ ។ អ្នកស្រីមិនបានបែងចែកឲ្យច្បាស់ដូចដែល ហ្វ្រើសុន និង អិចឆេសាន់ បានលើកឡើងរវាងប្រជាកសិករក្រីក្រដែលពេញចិត្តនឹងការឃោសនារបស់ខ្មែរក្រហម និងប្រជាកសិករភាគច្រើនដែលមិនទទួលយកនូវលទ្ធិសង្គមនិយមផងទេ ។ ធ្វើយ៉ាងនេះអាចជួយពង្រឹងទស្សនៈរបស់អ្នកស្រីឲ្យកាន់តែសុក្រឹតថែមទៀត ដែលថាខ្មែរក្រហមមិនដែលទទួលបានមូលដ្ឋានអំណាចគ្រប់គ្រាន់ឡើយ ដោយខ្វះនូវការគាំទ្រនិងការយល់ដឹងរបស់ប្រជាជនទូទៅដែលប្រការនេះបានបង្ខំចិត្តឲ្យខ្មែរក្រហមគ្រប់គ្រងអំណាចតាម

រយៈអំពើឃោរឃៅនិងភេរវកម្មនោះ ។

ប្រភេទទីពីរនៃកូនសៀវភៅនានាដែលនិយាយអំពីសារជាតិនៃបដិវត្តន៍កម្ពុជា បានច្រានចោលនូវពាក្យសំអាងនានាខាងដើមដែលនាំឲ្យមានព្រឹត្តិការណ៍នេះ ហើយមានតែស្នាដៃពីរប៉ុណ្ណោះដែលទាក់ទងនឹងការសិក្សានេះ ។ សៀវភៅទាំងពីរនេះផ្តល់នូវការយល់ដឹងយ៉ាងសំខាន់ទៅលើកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែទាញសេចក្តីសន្និដ្ឋានខុសគ្នាទៅលើមូលហេតុដើមនៃបដិវត្តន៍ខ្មែរក្រហម ។ ការវិភាគរបស់ វីកឃ័រី អំពីបដិវត្តន៍ខ្មែរក្រហមនៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា «កម្ពុជាៈ ១៩៧៥-១៩៨២» លើកឡើងជាច្រើនចំណុចប្រទាំងប្រទើសទៅនឹងគំនិតសន្មតកាលពីពេលនោះទាក់ទងនឹងសោកនាដកម្មរបស់កម្ពុជា ។ ប្រវត្តិវិទូរូបនេះអះអាងថា បដិវត្តន៍ខ្មែរក្រហម «ដំបូងបង្អស់គឺជាបដិវត្តន៍ប្រជាកសិករប្រកបដោយជោគជ័យ» ដែល «មានការគាំទ្រជាលើកទីមួយនិងយ៉ាងសន្ធឹកសន្ធាប់» ។ ដោយសារការពឹងផ្អែកទៅលើប្រជាកសិករ ជាពិសេសប្រជាកសិករដែលមានជីវភាពក្រីក្របំផុត វីកឃ័រី អះអាងថា កម្ពុជាប្រជាធិបតេយ្យមិនមែនជារដ្ឋកុម្មុយនិស្តពិតៗទេ (ទោះបីជាខ្មែរក្រហមមិនបានបញ្ជាក់ចំណុចនេះដោយខ្លួនឯងក៏ដោយ) ផ្ទុយមកវិញ ខ្មែរក្រហមគឺជា «ករណីមួយដែលជាតិនិយម ប្រជានិយម និងប្រជាកសិករនិយម សម្រេចបាននូវលទ្ធិកុម្មុយនិស្ត» ។ តាមពិតលោកសរសេរថា ខ្មែរក្រហមបង្កើតការសម្រិតសម្រាំងសតិអារម្មណ៍ដែលមានលក្ខណៈបំផ្លិចបំផ្លាញនិងមហាប្រល័យ ។ វីកឃ័រី ចាត់ទុកថា បរាជ័យធ្ងន់ខាងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ គឺដោយសារខ្មែរក្រហមជំទាស់មិនទទួលយក «លទ្ធិកុម្មុយនិស្តតាមបែបម៉ាក្សនិយម» ។ វីកឃ័រី មិនបានទម្លាក់កំហុសទៅលើមេដឹកនាំខ្មែរក្រហមដែល«បណ្តោយខ្លួន»ទៅតាមប្រជា-កសិករដែលដាច់ខាតនឹងបដិវត្តន៍ ហើយដែល«មិនបានប្រមើលដល់ផែនការអំពីការអភិវឌ្ឍន៍ប្រកបដោយអត្ថន័យសម្រាប់ឆ្នាំ ១៩៧៦-១៩៧៩ ។ ទស្សនៈរបស់ វីកឃ៏រី មិនផ្អែកលើឯកសារភ័ស្តុតាងដែលភ្ជាប់មេដឹកនាំខ្មែរក្រហមរួមទាំង ប៉ុល ពត ផង ទៅនឹង«ការអភិវឌ្ឍន៍គ្មានខ្លឹមសារ» ដែល វីកឃ៏រី បញ្ចេញមិនអស់សេចក្តី ។ មាគ៌ាម៉ាក្សស៊ីសនិយមរបស់ខ្មែរក្រហមត្រូវបានទទួលស្គាល់ដោយបក្សកុម្មុយនិស្តកម្ពុជា ហើយឯកសារនិយាយអំពីសមូហភាវូបនីយកម្មនិងការប្រព្រឹត្តិអំពើឃោរឃៅហួសកម្រិតនោះ សុទ្ធតែមានឫសគល់ចេញពីលទ្ធិកុម្មុយនិស្ត ។ វីកឃ័រី បានទទួលស្គាល់ឥទ្ធិពលប្រវត្តិសាស្ត្រថ្មីៗរបស់ចិនមកលើមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ប៉ុន្តែថាឥទ្ធិពលនោះមានតែត្រឹមគោលការណ៍ «មហាលោតផ្លោះមហាអស្ចារ្យតែប៉ុណ្ណោះ» ។ លោកបានបដិសេធថា ខ្មែរក្រហមមិនយកគំរូតាមបដិវត្តន៍វប្បធម៌ចិនឡើយ ដោយលើកឡើងនូវការផ្តោតសំខាន់ទៅលើប្រជាជនទីក្រុងនិងបញ្ញវន្ត ។ ប៉ុន្តែការលើកឡើងបែបនេះគឺភ្លេចគិតទៅលើភាពដាច់ខាតរបស់ចលនាបញ្ញវន្ត និងការប្រើប្រាស់ដ៏គំហុកនូវយុវជនវ័យក្មេងដែលទទួលការបំពាក់បំប៉នមនោគមវិជ្ជា ដែលនេះក៏ជាលក្ខណៈពិសេសរបស់បដិវត្តន៍កម្ពុជាដែរ ។

និយាយរួម ស្នាដៃនិពន្ធរបស់ វីកឃ័រី នៅតែមានសារសំខាន់ ទោះជាមានលក្ខណៈខ្វះចន្លោះយ៉ាងធ្ងន់ទៅលើការសរសេរប្រវត្តិសាស្ត្រនាសម័យនោះក៏ដោយ ។ អ្វីដែលមានសារសំខាន់ជាពិសេសនោះគឺជាការទាញហេតុផលថា ស្ថានភាពជាក់ស្តែងមានភាពខុសប្លែកពីគ្នានៅទូទាំងប្រទេសកម្ពុជាក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ហើយថា ការវាយតម្លៃរួមហួសហេតុអំពីស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាពីសំណាក់អ្នកសិក្សាស្រាវជ្រាវពីមុនៗ បាននាំឲ្យមានការយល់ឃើញមិនត្រឹមត្រូវអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែទ្រឹស្តីរបស់ វីកឃ័រី អំពីសារជាតិបដិវត្តន៍កម្ពុជារួមទាំងទ្រឹស្តីទាំងឡាយដែលទាក់ទងនឹងគ្រួសារខ្មែរដែលបានលើកមកពិភាក្សាខាងដើមត្រូវអស់ន័យខ្លឹមសារនៅចំពោះមុខភ័ស្តុតាងដែលមានស្រាប់និងការរិះគន់ពីអ្នកនិពន្ធផ្សេងៗទៀត ។

នៅក្នុងស្នាដៃនិពន្ធរបស់ប្រវត្តិវិទូ ប៉ែន ឃៀរនិន ដែលមានចំណងជើងថា «របប ប៉ុល ពតៈ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមរបបខ្មែរក្រហម ១៩៧៥-១៩៧៩» ប្រវត្តិវិទូរូបនេះបានចាត់ទុកទស្សនៈរបស់ ហ្វ្រីសុន ទាក់ទងនឹងការគាំទ្របន្តិចបន្តួចរបស់ប្រជាកសិករចំពោះខ្មែរក្រហម ថាមានលក្ខណៈ «ជ្រុលពេក» ហើយបានច្រានចោលនូវការអះអាងរបស់ វីកឃ័រី អំពីបដិវត្តន៍ចេញពីប្រជាកសិករថាជារឿងកុហក ។ ដូចដែលបង្ហាញជូននៅក្នុងចំណងជើងសៀវភៅរបស់ខ្លួនស្រាប់ ឃៀរនិន ជឿថា ផ្ទៃរឿងសំខាន់ៗ

ទាំងពីរ នៅក្នុងប្រវត្តិរបបខ្មែរក្រហមគឺពូជសាសន៍និយម និងការតស៊ូដើម្បីអំណាច» ។ នៅក្នុងការពិភាក្សារបស់លោកទៅលើសម័យសង្គ្រាមស៊ីវិលមុនពេលរបប ប៉ុល ពត ឡើងកាន់អំណាច តាមពិតការរកឃើញរបស់ យៀវនិន មិនមានលក្ខណៈខុសគ្នាច្រើនណាស់ណាពីការរកឃើញរបស់ ហ្វ្រីសុន នោះទេ ដែលលោកនិយាយថា ការគាំទ្ររបស់ប្រជាកសិករចំពោះបដិវត្តន៍មានលក្ខណៈទូលំទូលាយ ។ យៀវនិន មិនបានបង្ហាញទន្និករណ៍ថាបដិវត្តន៍ខ្មែរក្រហមទទួលបានការគាំទ្រភាគច្រើនពីប្រជាកសិករទេ ។ យៀវនិន បានសរសេរថា ក្រោយពីទទួលបានជ័យជម្នះក្នុងសង្គ្រាមស៊ីវិលភ្លាម ជាតិនិយមមានលក្ខណៈរាលដាលនៅក្នុងប្រទេសកម្ពុជា (ស្មើនឹងសេចក្តីសង្ឃឹមចង់បានអនាគតប្រសើរជាងនេះ) ហើយប្រជាកសិករមានឆន្ទៈចង់ផ្តល់ឱកាសដល់ខ្មែរក្រហមឲ្យដឹកនាំប្រទេស ។ លុះដល់ក្រោយមកការផ្តុំគ្នារវាងភេរវកម្មដែលចេះតែរាលដាល ការគ្មានបាយហូបគ្រប់គ្រាន់ និងការបង្ខំឲ្យបំបែកមនុស្សពីក្រុមគ្រួសារ ដែលប្រការទាំងអស់នេះបានបំផ្លាញការគាំទ្ររបស់ប្រជាកសិករមកលើរបបកម្ពុជាប្រជាធិបតេយ្យទៅវិញ ។

ទោះបីជា យៀវនិន បានច្រានចោលគំនិតប្រជាកសិករនិយមរបស់ វីកឃ័រី ក៏ដោយ ក៏ យៀវនិន ខ្លួនឯងបានបដិសេធមិនចាត់ទុកថាបដិវត្តន៍កម្ពុជាកើតចេញពីលទ្ធិម៉ាក្សនិយមដែរ ។ ផ្ទុយទៅវិញ យៀវនិន ទាញហេតុផលថា «ផ្នត់គំនិតរបស់ខ្មែរក្រហមអំពីពូជសាសន៍បានលុបលើគំនិតវណ្ណៈនិយមនេះទៅហើយ ។ យៀវនិន សរសេរទៀតថា «ការផ្តោតសំខាន់របស់លទ្ធិម៉ៅនិយមមកលើគោលបំណងគ្រប់គ្រងមនុស្ស គឺមានសារសំខាន់ចំពោះមេដឹកនាំខ្មែរក្រហមជាងបច្ច័យនិយមលទ្ធិម៉ាក្សនិយមទៅទៀត ។ ប៉ុន្តែដូចជាក្នុងករណី វីកឃ័រី ដែរការខិតខំបង្ហាញរបស់ យៀវនិន តាមបែបបញ្ហាអំពីលទ្ធិម៉ាក្សនិយម គឺមិនគួរឲ្យជឿទេ ។ និយាយរួម យៀវនិន បានផ្តោតតិចតួចណាស់ទៅលើដើមកំណើតនៃបដិវត្តន៍ខ្មែរក្រហម ដោយចៀសវាងការប្រឈមមុខជាមួយបុសគល់កុម្មុយនិស្តខ្មែរក្រហមដែលត្រូវបានប្រកាសឡើង ។ ជាលទ្ធផល ភាពអសកម្មនេះមិនបានបង្ហាញអំពីរូបភាពនៃរបបរ៉ាឌីកាល់នេះឲ្យបានពេញលេញឡើយ ដោយសារថា ទន្និករណ៍របស់ យៀវនិន ដែលសង្កត់ធ្ងន់ទៅលើកត្តាពូជសាសន៍ គឺមានលក្ខណៈខ្សោយពេកមិនអាចជាហេតុផលគ្រប់គ្រាន់តែមួយនេះបានទេ ។

ម្យ៉ាងវិញទៀត នៅក្នុងការពិនិត្យទៅលើសៀវភៅដែលមានចំណងជើងថា «របបប៉ុលពត» នយោបាយវិទូ ស៊ីវ ហេដឌ័រ បានបន្ទោស យៀវនិន ដែលបានពិនិត្យទៅលើពូជសាសន៍និងវណ្ណៈក្រោមរបបខ្មែរក្រហម ។ ហេដឌ័រ បានច្រានចោលការបែងចែករវាងម៉ាក្សនិយមនិងពូជសាសន៍ថា «មិនអាចយកជាការបាន» ដោយជឿថា គំនិតទាំងពីរនេះមានទំនាក់ទំនងមិនអាចដោះស្រាយបាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចជាមនោគមវិជ្ជាសម័យទំនើបដែរ ហេដឌ័រ បង្ហាញថា លទ្ធិម៉ាក្សនិយមជាលទ្ធិចាស់ (តឹងតែង) ដែលផ្ទុកទៅដោយ«កម្លាំងជំរុញ» ពូជសាសន៍និយម ។ យោងតាម ហេដឌ័រ ការនិយាយមិនអស់សេចក្តីរបស់ យៀវនិន អំពីបុសគល់កុម្មុយនិស្តនិងម៉ាក្សនិយមធ្វើឲ្យលោកមិនអាចយល់ជាទូទៅអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងដឹមកំណើតនៃនយោបាយជាច្រើនទៀតរបស់ ប៉ុល ពត ។

ការសិក្សានេះនឹងបង្ហាញថា ការច្រានចោលរបស់ យៀវនិន និង វីកឃ័រី ដែលថាបដិវត្តន៍កម្ពុជាមិនមានបុសគល់ចេញពីកុម្មុយនិស្តនិយមនោះ គឺមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ ។ ដូចដែលយើងឃើញស្រាប់ហើយថា គំនិតនៅពីក្រោយនយោបាយដាច់ខាតរបស់ខ្មែរក្រហមទៅលើស្ត្រីនិងគ្រួសារ មានមុនដំបូងបង្អស់នៅក្នុងស្នាដៃនិពន្ធរបស់ ហ្វ្រេដិរិក អ៊ែងដែល ។ ដូចនេះទោះបីជាខ្មែរក្រហមបានច្រានចោលគំរូនានានៃប្រទេសជិតខាងនៅអាស៊ីដែលកាន់លទ្ធិកុម្មុយនិស្តនៅក្នុងវិស័យទាំងនេះក៏ដោយ ក៏ប្រការនេះគ្មានអ្វីទាក់ទងជាមួយពូជសាសន៍និយមឬប្រជាកសិករនិយមរបស់ខ្មែរក្រហមដែរ ប៉ុន្តែទាក់ទងនឹងផ្នត់គំនិតរបស់ខ្មែរក្រហមទៅលើរបបទាំងនោះថាមិនពេញលក្ខណៈជារបបកុម្មុយនិស្តទេ ។

ការពិនិត្យទៅលើចលនាកុម្មុយនិស្តផ្សេងៗទៀតនិងនយោបាយរបស់ចលនាទាំងនោះនៅអាស៊ី ស្តីអំពីស្ត្រីនិងគ្រួសារ គឺស៊ីគ្នាជាមួយគោលបំណងរបស់យើង ហើយមានការយល់ដឹងច្រើនអំពីតួនាទីរបស់ស្ត្រីនិងសមាគមបដិវត្តន៍របស់ខ្លួននៅប្រទេសវៀតណាម និងជាពិសេសនៅប្រទេសចិន ។ បន្ទាប់មកទៀត យើងស្គាល់អំពីស្ថានភាពរបស់ស្ត្រីនៅកូរ៉េខាងជើង ប៉ុន្តែដោយ

សាររបបកុម្មុយនិស្តនេះរក្សាចំណងទាក់ទងជាមួយបក្សកុម្មុយនិស្តកម្ពុជា ហើយបានអនុវត្តនូវកម្មវិធីនានាដែលមានលក្ខណៈផ្តាច់ការស្រដៀងគ្នានោះនឹងមានការពិនិត្យទៅលើអនាគតដោយសារថាមានការយល់ដឹងកាន់តែច្រើនហើយអំពីសង្គមកុម្មុយនិស្តបិទជិតនេះ ។

យោងតាម អេមីលី ហូនីង បានឲ្យដឹងថា ការយល់ឃើញរបស់អ្នកស្រាវជ្រាវលោកខាងលិចទៅលើគោលនយោបាយរបស់បក្សកុម្មុយនិស្តចិនទៅលើស្ត្រីមានការផ្លាស់ប្តូរនៅក្រោយឆ្នាំ១៩៧៥ ។ មុនឆ្នាំ១៩៧៥មានអ្នកសង្កេតការណ៍ជាច្រើនបានអះអាងអំពីកំណែទម្រង់បញ្ហាស្ត្រីដែលបក្សបានធ្វើ ។ ការសិក្សាស្រាវជ្រាវជាប្រវត្តិសាស្ត្រថ្មីៗអំពីស្ត្រីបានច្រានចោលគំនិតសុទិដ្ឋិនិយមនេះ ។ ចាប់តាំងពីឆ្នាំ១៩៧៥មក ការស្រាវជ្រាវជាច្រើនបានបង្ហាញនូវការសោកស្តាយដល់ការខកខានរបស់បដិវត្តន៍កុម្មុយនិស្ត ក្នុងការរំលាយការគ្រប់គ្រងដោយព្រឹទ្ធាចារ្យជាលក្ខណៈប្រពៃណី និងខកខានមិនបានធ្វើតាមការសន្យាថានឹងនាំមកនូវភាពស្មើមុខគ្នានិងការរំដោះស្ត្រី ។ ការសិក្សាស្រាវស្រាវបានគូសបញ្ជាក់អំពីការចូលរួមយ៉ាងសកម្មរបស់បក្សកុម្មុយនិស្តចិននៅក្នុងការរៀបចំស្ត្រីជាលក្ខណៈនយោបាយនិងយោធា និងតួនាទីបដិវត្តដ៏សំខាន់របស់ស្ត្រី ប៉ុន្តែក៏បានលើកឡើងនូវភាពផ្សេងគ្នារវាងទ្រឹស្តីរបស់បក្សនិងការអនុវត្តន៍ជាក់ស្តែង ដោយសម្តែងចេញនូវការខកចិត្តទៅលើជំហរតាមផ្លូវចិត្តចំពោះ«ការរំដោះ»ស្ត្រី ជាជំហរដែលប្រែប្រួលរវាងការផ្លាស់ប្តូរទាំងស្រុងនិងការស្ទាក់ស្ទើរក្នុងការជម្នះការគ្រប់គ្រងជាលក្ខណៈប្រពៃណីដោយព្រឹទ្ធាចារ្យ ។

កាយ អាន ចនសុន ដែលនិពន្ធសៀវភៅមានចំណងជើងថា «ស្ត្រី គ្រួសារ និងបដិវត្តន៍ប្រជាកសិករនៅប្រទេសចិន» បានវិភាគនយោបាយស្ត្រីរបស់បក្សកុម្មុយនិស្តចិននៅអំឡុងសតវត្សរ៍ទី២០ ជាពិសេសនយោបាយដែលទាក់ទងដល់គ្រួសារនិងការរៀបអាពាហ៍ពិពាហ៍ និងលទ្ធផលនៃការអនុវត្តន៍គោលនយោបាយទាំងនេះនៅតាមជនបទស្រុកស្រែចម្ការ ។ នយោបាយវិទូទាញសេចក្តីសន្និដ្ឋានថា តាមពិត លទ្ធផលនៃការអនុវត្តន៍នយោបាយទាំងនេះរក្សាបាននូវរចនាសម្ព័ន្ធគ្រួសារជាប្រពៃណីជារចនាសម្ព័ន្ធដែលសង្កត់សង្កិនស្ត្រីចិនជាយូរយារណាស់មកហើយ ហើយមិនបានកែទម្រង់រចនាសម្ព័ន្ធនេះទេ ។ អ្នកស្រីជឿថាការរក្សានូវរចនាសម្ព័ន្ធគ្រួសារជាលក្ខណៈប្រពៃណីវាសមស្របទៅនឹងគោលដៅសេដ្ឋកិច្ចនិងនយោបាយរបស់បក្ស ហើយថាតាមពិតបក្សខកខានមិនបានជំរុញដោយស្មោះដៃឲ្យមានកំណែទម្រង់សមភេទទេ ដោយខ្លួនខ្លាចថាធ្វើឲ្យប្រជាកសិករមានការអាក់អន់ស្រពន់ចិត្តនិងបាត់បង់ការគាំទ្ររបស់ប្រជាកសិករ ។ ចនសុន ទាញហេតុផលថា កំណែទម្រង់វិស័យសមភេទពិតប្រាកដអាចកើតឡើង ប្រសិនបើការប្រតិបត្តិជាប្រពៃណីតាមខ្សែខាងឪពុកនិងសាច់ញាតិខាងឪពុកត្រូវបានវាយប្រហារ ប៉ុន្តែរដ្ឋាភិបាលគ្មានឆន្ទៈចង់ធ្វើកំណែទម្រង់ទាំងស្រុងនិងដាច់ដោយឡែកៗពីគ្នា ។ ចនសុន សរសេរថា លទ្ធិម៉ាក្សនិយមតឹងរ៉ឹងផ្តល់នូវទម្រង់មួយសមស្រប ដើម្បីអនុវត្តការកែទម្រង់ដែលហាក់ដូចជាមានការរីកចម្រើនទៅមុខ ខណៈដែលធ្វើឲ្យប្រជាកសិករស្ត្រីមានការស្កប់ចិត្តអំពីទំនោរអភិរក្សរបស់ខ្លួន ។ អ៊ែងដែលជឿថា ស្ត្រីអាចត្រូវបានរំដោះតាមរយៈតួនាទីខាងសេដ្ឋកិច្ចនៅក្នុងសង្គមដែលចេះតែកើនឡើងជាលំដាប់ ហើយការផ្អែកទៅលើគំនិតនេះ បានធ្វើឲ្យបក្សលែងអនុវត្តដោយផ្ទាល់ទៅលើកំណែទម្រង់ស្ត្រី ។ មិនតែប៉ុណ្ណោះ ចនសុន សរសេរថាប្រការនេះបង្ហាញអំពីករណីមួយដែលការយល់ឃើញតាមទ្រឹស្តីរបស់ចិនស្របគ្នាជាមួយនឹងឥទ្ធិពល «យន្តម័យសម្ភារនិយមនិងសេដ្ឋកិច្ចដែលទទួលពីលទ្ធិប្រកាន់វិន័យតឹងរ៉ឹង» ។ ប្រការនេះប្រហែលជាការបំផ្លើសពីព្រោះការរៀបចំផែនការរបស់បក្សកុម្មុយនិស្តចិនចំពោះស្ត្រី ដែលក្នុងនោះរួមមាន «កិច្ចការដែលត្រូវធ្វើពីរគ្រួត» សម្រាប់ស្ត្រីនៅផ្ទះនិងនៅក្នុងសង្គម ពិបាកនឹងទាញថាអ្វីដែលបានលើកឡើងដោយ អ៊ែងដែល ចនសុន ជាការត្រឹមត្រូវណាស់នៅក្នុងការកត់សម្គាល់ទៅលើភាពមិនគ្រប់គ្រាន់នៃផែនការរបស់ អ៊ែងដែល នៅក្នុងករណីប្រទេសចិន ដោយសារថា ការផ្តោតសំខាន់របស់ផែនការរបស់ អ៊ែងដែល ទៅលើកំណែទម្រង់សេដ្ឋកិច្ច ភ្លេចគិតដល់សារសំខាន់នៃរចនាសម្ព័ន្ធជាប្រពៃណីនៃការគោរពញាតិខាងឪពុកនិងរបាំងដ៏គួរឲ្យខ្លាចដែលរចនាសម្ព័ន្ធទាំងនេះមានចំពោះការកែទម្រង់ស្ត្រី ។

**(នៅមានត)**

**ហ្សាល់ កាការីយ៉ា**

# នៅសល់តែបាតដៃទទេ

ចំការតាង៉ែតគឺជាឈ្មោះភូមិមួយនៅក្នុងឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានព្រំប្រទល់ទិសខាងលិចជាប់ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិចំការតាង៉ែតគឺពឹងផ្អែកទាំងស្រុងទៅលើមុខរបរធ្វើស្រែនិងឡើងត្នោត ។

ហែម វ៉ន ហៅ វិត ស្ថិតក្នុងវ័យ៤២ឆ្នាំ រស់នៅជាមួយប្តីនិងកូនប្រាំពីរនាក់ក្នុងភូមិចំការតាង៉ែត ដោយប្រកបមុខរបរធ្វើស្រែនិងឡើងត្នោតដើម្បីចិញ្ចឹមជីវិត ។ ដោយសារឆ្នាំនេះផលស្រូវនិងត្នោតមិនបានល្អ វ៉ន និងប្តី ឆ្លៀតពេលទៅស៊ីឈ្នួលច្រូតស្រូវឲ្យអ្នកភូមិដើម្បីរកប្រាក់កម្រៃបន្ថែមមកចិញ្ចឹមកូនដែលនៅតូចៗនៅឡើយ ។

វ៉ន ជាកូនពៅក្នុងចំណោមបងប្អូនប្រាំបីនាក់ ។ ឪពុករបស់គាត់ឈ្មោះ ដោក និងម្តាយឈ្មោះ គេង ។ ឪពុកម្តាយរបស់ វ៉ន បានស្លាប់តាំងពី វ៉ន នៅជាទារកម្ល៉េះ ។

វ៉ន បានចូលបដិវត្តន៍នៅពេលដែលមានអាយុ១៥ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៧ ដែលមានអ្នកខេ្មសនាមឈ្មោះ រុន នៅឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ។ វ៉ន មានឋានៈជាប្រធានក្រុមកុមារ ។ នៅក្នុងប្រវត្តិរូបបានបញ្ជាក់ថា វ៉ន ជាកុមារីម្នាក់មានអត្តចរិតស្លូតបូត ។ នៅដើមឆ្នាំ១៩៧៧ វ៉ន ត្រូវបានសមមិត្ត ឆន ជ្រើសរើសបញ្ជូនទៅខេត្តតាកែវ ។ ស្នាក់នៅក្នុងខេត្តតាកែវបានតែមួយថ្ងៃ តាម៉ុក ដែលពេលនោះជាគណៈភូមិភាគនិរតី បានបញ្ជូន វ៉ន ឲ្យឡើងឡានទាំងយប់ទៅធ្វើការនៅអរិយក្សត្រ ។ វ៉ន បាននិយាយថា «កាលនោះគេជ្រើសរើសមួយឃុំតែម្នាក់ទេ ហើយ តាម៉ុក ជាអ្នកពិនិត្យប្រវត្តិរូបនិងជ្រើសរើសដោយផ្ទាល់» ។

វ៉ន រស់នៅអរិយក្សត្ររយៈពេលពីរខែស្ថិតនៅក្រោមការគ្រប់គ្រងរបស់មិត្តនារី ឃឹន ។ ការងាររបស់ វ៉ន គឺដាំបន្លែ ។ វ៉ន ត្រូវបានអង្គការឲ្យធ្វើប្រវត្តិរូបម្តងទៀត ហើយបន្ទាប់មកគាត់ក៏ត្រូវបានឈ្មោះ តាំង ដែលជាគណៈគ្រប់គ្រងនៅអរិយក្សត្រជ្រើសរើសបញ្ជូនឲ្យមកធ្វើការនៅក្នុងព្រះបរមរាជវាំងរួមជាមួយមិត្តរួមក្រុម (កុមារី) ដែលមានអាយុប្រហាក់ប្រហែលគ្នាចំនួនប្រាំពីរនាក់ទៀត ។ អ្នកទាំងនោះភាគច្រើនមកពីខេត្តតាកែវនិងខេត្តកំពត ។

នៅក្នុងព្រះបរមរាជវាំង វ៉ន និងមិត្តភក្តិផ្សេងទៀតត្រូវបានអង្គការចាត់តាំងឲ្យដាំផ្កា ។ ប្រមាណជាងកន្លះខែក្រោយមក វ៉ន បានឃើញសម្តេច ព្រះនរោត្តម សីហនុ និងស្ត្រីចំណាស់ម្នាក់រាងស្គម ស្តើង សម្បុរស ព្រមទាំងក្មេងប្រុសម្នាក់ទៀត ចូលមកក្នុងវាំងដោយមានមនុស្សប្អូននាក់ផ្សេងទៀតអមដំណើរ ។ ពេលនោះ វ៉ន កំពុងតែធ្វើការក្នុងសួនច្បារក្នុងវាំងស្ថិតនៅចម្ងាយប្រមាណមិនដល់ដប់ម៉ែត្រពីអ្នកទាំងនោះ ។

បន្ទាប់ពីសម្តេចឪយាងចូលវាំង អង្គការក៏បានបួរឲ្យ វ៉ន មកដាំបាយនិងយកម្ហូបអាហារ (ព្រះក្រយា) ទៅថ្វាយសម្តេច ។ មុនដំបូង វ៉ន មិនដឹងថាអ្នកដែលខ្លួនយកម្ហូបអាហារទៅឲ្យនោះជាអ្នកណាទេ លុះអ្នកយាមនៅទីនោះនិយាយប្រាប់ថា «ជាសម្តេចឪ» ទើបគាត់មានការភ្ញាក់ផ្អើល ព្រោះពីមុនមកគាត់មិនដែលបានឃើញព្រះភក្ត្រ «សម្តេចឪ» ទេ ឮសូរតែព្រះនាមរបស់ព្រះអង្គតែប៉ុណ្ណោះ ។ វ៉ន ក៏មិនដឹងថាស្ត្រីចំណាស់និងក្មេងដែលស្ថិតនៅក្នុងប្រាសាទជាមួយសម្តេចឪនោះជាអ្នកណាដែរ ។ ការងារនៅព្រះបរមរាជវាំងត្រូវផ្លាស់វេនគ្នា គឺប្រាំពីរថ្ងៃមើលថែសួននិងប្រាំពីរថ្ងៃធ្វើម្ហូបដោយបែងចែកជាពីរក្រុម ។

វ៉ន បានឲ្យដឹងថា ការរស់នៅរបស់សម្តេចឪនៅក្នុងវាំងកាលពីពេលនោះគឺនៅក្រោមការយាមកាមរបស់កងទ័ពដែលមានឯកសណ្ឋានពណ៌ត្រួយចេក ។ ព្រះអង្គគង់នៅក្នុងដំណាក់ចំកណ្តាលបរិវេណព្រះបរមរាជវាំង ។ ចំណែក វ៉ន និងមិត្តភក្តិរួមក្រុម រស់នៅក្នុងផ្ទះមួយស្ថិតនៅខាងជើងប្រាសាទនោះ ។ វ៉ន

មិនសូវហ៊ាននិយាយជាមួយសម្តេចឪប៉ុន្មានទេ ព្រោះព្រះអង្គបានប្រាប់គាត់ថា បើខ្មែរក្រហមឃើញព្រះអង្គនិយាយជាមួយគាត់ នោះនឹងមានផលវិបាកដល់គាត់ឬខ្លួនព្រះអង្គផ្ទាល់ជាមិនខាន ។

រ៉ន បាននិយាយទៀតថា ម្ហូបអាហារប្រចាំថ្ងៃរបស់ព្រះអង្គ គឺមានត្រីចំហុយ សម្លម្ជូរប៉េងប៉ោះឬត្រប់ ជួនកាលមានត្រីចៀន គឺធម្មតាដូចអ្នកដទៃដែរ ហើយគ្មានភេសជ្ជៈទេ ។ ព្រះអង្គសោយតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់និងពេលល្ងាច ។ នៅរៀងរាល់ពេលដែលត្រូវយកម្ហូបអាហារទៅថ្វាយព្រះអង្គ គាត់ត្រូវរៀបចំម្ហូបដាក់ថាសមួយសម្រាប់មនុស្សបីនាក់ ។ បន្ទាប់មក គាត់ទូលយកទៅថ្វាយព្រះអង្គនៅក្នុងដំណាក់ ហើយដើរចេញមកក្រៅធ្វើការងារធម្មតាវិញ ។ ដល់ពេលបាយលើកក្រោយទៀត រ៉ន ចូលរៀបម្ហូបអាហារថ្មី ហើយយកថាសម្ហូបចាស់ចេញមកវិញ ។ ជារៀងរាល់ថ្ងៃ រ៉ន មិនដែលឃើញអាហារអស់ពីចានទេ គឺសល់ស្ទើរតែទាំងអស់ ។ ម្ហូបអាហារដែលយកទៅថ្វាយព្រះអង្គសុទ្ធតែមានការត្រួតពិនិត្យនិងកំណត់ពីអ្នកគ្រប់គ្រងនៅទីនោះ ប៉ុន្តែ រ៉ន តែងតែលួចដាក់លើសពីបញ្ជាដែលថ្នាក់លើបានប្រាប់គាត់ ព្រោះគាត់មានចិត្តអាណិតព្រះអង្គ ដោយឃើញព្រះកាយរបស់ព្រះអង្គចុះស្គម ហើយសម្បុរស្រអាប់ (មិនដូចឥឡូវនេះទេ) ។ នៅក្នុងពេលធ្វើការក្នុងវាំង រ៉ន មិនឃើញមានគ្រូពេទ្យចេញចូលដំណាក់របស់ព្រះអង្គឡើយ ។

ក្រៅអំពីធ្វើម្ហូបថ្វាយសម្តេច រ៉ន ក៏ត្រូវធ្វើម្ហូបឲ្យ ខៀវ សំផន ដែរ ។ ខៀវ សំផន ស្នាក់នៅក្នុងផ្ទះមួយក្បែរផ្ទះដែល រ៉ន ស្នាក់នៅដើម្បីមើលខុសត្រូវកិច្ចការបម្រើព្រះអង្គ ។

ជារៀងរាល់ថ្ងៃ រ៉ន តែងតែព្យាយាមនិយាយលេងជាមួយនឹងព្រះអង្គបន្តិចបន្តួចដែរ ព្រោះក្រៅពីអ្នកបម្រើដែលយកបាយទៅឲ្យ រ៉ន មិនដែលឃើញអ្នកណាផ្សេងចូលទៅគាល់ព្រះអង្គសោះ ។ មានពេលមួយ ព្រះអង្គបានប្រាប់គាត់ថា “មុននឹងបញ្ជូនព្រះអង្គមកដាក់នៅក្នុងវាំងនេះ ខ្មែរក្រហមបានយកព្រះអង្គទៅឃុំឃាំងនៅមហោស្រពខាងត្បូងវាំងអស់រយៈពេលពីរខែ” ។ ព្រះអង្គក៏បានសួរ រ៉ន ថាមកពីខាងណា? រ៉ន ប្រាប់ថា គាត់មកពីឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

រយៈពេលប៉ុន្មានថ្ងៃមុនពេលដែលរបបខ្មែរក្រហមត្រូវវាយបណ្តេញចេញពីអំណាច ខៀវ សំផន បានហៅអ្នកធ្វើការនៅក្នុងវាំងមកប្រជុំប្រាប់ទាំងអស់គ្នាពីកិច្ចការនៅក្នុងវាំងកុំឲ្យមានការជ្រួលច្របល់នៅពេលដែលគេជម្លៀស សម្តេច សីហនុ ចេញពីវាំង ។ ក្រោយមកប៉ុន្មានថ្ងៃ ក្រុមរបស់ រ៉ន ត្រូវបានអង្គការដឹកតាមរថយន្តទៅដល់ស្រុកបវេល ខេត្តបាត់ដំបង ។

ប្រហែលជាក្នុងខែមិថុនា ឆ្នាំ១៩៧៩ រ៉ន បានវិលមកភូមិកំណើត និងបានជួបជុំបងប្អូនរបស់គាត់ឡើងវិញ ប៉ុន្តែបងរបស់គាត់ម្នាក់បានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ រ៉ន កំពុងរស់នៅក្នុងអនក្ខរភាពនិងភាពទ្រុឌទ្រោមផ្នែករាងកាយនិងផ្លូវចិត្ត ។ នេះគឺជាអ្វីដែល រ៉ន បានទទួលពីរបបខ្មែរក្រហម ។

**ផាន់ សុខជា**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **អគ្គបញ្ញាការៈ** គឺគ្រប់គ្រងនឹងចាត់ចែងការងារបដិវត្តន៍ទាំងអស់មិនមែននៅស្ងៀមទេ ។ អគ្គបញ្ញាការគឺគ្រប់គ្រងនយោបាយ សតិអារម្មណ៍ ចាត់តាំងមិនមែន បញ្ជាអាជ្ញាទេ ។

(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)

◆ **ប្រយុទ្ធៈ** ពុះពារការលំបាកក្នុងន័យជាកងទ័ពស្រួច លំបាកខាងផ្លូវកាយក្តី លំបាកខាងផ្លូវចិត្តក្តី ។ គឺដាច់ខាតឥតរួញរាឥតរាថយ ។

◆ **ជាប់ជាមូលដ្ឋានៈ** ស៊ីជម្រៅទៅក្នុងចលនា គឺជាប់នឹងប្រជាជនកសិករក្រ និងកណ្តាលថ្នាក់ក្រោម ។

◆ **ជាក់ស្តែងៈ** ក្តាប់សភាពការណ៍បានគ្រប់ជ្រុងជ្រោយ តាមដានហើយតម្រែតម្រង់ទាន់ពេលវេលាបន្តបន្ទាប់ ។

◆ **ម៉ឺត់ចត់ៈ** គឺខ្លួនឯងត្រូវម៉ឺត់ចត់ តឹងរ៉ឹង តែអាធ្យាស្រ័យឲ្យអ្នកដទៃ ។ ម្យ៉ាងទៀតត្រូវគិតគូរដោះស្រាយគ្រប់បញ្ហាតាមសមូហភាព តាមខ្សែចាត់តាំង និងដោយថ្លឹងថ្លែងក្នុងស្មារតីទទួលខុសត្រូវចំពោះប្រជាជនមូលដ្ឋាន ។

(ទង់បដិវត្តន៍លេខពិសេស)

# គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌអន្តរជាតិ៖ ទស្សនៈរបស់អ្នកច្បាប់ព្រហ្មទណ្ឌជាតិមួយរូប

មកដល់ពេលនេះ អ្វីដែលហៅថា «ផ្នែកទូទៅ» នៃនីតិព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានចងក្រងជាក្រមច្បាប់ខ្លះៗតែប៉ុណ្ណោះ ។ អត្ថបទនេះពិភាក្សាអំពីភាពចាំបាច់ឲ្យមាននិងការលំបាកនានាក្នុងការបង្កើតនូវ «ផ្នែកទូទៅ» មួយ ជាពិសេសទាក់ទងនឹងបញ្ហានានាដូចជាយុត្តាធិការ គោលការណ៍នីត្យានុកូលភាព បែបបទនៃការចូលរួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ទិដ្ឋភាពផ្សេងៗទៀតនៃបំណងឧក្រិដ្ឋ យុត្តិកម្ម សេចក្តីដោះសា និងទិដ្ឋភាពផ្សេងៗទៀត ។ អត្ថបទនេះផ្តល់នូវចំណុចសំខាន់ៗដែលយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិបានធ្វើឲ្យមានការរីកចម្រើនកន្លងមក ។ មិនតែប៉ុណ្ណោះសោតអត្ថបទនេះផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរឥតឈប់ឈររវាងប្រព័ន្ធយុត្តិធម៌អន្តរជាតិនិងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិ ក្នុងការសម្រេចបាននូវដំណោះស្រាយចំពោះបញ្ហាទាំងនេះ ។

## ១) ភាពចាំបាច់ឲ្យមាន«ផ្នែកទូទៅ»នៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ

ក៏ដូចជានីតិព្រហ្មទណ្ឌជាតិដែរ ដើម្បីឲ្យមានការជាប់ទាក់ទងគ្នា នីតិព្រហ្មទណ្ឌអន្តរជាតិចាំបាច់ត្រូវតែមានមិនត្រឹមតែ «ផ្នែកពិសេស» មួយដែលមានបទឧក្រិដ្ឋអន្តរជាតិដាច់ដោយឡែកប៉ុណ្ណោះទេ ប៉ុន្តែត្រូវមាន «ផ្នែកទូទៅ» ដែលគ្របនូវគោលការណ៍គ្រឹះនិងវិធានទូទៅមានសុពលភាពចំពោះបទឧក្រិដ្ឋអន្តរជាតិ ឬយ៉ាងហោចណាស់មានសុពលភាពចំពោះផ្នែកមួយចំនួននៃបទឧក្រិដ្ឋអន្តរជាតិ ។

បើប្រៀបធៀបទៅនឹង «ផ្នែកពិសេស» ផ្នែកទូទៅនៃនីតិព្រហ្មទណ្ឌជាតិនិងនីតិព្រហ្មទណ្ឌអន្តរជាតិ គឺកើតចេញពីដំណើរការវិវត្តន៍បន្តបន្ទាប់មក ទោះជាដោយហេតុផលផ្សេងគ្នាក៏ដោយ ។ «ផ្នែកទូទៅ» នៃនីតិព្រហ្មទណ្ឌជាតិ គឺជាលទ្ធផលកើតចេញពីការបង្រួញទ្រឹស្តីដែលមានលក្ខណៈរីកចម្រើន ការចាប់បដិសន្ធិឡើងនូវចរិតលក្ខណៈទូទៅនៃបទឧក្រិដ្ឋដាច់ដោយឡែក និងការដុសចេញនូវគោលការណ៍កើតចេញពីហេតុផលនយោបាយដែលយកប្រព័ន្ធច្បាប់ជាមូលដ្ឋាន (ពោលគឺនីត្យានុកូលភាពការដាក់ទោសពិរុទ្ធភាព ការទម្លាក់ការទទួលខុសត្រូវទៅលើអ្នកដទៃជាដើម) ។ នៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ អ្វីដែលហៅថា «ប្រព័ន្ធអនុវត្តច្បាប់ប្រយោល» ដែលក្នុងនោះប្រព័ន្ធច្បាប់ជាតិគ្រប់គ្រងលើការជំនុំជម្រះក្តីនិងការផ្តន្ទាទោសតាមច្បាប់សារវ័ន្តមាននិងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួនផ្ទាល់ មិនបានតម្រូវឲ្យមានការបង្កើត«ផ្នែកទូទៅ»ទេ ។ មកទល់នឹងពេលនេះប្រព័ន្ធប្រយោលនេះបានកើតឡើងនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ។ ផ្ទុយមកវិញ «ផ្នែកទូទៅ» នៃនីតិព្រហ្មទណ្ឌអន្តរជាតិត្រូវបានចាត់ទុកថាមានសារសំខាន់ទាក់ទងនឹងអ្វីដែលហៅថា ប្រព័ន្ធអនុវត្តច្បាប់ដោយប្រយោលដូចរៀបរាប់ខាងលើ ។ ប្រព័ន្ធអនុវត្តច្បាប់ដោយផ្ទាល់មិនត្រឹមតែមានការបង្កើតនូវអង្គវិនិច្ឆ័យក្តីជាអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តជាក់ស្តែងនៅក្នុងកម្រិតអន្តរជាតិទៀតផងនូវសកម្មភាពទាំងអស់ពាក់ព័ន្ធទៅនឹងការកាត់សេចក្តីបទឧក្រិដ្ឋអន្តរជាតិ ដូចជាការស៊ើបអង្កេតនីតិវិធីក្នុងការជំនុំជម្រះក្តី ការចេញសាលក្រម ទណ្ឌកម្ម និងការអនុវត្តសាលក្រម ។ ចំណុចចុងក្រោយមួយទៀតគឺប្រព័ន្ធអនុវត្តច្បាប់ចម្រុះក៏ជំរុញឲ្យមានការបង្កើតនូវ«ផ្នែកទូទៅ»ដែរនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ។ ប្រព័ន្ធនេះដែលប្រមើលមើលទៅលើការបង្កើតឡើងនូវអង្គវិនិច្ឆ័យក្តីផ្អែកយ៉ាងសំខាន់ទៅលើកិច្ចសហការពីសំណាក់រដ្ឋដើម្បីចាប់ខ្លួន និងប្រគល់ខ្លួនជនជាប់ចោទការផ្តល់ជំនួយជាទម្រង់ផ្សេងៗដល់អង្គតុលាការ និងការអនុវត្តន៍សាលក្រមកំណត់ទោស ។ ប្រព័ន្ធពីរក្រោយនេះត្រូវបានយកមកអនុវត្តជាក់ស្តែងនៅក្នុងដំណាក់កាលផ្សេងៗគ្នាកាលពីអតីតកាល ។ តុលាការយោធាអន្តរជាតិនៅនូរិមប៊ឺកនិងនៅតុងក្យូគឺជាឧទាហរណ៍នៃប្រព័ន្ធអនុវត្តច្បាប់ដោយផ្ទាល់ ។ ចំណែកឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដាគឺជាប្រព័ន្ធអនុវត្តច្បាប់ចម្រុះ ។ ទោះជាប្រព័ន្ធទាំងនេះមាន

លក្ខណៈផ្សេងៗពីគ្នាយ៉ាងណាក៏ដោយ ប៉ុន្តែប្រព័ន្ធទាំងនេះបានលើកកម្ពស់នូវការយល់ដឹងទាក់ទងនឹងតម្រូវការចាំបាច់ឲ្យមាន «ផ្នែកទូទៅ»នៃនីតិព្រហ្មទណ្ឌអន្តរជាតិ ដែលអាចផ្តល់ដល់តុលាការអន្តរជាតិនាពេលអនាគត ទោះជាមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្តី ជាមួយនឹងគោលការណ៍ទូទៅស្តីអំពីការទទួលខុសត្រូវនិងការផ្តន្ទាទោសដែលបច្ចុប្បន្ននេះត្រូវបានលើកកម្ពស់ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមានការវិវត្តន៍ខ្លាំងបំផុតនៅក្នុងពិភពលោក ។

## ២) ដើមកំណើតនិងការបង្កើត «ផ្នែកទូទៅ»

ផ្អែកតាមការសន្និដ្ឋានខាងលើ គេយល់នូវមូលហេតុដែលបណ្តាលឲ្យសន្ធិសញ្ញាអន្តរជាតិនិងច្បាប់ទំនៀមទម្លាប់អន្តរជាតិផ្តល់វិភាគទានដែលមានលក្ខណៈយឺតយ៉ាវ ឥតរបៀប និងស្តួចស្តើងបែបនេះចំពោះការបង្កើតនូវ«ផ្នែកទូទៅ»មួយ ។ ដើមកំណើតនៃ«ផ្នែកទូទៅ»នៃនីតិព្រហ្មទណ្ឌអន្តរជាតិមានឫសគល់ចេញពីធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិនៅនូរិមប៊ឺក (ឆ្នាំ១៩៤៥) និងនៅតូក្យូ (ឆ្នាំ១៩៤៦) ។ អ្វីដែលត្រូវបានបង្កើតឡើងនៅនូរិមប៊ឺកនិងតូក្យូបានលេចរូបរាងសាជាថ្មីនៅក្នុងច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ្វ៉ាន់ដា ។ ទោះជាយ៉ាងណា ដើម្បីកំណត់ឲ្យបានច្បាស់នូវធាតុផ្សំនៃការទទួលខុសត្រូវព្រហ្មទណ្ឌនិងក្នុងករណីដែលមានការបដិសេធមិនទទួលខុសត្រូវចំពោះមុខច្បាប់ តុលាការទាំងពីរចុងក្រោយនេះបានផ្អែកយ៉ាងសំខាន់ទៅលើគោលការណ៍ទូទៅដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌសំខាន់ៗនៅលើពិភពលោក ។ ច្បាប់យុត្តិសាស្ត្រចេញពីតុលាការទាំងនេះបានរួមចំណែកបន្ថែមទៀតទៅលើការបង្កើតនូវ«ផ្នែកទូទៅ»នេះ ។ ក៏ប៉ុន្តែ ការរួមចំណែកនេះមានវិវាទជាមួយនឹងគោលការណ៍នីត្យានុកូលភាព ។ ទីមួយ តុលាការទាំងនេះបានរកឃើញឬកំណត់ច្បាស់អំពីគោលការណ៍ទូទៅក្រោយពីមានការប្រព្រឹត្តិបទឧក្រិដ្ឋ ។ ទីពីរ ដោយតុលាការទាំងនេះផ្អែកទៅលើប្រព័ន្ធព្រហ្មទណ្ឌជាតិផ្សេងៗគ្នា ហើយជូនកាលឲ្យនិយមន័យទៅលើគោលការណ៍ទាំងនេះផ្សេងៗគ្នា ដូចនេះអាចនាំឲ្យមានវិវាទកម្ម ។

ជាការពិតណាស់ ការប្រទាំងប្រទើសគ្នាជាយូរមកហើយរវាងនីត្យានុកូលភាពជាក់លាក់និងយុត្តិធម៌សារវ័ន្តមាន គឺមានលក្ខណៈជាប្រវត្តិសាស្ត្រដែលមិនប្រែប្រួលទាក់ទងនឹងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋអន្តរជាតិ ។ មានដំណោះស្រាយបីដែលអាចធ្វើទៅរួចចំពោះការប្រទាំងប្រទើសគ្នានេះ ។

ក) ភាពទូទៅនៃនីត្យានុកូលភាពជាក់លាក់បច្ចេកទេសដែលមានការធានាដល់ភាពជាក់លាក់តាមផ្លូវតុលាការនិងសមភាពបទឧក្រិដ្ឋចំពោះរដ្ឋស្ថិតក្រោមប្រព័ន្ធព្រហ្មទណ្ឌក្នុងស្រុកទៅតាមរដ្ឋនីមួយៗ ។ នេះគឺជាមធ្យោបាយមួយក្នុងការធានានូវការគោរពដល់គោលការណ៍នៃ «ផ្នែកទូទៅ» ។ ក៏ប៉ុន្តែត្រឡប់មកនិយាយអំពីរដ្ឋវិញ គឺនិយាយអំពីការខាតបង់ដែលអាចកើតឡើងចំពោះយុត្តិធម៌សារវ័ន្តមាន ពីព្រោះថា ការផ្តន្ទាទោសចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋត្រូវអាស្រ័យទៅលើឆន្ទៈរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ក្នុងចំណោមបញ្ហាផ្សេងៗទៀត ដើម្បីផ្តន្ទាទោសដល់ការប្រព្រឹត្តិបទឧក្រិដ្ឋអន្តរជាតិ ។ ការផ្តន្ទាទោសនេះក៏ផ្អែកទៅលើផលល្អនៃប្រព័ន្ធយុត្តិធម៌របស់រដ្ឋនានា និងផ្អែកទៅលើឆន្ទៈនិងសមត្ថភាពរបស់រដ្ឋទាំងនេះក្នុងការសហការ ។ ប៉ុន្តែការសហការបែបនេះដោយមានកន្លះខាតនូវការសម្របសម្រួលនិងការទាក់ទងគ្នាក្លាយទៅជាចំណុចខ្សោយបំផុតនៅក្នុងការពុះពារប្រឆាំងមិនត្រឹមតែប្រឆាំងខក្រិដ្ឋកម្មអន្តរជាតិទេ ប៉ុន្តែប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មក្នុងស្រុកទៀតផង ជាពិសេស ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងច្បាស់លាស់ ។ ភាពមិនទាន់សម្រេចដ៏គួរឲ្យគ្រោះថ្នាក់នៃឧក្រិដ្ឋកម្មជាលក្ខណៈអន្តរជាតិចាប់តាំងពីសង្គ្រាមលោកលើកទីពីរ និងបទឧក្រិដ្ឋដែលកើនឡើងខ្ពស់និងមិនត្រូវបានផ្តន្ទាទោស បង្ហាញឲ្យឃើញជាក់ស្តែងនូវការប្រថុយគ្រោះថ្នាក់នៃបច្ចេកទេសនេះ ។

១) ភាពទូទៅនៃយុត្តិធម៌សារវ័ន្តមានៈ

ដំណោះស្រាយនេះត្រូវបានជ្រើសរើសគ្រាន់តែក្នុងកម្រិតតិចឬច្រើនប៉ុណ្ណោះ នូវគ្រប់ករណីដែលបទឧក្រិដ្ឋអន្តរជាតិត្រូវបានវិនិច្ឆ័យនិងផ្តន្ទាទោសដោយតុលាការអន្តរជាតិ បើទោះជាខ្វះនូវបទបញ្ញត្តិនានាដែលមានលក្ខណៈច្បាស់លាស់និងរៀបចំជាក្រមច្បាប់លាស់ទាក់ទងនឹងទិដ្ឋភាពនានានៃការទទួលខុសត្រូវព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិក៏ដោយ ។ ស្ទើរតែមានការទទួល

ខុសត្រូវជាសកលទៅហើយថា នៅក្នុងជម្រើសរវាងយុត្តិធម៌សាវរិជ្ជមាននិងការគោរពដាច់ខាតចំពោះនីត្យានុកូលភាពដាក់លាក់នេះប្រហែលជាអាចលះបង់បន្តិចបន្តួចដល់យុត្តិធម៌សាវរិជ្ជមាន ។ តាមការពិត ការអនុវត្តន៍ទៅតាមនីត្យានុកូលភាពដាច់ខាតចារីប្រព្រឹត្តបទល្មើសនៃ«រដ្ឋដែលមានបទល្មើសកើតឡើង» អាចត្រូវបានធ្វើឲ្យរួចផុតពីការកាត់សេចក្តីបាន ពីព្រោះថា ទង្វើរបស់ខ្លួនមានលក្ខណៈត្រឹមត្រូវទៅតាមច្បាប់ក្នុងស្រុក ។ ផ្ទុយមកវិញ សាលក្រមរបស់តុលាការនៅនូរិមប៊ឺកនិងតូក្យូត្រូវបានចាត់ទុកថាមានលក្ខណៈធម្មានុរូប ពីព្រោះថា សាលក្រមទាំងនេះផ្អែកលើ «គោលការណ៍មនុស្សជាតិ» ជាចម្បង ជាគោលការណ៍ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងបទបញ្ញត្តិច្បាប់ជាតិ ដែលមិនអនុញ្ញាតឲ្យមានការដោះសាតាមផ្លូវច្បាប់ដែលបង្កើតឡើងត្រឹមកម្រិតជាតិពីសំណាក់មេដឹកនាំឬមន្ត្រីជាន់ខ្ពស់របស់រដ្ឋ ដើម្បីផ្តល់យុត្តិធម៌ចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ។ តាមការពិត អនុសញ្ញាអឺរ៉ុបឆ្នាំ១៩៥០ស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សុទ្ធតែបានបញ្ជាក់សាជាថ្មីនូវដំណោះស្រាយនេះ ដោយចូលរួមជាគំនិតថា គោលការណ៍អប្រតិសកម្មមិនអាចបដិសេធចោលនូវការទទួលខុសត្រូវក្នុងការផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌបានឡើយ «ដោយយោលទៅតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយអារ្យប្រទេសនានា» ។ ច្បាប់យុត្តិសាស្ត្រនៃតុលាការបង្កើតឡើងសម្រាប់អតីតយូហ្គោស្លាវីនិងរ៉ាន់ដា បានបោះជំហានទៅមុខជាបណ្តើរៗ ឆ្ពោះទៅរកការគោរពទៅតាមគោលការណ៍នីត្យានុកូលភាព ។ ការលះបង់នូវនីត្យានុកូលភាពដាក់លាក់តាមវិធីសាស្ត្ររបស់តុលាការទាំងនេះ មានកម្រិតតិចណាស់ ប្រសិនបើ(វាសឹងតែជាទូទៅ) លក្ខណៈវិនិច្ឆ័យជាមូលដ្ឋានដែលយកចេញប្រព័ន្ធច្បាប់ជាតិនានាដើម្បីកំណត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌ គឺសម្រាប់ផ្នែកភាគច្រើនដែលមានលក្ខណៈស្រដៀងគ្នាដោយមានការខុសគ្នាតែបន្តិចបន្តួច ។ មិនតែប៉ុណ្ណោះ តុលាការទាំងនេះខិតខំរកឲ្យឃើញនូវកត្តារួម ហើយប្រសិនបើមានការខុសប្លែកគ្នាដែលមិនអាចជំនះបាន តុលាការទាំងនោះមានទំនោរទៅតាមការបកស្រាយដែលមានលក្ខណៈអនុគ្រោះបំផុតដល់ជនជាប់ចោទ ។

លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈច្បាស់លាស់ជាងលើបញ្ហានេះ ។ យោងតាមមាត្រាទី២១នៃតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានផ្តល់នូវឋានានុក្រមនៃច្បាប់ដែលមានអានុភាពអនុវត្ត ។ បទបញ្ញត្តិនេះបង្ហាញឲ្យឃើញថាតុលាការនេះត្រូវអនុវត្តបទបញ្ញត្តិរបស់លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិមុន បន្ទាប់មកនៅពេលមានការចាំបាច់ត្រូវអនុវត្តតាម«សន្ធិសញ្ញានិងគោលការណ៍ដែលមានអានុភាពអនុវត្តនិងវិធានច្បាប់អន្តរជាតិ» ។ បើមិនបានសម្រេចតុលាការត្រូវបន្តរហូតដល់«គោលការណ៍ទូទៅនៃច្បាប់ដែលស្រង់ដោយតុលាការ ចេញពីច្បាប់ជាតិដែលមានប្រព័ន្ធច្បាប់ពិភពលោក ក្នុងនោះប្រសិនបើមានលក្ខណៈសមស្រប រួមមានច្បាប់ជាតិរបស់រដ្ឋដែលអនុវត្តជាធម្មតានូវយុត្តាធិការទៅលើបទល្មើស ដោយសារថា គោលការណ៍ទាំងនោះមានលក្ខណៈស្រដៀងគ្នាទៅនឹងលក្ខន្តិកៈច្បាប់នេះ និងដោយមានច្បាប់អន្តរជាតិ ព្រមទាំងបទដ្ឋាននិងមាត្រដ្ឋានដែលទទួលស្គាល់ដោយអន្តរជាតិទៀតផង» ។ លក្ខន្តិកៈច្បាប់នេះក៏បានចែងដែរថា តុលាការ «អាចអនុវត្តនូវគោលការណ៍និងវិធានច្បាប់ដូចដែលបានបកស្រាយនៅក្នុងសេចក្តីសម្រេចមុនៗ» ។

*ក) ការបញ្ចូលគ្នារវាងយុត្តិធម៌សាវរិជ្ជមាននិងនីត្យានុកូលភាពជាក់លាក់*

ដំណោះស្រាយនេះអាចសម្រេចបានតែតាមរយៈការរៀបចំជាក្រមសរសេរជាលាយលក្ខណ៍អក្សរមានលក្ខណៈទូលំទូលាយទាក់ទងនឹង «ផ្នែកពិសេស» និង «ផ្នែកទូទៅ» នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះ ។ ប្រការនេះហាក់ដូចជាដំណោះស្រាយដ៏ល្អបំផុតក្នុងការយកមកផ្សំគ្នារវាងយុត្តិធម៌សាវរិជ្ជមាននិងនីត្យានុកូលភាពជាក់លាក់ ពីព្រោះថា វិធីនេះដោះស្រាយនូវបញ្ហាសំខាន់ពីរទាក់ទងនឹងធម្មានុរូបនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ទីមួយ ដំណោះស្រាយនេះយកចិត្តទុកដាក់ចំពោះរបៀបក្នុងការអនុលោមទៅតាមគោលការណ៍នីត្យានុកូលភាព ដែលតែងតែជាបញ្ហាធ្ងន់ធ្ងរនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះថា គោលការណ៍ទូទៅច្បាប់ទម្លាប់និងបទបញ្ញត្តិនានាចែងនៅក្នុងអនុសញ្ញា

កម្រចែងឲ្យចំៗអំពីធាតុផ្សំជាក់ច្បាស់នៃការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ហើយមិនទាក់ទងនឹង «ផ្នែកទូទៅ» ទៀតផង ។ ទីពីរ ដំណោះស្រាយនេះឆ្លើយតបទៅនឹងការព្រួយបារម្ភ ដែលស្តែងចេញនៅក្នុងភាពមានវិជ្ជាជ្រៅជ្រះនាពេលបច្ចុប្បន្នដែលថា គោលការណ៍នីត្យានុកូលភាពត្រូវតែបានលើកស្ទួយទោះជានៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ។ ប្រការនេះមានការទាក់ទងជាពិសេសក្នុងករណីនានាដែលច្បាប់អន្តរជាតិត្រូវបានអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះដូចដែលខ្ញុំបានលើកឡើងពីខាងដើមរួចមកហើយថា អង្គច្បាប់នេះដែលខ្វះនូវនិយមន័យច្បាស់លាស់អំពីបទល្មើសផ្សេងៗ និងបញ្ញត្តិនានាដែលគ្រោបនូវ «ផ្នែកទូទៅ» បំពេញបានត្រឹមតែកម្រិតតូចប៉ុណ្ណោះចំពោះគោលការណ៍នីត្យានុកូលភាព ។ វិធីដ៏ប្រសើរបំផុតក្នុងការប៉ះប៉ូវចំពោះលក្ខខណ្ឌមិនគាប់ប្រសើរនេះ គឺត្រូវធ្វើឲ្យបានម៉ត់ចត់នូវសន្ធិសញ្ញាមួយដែលចងក្រងជាក្រមនីតិព្រហ្មទណ្ឌអន្តរជាតិ ។ ក៏ប៉ុន្តែ បើទោះជាធ្វើដូចនេះផ្តល់នូវផលប្រយោជន៍ក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងក្នុងការចងក្រងជាក្រមច្បាប់ ត្រូវបានបំផ្លាញចោលតាំងពីចប់សង្គ្រាមលោកលើកទីមួយមកម្ល៉េះ ។ ការមិនទុកចិត្តទៅលើយុត្តាធិការអន្តរជាតិ ការងាកមកប្រើប្រាស់អំពើហិង្សាជាអាវុធនយោបាយ (ដូចជាសង្គ្រាមកូរ៉េ ការបង្ក្រាបបដិវត្តន៍ហុងគ្រី វិបត្តិនៅហ្ស៊ុស ។ល ។) បញ្ហាដែលមិនអាចជម្នះបានក្នុងការកំណត់និយមន័យពាក្យថា «ឈ្លានពាន» ទាំងអស់នេះបានធ្វើឲ្យវិនាសអស់នូវការប៉ុនប៉ងចងក្រងជាក្រមច្បាប់ ។

## ៣) គោលការណ៍នីត្យានុកូលភាពនិងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ការវិវត្តន៍ថ្មីៗនិងដែលអាចមានជោគជ័យនៅក្នុងការចងក្រងជាក្រមនូវ «ផ្នែកពិសេស» និង «ផ្នែកទូទៅ» នៃនីតិអន្តរជាតិ អាចរកឃើញនៅក្នុងលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ឆ្នាំ១៩៩៨) ។ ដោយសង្កត់ធ្ងន់ទៅលើភាពចាំបាច់ឲ្យមាននីត្យានុកូលភាពនិងជាពិសេស«ភាពជាក់លាក់» លក្ខន្តិកៈច្បាប់នេះប្រហែលជារាយនិងកំណត់លក្ខខណ្ឌមិនសូវច្បាស់លាស់អំពីឧក្រិដ្ឋកម្មអន្តរជាតិ ។ ច្បាប់នេះឲ្យនិយមន័យលើពាក្យប្រល័យពូជសាសន៍ (មាត្រា៦) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មាត្រា៧) និងឧក្រិដ្ឋកម្មសង្គ្រាម (មាត្រា៨) ។ មិនតែប៉ុណ្ណោះ ច្បាប់នេះក៏បញ្ជាក់ច្បាស់ដែរថា ឧក្រិដ្ឋកម្មឈ្លានពាននឹងត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅពេលដែលបញ្ញត្តិអំពីបទល្មើសនេះត្រូវបានអនុម័ត (មាត្រា៥-២) ។



មេដឹកនាំចិនក្នុងដំណើរទស្សនកិច្ចកម្ពុជាប្រជាធិបតេយ្យ

លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិមិនមែនមិនត្រូវបានទទួលការរិះគន់នោះទេ ។ ជាអាទិ៍ មានចន្លោះប្រហោងមិនងាយបំពេញនៅក្នុងបញ្ញត្តិនានាដែលចែងអំពីការប្រល័យពូជសាសន៍ ដែលមិនផ្តល់នូវការការពារដល់ក្រុមសង្គមនិងក្រុមនយោបាយដែលមិនស្ថិតនៅក្នុងក្រុមជាតិពិន្ទុ ក្រុមសាសនា ឬក្រុមជនជាតិ ។ ក្រៅពីនេះក៏មានការស្ទួនគ្នារវាងបទបញ្ញត្តិរបស់លក្ខន្តិកៈច្បាប់នេះចំពោះការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ បើទុកណាជា

មានចំណុចខ្វះខាតយ៉ាងណាក៏ដោយ លក្ខន្តិកៈច្បាប់នេះជាសញ្ញាបញ្ជាក់អំពីជំហានច្បាស់លាស់ឆ្ពោះទៅមុខក្នុងការកំណត់ឲ្យបានកាន់តែម៉ត់ចត់នូវនិយមន័យនៃបទឧក្រិដ្ឋអន្តរជាតិ ព្រមទាំងដាក់បទឧក្រិដ្ឋអន្តរជាតិទាំងនេះឲ្យស្ថិតនៅក្រោមគោលការណ៍ដាក់លាក់ ។

លក្ខន្តិកៈច្បាប់នេះក៏ប្រកាសនូវគោលការណ៍ច្បាប់សំខាន់ៗដទៃទៀត ។ ទីមួយ មាត្រា២២ចែងអំពីគោលការណ៍«គ្មាន



បទល្មើសគ្មានច្បាប់ចែង» ព្រមទាំងហាមមិនឲ្យមានការពង្រីកនិយមន័យបទឧក្រិដ្ឋតាមរយៈសទិសភាព ។ ជាពិសេសនៅមាត្រា២២(៣) លក្ខន្តិកៈច្បាប់នេះធ្វើឲ្យការកំណត់លក្ខណៈនៃការប្រព្រឹត្តិដែលមិនមានចែងនៅក្នុងលក្ខន្តិកៈគ្មានឥទ្ធិពលជាលក្ខណៈព្រហ្មទណ្ឌក្រោមវិធាននៃនីតិអន្តរជាតិ ។ និយាយម្យ៉ាងទៀត ការកំណត់និយមន័យដែលមាននៅក្នុងលក្ខន្តិកៈច្បាប់មានលក្ខណៈចាប់បង្ខំតែក្នុងគោលបំណងអនុវត្តតែក្នុងលក្ខន្តិកៈច្បាប់នេះតែប៉ុណ្ណោះ ។ មាត្រា២៣បញ្ជាក់អំពីគោលការណ៍«គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង» ពោលគឺបុគ្គលដែលទទួលរងការចោទប្រកាន់អំពីតុលាការត្រឹមតែអាចទទួលទោសអនុលោមទៅតាមច្បាប់លក្ខន្តិកៈកំណត់ប៉ុណ្ណោះ ។ មាត្រា២៤បញ្ជាក់អំពីអប្រតិសកម្ម ដោយបង្ហាញច្បាស់ៗថា «គ្មានបុគ្គលណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌក្រោមលក្ខន្តិកៈច្បាប់នេះទេចំពោះការប្រព្រឹត្តិឡើងនៅមុនពេលច្បាប់នេះចូលជាធរមាន» ។ មិនតែប៉ុណ្ណោះ មាត្រា២៤(២) លក្ខន្តិកៈច្បាប់នេះចែងអំពីអប្រតិសកម្មនៃច្បាប់អនុគ្រោះដល់ជនជាប់ចោទនៅពេលដែលការសើរើផ្លាស់ប្តូរច្បាប់ពាក់ព័ន្ធត្រូវបានអនុម័តមុនពេលសម្រេចសាលក្រមជាស្ថាពរ ។ លើកលែងចំណុចចុងក្រោយនេះចេញ ការបញ្ជាក់ដាច់ខាតអំពីគោលការណ៍អប្រតិសកម្ម ហាក់ដូចជាធ្វើឲ្យលក្ខន្តិកៈច្បាប់មិនត្រឹមតែមានភាពផ្សេងគ្នាពីជំហរដែលធ្វើឡើងនៅតុលាការនូរិមប៊ឺកនិងតូក្យូ ដែលសាលក្រមរបស់ខ្លួនគឺផ្អែកជាមូលដ្ឋានទៅលើការរំលោភពីសំណាក់ចុងចោទទៅលើ«គោលការណ៍មនុស្សជាតិ» ខ្ពស់បំផុតប៉ុណ្ណោះទេ ប៉ុន្តែមានភាពផ្សេងគ្នាពីមាត្រា១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ព្រមទាំងមាត្រា៧នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស ។ តាមការពិត បើទុកណាជាបទបញ្ញត្តិនៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សក្រសោបនូវគោលការណ៍អប្រតិសកម្មក៏ដោយ ក៏បទបញ្ញត្តិទាំងនេះចាត់ទុកគោលការណ៍នេះថាមានលក្ខណៈមិនចាប់បង្ខំចំពោះអំពើដែលនៅពេលកំពុងប្រព្រឹត្តជាបទឧក្រិដ្ឋ«ដោយយោងតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយអារ្យប្រទេស» ។ ប៉ុន្តែបទបញ្ញត្តិទាំងនេះមិនអាចដោះស្រាយបាននូវបញ្ហានៃការកំណត់អំពើឧក្រិដ្ឋដោយឈរនៅលើមូលដ្ឋាននៃបទបញ្ញត្តិទាំងនេះឡើយ ។

ការអនុវត្តន៍ដំណាលៗគ្នានៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនិងអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សព្រមទាំងលក្ខន្តិកៈច្បាប់ផ្ទាល់ អាចធ្វើឲ្យកាន់តែពិបាកដោះស្រាយនូវបញ្ហានៃការកំណត់អំពើឧក្រិដ្ឋដោយឈរនៅលើមូលដ្ឋាននៃបទបញ្ញត្តិទាំងនេះ ។

ការអនុវត្តដំណាលៗគ្នានៃកតិកាសញ្ញាអន្តរជាតិស្តីអំពី

សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្ស ព្រមទាំងលក្ខន្តិកៈច្បាប់ផ្ទាល់ អាចធ្វើឲ្យកាន់តែពិបាកដោះស្រាយនូវបញ្ហានៃការសម្របសម្រួលសម្រាប់ភាគីចុះសន្ធិសញ្ញាក្នុងការអនុវត្តន៍នីតិព្រហ្មទណ្ឌជាតិទៅតាមពេលវេលា ។ សូមលើកឧទាហរណ៍ករណីប្រព័ន្ធច្បាប់ប្រទេសអ៊ីតាលី ។ ទាក់ទងនឹងប្រព័ន្ធច្បាប់ប្រទេសអ៊ីតាលី គេអាចនិយាយបានថា ការឃ្លាតចាកពីគោលការណ៍អប្រតិសកម្មដូចដែលបានលើកឡើងខាងលើ ដែលចែងដោយកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មានការពាក់ព័ន្ធជាមួយនឹងច្បាប់ព្រហ្មទណ្ឌក្នុងស្រុក ។ ចំណែកឯគោលការណ៍អប្រតិសកម្មដូចដែលមានចែងនៅក្នុងលក្ខន្តិកៈច្បាប់ មានការពាក់ព័ន្ធជាមួយយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមកជាមួយយុត្តាធិការជាតិ (មាត្រា១) ។ មិនតែប៉ុណ្ណោះសោត បញ្ហាប្រទាំងប្រទើសដែលថា ការប្រាសចាកពីវិធានដែលមានចែងស្រាប់ អាចបង្កើតឡើងជាមួយនឹងគោលការណ៍អប្រតិសកម្មដូចដែលចែងនៅត្រង់មាត្រា២៥(២) នៃរដ្ឋធម្មនុញ្ញប្រទេសអ៊ីតាលីនោះ ហាក់ដូចជាមិនអាចដោះស្រាយបានតាមរយៈការយកនីត្យានុកូលភាពជាក់លាក់ជាធំបានទេ ពីព្រោះថា ការប្រាសចាកពីគោលការណ៍អប្រតិសកម្មទាំងនោះគឺជាការរំលោភទៅលើស្មារតីនៃគោលការណ៍រដ្ឋធម្មនុញ្ញដែលបានជម្រាបជូនខាងលើ ។ ក្រៅពីការសង្កត់សង្កិនឬការរំលោភបំពាន អញ្ញត្រកម្មទាំងនេះគឺជាការបញ្ជាក់សាជាថ្មីនៃគោលការណ៍យុត្តិធម៌សារវិជ្ជមានដែលមានលក្ខណៈសំខាន់និងមិនអាចរំលោភបាន ដែលតាមរយៈប្រការនេះ សូម្បីតែគោលការណ៍អប្រតិសកម្មក៏គួរតែអាចវាស់ស្ទង់បានដែរ ហើយដែលចេញពីគោលការណ៍នេះវាគឺជាវិញ្ញត្តិមួយ ។ ហេតុដូចនេះករណីប្រទេសអ៊ីតាលីសបញ្ជាក់ឲ្យឃើញថា អញ្ញត្រកម្ម (ការលើកលែង) ចំពោះគោលការណ៍អប្រតិសកម្មទាំងនេះអាចត្រូវបានចាត់ទុកថាមានការកំណត់មិនច្បាស់លាស់ចំពោះគោលការណ៍ដែលចែងនៅត្រង់មាត្រា២៥(២) នៃរដ្ឋធម្មនុញ្ញអ៊ីតាលីក្តីឬអញ្ញត្រកម្មទាំងនេះអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រព័ន្ធច្បាប់អ៊ីតាលីតាមស្មារតីមាត្រា១០(១) ដែលសម្រួលច្បាប់ទម្លាប់អន្តរជាតិបញ្ចូលក្នុងច្បាប់អ៊ីតាលីជាស្វ័យប្រវត្តិក្តី ប្រការនេះជាការពិតណាស់ដោយផ្អែកតាមការសន្មតដែលថាការប្រាសចាកពីគោលការណ៍ (អប្រតិសកម្ម) ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សនោះបានប្រែក្លាយទៅជាវិធាននៃច្បាប់ទម្លាប់អន្តរជាតិរួចទៅហើយ ។

ចំណុចចុងក្រោយបង្អស់គឺថា លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិចងក្រងគោលការណ៍និងផ្តត់គំនិតជាច្រើនទាក់ទងនឹង «ផ្នែកទូទៅ» ជាក្រមដោយកម្រិតលក្ខន្តិកៈច្បាប់ខ្លួនឯងក្នុងការផ្តល់នូវវិធាននិងនិយតកម្មនានាចំពោះតែតម្រូវការឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលត្រូវបានចាត់ទុកថាមានសារសំខាន់ចម្បងឬត្រូវការនូវការស្រាយបំភ្លឺឲ្យបានច្បាស់លាស់បំផុត ។ ជាការមិនល្អ ការដែលផ្អែកលើវិធានដែលទាញចេញពីប្រព័ន្ធច្បាប់ព្រហ្មទណ្ឌប្រទេសផ្សេងៗគ្នា ដែលជួនកាលមានលក្ខណៈជាន់គ្នាឬផ្ទុយគ្នានោះ វាបានធ្វើឲ្យឃ្លាតចាកពីបន្ទាត់និងការជាប់ទាក់ទងគ្នារបស់លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

## ៤) ធាតុផ្សំនៃបទឧក្រិដ្ឋអន្តរជាតិ

ក) ធាតុសត្យានុម័ត (ធាតុសម្ភារ):

លក្ខន្តិកៈច្បាប់តុលាការនូរិមប៊ឺកនិងតូក្យូ តុលាការសម្រាប់អតីតយូហ្គោស្លាវីនិងរវ៉ាន់ដា និងលក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ស្ទើរតែមិនបានចែងអំពីធាតុផ្សំដ៏សំខាន់នៃបទឧក្រិដ្ឋអន្តរជាតិ យ៉ាងហោចណាស់ឲ្យទាក់ទងនឹងធាតុសត្យា-នុម័តឡើយ ។ ចំពោះធាតុផ្សំទាំងនេះដូចជាចំណងហេតុផលជាដើម គឺតុលាការដែលរៀបរាប់នេះយកគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលមានចែងក្នុងប្រព័ន្ធច្បាប់ធំៗនៅលើពិភពលោកជាមូលដ្ឋានរបស់ខ្លួន ។

ទ្រឹស្តីនីតិព្រហ្មទណ្ឌបែងចែកប្រភេទបទល្មើសបួនដាច់ពីគ្នា ។ បទល្មើសសកម្មអន្តរជាតិមានចំនួនច្រើនបំផុតទាំងក្នុងនីតិព្រហ្មទណ្ឌជាតិនិងនីតិព្រហ្មទណ្ឌអន្តរជាតិ ។ បទល្មើសអសកម្មអន្តរជាតិបង្កើតបានជាផ្នែកមួយដែលត្រូវបានយល់ថាជាការជាក់កាតព្វកិច្ចអន្តរជាតិកាន់តែធ្ងន់ក្នុងការធ្វើសកម្មភាពប្រឆាំង

នឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ។ ឧទាហរណ៍ដូចដែលបានចែងច្បាស់នៅត្រង់មាត្រា៧(៦) នៃសេចក្តីព្រាងក្រមច្បាប់ស្តីអំពីបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាពនិងសន្តិសុខមនុស្សជាតិ (ឆ្នាំ១៩៥៤) រដ្ឋនានាមានកាតព្វកិច្ចទប់ស្កាត់សកម្មភាពនានានៅក្នុងរង្វង់ព្រំដែនរបស់ខ្លួន ដែលសកម្មភាពទាំងនេះត្រូវបានរៀបចំឡើងដើម្បីធ្វើភេរវកម្មនៅបរទេស ។ បទល្មើសអន្តរជាតិសាមញ្ញគឺជាបទល្មើសដោយសកម្មភាពមួយ ឬការមិនចាត់ការរបស់អង្គការមួយ ។ បទល្មើសអន្តរជាតិមានលក្ខណៈស្មុគស្មាញ គឺជាលទ្ធផលចេញពីអំពើល្មើសធ្វើឡើងដោយអង្គការលើសពីមួយដែលសកម្មភាពរបស់ខ្លួននាំដល់ (ឬបង្កើតបានជា) ការរំលោភច្បាប់អន្តរជាតិ ។

លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិច្រានចោលនូវការទទួលខុសត្រូវចំពោះមុខច្បាប់អំពីបទល្មើសអកម្ម លើកលែងតែមេបញ្ជាការយោធា ឬមេកោយដែលខកខានមិនបានគ្រប់គ្រងឲ្យបានម៉ត់ចត់ ឬការធ្វេសប្រហែសក្នុងការចាត់វិធានការចាំបាច់ដើម្បីទប់ស្កាត់ ឬបង្ក្រាបការប្រព្រឹត្តិបទល្មើសពីសំណាក់កូនចៅក្រោមបង្គាប់(មាត្រា២៨) ។ លក្ខន្តិកៈច្បាប់មិនបានផ្តល់នូវចំណុចសំខាន់ៗទៅលើគោលការណ៍ទូទៅឡើយ ដែលគោលការណ៍នេះត្រូវបានដាក់បញ្ចូលរួចហើយ ឬការលាយបញ្ចូលគ្នារវាងអំពើទាំងពីរ ។ ប៉ុន្តែលក្ខន្តិកៈច្បាប់នេះពិតជាបានចែងថា ការទទួលខុសត្រូវចំពោះបទល្មើសអកម្មត្រូវទទួលយកបានតែពេលណាដែល «បុគ្គលនោះមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការពង្វាងមិនឲ្យមានព្រឹត្តិការណ៍នោះ» ។ ការបដិសេធនូវគោលការណ៍ទូទៅ គឺដោយសារការលំបាកដែលត្រូវបានដឹងឮក្នុងការសម្រេចឲ្យបាននូវមតិទូទៅស្តីអំពីស្ថានភាពជាក់ស្តែងដែលភាពអកម្មគួរតែត្រូវបានផ្តន្ទាទោស និងដោយសារតែភាពចម្រូងចម្រាសរវាងអ្នកដែលគាំទ្រវិធានជាក់លាក់ដែលតម្រូវឲ្យបុគ្គលស្តែងចេញជាសកម្មភាពឡើងនិងអ្នកដែលមានទឡ្ហីករណ៍ថា វិធានបែបនេះអាចមានលក្ខណៈមិនគ្រប់គ្រាន់សម្រាប់គ្របនូវរាល់ករណីអកម្មទាំងអស់ដែលសមនឹងទទួលការផ្តន្ទាទោស ។ ក្រុមទីពីរនេះបង្ហាញបញ្ច្រាសវិញថា បទល្មើសទាំងនេះយកល្អគួរតែត្រូវផ្តន្ទាទោសដូចដែលបានបញ្ជាក់រួចហើយដោយតុលាការនៅនូរិមប៊ឺកនិងសេចក្តីព្រាងក្រមច្បាប់ស្តីអំពីបទល្មើសប្រឆាំងនឹងសន្តិភាពនិងសន្តិសុខមនុស្សជាតិ (ឆ្នាំ១៩៥៤) ដោយឈរលើមូលដ្ឋាននៃ«ការទទួលខុសត្រូវចំពោះភាពសកម្មតាមរយៈភាពអកម្ម» ។ ផ្អែកតាមទស្សនៈនេះ បុគ្គលគ្រប់រូបមានកាតព្វកិច្ចអនុវត្តទៅតាមវិធាននៃច្បាប់អន្តរជាតិ ហើយអាចដាក់ឲ្យទទួលខុសត្រូវចំពោះការធ្វេសប្រហែសក្នុងការអនុវត្តន៍តាម ។ បើទោះជាលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដាមិនបានចែងច្បាស់អំពីការទទួលខុសត្រូវចំពោះបទល្មើសអកម្មក៏ដោយ ប៉ុន្តែលក្ខន្តិកៈច្បាប់នៃតុលាការទាំងពីរនេះទំនងជាពង្រីកការទទួលខុសត្រូវចំពោះមេបញ្ជាការយោធាជាទម្រង់មួយនៃការទទួលខុសត្រូវនេះដែរ តាមរយៈភាពអកម្មពីបទមិនបានទប់ស្កាត់កូនចៅក្រោមបង្គាប់មិនឲ្យប្រព្រឹត្តបទល្មើស ។

ខ) ធាតុអត្តនោម័តៈ

ខណៈដែលការបង្កើតនូវចំណងហេតុផលរវាងសកម្មភាពនិងលទ្ធផលនៃបទល្មើស (ត្រឹមតែការទទួលខុសត្រូវជាលក្ខណៈសត្យានុម័ត) មានលក្ខណៈគ្រប់គ្រាន់សម្រាប់អ្នកអត្ថាធិប្បាយមួយចំនួន ជាពិសេសអ្នកដែលទទួលយកនូវការទទួលខុសត្រូវរបស់រដ្ឋ អ្នកនិពន្ធនាពេលបច្ចុប្បន្នមានការយល់ស្របជាមួយជំហរដែលបញ្ជាក់ដោយតុលាការនៅនូរិមប៊ឺក ដោយចាត់ទុកការដាក់ទណ្ឌកម្មទៅលើបទឧក្រិដ្ឋអន្តរជាតិថាមានលក្ខណៈមិនអាចបំបែកចេញពីគោលការណ៍ពិរុទ្ធភាពឡើយ ។ ទាក់ទងនឹងការបែងចែកជាពិសេសរវាងចេតនានិងការធ្វេសប្រហែស (ពោលគឺកំហុស) ដែលនិយាយជាទូទៅនៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ វាជាវិធាននិងអញ្ញត្រកម្មនោះ គេកត់សម្គាល់ឃើញថា បទល្មើសអន្តរជាតិជាការផ្ទុយមកវិញ គឺត្រូវតែផ្តន្ទាទោស ទោះជាត្រូវដាក់ទណ្ឌកម្មកម្រិតទាបជាងក៏ដោយ នៅពេលដែលបទល្មើសទាំងនេះកើតចេញពីការប្រព្រឹត្តិមិនប្រុងប្រយ័ត្ន (ដូចជាការបង្កឲ្យមានសង្គ្រាមឈ្លានពានដោយសារការធ្វេសប្រហែសជាដើម) ។ ក៏ដូចជានៅក្នុងច្បាប់ជាតិដែរ គឺគេមានបញ្ញត្តឲ្យអនុវត្តចំពោះចេតនានិងការព្រហើនដូចៗគ្នា ។ ផ្ទុយមកវិញ បទបញ្ញត្តិនានារបស់ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

ស្តីអំពីធាតុផ្សំខាងស្មារតី (មាត្រា៣០) ទំនងជាកំណត់ចំពោះ «ចេតនា» តែមួយប៉ុណ្ណោះ ដោយមិនរួមបញ្ចូលការធ្វេសប្រហែសផងទេ ។ ដោយប្រើពាក្យមិនមានន័យច្បាស់លាស់និងមានន័យខាងចិត្តសាស្ត្រមិនច្បាស់លាស់ បទបញ្ញត្តិនេះឃ្លាតឆ្ងាយពីភាសាដែលប្រើនៅក្នុងក្រមព្រហ្មទណ្ឌភាគច្រើននៅអឺរ៉ុប (ដែលខ្ញុំលើកយកមកជម្រាបជូននៅក្នុងអត្ថបទនេះដែរ) ។ បទបញ្ញត្តិនេះ (១)រួមបញ្ចូលធាតុផ្សំ «ចេតនា» និង «ការធ្វេសប្រហែស» (២)បើទោះជាវាមិនបដិសេធដោយច្បាស់លាស់នូវការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងករណីត្រឹមតែមានការធ្វេសប្រហែសក៏ដោយ (៣)ប៉ុន្តែវាថែមទាំងបដិសេធដោយមិនច្បាស់លាស់នូវការទទួលខុសត្រូវចំពោះភាពព្រហើន (ឥតកោតក្រែង) នៅពេលដែលបទល្មើសជាបុគ្គលតម្រូវឲ្យមានចេតនាឬការគិតទុកជាមុន ដូចជា បទឧក្រិដ្ឋនៃការសម្លាប់បំផុតពូជ ការរំលោភទៅលើជាតិពន្ធ ការជម្លៀស ការបង្ខំឲ្យធ្វើជាទាសករ ឬការវាយប្រហារដោយចេតនាមកលើជនស៊ីវិល ។ (៤)នៅពេលបទល្មើសជាបុគ្គលតម្រូវឲ្យមានចេតនាជាក់លាក់ (ដូចជាបទឧក្រិដ្ឋប្រល័យពូជសាសន៍) វាក៏បដិសេធចោលនូវការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងករណីដែលមានការបង្ហាញត្រឹមតែចេតនាទូទៅ ។ (៥)ការធ្វេសប្រហែសជាទូទៅមិនបញ្ចូលទៅក្នុងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ដោយមានអញ្ញត្រកម្មមិនច្បាស់លាស់ដូចជា នៅក្នុងមាត្រា២៨ ទាក់ទងនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះមេបញ្ជាការយោធា ដោយសារការខកខានមិនបានគ្រប់គ្រងកងកម្លាំងស្ថិតនៅក្រោមបញ្ជានៅពេលដែលមេបញ្ជាការ «គួរតែបានដឹងថាកងកម្លាំងទាំងនោះកំពុងប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តបទល្មើស» នៅក្នុងយុត្តាធិការរបស់តុលាការ ។

ស្តីអំពីវិធានទាក់ទងនឹង«កំហុសអង្គហេតុ ឬកំហុសអង្គច្បាប់» (មាត្រា៣២) លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវនូវការដោះសាពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយឈរលើមូលដ្ឋានទាំងនោះ ។ ចំពោះកំហុសអង្គហេតុ លក្ខន្តិកៈច្បាប់នេះប្រានចោលនូវការទទួលខុសត្រូវតែនៅពេលណាដែលកំហុសអង្គហេតុបដិសេធចោលធាតុផ្សំខាង«ស្មារតី» ដែលបទល្មើសមួយចំនួនតម្រូវឲ្យមាន ពោលគឺ នៅពេលដែលជនជាប់ចោទដោយសារកំហុស«ចាំបាច់»ជ្រើសរើសយកនូវអង្គហេតុផ្សេងពីអង្គហេតុដែលត្រូវបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ។ កំហុសអង្គច្បាប់អាចត្រូវបានប្រើជាមូលដ្ឋានសម្រាប់បដិសេធចោលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើកំហុសអង្គច្បាប់បដិសេធនូវធាតុផ្សំខាងស្មារតី ពោលគឺ ចេតនាដែលតម្រូវដើម្បីឲ្យក្លាយជាបទល្មើសព្រហ្មទណ្ឌ ។ ដូចនេះគេមិនអាចប្រើកំហុសអង្គច្បាប់ជាមូលដ្ឋានក្នុងការបដិសេធការទទួលខុសត្រូវតាមផ្លូវច្បាប់នៅពេលដែលវាមានកំណត់ចំពោះកំហុសអំពីភាពមិនត្រឹមត្រូវតាមច្បាប់នៃការប្រព្រឹត្តិនោះ ។ ផ្ទុយមកវិញ វាគឺជាមូលដ្ឋានសម្រាប់បដិសេធនូវការទទួលខុសត្រូវនៅពេលដែលវាបដិសេធនូវធាតុផ្សំ «បំណងឧក្រិដ្ឋ» ពោលគឺចេតនាហើយចូលជាកំហុសអង្គហេតុយ៉ាងស៊ីជម្រៅ ។ ប្រការនេះហាក់ដូចជាចង់បញ្ជាក់ថាបទល្មើសដែលកំហុសចេញពីចេតនាត្រូវបានផ្តន្ទាទោស ចំណែកឯបទល្មើសដែលយកកំហុសដោយការធ្វេសប្រហែសជាមូលដ្ឋាននៅតែមិនទទួលការផ្តន្ទាទោសដដែល ។

## ៦) បែបផែននៃបទឧក្រិដ្ឋអន្តរជាតិ

លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានចែងអំពីស្ថានភាពនៃបទល្មើសដែលត្រូវយកមកពិចារណាក្នុងគោលបំណងកំណត់នូវបទល្មើសទេ ពោលគឺគ្មានបញ្ញត្តិណាមួយចែងអំពីអ្វីដែលហៅថា «បទល្មើសប្រយោល» ឡើយ ។ ផ្ទុយមកវិញ លក្ខន្តិកៈនេះចែងអំពីការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនិងការចូលរួមប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌពីសំណាក់ជនធ្វើសកម្មភាពព្រហ្មទណ្ឌ ដោយមានចេតនាចង់បញ្ជាក់ច្បាស់នូវនិយមន័យ និងបំពេញចន្លោះប្រហោងដែលកំពុងមានសព្វថ្ងៃនៅក្នុងលក្ខន្តិកៈនៃតុលាការមុនៗ និងសេចក្តីព្រាងក្រមស្តីអំពីបទល្មើស ។ ជាអាទិ៍ មុនពេលមានលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ «ការប៉ុនប៉ង»ដែលជាប្រភេទបទល្មើសទូទៅមិនមានចែងឡើយ លើកលែងតែប្រភេទបទល្មើសជាក់លាក់មួយចំនួន (ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) ហើយបទល្មើសដែលប៉ុនប៉ងទុកជាមុនជាទូទៅនៅតែមិនទទួលទណ្ឌកម្មដដែល ។

ជាមធ្យោបាយក្នុងការទប់ស្កាត់បទល្មើស លក្ខន្តិកៈច្បាប់

របស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា ការប៉ុនប៉ងប្រព្រឹត្តបទល្មើសជាប្រភេទបទល្មើសទូទៅត្រូវតែផ្តន្ទាទោស (មាត្រា ២៥-៣ច) ។ ប្រការនេះបានបញ្ចប់នូវភាពចម្រូងចម្រាស់ទៅលើថាតើបទល្មើសអន្តរជាតិខ្លះៗឬទាំងអស់មានការពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ។ លក្ខន្តិកៈច្បាប់នេះមានការកំណត់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដោយយោងទៅតាមលក្ខខណ្ឌពិសេសនៃ«ការចាប់ផ្តើមអនុវត្ត»អំពើល្មើសព្រហ្មទណ្ឌដោយមានលក្ខខណ្ឌបន្ថែមទៀតថា «ជំហានចម្បង» ត្រូវបានអនុវត្តជាក់ស្តែងទៀតផង ។ ជាលទ្ធផល បញ្ហាក្នុងការកំណត់«ជំហានចម្បង»បានបន្ថែមថា បញ្ហាមួយទៀតក្នុងការកាត់ចែកឲ្យច្បាស់រវាងអំពើរៀបចំខ្លួន និងដំណាក់កាលចាប់ផ្តើមប្រព្រឹត្តបទល្មើស ។ ដើម្បីចៀសវាងការដោះសាតាមទ្រឹស្តីដែលថាដំណាក់កាលចាប់ផ្តើមប្រព្រឹត្តស្របគ្នានឹងបទល្មើស (ដូចជានៅក្នុងករណីដែលបុគ្គលម្នាក់ទិញកាំភ្លើងក្នុងគោលបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍) និងតាមលទ្ធផលនៃជម្រើសដ៏តឹងរ៉ឹងរវាងការទទួលខុសត្រូវនិងនិទណ្ឌភាព លក្ខន្តិកៈច្បាប់នេះហាក់ដូចជាក្រសោបនូវទស្សនៈតាមបាតុភូតសាស្ត្រនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើស ។ ក្នុងទស្សនៈនេះ «ការប៉ុនប៉ង» អាចគ្រោបរាល់អំពើទាំងអស់ដែលជាការគំរាមកំហែងចំពោះផលប្រយោជន៍ដែលការពារដោយនីតិវិធីព្រហ្មទណ្ឌ ។ អំពើបែបនេះអាចរួមបញ្ចូលអំពើដែលតាមនិយមន័យ មិនមែនជាផ្នែកនៃការប្រព្រឹត្តិបទល្មើសឡើយ ដូចជាសកម្មភាពរៀបចំទុកជាមុន (ឧទាហរណ៍យករថយន្តទៅកន្លែងដែលមានមនុស្សរង់ចាំការជម្លៀស) ។ គេអាចទាញចេញពីមាត្រា៣០ (វិធានទូទៅស្តីអំពីបំណងឧក្រិដ្ឋ) នៃលក្ខន្តិកៈថា ធាតុផ្សំ«ស្មារតី»ដើម្បីឲ្យចូលជាការប៉ុនប៉ង មិនត្រឹមតែមានចេតនានោះទេ ប៉ុន្តែត្រូវការព្រហើនទៀតផង ។ តាមពិត នៅក្នុងមាត្រា២៥(ច) គ្មានការចែងផ្ទុយពីនេះឡើយ ។ មិនតែប៉ុណ្ណោះ លក្ខន្តិកៈច្បាប់មិនបានចែងអំពីទោសបញ្ញត្តិជាក់លាក់ដើម្បីដាក់ទណ្ឌកម្មដល់បទល្មើសប៉ុនប៉ងឡើយ ។ ផ្ទុយទៅវិញ ទោសបញ្ញត្តិសម្រាប់ការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមានលក្ខណៈដូចគ្នាទៅនឹងទោសបញ្ញត្តិនៃបទល្មើសបានសម្រេចដែរ ទោះជាតុលាការនេះអាចកំណត់ទោសស្រាលជាងក៏ដោយ ដូចដែលមានចែងនៅក្នុងមាត្រា៧៨ ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺថា ដំណោះស្រាយនេះហាក់ដូចជាមានលក្ខណៈដូចទៅនឹងទស្សនៈអត្តនោម័ត នៃការប៉ុនប៉ងដែលដូចគ្នាទៅនឹងប្រព័ន្ធមួយដែលយក«ឆន្ទៈ» ផ្ទាស់ឲ្យទៅជារឿងឧក្រិដ្ឋ ជាជាងទស្សនៈសត្យានុម័តនៃបទល្មើសដែលលក្ខន្តិកៈច្បាប់ក្រសោប នៅពេលដែលច្បាប់នេះកំណត់ការប៉ុនប៉ងតាមរយៈរូបមន្តមិនអត្តនោម័ត និយាយយោងដល់សកម្មភាពដែលចាប់ផ្តើមអនុវត្ត (បទល្មើស) ជាជាងតាមរយៈទស្សនៈអត្តនោម័តនៃការប៉ុនប៉ងថាមានសកម្មភាព«សំដៅ» អនុវត្តជាក់ស្តែងនូវបទល្មើស ។ លក្ខន្តិកៈច្បាប់ក៏បានចែងអំពីការបដិសេធនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ប្រសិនបើសាមីខ្លួនបោះបង់ចោលនូវកិច្ចខិតខំប្រព្រឹត្តបទល្មើស ឬបើមិនដូច្នោះទេ ទប់ស្កាត់មិនឲ្យបទល្មើសបានសម្រេច មាត្រា២៥-៣(១) ដែលធាតុផ្សំនេះ ទាំងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ព្រមទាំងក្រមច្បាប់ព្រាងឆ្នាំ១៩៥៤, ១៩៩១ និង ១៩៩៦ មិនបានយកទៅពិចារណាឡើយ ។ ចំណុចចុងក្រោយមួយទៀតគឺថា និទណ្ឌភាពបែបនេះមិនត្រឹមតែអាស្រ័យទៅលើការដែលថាសាមីជននោះបោះបង់ចោលនូវសកម្មភាពល្មើសដោយស្ម័គ្រចិត្តប៉ុណ្ណោះទេ ប៉ុន្តែសាមីជននោះត្រូវបោះបង់ចោលសកម្មភាពល្មើសចប់សព្វគ្រប់ទៀតផង ។ លក្ខខណ្ឌចុងក្រោយនេះ (ចប់សព្វគ្រប់) ដែលមានលក្ខណៈមិនប្រាកដប្រជា ហាក់ដូចជាតម្រូវថា ការបោះបង់ចោលនូវកិច្ចប្រឹងប្រែងប្រព្រឹត្តិបទល្មើស មិនត្រូវមានលក្ខណៈបណ្តោះអាសន្ន ហើយកំណត់ចំពោះបទល្មើសណាមួយជាក់លាក់ឡើយ ប៉ុន្តែត្រូវតែមានលក្ខណៈស្ថាពរនិងទូលំទូលាយ ដើម្បីកុំឲ្យកើតឡើងនូវករណីដែលថា នៅពេលដែលបុគ្គលម្នាក់បោះបង់ចោលការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមមួយ ប៉ុន្តែបន្តសកម្មភាពដដែលនេះប្រឆាំងនឹងក្រុមមួយទៀត ។

លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានចែងអំពីអ្វីដែលហៅថា «បទល្មើសមិនអាចកើតឡើង» មានន័យថា នៅពេលដែលសកម្មភាពមិនអាចចេញជាបទល្មើស ឬគ្មានកម្មវត្ថុនៃបទល្មើស ។ បទល្មើសដែលមិនអាចកើតឡើងអាចផ្តន្ទាទោស

បានតែឈរលើមូលដ្ឋាននៃទ្រឹស្តីអត្ថនោម័តនៃបទឧក្រិដ្ឋប៉ុណ្ណោះ មិនមែនឈរលើទស្សនៈសត្យានុម័តនោះទេ ដែលទស្សនៈនេះគឺជាទស្សនៈដែលទទួលយកដោយលក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលយោងតាមលក្ខន្តិកៈនេះ បទល្មើសដែលមិនអាចកើតឡើងគឺមិនមែនជាបទល្មើសឡើយ ពីព្រោះគ្មានបទល្មើសតាមច្បាប់ចែង បើទុកជាក្នុងទម្រង់ជាការគំរាមកំហែងដល់ផលប្រយោជន៍ដែលត្រូវបានការពារ ក៏មិនមែនជាបទល្មើសដែរ ។

លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើនិយតកម្មទៅលើការចូលរួមរបស់មនុស្សទាំងអស់នៅក្នុងបទល្មើសអន្តរជាតិបានសម្រេចនិងទើបចាប់ផ្តើម (មាត្រា៣៥-៣) ដែលក៏ត្រូវយកមកពិចារណាគិតគូរនៅក្នុងលក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដាដែរ ។ ទាក់ទងដល់ចំណុចនេះ លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានច្រានចោលនូវទស្សនៈស្មុគស្មាញនៃការទទួលខុសត្រូវដាច់ដោយឡែកពីគ្នា ទាក់ទងនឹងប្រភេទនៃការប៉ងទុកជាមុនរបស់អ្នកចូលរួមមាន (ដូចជាចារីនៃបទល្មើស អ្នកសមគំនិតជាដើម) ។ ការរិះគន់ទៅលើគំនិតនេះមានលក្ខណៈសុសសាយណាស់ ជាពិសេសការរិះគន់ទាក់ទងនឹងអសមត្ថភាពក្នុងការចង្អុលចំៗនូវកម្រិតនៃការទទួលខុសត្រូវរបស់អ្នកចូលរួមប្រព្រឹត្តបទល្មើសជាបុគ្គលនៅក្នុងសកម្មភាពល្មើសច្បាប់ ដោយឈរលើមូលដ្ឋាននៃប្រភេទនៃការចូលរួមប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទាំងអស់ដែលមានលក្ខណៈអរូបនិងជាអាទិការណ៍ (ដូចជាថាចារីប្រព្រឹត្តបទល្មើសអាចមានពិរុទ្ធិតជាងចៅហ្វាយនាយរបស់ខ្លួន) ។ លក្ខន្តិកៈច្បាប់នេះទទួលយកនូវគោលការណ៍មានលក្ខណៈងាយជាង ស្តីអំពីការទទួលខុសត្រូវស្មើគ្នាសម្រាប់អ្នកចូលរួមប្រព្រឹត្តបទល្មើស ដែលគោលការណ៍នេះមានចែងរួចជាស្រេចនៅក្នុងលក្ខន្តិកៈច្បាប់របស់តុលាការនៅនូរិមប៊ឺកនិងតូក្យូ និងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដា ។ យោងតាមគោលការណ៍នេះ អ្នកចូលរួមមានការទទួលខុសត្រូវដោយហេតុថា បុគ្គលនោះបានរួមចំណែកឬជួយជ្រោមជ្រែងនៅក្នុងការប្រព្រឹត្តិបទល្មើស ។ ច្បាប់តុលាការអន្តរជាតិផ្តល់អំណាចដល់ចៅក្រមក្នុងការវាយតម្លៃនូវកម្រិតពិតប្រាកដនៃការទទួលខុសត្រូវរបស់អ្នកចូលរួមម្នាក់ៗនៅក្នុងករណីនីមួយៗ ។ ទោះជាយ៉ាងណាក៏ដោយ លក្ខន្តិកៈច្បាប់នេះមិនរួចផុតពីឥទ្ធិពលពីទស្សនៈនៃការទទួលខុសត្រូវដាច់ដោយឡែកពីគ្នា និងភាពចាំបាច់ក្នុងការបែកឲ្យដាច់ពីគ្នានូវប្រភេទបទល្មើសព្រហ្មទណ្ឌឡើយ ។ ហេតុដូចនេះ ជាជាងការគ្រាន់តែកម្រិតនិយមន័យនៃការចូលរួមក្នុងការប្រព្រឹត្តិបទល្មើស ទោះជាតាមរយៈការបង្កឲ្យមាន (ឬជួយសម្រួលឲ្យមានបទល្មើសក៏ដោយ) លក្ខន្តិកៈច្បាប់មានចែងជាក់លាក់អំពីទម្រង់នៃការចូលរួមក្នុងនោះរួមមានសហការប្រព្រឹត្ត ការបញ្ជា រិះរកវិធី អន្ទោកអន្ទងសម្រួល ជ្រោមជ្រែង ឲ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ល។ ជាងនេះទៅទៀត លក្ខន្តិកៈច្បាប់នេះចែងអំពីអវសានបញ្ញត្តិត្រង់មាត្រា៥៣(៣-ឃ) ដែលចាត់ទុកការចូលរួមផ្សេងៗទៀតក្នុងការប្រព្រឹត្តិ ឬប៉ុនប៉ងប្រព្រឹត្ត ថាជាបទល្មើសត្រូវទទួលទណ្ឌកម្មដែរ ។ បទបញ្ញត្តិនេះចាត់ទុកថាមានលក្ខណៈជ្រុលហួសហេតុឥតប្រយោជន៍ ពីព្រោះថាវាពិបាកនឹងនឹកគិតដល់សម្មតិកម្មដទៃទៀតដែលមិនបានចូលទៅក្នុងបទល្មើសដ៏ទូលំទូលាយដូចមានរៀបរាប់ខាងដើម ។ គេក៏អាចចាត់ទុកថាជាការចាំបាច់និងមិនស៊ីគ្នា ពីព្រោះថាវាធ្វើឲ្យខកខានដល់ការប្រឹងប្រែងក្នុងការប្រមូលផ្តុំធ្វើជាតារាងមួយទូលំទូលាយ ហើយចុងក្រោយផ្តល់នូវការរាយឈ្មោះបទល្មើសដូចដែលលើកមកនិយាយខាងលើដែលគ្រាន់តែជាការលម្អតែប៉ុណ្ណោះ ។

ដូចជាអនុសញ្ញាស្តីអំពីការទប់ស្កាត់និងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ និងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដា លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនេះរិះរកមធ្យោបាយក្នុងការអនុវត្តន៍ឲ្យមានប្រសិទ្ធភាពនូវការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដោយចែងអំពីការផ្តន្ទាទោសដល់ការញុះញង់ដោយផ្ទាល់និងជាសាធារណៈឲ្យមានការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ បើទុកជាអំពើប្រល័យពូជសាសន៍មិនទាន់ត្រូវបានប្រព្រឹត្តជាក់ស្តែង ឬមិនទាន់ត្រូវគេប៉ុនប៉ងប្រព្រឹត្តក៏ដោយ ។

### ៧) មូលដ្ឋានសម្រាប់ច្រានចោលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

បញ្ហាទីមួយដែលទាក់ទងនឹងការការពារឲ្យរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌគឺថា តើមូលដ្ឋាននៃការបដិសេធការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌត្រូវបានលើកកម្ពស់រួចជាស្រេចនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទោះជាគោលការណ៍ទូទៅនៃច្បាប់ចេញពីប្រព័ន្ធច្បាប់អន្តរជាតិ ឬដោយសារមូលដ្ឋានទាំងនេះត្រូវបានបញ្ជាក់នៅក្នុងនិយមន័យនៃបទល្មើសព្រហ្មទណ្ឌក្តី ។ ឧទាហរណ៍គ្រប់សិទ្ធិបុគ្គលនិងសិទ្ធិជាវត្ថុនិយាយអំពីអំណាចច្បាប់នៃការការពារធម្មានុរូប ពីព្រោះថាគ្មានបទបញ្ញត្តាមផ្លូវច្បាប់អាចទទួលស្គាល់សិទ្ធិទាំងនោះ ហើយមិនកម្រិតដល់ប្រតិកម្មរបស់ម្ចាស់នៃសិទ្ធិនោះ សំដៅការពារសិទ្ធិទាំងនោះនៅពេលដែលភាគីផ្សេងទៀតប៉ុនប៉ងរំលោភសិទ្ធិនោះឡើយ ។ ដើម្បីវែកញែកអំពីបញ្ហានេះ លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងអំពីការការពារបីយ៉ាងសម្រាប់បដិសេធនូវការទទួលខុសត្រូវ ដែលការការពារទាំងបីយ៉ាងនេះមានផលប្រយោជន៍ជាក់ច្បាស់ដល់ច្បាប់អន្តរជាតិ ។ ការដោះសាផ្សេងទៀត ដូចជាការយល់ព្រមត្រូវបានទាត់ចោល ពីព្រោះបទដ្ឋានទាំងនោះដែលលុបចោលបទល្មើសអន្តរជាតិ ដោយសារនិយមន័យនោះអាចធ្វើឲ្យធ្វើការដោះសានោះមិនមានការពាក់ព័ន្ធ ។ តាមការពិត បទដ្ឋានទាំងនេះមានបំណងចង់ហាមប្រាមនូវអ្វីដែលហៅថាឧក្រិដ្ឋភាពធំ ។ លើសពីនេះទៀត ទ្រព្យសម្បត្តិនិងផលប្រយោជន៍តាមផ្លូវច្បាប់ដែលការពារដោយបទដ្ឋានបែបនេះមិនអាចត្រូវគេលះបង់ចោលឡើយ ។ ការការពារក្តីបីយ៉ាងដែលមានចែងនៅក្នុងលក្ខន្តិកៈច្បាប់ មានដូចខាងក្រោម÷

១) ការការពារធម្មានុរូប រួមមានការការពារបុគ្គលផ្សេងទៀត (មាត្រា៣១-១គ) ។

២) ភាពចាំបាច់ឬការបង្ខិតបង្ខំនៅពេលដែលការប្រព្រឹត្តិនោះត្រូវបានសម្តែងចេញក្រោមការគំរាមកំហែងដល់អាយុជីវិត ឬការធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់រាងកាយចំពោះបុគ្គលនោះ ឬបុគ្គលម្នាក់ទៀត (មាត្រា៣១-១ឃ) ។

ការការពារតាមផ្លូវច្បាប់ទាំងពីរនេះយកចេញមកអំពីច្បាប់ព្រហ្មទណ្ឌជាតិ ប៉ុន្តែការមានកម្រិតច្រើនណាស់ចំពោះការអនុវត្តវិធីទាំងបីនេះ ។ ឧទាហរណ៍នៅក្នុងករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងប្រឆាំងមនុស្សជាតិ ការការពារធម្មានុរូប (រួមទាំងការការពារអ្នកដទៃផង) អាចមិនមានហេតុផលត្រឹមត្រូវជាមួយនឹងបទល្មើសដោយសារខ្វះនូវភាពសមាមាត្រឬតុល្យភាពរវាងផលប្រយោជន៍ដែលការពារ ។ ចំពោះការបង្ខិតបង្ខំឬភាពចាំបាច់ក៏មិនត្រឹមត្រូវដែរ ពីព្រោះអាចថាវាមិនមែនជាការគំរាមកំហែងដល់ជីវិតនិងអវយវៈរបស់អ្នកដទៃ ឬពីស្ថានភាពជាក់ស្តែងដែលបណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ដូចនេះ យុត្តិកម្មទាំងនេះជំនួសឲ្យនិងស្ទើរតែកំណត់ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ប្រសិនបើយុត្តិកម្មទាំងនេះត្រូវបានធ្វើឡើងជាប្រតិកម្មក្នុងលក្ខណៈការពារខ្លួនប្រឆាំងនឹងការវាយប្រហារមិនយុត្តិធម៌ (ប៉ុន្តែបើទោះជាមានការពិបាកបង្ហាញថាវាមានលក្ខណៈអយុត្តិធម៌និងការវាយប្រហារហៀបនឹងកើតឡើងក៏ដោយ) ។

៣) បញ្ជាពីចៅហ្វាយនាយរបស់រដ្ឋាភិបាល ឬមកពីអាជ្ញាធរយោធាឬស៊ីវិលដែលជាអ្នកចេញបញ្ជា ។ យើងដឹងជាទូទៅហើយថា បទបញ្ជាពីចៅហ្វាយនាយអាចជាមូលដ្ឋានសម្រាប់បដិសេធនូវការទទួលខុសត្រូវព្រហ្មទណ្ឌ វៀរលែងតែបទបញ្ជានោះជាក់ស្តែងមានលក្ខណៈអនីត្យានុកូល ហើយផ្ទុយមកវិញបទបញ្ជាពីថ្នាក់លើអាចមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់បដិសេធចោលនូវការទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ ដោយយោលទៅលើភាពធ្ងន់ធ្ងរនៃបទល្មើសអន្តរជាតិ ទោះជាបទបញ្ជាបែបនេះអាចត្រូវបានចាត់ទុកជាធាតុសម្រាលទោសក៏ដោយ (វិធីនេះត្រូវបានចែងនៅក្នុងលក្ខន្តិកៈតុលាការនៅនូរិមប៊ឺកនិងតូក្យូ ព្រមទាំងតុលាការនៅអតីតយូហ្គោស្លាវីនិងរ៉្វាន់ដា) ។ លក្ខន្តិកៈច្បាប់តុលាការអន្តរជាតិប្រកាស (ត្រង់មាត្រា៣៣-១) គោលការណ៍ដែលថា បទបញ្ជារបស់ចៅហ្វាយនាយត្រូវសម្រាលដល់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ ។ គោលការណ៍នេះមិនទាំងចាត់ទុកចៅហ្វាយនាយជាស្ថានសម្រាលទោសផង ។ ព្រមជាមួយគ្នានេះដែរ លក្ខន្តិកៈច្បាប់ត្រង់មាត្រា៣៣(១) បានចែងអញ្ញត្រកម្មមួយចំនួន ដោយធ្វើឲ្យបទបញ្ជាចៅហ្វាយនាយមានលក្ខណៈជាការការពារអាចទទួលយកបាន ពេលដែលបុគ្គលនោះមានភារកិច្ចត្រូវតែអនុវត្ត

តាមបញ្ជានោះ មិនដឹងថាបទបញ្ជានោះមិនស្របច្បាប់ ហើយបទបញ្ជានោះទៀតសោតមិនស្របច្បាប់ខ្លួនឯងផ្ទាល់ទៀតផង ។ លក្ខន្តិកៈច្បាប់ចែងនៅត្រង់មាត្រា៣៣(២) អំពីការសន្មតតាមផ្លូវច្បាប់ថា បទបញ្ជាឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តែងតែមានលក្ខណៈខុសច្បាប់ទៅហើយ ។

## ៨) ទោសបញ្ញត្តិ

បញ្ហាគោរពគោលការណ៍ «គ្មានបទល្មើសបើគ្មានច្បាប់ចែង គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង» មានលក្ខណៈពីរយ៉ាង ។ ទីមួយ គោលការណ៍នេះត្រូវបានគោរពយ៉ាងម៉ត់ចត់នៅក្នុង «ប្រព័ន្ធអនុវត្តច្បាប់ប្រយោល» ដូចដែលបានរៀបរាប់ខាងដើម ដែលតាមរយៈប្រព័ន្ធនេះការកាត់សេចក្តីធ្វើឡើងដោយរដ្ឋ ។ ក្រោមប្រព័ន្ធនេះ រដ្ឋនីមួយៗសម្រេចទៅតាមច្បាប់ឬច្បាប់យុត្តិសាស្ត្ររបស់ខ្លួនទៅលើទោសបញ្ញត្តិសម្រាប់បទល្មើសក្នុងថ្នាក់នីមួយៗ ។ ប្រការនេះមានចែងនៅក្នុងបទបញ្ញត្តិនៃអនុសញ្ញាជាច្រើនស្តីអំពីបទល្មើសអន្តរជាតិដែលនិយាយយោងដល់ច្បាប់ជាតិនិងទោសបញ្ញត្តិពាក់ព័ន្ធ ។ ទីពីរ នៅក្នុង«ប្រព័ន្ធអនុវត្តច្បាប់ផ្ទាល់»នៃនីតិព្រហ្មទណ្ឌអន្តរជាតិដែលបានលើកឡើងពីខាងដើមរួចមកហើយ និងដែលអាស្រ័យលើការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនិងសាលាក្តី គោលការណ៍«គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង» គឺស្ថិតនៅក្នុងលក្ខណៈប្រថុយប្រថាន ។ សហគមន៍អន្តរជាតិនៅតែមិនអាចមានលទ្ធភាពក្នុងការរកឲ្យឃើញនូវដំណោះស្រាយគួរជាទីគាប់ចិត្តចំពោះបញ្ហាដ៏ពិបាកដោះស្រាយនេះ ។

នៅពេលដែលធម្មនុញ្ញនូរិមប៊ឺកនិងតូក្យូគ្រាន់តែចែងថា តុលាការអាចដាក់ទោសប្រហារជីវិតនិងទណ្ឌកម្មដទៃទៀត ដែលគេចាត់ទុកថាមានលក្ខណៈសមស្របនោះ លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងរ៉្វាន់ដាមានបំណងចង់ដោះស្រាយឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតចំពោះគោលការណ៍ «គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង» ។ ទោះបីជាលក្ខន្តិកៈច្បាប់នៃតុលាការទាំងនោះមិនបានភ្ជាប់ទោសបញ្ញត្តិជាក់លាក់ចំពោះបទល្មើសនីមួយៗក៏ដោយ ប៉ុន្តែវាបានចែងអំពីយន្តការរួមនិងដូចៗគ្នា ដែលចៅក្រមគួរតែប្រើនៅក្នុងការសម្រេចសេចក្តីកំណត់ទោស ពោលគឺអ្នកធ្វើសេចក្តីព្រាងច្បាប់បានប្រមើលរួចហើយទៅលើការអនុវត្តន៍ជាក់ស្តែងទូទៅនៃតុលាការជាតិទាក់ទងនឹងការកំណត់ទោសឲ្យជាប់ពន្ធនាគារចំពោះបទឧក្រិដ្ឋអន្តរជាតិ ។ ជាងនេះទៅទៀត ទោសប្រហារជីវិតត្រូវបានលុបចោលយ៉ាងជាក់ច្បាស់ ។ ប៉ុន្តែដំណោះស្រាយនេះនៅតែមិនគួរជាទីពេញចិត្ត ពីព្រោះតុលាការអន្តរជាតិត្រូវបានបង្គាប់ឲ្យយោងដល់ប្រព័ន្ធច្បាប់ជាតិដែលមិនចាំបាច់ផ្ទុកនូវបទបញ្ញត្តិទាក់ទងនឹងបទល្មើសអន្តរជាតិឡើយ ។

ការអនុម័តនូវលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនាំមកនូវការវិវត្តន៍ថែមទៀត ទាក់ទងនឹង «គោលការណ៍គ្មានការផ្តន្ទាទោសបើគ្មានច្បាប់ចែង» ។ លក្ខន្តិកៈច្បាប់នេះមិនបានភ្ជាប់មកជាមួយនូវទោសទណ្ឌជាក់លាក់របស់បទល្មើសនីមួយៗឡើយ (ការកំណត់ការកាត់ទោសត្រូវបានច្រានចោលរួចទៅហើយ) ។ យ៉ាងណាក៏ដោយ ប្រព័ន្ធដាក់ទណ្ឌកម្មដែលមានការវិវត្តន៍ទៅមុខ ត្រូវបានប្រមើលរួចជាស្រេច ។ ទីមួយ ការដាក់ពន្ធនាគារមួយជីវិតអាចធ្វើទៅបាននៅពេលដែលឃើញថាមានយុត្តិកម្មជាមួយនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនិងស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ ។ ទីពីរ ចៅក្រមអាចកំណត់ទោសជាប់ពន្ធនាគារ ប៉ុន្តែមិនឲ្យលើសពី៣០ឆ្នាំ ។ ទីបី ចៅក្រមក៏អាចដាក់ពិន័យ ។ ទីបួន តុលាការអាចរឹបអូស «ផលចំណេញ ទ្រព្យសម្បត្តិ និងទ្រព្យសកម្មបានមកដោយផ្ទាល់ឬដោយប្រយោលពីបទឧក្រិដ្ឋ» (មាត្រា៧៧-២-ខ) ។ ទីប្រាំ លក្ខន្តិកៈច្បាប់ផ្តល់នូវលក្ខខណ្ឌកំណត់ដែលចៅក្រមគួរតែប្រើនៅក្នុងការសម្រេចចិត្តរបស់ខ្លួនទៅលើទណ្ឌកម្ម ជាពិសេស «ទម្ងន់នៃបទឧក្រិដ្ឋ» និង «ស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ» (មាត្រា៧៨) ។ ទីប្រាំមួយ តុលាការអាចបន្ថយពេលជាប់ពន្ធនាគារចំពោះបទឧក្រិដ្ឋដូចគ្នា ។ ទីប្រាំពីរ ប្រសិនបើបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់លើសពីមួយករណី តុលាការត្រូវប្រកាសការសម្រេចសេចក្តីចំពោះបទល្មើសនីមួយៗ ហើយសាលក្រមរួមគ្នាដែលបញ្ជាក់អំពីរយៈពេលសរុបជាប់ពន្ធនាគារ ដែលមិនត្រូវឲ្យតិចជាងការកាត់ឲ្យជាប់ទោសជាបុគ្គលខ្ពស់បំផុត ហើយក៏មិនឲ្យលើសពីកម្រិត

អតិបរមានៃទោសជាប់ពន្ធនាគារ (៣០ឆ្នាំ) ដែរ វៀរលែងតែការកាត់ឲ្យជាប់ទោសនោះជាការជាប់ពន្ធនាគារអស់មួយជីវិត (មាត្រា៧៨) ។ ចំណុចចុងក្រោយគឺលក្ខន្តិកៈច្បាប់នេះផ្តល់អំណាចដល់តុលាការក្នុងការសម្រេចទៅលើការសម្រាលទោសក្រោយពីទណ្ឌិតជាប់ពន្ធនាគារមួយផ្នែកនៃរយៈពេលសរុបរួចហើយ និងបានឆ្លើយតបទៅនឹងតម្រូវការដាក់លាក់មួយចំនួនជាមុនសិន (មាត្រា១១០) ។

**៩) ការជ្រៀតចូលរបស់នីតិព្រហ្មទណ្ឌអន្តរជាតិទៅក្នុងនីតិព្រហ្មទណ្ឌជាតិ និងបញ្ច្រាសមកវិញ**

ទំនាក់ទំនងទៅវិញទៅមករវាងនីតិព្រហ្មទណ្ឌអន្តរជាតិនិងនីតិព្រហ្មទណ្ឌជាតិចេញជារូបរាងកាន់តែច្រើនឡើងៗ ។ ម្យ៉ាងនីតិព្រហ្មទណ្ឌអន្តរជាតិកំពុងតែត្រូវបាន «ធ្វើឲ្យមានលក្ខណៈជាតិ» តាមរយៈការធ្វើសមាហរណកម្មគោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌដែលមានលក្ខណៈស្របគ្នាទៅនឹងប្រព័ន្ធច្បាប់សំខាន់ៗក្នុងពិភពលោកចូលទៅក្នុងច្បាប់អន្តរជាតិ ជាពិសេសក្នុងន័យ «ផ្នែកទូទៅ»នៃនីតិព្រហ្មទណ្ឌអន្តរជាតិ ។ ម្យ៉ាងវិញទៀត ប្រភេទច្បាប់ព្រហ្មទណ្ឌជាតិដែល «ធ្វើឲ្យទៅជាលក្ខណៈអន្តរជាតិ» កំពុងតែចេញរូបរាងឡើង ខណៈដែលច្បាប់ទម្លាប់អន្តរជាតិនិងនីតិអន្តរជាតិសាមញ្ញកំពុងត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិ ។ ទិដ្ឋភាពនេះមិនបញ្ចូល «ផ្នែកទូទៅ» នៃច្បាប់ព្រហ្មទណ្ឌទេ ពីព្រោះជាធម្មតា សន្ធិសញ្ញាច្បាប់ព្រហ្មទណ្ឌអន្តរជាតិនិងសន្ធិសញ្ញាច្បាប់ទម្លាប់អន្តរជាតិមិនបាននិយាយអំពី «ផ្នែកទូទៅ» ឡើយ ។ ក្នុងន័យនេះ សន្ធិសញ្ញានិងច្បាប់ទម្លាប់ទាំងនេះគ្រាន់តែនិយាយដល់ច្បាប់ជាតិប៉ុណ្ណោះទាក់ទងនឹងនិយតកម្មនៃ«ផ្នែក»នោះ ។ តាមការពិត ជាទូទៅ បទបញ្ញត្តិអន្តរជាតិធ្វើឲ្យនិយតកម្មនៃទិដ្ឋភាពទាំងអស់ដែលភ្ជាប់ទៅនឹងផ្នែកទូទៅនៃច្បាប់ព្រហ្មទណ្ឌ ទៅជានិយតកម្មសាមញ្ញនៃប្រព័ន្ធច្បាប់ជាតិនីមួយៗ ។ ផ្ទុយមកវិញ ការជ្រៀតចូលរបស់នីតិអន្តរជាតិទៅក្នុងប្រព័ន្ធច្បាប់ជាតិ មានលក្ខណៈប្រត្យក្សទាក់ទងនឹងទិដ្ឋភាពមួយចំនួននៃ «ផ្នែកពិសេស» ជាពិសេសទាក់ទងនឹងបទបញ្ញត្តិនានាដែលចែងអំពីនិយមន័យឲ្យក្រិដ្ឋកម្មអន្តរជាតិ ។ ដូចនេះច្បាប់អន្តរជាតិបានបញ្ចូលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ភេរវកម្មអន្តរជាតិ អំពើទាសភាព ។ល ។ ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិ ។

លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបង្កឲ្យមានបញ្ហាមួយចំនួនទាក់ទងនឹងការជ្រៀតចូលនៃនីតិអន្តរជាតិចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិ ។ ទីមួយ គួរតែកត់សម្គាល់ថា យុត្តាធិការរបស់តុលាការនេះមានលក្ខណៈបំពេញបន្ថែមទៅនឹងតុលាការជាតិ ។ ក្នុងករណីនេះ យុត្តាធិការនេះត្រូវបានអនុវត្តនៅក្នុងករណីដែលតុលាការជាតិគ្មានឆន្ទៈ ឬគ្មានលទ្ធភាពបំពេញតួនាទីរបស់ខ្លួន ។ ទីពីរ តុលាការជាតិមានអាទិភាពក្នុងការអនុវត្តន៍យុត្តាធិការតាមតែច្បាប់ក្នុងស្រុករបស់ខ្លួនបានចែងអំពីបទល្មើសនៅក្នុងលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ច្បាប់ជាតិក៏ត្រូវចែងអំពីបទឧក្រិដ្ឋក្រោមលក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាទោសបញ្ញត្តិនានាសម្រាប់បទឧក្រិដ្ឋទាំងនោះ ដើម្បីលើកតម្កើងគោលការណ៍ «គ្មានបទល្មើសបើគ្មានច្បាប់ចែង គ្មានទណ្ឌកម្មបើគ្មានច្បាប់ចែង» ។ ការទទួលយករបស់ប្រព័ន្ធច្បាប់ជាតិនូវបទបញ្ញត្តិ ជាក់លាក់ស្តីអំពីបទឧក្រិដ្ឋអន្តរជាតិគឺជាកាតព្វកិច្ចជាក់លាក់របស់រដ្ឋជាភាគីជាកាតព្វកិច្ចដែលមានមុនកាតព្វកិច្ចទូទៅរបស់ខ្លួនទៅទៀត ក្នុងការសហការជាមួយតុលាការនោះ ។

**ហ៊ីរ៉ាន់ជូ មែនតូវ៉ានី**

## ពាក្យស្លោកខ្មែរក្រហម

◆ **ប្រយុទ្ធពុំបានជ័យជំនះ ប្រយុទ្ធជាថ្មីពុំបានជ័យជំនះទៀតប្រយុទ្ធហើយប្រយុទ្ធទៀតដល់ទីបំផុតសម្រេចជោគជ័យប្រាកដនេះជាដំណើរសមហេតុសមផលរបស់ប្រជាជន ប្រជាជនក៏មិនអាចចៀសវាងដំណើរសមហេតុសមផលនេះដែរ នេះជាច្បាប់មួយនៃម៉ាក្សស៊ីសនិយម បដិវត្តន៍របស់ប្រជាជនមិនបានសម្រេចបានសម្រេចឡើងតាមគម្រោងច្បាប់ បដិវត្តន៍របស់ប្រជាជនខ្មែរក៏បានសម្រេចឡើងតាមគម្រោងច្បាប់នេះដែរ។**

*(កំណត់ហេតុរបស់សមមិត្ត ញ៉ុក សារិន)*





វិចិត្រករៈ ប៊ូ ម៉េង អតីតអ្នកទោសមន្ទីរ ស-២១

# តុលាការប្រជាជននៅប្រទេសរ៉្វាន់ដា


អៀ ម៉េងទ្រី

***កំណត់របស់អ្នកនិពន្ធៈ*** *អត្ថបទនេះគឺជាផ្នែកមួយនៃអត្ថបទសិក្សារបស់ខ្ញុំអំពីតួនាទីយុត្តិធម៌នៅក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា ។ ខ្ញុំសរសេរអត្ថបទសិក្សានេះនៅសាកលវិទ្យាល័យខូវិនទ្រី ប្រទេសអង់គ្លេសក្នុងឆ្នាំ២០០៣ ។ អត្ថបទសិក្សារបស់ខ្ញុំចែកចេញជាបួនផ្នែក ។ ផ្នែកទីមួយបង្ហាញអំពីតួនាទីរបស់យុត្តិធម៌ក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួម ។ ផ្នែកទីពីរវិភាគចំណុចខ្លាំងនិងចំណុចខ្សោយរបស់យុត្តិធម៌ដែលផ្តល់ឲ្យដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងប្រព័ន្ធតុលាការប្រជាជនរ៉្វាន់ដាហៅថាកាឆាឆា ។ ផ្នែកទីបី ក្រឡេកមើលអំពីទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះតួនាទីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ផ្នែកទីបួន ខ្ញុំផ្តល់ការពិភាក្សាអំពីលទ្ធភាពនៃការបង្កើតគណៈកម្មការស្វែងរកការពិតនៅប្រទេសកម្ពុជាដើម្បីជាជំនួយដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ផ្នែកដែលផ្សាយជូនលោកអ្នកអាននៅពេលនេះគឺជាផ្នែកទីពីរ ។*

តុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសរ៉្វាន់ដាបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ប៉ុន្តែតុលាការនេះពុំបានផ្តល់នូវការពិតនិងផ្សះផ្សាបង្រួបបង្រួមជាតិសម្រាប់ប្រទេសរ៉្វាន់ដាឡើយ ។ គណៈកម្មការស្វែងរកការពិតសម្រាប់ប្រទេសអាហ្វ្រិកខាងត្បូងមិនបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ហើយមានមតិខុសៗគ្នាជាច្រើនអំពីតួនាទីរបស់គណៈកម្មការនេះក្នុងដំណើរការបង្រួបបង្រួមជាតិនៅអាហ្វ្រិកខាងត្បូង ។

ប្រព័ន្ធតុលាការប្រជាជននៅប្រទេសរ៉្វាន់ដាហៅថា កាឆាឆា មានលក្ខណៈប្រសើរជាងគេដោយសារ ទីមួយ ប្រព័ន្ធកាឆាឆាបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ទីពីរផ្តល់ការពិត និងទីបីអាចជំរុញឲ្យប្រជាជនដែលមិនចេះអានកាសែតឬគ្មានវិទ្យុស្តាប់ធ្វើការបង្រួបបង្រួមគ្នាឡើងវិញ ហើយថវិកាជំនួយលើតុលាការកាឆាឆាមានចំនួនតិចជាងថវិកាជំនួយលើតុលាការព្រហ្មទណ្ឌអន្តរជាតិចំនួន ២៥ដង ។

## ១) ប្រវត្តិនៃជម្លោះ

ឆ្នាំ១៩៥៩ ពោលគឺបីឆ្នាំបន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបែលហ្ស៊ិក ជនជាតិហ៊ូទូដែលជាប្រជាជនភាគច្រើនរស់នៅក្នុងប្រទេសរ៉្វាន់ដា បានផ្តួលរំលំរបបគ្រប់គ្រងដោយស្តេចដែលជាជនជាតិទុតស៊ី ។ បន្ទាប់ពីហេតុការណ៍នេះ ជនជាតិទុតស៊ីជាច្រើនពាន់នាក់ត្រូវបានសម្លាប់ជាបន្តបន្ទាប់ ហើយប្រមាណ ១៥ម៉ឺននាក់ផ្សេងទៀតបង្ខំចិត្តរត់ភៀសខ្លួនទៅជ្រកកោននៅប្រទេសជិតខាង ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៦០រហូតដល់ឆ្នាំ១៩៩០ ជនជាតិទុតស៊ីដែលរស់នៅក្នុងប្រទេសជិតខាងបានប្រមូលផ្តុំគ្នាបង្កើតជារណសិរ្សស្នេហាជាតិរ៉្វាន់ដា ហើយវាយលុកជាច្រើនលើកច្រើនសាចូលប្រទេសរ៉្វាន់ដា ដើម្បីដណ្តើមអំណាចដែលកាន់កាប់ដោយរដ្ឋអំណាចសញ្ជាតិហ៊ូទូ ។

ប្រធានាធិបតី កាយីបាន់ដា ត្រូវលោកឧត្តមសេនីយ៍ជាតិហ៊ូទូធ្វើរដ្ឋប្រហារទម្លាក់និងដណ្តើមអំណាចនៅឆ្នាំ១៩៧៣ ។ បន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារ កាយីបាន់ដា និងអ្នកគាំទ្រជាតិទុតស៊ីជាច្រើននាក់ត្រូវបានចាប់ខ្លួននិងសម្លាប់ ។ នៅរវាងខែកញ្ញានិងខែតុលាឆ្នាំ១៩៩០ កម្លាំងរណសិរ្សស្នេហាជាតិរ៉្វាន់ដាប្រមាណពី៥ពាន់ទៅ១ម៉ឺននាក់បានលុកលុយចូលប្រទេសរ៉្វាន់ដាពីព្រំដែនប្រទេសអ៊ូហ្កាន់ដា ។ ឆ្លើយតបចំពោះការវាយប្រហារនេះ រដ្ឋា-

ភិបាលរ៉្វាន់ដាដែលដឹកនាំដោយប្រធានាធិបតី ហាប់យ៉ារី ម៉ាណា បានចាប់ខ្លួននិងឃុំឃាំងជនគាំទ្រចលនារណសិរ្សប្រមាណមួយម៉ឺននាក់ ។ សង្គ្រាមរវាងរណសិរ្សស្នេហាជាតិរ៉្វាន់ដានិងរដ្ឋាភិបាលរ៉្វាន់ដាបានអូសបន្លាយរហូតដល់ឆ្នាំ១៩៩២ និងបានសម្លាប់ជីវិតមនុស្សអស់ជាច្រើនពាន់នាក់ ។ ក្នុងអំឡុងពេលសង្គ្រាម ហាប់យ៉ារី ម៉ាណា បានសុំឲ្យរដ្ឋាភិបាលប្រទេសបែលហ្ស៊ិកនិងបារាំងជួយធ្វើអន្តរាគមន៍ផ្ដួចផ្ដើមការចរចានិងបទឈប់បាញ់គ្នារវាងរដ្ឋាភិបាលនិងក្រុមរណសិរ្សនៅចុងឆ្នាំ១៩៩០ ។ នៅខណៈនោះ ចំណុចសំខាន់និងចម្រូងចម្រាសនៅក្នុងការចរចាគឺអំពីជោគវាសនានៃជនភៀសខ្លួនទុតស៊ីនៅក្រៅប្រទេស ។ ក្រុមរណសិរ្សទាមទារឲ្យរដ្ឋាភិបាលទទួលយកនិងប្រគល់ដីធ្លីឲ្យជនភៀសខ្លួន ប៉ុន្ដែរដ្ឋា-ភិបាលរ៉្វាន់ដាបានបដិសេធដោយហេតុផលថាគ្មានដីទំនេរសម្រាប់ជនភៀសខ្លួនទាំងនោះ ។ ការចរចាបានអូសបន្លាយ ហើយនៅទីបំផុតរដ្ឋាភិបាលយល់ព្រមទទួលយកការទាមទាររបស់រណសិរ្ស ។ កិច្ចព្រមព្រៀងឈប់បាញ់គ្នាត្រូវបានចុះហត្ថលេខាម្ដងទៀតនៅពាក់កណ្ដាលឆ្នាំ១៩៩២ ហើយជំរុញឲ្យមានកិច្ចព្រមព្រៀងសន្ដិភាពទីក្រុងអារ៉ូហ្សា ប្រទេសតង់ហ្សានី នៅក្នុងខែសីហា ឆ្នាំ១៩៩៣ ។

ក្រោមកិច្ចព្រមព្រៀងសន្ដិភាពទីក្រុងអារ៉ូហ្សា ឆ្នាំ១៩៩៣ ប្រធានាធិបតី ហាប់យ៉ារី ម៉ាណា ត្រូវបន្ដកាន់កាប់អំណាច ។ ពិធីបន្ដអំណាចជាផ្លូវការត្រូវបានប្រារព្ធឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៩៤ ប៉ុន្ដែសភាជាតិនិងគណៈរដ្ឋមន្ដ្រីសម្រាប់សម័យអន្ដរកាលត្រូវជាប់ផុងនិងដោះស្រាយមិនចេញ ។ បាតុកម្មទាមទារឲ្យរដ្ឋាភិបាលនិងក្រុមរណសិរ្សស្វែងរកដំណោះស្រាយទម្លាយភាពទាល់ច្រក បានកើតឡើងជាបន្ដបន្ទាប់ ។ ព្រមជាមួយគ្នានេះ ការចាប់ខ្លួនជនប្រឆាំង ការបំភិតបំភ័យផ្នែកនយោបាយ និងការរំលោភបំពានលើប្រជាជន ក៏បានកើតឡើងដែរ ។

នៅរវាងខែមករានិងខែមេសា ឆ្នាំ១៩៩៤ អសន្ដិសុខកើតឡើងនៅទូទាំងប្រទេស ។ ពេលនោះប្រធានាធិបតី ហាប់យ៉ារី ម៉ាណា ត្រូវស្ថិតនៅក្រោមសម្ពាធរបស់ប្រជាជន ក៏ដូចជាប្រទេសក្នុងតំបន់និងសហគមន៍អន្ដរជាតិ ឲ្យដោះស្រាយភាពទាល់ច្រក ហើយអនុវត្តកិច្ចព្រមព្រៀងទីក្រុងអារ៉ូហ្សា ។ ទីបំផុតប្រធានាធិបតី ហាប់យ៉ារី ម៉ាណា បានសម្រេចចិត្តជួបប្រជុំជាមួយមេដឹកនាំក្នុងតំបន់នៅទីក្រុងអារ៉ូហ្សា ។ បន្ទាប់ពីកិច្ចប្រជុំ ប្រធានាធិបតី ហាប់យ៉ារី ម៉ាណា បានធ្វើដំណើរតាមយន្ដហោះពិសេសរបស់ខ្លួនវិលត្រឡប់មកទីក្រុង គីកាលី ប្រទេសរ៉្វាន់ដាវិញ ។ យន្ដហោះរបស់គាត់ត្រូវគ្រាប់រ៉ុក្កែតបាញ់ទម្លាក់ក្នុងពេលដែលកំពុងព្យាយាមចុះចតនៅព្រលានយន្ដហោះក្នុងទីក្រុងគីកាលី នៅវេលាម៉ោង៦និង៣០នាទី ។

ព្រមពេលជាមួយហេតុការណ៍នេះ ការសម្លាប់ជនជាតិទុតស៊ីនិងអ្នកនយោបាយប្រឆាំងជនជាតិហ៊ូទូ បានកើតឡើងទូទាំងប្រទេស ។ របាយការណ៍ជាច្រើនពិពណ៌នាអំពីការសម្លាប់នេះថាមានផែនការរៀបចំទុកជាមុន ជាពិសេសផែនការញុះញង់តាមវិទ្យុផ្សាយសំឡេងដែលឃោសនាឲ្យជនជាតិហ៊ូទូមានការរើសអើងនិងកាប់សម្លាប់ជនជាតិទុតស៊ី ។ នៅពេលនោះ ជនដៃដល់ភាគច្រើនគឺជាសមាជិកក្រុមសេនាជនដែលមានឈ្មោះថា អិនធើហាមវេ (ឬអ្នកវាយប្រហាររួមគ្នា) និងក្រុមអិមពូសាមុយហ្គាមបី (ឬអ្នកមានបំណងដូចគ្នា) ។ ក្រុមសេនាជនទាំងពីរនេះបង្កើតឡើងរួមគ្នារវាងគណបក្សកាន់អំណាច MRND និងក្រុមសម្ព័ន្ធភាពដែលហៅកាត់ថា សម្ព័ន្ធដើម្បីការពារសាធារណរដ្ឋ (CDR) និងក្រុមកងការពារប្រធានាធិបតី ។ អំពើប្រល័យពូជសាសន៍បានកើតឡើងទូទាំងប្រទេសរ៉្វាន់ដា ដោយសារទីមួយ គ្មានការទប់ស្កាត់ពីសហគមន៍អន្ដរជាតិ និងទីពីរ ការកាត់បន្ថយចំនួនកងរក្សាសន្ដិសុខអង្គការសហប្រជាជាតិ បន្ទាប់ពីកងរក្សាសន្ដិសុខអង្គការសហ-ប្រជាជាតិមកពីប្រទេសបែលហ្ស៊ិកចំនួន១០នាក់ត្រូវបានសម្លាប់ ។

អំពើកាប់សម្លាប់របស់ក្រុមនិយមជ្រុលនៃរដ្ឋាភិបាលរ៉្វាន់ដាលើជនជាតិភាគតិចទុតស៊ី និងសង្គ្រាមរវាងក្រុមរណសិរ្សទុតស៊ីនិងរដ្ឋាភិបាលរ៉្វាន់ដា ដែលចាប់តាំងពីថ្ងៃទី៦ ខែមេសា រហូតដល់ពាក់កណ្ដាលខែកក្កដា ឆ្នាំ១៩៩៤ បានបង្កឲ្យប្រជាជនប្រមាណ៨សែនទៅមួយលាននាក់ស្លាប់បាត់បង់ជីវិត ។ ប្រជាជនប្រមាណ២លាននាក់ដែលភាគច្រើនជាជនជាតិហ៊ូទូ បានរត់គេចខ្លួនទៅជ្រកកោននៅបណ្ដាប្រទេសជិតខាងដូចជា ប្រទេសកុងហ្គោ ប៊ូរុនឌី

និង គង់ហ្គាឡានី ហើយប្រមាណ១លាននាក់ផ្សេងទៀតត្រូវរស់នៅដោយគ្មានទីជម្រក មានជំងឺផ្លូវចិត្តដោយសារការរំលោភលើផ្លូវភេទនិងការបាត់បង់សមាជិកគ្រួសារ ។

បន្ទាប់ពីសង្គ្រាម ទីក្រុងគីកាលីក្លាយជាទីក្រុងស្ងាត់ជ្រងំ ។ នៅមុនសង្គ្រាម ទីក្រុងនេះមានប្រជាជនរស់នៅប្រមាណ៣សែននាក់ ។ ក្រោយសង្គ្រាម ប្រជាជនដែលរស់នៅទីនោះមានត្រឹមតែ៥ម៉ឺននាក់ប៉ុណ្ណោះ ហើយពាក់កណ្តាលនៃប្រជាជនទាំងនោះរស់នៅដោយគ្មានទីជម្រក ។ សង្គ្រាមបានសម្លាប់កុមារចំនួន៣សែននាក់ បន្សល់ទុកកុមារកំព្រាចំនួន១សែននាក់ និងស្ត្រីមេម៉ាយចំនួន៣សែន៥ម៉ឺននាក់ ។ កុមារដែលនៅរស់ភាគច្រើនគ្មានសង្ឃឹមថាខ្លួនអាចមានជីវិតរស់នៅឡើយ ព្រោះកុមារទាំងនោះសុទ្ធតែធ្លាប់ទទួលរងការធ្វើបាប ។ នៅក្នុងចំណោមកុមារដែលនៅរស់ កុមារចំនួនបីរយនាក់មានអាយុក្រោម១០ឆ្នាំ ហើយជាប់ពាក់ព័ន្ធក្នុងអំពើប្រល័យពូជសាសន៍ ។ ក្រោយសង្គ្រាម ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាល ក្រសួង មន្ទីរ គ្មានដំណើរការ ដោយសារកង្វះខាតសម្ភារដូចជា តុ កៅអី និងសូម្បីតែក្រដាសសម្រាប់បំពេញការងារក៏គ្មានដែរ ។

ដប់ឆ្នាំបន្ទាប់ពីសង្គ្រាម ហេដ្ឋារចនាសម្ព័ន្ធនិងវិស័យផ្សេងៗ ជាពិសេសវិស័យសេដ្ឋកិច្ចជាតិ ត្រូវបានយកចិត្តទុកដាក់និងស្តាបនាឲ្យរស់ឡើងវិញ ។ ប៉ុន្តែដំណើរការស្វែងរកយុត្តិធម៌និងផ្សះផ្សាបង្រួបបង្រួមរវាងជនជាតិហ៊ូទូនិងទុតស៊ីមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ ។

## ២) យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួម

ចាប់តាំងពីឆ្នាំ១៩៩៦រហូតដល់ឆ្នាំ២០០៣ រដ្ឋាភិបាលរ៉ាន់ដានិងសហគមន៍អន្តរជាតិបានបង្កើតយុទ្ធសាស្ត្រសំខាន់ពីរដើម្បីផ្សះផ្សានិងបង្រួបបង្រួមភាគីជម្លោះ ។ យុទ្ធសាស្ត្រទាំងពីរគឺ ១)បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ដើម្បីកាត់ទោសជនឧក្រិដ្ឋប្រល័យពូជសាសន៍ (ICTR) និង ២)បង្កើតប្រព័ន្ធតុលាការប្រជាជន ដែលហៅថា កាឆាឆា ដើម្បីបង្ហាញការពិតអំពីអ្វីដែលបានកើតឡើង និងជំរុញឲ្យប្រជាជនយល់អធ្យាស្រ័យនិងអត់ទោសចំពោះជនដៃដល់ថ្នាក់ក្រោម បន្ទាប់ពីជនដៃដល់ទាំងនោះសារភាពកំហុសរបស់ខ្លួនប្រាប់ការពិត និងសុំអភ័យទោស ។

## ៣) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាអង្គការសហប្រជាជាតិនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ឆ្លើយតបតាមសំណើរបស់រដ្ឋាភិបាលថ្មីនៃប្រទេសរ៉ាន់ដា និងក្រុមស្រាវជ្រាវពិសេសអំពីស្ថានភាពប្រទេសរ៉ាន់ដា ។ តុលាការអន្តរជាតិនេះបង្កើតឡើងដើម្បីកាត់ទោសបុគ្គលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភបំពានច្បាប់អន្តរជាតិ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលកើតឡើងនៅក្នុងប្រទេសរ៉ាន់ដា និងនៅបណ្តាប្រទេសជិតខាង ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ។ បំណងសំខាន់របស់តុលាការនេះគឺលុបបំបាត់ប្រពៃណីលើកលែងទោស និងជំរុញឲ្យមានការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅប្រទេសរ៉ាន់ដា ។ ឯកឧត្តម កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជាក់អំពីសារសំខាន់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដូចខាងក្រោម ៖

*"ខ្ញុំនិងសហគមន៍អន្តរជាតិទាំងមូលសង្ឃឹមថា យុត្តិធម៌ដែលផ្តល់ដោយតុលាការអន្តរជាតិ ពិតជាអាចចូលរួមចំណែកក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅប្រទេសរ៉ាន់ដា ។ ការព្យាបាលសុខភាពផ្លូវចិត្តត្រូវការសន្តិភាព សន្តិភាពត្រូវការយុត្តិធម៌ ហើយយុត្តិធម៌ត្រូវការការគោរពសិទ្ធិមនុស្សនិងច្បាប់ទម្លាប់"* ។

ចាប់តាំងពីថ្ងៃចាប់បដិសន្ធិនៅខែវិច្ឆិកាឆ្នាំ១៩៩៤ តុលាការព្រហ្មទណ្ឌអន្តរជាតិបានចាប់ខ្លួនជនសង្ស័យចំនួន៦៥នាក់ ។ សមាសភាពជនសង្ស័យដែលត្រូវបានចាប់ខ្លួនរួមមានអតីតរដ្ឋមន្ត្រីចំនួន១២រូប និងអតីតមន្ត្រីបម្រើការងារក្នុងក្រសួង មន្ទីរ កងកម្លាំងប្រដាប់អាវុធ អ្នកជំនួញ មេដឹកនាំសាសនា និងអ្នកសារព័ត៌មាន ។

ខាងក្រោមនេះគឺជាចំនួនជនសង្ស័យដែលត្រូវបានចាប់ខ្លួន៖

- ជំនុំជម្រះក្តីរួចនៅអារ៉ូហ្សា ១៨នាក់

- ◆ រង់ចាំការជំនុំជម្រះក្តី ៣១នាក់
- ◆ រង់ចាំការបញ្ជូនខ្លួន ២នាក់
- ◆ បណ្តឹងឧទ្ធរណ៍ ៤នាក់
- ◆ សាលក្រម (ទីក្រុងម៉ាលី) ៦នាក់
- ◆ ដោះលែង ៣នាក់
- ◆ ស្លាប់ ១នាក់
- ◆ សរុប ៦៥នាក់

### ៤) ចំណុចខ្លាំងនិងចំណុចខ្សោយ

យុត្តិធម៌មានសារសំខាន់សម្រាប់គ្រប់ជាតិសាសន៍ ជាពិសេសប្រទេសរ៉ាន់ដាដែលបានទទួលរងគ្រោះដោយអំពើប្រល័យពូជសាសន៍។ យុត្តិធម៌អាចជួយឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយ និងបង្កើតក្តីសង្ឃឹមសម្រាប់ការបង្រួបបង្រួមជាតិ។ ការស្វែងរកយុត្តិធម៌អាចជួយលុបបំបាត់វប្បធម៌លើកលែងទោសកសាងច្បាប់ទម្លាប់និងចៀសវាងការគុំកួន ការសងសឹក និងការកាប់សម្លាប់គ្នាទៅវិញទៅមក។ ការស្វែងរកយុត្តិធម៌ជួយជំរុញឲ្យមានកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ការគោរពសិទ្ធិមនុស្សនិងការកសាងប្រទេសរ៉ាន់ដាឲ្យក្លាយជានីតិរដ្ឋ។ ប្រជាជនរ៉ាន់ដាជាច្រើនមានចិត្តរីករាយ ហើយមានអារម្មណ៍ធូរស្បើយ ទីមួយដោយសារការរងគ្រោះរបស់ខ្លួនត្រូវបានទទួលស្គាល់ និងទីពីរដោយសារមានការស្វែងរកយុត្តិធម៌សម្រាប់ផ្តល់ឲ្យខ្លួន។ លេនណាត អេសពើគ្រិន អតីតចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា រៀបរាប់អំពីអត្ថប្រយោជន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដូចខាងក្រោម ÷

តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាការព្រមានចំពោះឧក្រិដ្ឋជនដែលបានកាប់សម្លាប់និងរំលោភបំពានលើផ្លូវភេទថា អំពើទាំងអស់នោះគឺជាអំពើផ្ទុយពីច្បាប់ ហើយដាច់ខាតត្រូវតែទទួលទោស ទោះបីជាការប្រព្រឹត្តិនោះស្ថិតនៅទីកន្លែងណាក្តី។ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏អាចជួយលើកស្ទួយសន្ធិសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវដែលបានចែងថា ឧក្រិដ្ឋជនទាំងអស់ត្រូវតែទទួលខុសត្រូវ ទាំងបុគ្គលដែលបញ្ជា និងបុគ្គលដែលអនុវត្តតាមបញ្ជា។ ម្នាក់ៗសុទ្ធតែមានចំណែកទទួលខុសត្រូវចំពោះមុខច្បាប់។

អត្ថប្រយោជន៍ផ្សេងទៀតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត។ កាបារ៉ា អាសៀល អភិបាលក្រុងគីបូយេ បញ្ចេញយោបល់ថា ដំណើរការកាត់ទោសឧក្រិដ្ឋជនទទួលខុសត្រូវខ្ពស់បំផុតយ៉ាងហោចណាស់អាចធ្វើឲ្យជនដែលមានបំណងអាក្រក់ឬផែនការសម្លាប់ប្រជាជនគិត សាជាថ្មីថាគួរធ្វើឬមិនគួរធ្វើ។ អាសៀល ពន្យល់ថា "ប្រទេសរ៉ាន់ដាជាប្រទេសដែលតែងមានការកាប់សម្លាប់ ហើយឧក្រិដ្ឋជនតែងតែរួចពីសំណាញ់ច្បាប់។ ការបង្កើតឲ្យមានការកាត់ទោសនៅពេលនេះ ពិតជាអាចលុបបំបាត់វប្បធម៌រួចទោសនៅប្រទេសនេះបាន"។ អ្នកនាំពាក្យប្រចាំតុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ជាក់បន្ថែមថា "ការកាត់ទោសឧក្រិដ្ឋជនប្រល័យពូជសាសន៍ គឺជាការបញ្ជាក់ប្រាប់អ្នកដឹកនាំនៅទូទាំងពិភពលោកក្នុងសតវត្សរ៍ទី២១នេះថា បើមានការប្រព្រឹត្តិខុសគឺត្រូវតែមានការកាត់ទោស"។

ដោយសារអំពើវិនាសកម្មមានទំហំធំធេង ជនជាតិទុតស៊ីមួយចំនួនបានចងកំហឹងចំពោះជនជាតិហ៊ូទូ ហើយចាត់ទុកជនជាតិហ៊ូទូជាសត្រូវស្លាប់រស់របស់ខ្លួន។ ម៉ាហ្គារ៉េត ឡេន ណាយរ៉េននិនកា គឺជាស្ត្រីមេម៉ាយ។ សមាជិកទាំងអស់នៃគ្រួសាររបស់គាត់ត្រូវបានសម្លាប់។ បន្ទាប់ពីការជំនុំជម្រះក្តីឧក្រិដ្ឋជនដែលបានសម្លាប់សមាជិកក្រុមគ្រួសាររបស់គាត់ចប់សព្វគ្រប់ ណាយរ៉េននិនកា រៀបរាប់ថា "ថ្ងៃនេះយើងមានអារម្មណ៍ថាយើងជាមនុស្សជាតិពិតប្រាកដ"។ ស្ត្រីរងគ្រោះដោយអំពើរំលោភម្នាក់ទៀតបញ្ចេញយោបល់នៅក្នុងសវនាការថា "ការពិតមិនមែនជនជាតិហ៊ូទូសុទ្ធតែអាក្រក់និងជាឃាតករនោះទេ"។ ឧទាហរណ៍ខាងលើនេះបញ្ជាក់ថា ការដាក់ទោសរបស់តុលាការចំពោះឧក្រិដ្ឋជនអាចជួយលើកស្ទួយតម្លៃរបស់ជនរងគ្រោះ ហើយក៏អាចបញ្ជាក់អំពីភាពបរិសុទ្ធរបស់ប្រជាជនស្លូតត្រង់ដែរ។

ដំណើរការកាត់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចជួយជំរុញឲ្យមានការផ្សះផ្សាបង្រួបបង្រួមជាតិតាមរយៈការថែរក្សាឯកសារនិងភស្តុតាងសម្រាប់ប្រើប្រាស់ទាំងនៅក្នុង

តុលាការនិងប្រវត្តិសាស្ត្រ ។ លេនណាត អេសពើគ្រិន បញ្ជាក់ថា នៅក្នុងដំណើរការជំនុំជម្រះតែងតែមានការកត់ត្រាអំពីហេតុការណ៍ដែលបានកើតឡើងការរៀបរាប់របស់សាក្សីដែលករណីនីមួយៗមានចាប់ពី៦ពាន់រហូតដល់៨ពាន់ទំព័រ ។ ក្រៅពីឯកសារនិងភស្តុតាងដែលរៀបរាប់ដោយសាក្សី តុលាការនៅមានឯកសារប្រភេទរូបថតនិងកាសែតវីដេអូជាច្រើនទៀត ។ ឯកសារនិងភស្តុតាងទាំងអស់មានតម្លៃធំធេងសម្រាប់ប្រវត្តិសាស្ត្រនិងមនុស្សជាតិទូទៅ ។

ការដាក់ទោសលើឧក្រិដ្ឋជនអាចជួយធ្វើឲ្យអារម្មណ៍ជនរងគ្រោះបានធូរស្បើយមួយកម្រិត ។ ការដាក់ទោសចំពោះការរំលោភសិទ្ធិមនុស្សអាចកសាងច្បាប់ទម្លាប់និងនីតិរដ្ឋ ហើយការកាត់ទោសគឺជារនាំងការពារការរំលោភបំពានពីសំណាក់អ្នកកាន់អំណាចមកលើប្រជាជន ។ ប៉ុន្តែប្រជាជនរ៉្វាន់ដា មួយចំនួនមិនយល់ស្របរាល់អត្ថប្រយោជន៍របស់តុលាការដូចដែលពោលខាងលើឡើយ ។ អ្នកទាំងនោះបដិសេធមិនទទួលស្គាល់តួនាទីនិងអត្ថប្រយោជន៍របស់តុលាការក្នុងដំណើរការបង្រួបបង្រួមដោយសារ ÷

### ក) បញ្ហាផ្នែកសម្ភារ

តាមការសិក្សារបស់ក្រុមឃ្លាំមើលផ្នែកសិទ្ធិមនុស្ស បន្ទាប់ពីអំពើប្រល័យពូជសាសន៍បានបញ្ចប់ ប្រជាជនរ៉្វាន់ដាទាមទាររកយុត្តិធម៌ ប៉ុន្តែត្រូវខកចិត្តដោយសារប្រព័ន្ធតុលាការក្នុងស្រុកមិនអាចជឿទុកចិត្តបាន ហើយតុលាការអន្តរជាតិមានលក្ខណៈយឺតយ៉ាវដោយសារកង្វះខាតថវិកា ។ នៅក្នុងដំណាក់កាលដំបូងបុគ្គលិកបម្រើការងារក្នុងតុលាការបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីរៀបចំការិយាល័យនិងការងាររដ្ឋបាល ។ ការខ្វះខាតសម្ភារដូចជាប៊ិច ក្រដាស និងអំពើពុករលួយ បានធ្វើឲ្យបុគ្គលិកបម្រើការងារមានការនឿយណាយ ។ ម្យ៉ាងទៀតតុលាការតែងតែជួបប្រទះបញ្ហាក្នុងការជួលបុគ្គលិក ដោយសារពេលនោះតុលាការត្រូវចំណាយពេលប្រមាណមួយឆ្នាំដើម្បីរង់ចាំការិយាល័យអគ្គការសហប្រជាជាតិសម្រេចចុះហត្ថលេខាជួលបុគ្គលិក ។ ថូម៉ាស ហ្វ្រើតមែន ប្រាប់ឲ្យដឹងថា «បន្ទាប់ពីមានអំពើប្រល័យពូជសាសន៍ ប្រជាជនរ៉្វាន់ដាស្រេកឃ្លានយុត្តិធម៌ ហើយទាមទារយុត្តិធម៌ដើម្បីរីសងសឹក ។ ប៉ុន្តែប្រជាជនទាំងនោះត្រូវខកចិត្តយ៉ាងខ្លាំងដោយសារភាពយឺតយ៉ាវរបស់តុលាការ» ។

### ខ) បញ្ហាផ្នែកប្រតិបត្តិការ

តុលាការព្រហ្មទណ្ឌអន្តរជាតិស្ថិតនៅក្រៅប្រទេស ឆ្ងាយពីប្រជាជន បណ្ដាលឲ្យប្រជាជនជួបប្រទះការលំបាកក្នុងការទាក់ទង ។ ម្យ៉ាងទៀត ប្រតិបត្តិការរបស់តុលាការក៏មានលក្ខណៈស្មុគស្មាញចំពោះប្រជាជនរ៉្វាន់ដាដែរ ។ ទម្លាប់របស់ប្រជាជនរ៉្វាន់ដាក្នុងការប្ដឹងផ្ដល់គឺ សរសេរពាក្យបណ្ដឹងរួចផ្ញើជូនតុលាការឬមេដឹកនាំភូមិឃុំដើម្បីដោះស្រាយ ។ ប៉ុន្តែតុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវឲ្យប្រជាជនទាក់ទងដោយផ្ទាល់ជាមួយក្រុមអ្នកច្បាប់បរទេសដែលគាត់មិនធ្លាប់ស្គាល់ពីមុនសោះ ។ ការចេញចូលធ្វើទំនាក់ទំនងជាមួយបុគ្គលិកទាំងនោះ ក៏មានភាពលំបាកនិងស្មុគស្មាញដែរ ។ ការិយាល័យរបស់មេធាវីស្ថិតនៅក្នុងទីក្រុង ហើយមានការយាមកាមយ៉ាងតឹងរ៉ឹងបំផុត ។ ប្រជាជនរ៉្វាន់ដាដែលមានបំណងទាក់ទងជាមួយអ្នកស៊ើបអង្កេតក្ដី គឺតែងតែត្រូវការអ្នកបកប្រែភាសា ។ លើសពីនេះ ប្រតិបត្តិការរបស់តុលាការមានលក្ខណៈមិនប្រក្រតីតាំងពីចាប់ដំណើរការដំបូងម្ល៉េះ ។ ឧទាហរណ៍ រីឆាដ ហ្គូលស្ដូន ដែលជាប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ហាក់ចាប់អារម្មណ៍ខ្លាំងលើដំណើរការកាត់ទោសឧក្រិដ្ឋជននៅប្រទេសយូហ្គូស្លាវីជាជាងនៅប្រទេសរ៉្វាន់ដា ។ លូស អាបួរ ដែលបន្តតំណែងពី ហ្គូលស្ដូន ខិតខំប្រមែប្រមូលក្ដីបញ្ចូលគ្នាដើម្បីបើកសវនាការក្នុងពេលតែមួយ ប៉ុន្តែការព្យាយាមរបស់គាត់ត្រូវបរាជ័យ ។ ព្រមពេលជាមួយគ្នានេះដែរ ការជំនុំជម្រះក្ដីត្រូវអូសបន្លាយពេលជាច្រើនលើការសិក្សាអំពីតួនាទីនិងការទទួលខុសត្រូវរបស់ចុងចោទ ។ អាលីសុន ដេសហ្វក ពន្យល់ថាបញ្ហាខាងលើធ្វើឲ្យប្រជាជនរ៉្វាន់ដាធុញទ្រាន់លែងចង់ប្ដឹងផ្ដល់ដោយគិតថា ការប្ដឹងផ្ដល់ធ្វើឲ្យគាត់កាន់តែលំបាកនិងឈឺចាប់ ។

### គ) គ្មានការពាក់ព័ន្ធ

ប្រជាជនរ៉្វាន់ដាភាគច្រើនគិតថា តុលាការព្រហ្មទណ្ឌអន្តរជាតិ

មិនមែនបង្កើតឡើងដើម្បីរកយុត្តិធម៌សម្រាប់ប្រជាជនឡើយ ដោយសារតែតុលាការមានទីតាំងនៅក្រៅប្រទេស ហើយប្រជាជនពុំបានដឹងច្បាស់អំពីប្រតិបត្តិការនិងអ្វីដែលបានកើតឡើងពិតប្រាកដ ។ ឧទាហរណ៍ មាត្រាមួយរបស់តុលាការបានចែងថា ឧក្រិដ្ឋជនអាចត្រូវឃុំឃាំងនៅក្នុងពន្ធនាគារក្នុងស្រុកនិងបរទេស អាស្រ័យតាមការជំនុំជម្រះរបស់តុលាការ ។ មាត្រានេះ ធ្វើឲ្យប្រជាជនរ៉ាន់ដាមិនសប្បាយចិត្តនិងខកចិត្ត ជាពិសេស ករណីការឃុំឃាំងខ្លួន យេនកាមបានដា និង ថេនេស្តេ បាហ្គូសូរ៉ា ។ មន្ទីរឃុំឃាំងខ្លួនជនឧក្រិដ្ឋទាំងពីរមានលក្ខណៈល្អប្រសើរជាងផ្ទះរបស់ជនរងគ្រោះទៅទៀត ។ ប្រជាជនមួយចំនួនទៀតមិនសប្បាយចិត្តចំពោះតុលាការ ដែលកាត់ទោសឲ្យមេដឹកនាំទាំងពីរជាប់ពន្ធនាគារអស់មួយជីវិត ចំណែកឯឧក្រិដ្ឋជនដែលអនុវត្តតាមបញ្ជារបស់ជនទាំងពីរនេះប្រឈមនឹងការកាត់ទោសប្រហារជីវិតដោយតុលាការក្នុងស្រុក ។

## ឃ) យុត្តិធម៌យឺតយ៉ាវ

ចាប់តាំងពីឆ្នាំ១៩៩៦មក តុលាការជំនុំជម្រះក្តីបានត្រឹមតែ៦ភាគរយនៃចំនួនជនសង្ស័យដែលបានចាប់ខ្លួនប៉ុណ្ណោះ ។ តុលាការត្រូវចំណាយពេលរាប់រយឆ្នាំទើបអាចជំនុំជម្រះក្តីអ្នកជាប់ឃុំឃាំងទាំងអស់ឲ្យចប់សព្វគ្រប់ ។ ជនសង្ស័យដែលជាប់ឃុំឃាំងមានចំនួន១ម៉ឺននាក់នៅឆ្នាំ១៩៩៤ ។ ចំនួនជនសង្ស័យបានកើនឡើងដល់១សែន២ម៉ឺន៥ពាន់នាក់នៅឆ្នាំ១៩៩៩ ។ ក្នុងចំនួនខាងលើនេះបុរសពេញកម្លាំងមានចំនួន១០ភាគរយនៃចំនួនប្រជាជនពេញកម្លាំងទូទាំងប្រទេស ។ ដោយសារការកើនឡើងនៃចំនួនជនសង្ស័យដែលត្រូវចាប់ខ្លួន មន្ទីរឃុំឃាំងអាចដាក់អ្នកទោសបាន១ម៉ឺន៥ពាន់នាក់ ត្រូវផ្ទុកលើសចំណុះនិងមានសភាពចង្អៀតណែនណាន់តាន់តាប់ ។ ចំណុចដែលគួរចាប់អារម្មណ៍មួយផ្សេងទៀតនោះគឺថា អ្នកទោសមួយចំនួនត្រូវបានឃុំឃាំងអស់រយៈពេលរាប់ឆ្នាំដោយខុសច្បាប់ និងដោយគ្មានការស្រាវជ្រាវច្បាស់លាស់ ។ ភាពចង្អៀតនិងគ្មានអនាម័យនៅក្នុងមន្ទីរឃុំឃាំងបណ្តាលឲ្យអ្នកទោសធ្លាក់ខ្លួនឈឺហើយស្លាប់ជាបន្តបន្ទាប់នៅមុនពេលជំនុំជម្រះក្តី ។ ឧទាហរណ៍មន្ទីរឃុំឃាំងនៅគីបូយេ ដែលសាងសង់សម្រាប់ឃុំឃាំងអ្នកទោសចំនួន៨រយនាក់ ប៉ុន្តែជាក់ស្តែងត្រូវផ្ទុកអ្នកទោសរហូតដល់៣១៩៧នាក់ ។ មាត្រដ្ឋានសម្រាប់អ្នកទោសក្នុងមន្ទីរឃុំឃាំងនេះគឺ៥នាក់ក្នុងមួយម៉ែត្រការ៉េ ដូច្នេះអ្នកទោសត្រូវដេកលើគ្រែដែលបន្តុបពីលើគ្នាជាច្រើនជាន់ ហើយអ្នកទោសមិនអាចអង្គុយទាំងអស់គ្នាក្នុងពេលតែមួយឡើយ ។ អ្នកទោសខ្លះត្រូវដេកនៅពេលដែលអ្នកទោសខ្លះអង្គុយ ។ អ្នកទោសទាំងអស់រស់នៅក្នុងសភាពចង្អៀតនិងលំបាកបែបនេះអស់រយៈពេលជិត៨ឆ្នាំមកហើយ ដើម្បីរង់ចាំពេលវេលាតុលាការជំនុំជម្រះក្តីរបស់ខ្លួន ។

ភាពស្ងៀមស្ងាត់មិនជជែករកដំណោះស្រាយ មិនអាចជួយធ្វើឲ្យដំណើរការផ្សះផ្សារាបផ្សួបបង្រួមលឿនទៅមុខ ហើយការយឺតយ៉ាវក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ គឺកាន់តែមិនអាចជួយដល់ដំណើរការផ្សះផ្សារាបផ្សួបបង្រួមទាល់តែសោះ ។

## ង) យុត្តិធម៌របស់អ្នកឈ្នះ

តុលាការអាចផ្តល់យុត្តិធម៌ ប៉ុន្តែមិនអាចរកឃើញការពិតឡើយ ។ យុត្តិធម៌តាមផ្លូវតុលាការគឺជាយុត្តិធម៌សម្រាប់តែអ្នកឈ្នះប៉ុណ្ណោះ ។ ជាក់ស្តែង នៅពេលសួរបញ្ជាក់អំពីចំណាប់អារម្មណ៍របស់គាត់ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនជាតិហ៊ូទូម្នាក់បាននិយាយថា “យុត្តិធម៌ដែលផ្តល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាយុត្តិធម៌របស់ឈ្នះ ។ ខ្ញុំចង់និយាយថា វាមិនមែនជាយុត្តិធម៌ទេ ប៉ុន្តែគឺជាការសងសឹករបស់អ្នកឈ្នះទៅលើអ្នកចាញ់” ។ **(នៅមានត)**

**អៀ ម៉េងទ្រី**

## ពាក្យស្លោកខ្មែរក្រហម

◆ នៅពេលដែលពពកពោរពេញទៅដោយខ្លាំងក្រាស់ យើងសង្កេតឃើញថាភាពងងឹតនេះគ្រាន់តែជាការបណ្តោះអាសន្នទេក្នុងពេលឆាប់ៗនេះ មុខតែនឹងឃើញពន្លឺថ្ងៃភ្លឺឡើងវិញ។

(កំណត់ហេតុលេខ០៥៣)

# គ្រួសារខ្ញុំនៅក្នុងរបបអន្ធការ

ក្នុងឆ្នាំ១៩៧៣ សង្គ្រាមរវាងរដ្ឋាភិបាល លន់ ណុល និងខ្មែរក្រហមកាន់តែរីករាលខ្លាំងឡើងៗ ។ គ្រប់ប្រព័ន្ធគមនាគមន៍និងជំនួញទាំងក្នុងនិងក្រៅប្រទេសត្រូវកាត់ផ្ដាច់ ។ លុះដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមដណ្ដើមអំណាចបានទាំងស្រុងនៅក្នុងកណ្ដាប់ដៃ ។

ប្រជាជនទូទាំងប្រទេសសប្បាយរីករាយ ហើយអបអរសាទរនឹងកងទ័ពខ្មែរក្រហមដែលគាត់គិតថានាំសន្តិភាពមកឲ្យប្រទេសកម្ពុជា ។ ទីបំផុតប្រជាជនកម្ពុជាបែរជាត្រូវរងទុក្ខពីលើសពីពេលមុនទៅទៀត ។ អង្គការបានចាប់ផ្ដើមជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ ។ សូរគ្រាប់កាំភ្លើងបានលាន់ឮយ៉ាងសន្ធាប់គំរាមប្រជាជនចេញពីទីក្រុងឲ្យបានឆាប់ជាទីបំផុត ។ ក្រុមគ្រួសារខ្ញុំត្រូវអង្គការជម្លៀសទៅដល់ស្រុកសិរីសោភ័ណ ឃុំចង្ហារ ភូមិតាជ្រីង ខេត្តបន្ទាយមានជ័យ ។ នៅតាមផ្លូវ កងទ័ពប្រដាប់ដោយអាវុធគ្រប់ដៃឈរចាំគំរាមប្រជាជនឲ្យធ្វើដំណើរតាមទិសដែលអង្គការបានកំណត់ ជាមួយនឹងសាកសពរណ្ដូករណែលនៅតាមដងផ្លូវ ។ គ្រួសារជម្លៀសទាំងអស់ត្រូវធ្វើដំណើរឆ្លងកាត់វាលសាកសពនេះចម្ងាយប្រមាណមួយគីឡូម៉ែត្រ ។ ឪពុកខ្ញុំបណ្ដើរម៉ូតូវេស្ប៉ា ដោយមានដុកអង្ករនិងរូបខ្ញុំ ចំណែកបងប្រុសបីនាក់ដើរជាមួយម្ដាយខ្ញុំ ។ យើងធ្វើដំណើរក្រោមភ្លៀងរលឹមស្រិចៗ ។

មកដល់ស្រុកសិរីសោភ័ណ ក្រុមគ្រួសារខ្ញុំត្រូវបំបែកគ្នា ។ បងប្រុសពីរនាក់បែកទៅជាមួយម្ដាយខ្ញុំ ចំណែកខ្ញុំនិងបងប្រុសបន្ទាប់នៅជាមួយឪពុក ។ ដល់ពេលព្រលប់ទើបឪពុកខ្ញុំមកយកខ្ញុំនិងបងប្រុសទៅស្នាក់នៅភូមិអូរអំបិល បន្ទាប់មកគាត់ទៅតាមរកម្ដាយខ្ញុំរហូតដល់ស្រុកព្រះនេត្រព្រះ ប៉ុន្តែរកមិនឃើញ ។ ម្ដាយខ្ញុំមករកដល់ភូមិព្រហូត ។ នៅទីបំផុតក្រុមគ្រួសារយើងបានជួបជុំគ្នានៅម៉ោង៨យប់ ។ ព្រលឹមឡើងយើងបានបន្តដំណើរទៅដល់ភូមិតាជ្រីង ។ គ្រាន់តែមកដល់ភូមិតាជ្រីងភ្លាម កងឈ្លប៤នាក់បានមកហៅឪពុកខ្ញុំថា “មិត្តៗអង្គការឲ្យមិត្តទៅរៀនសូត្រមួយរយៈចាំត្រឡប់មកវិញ ព្រោះមិត្តជាគ្រុបជ្រៀន” ។ តាមការពិត កងឈ្លបទាំងនោះមិនបានយកឪពុកខ្ញុំទៅរៀនទេ គឺយកគាត់ទៅលត់ដំឲ្យបោចវល្លិ៍នៅក្នុងព្រៃកូនខ្លាទៅវិញ ។ អ្នកដែលចូលព្រៃកូនខ្លាហើយច្បាស់ជាត្រូវស្លាប់ ដោយមិនចាំបាច់សម្លាប់ឡើយ ។ ព្រៃកូនខ្លាជាមណ្ឌលសម្លាប់មនុស្សតាមវិធីគ្រប់បែបយ៉ាង សម្លាប់ដោយផ្ទាល់ឬដោយប្រយោលគឺមានជាប្រចាំ ។ ឪពុកខ្ញុំត្រូវខ្មែរក្រហមធ្វើទារុណកម្មដោយឲ្យបោចវល្លិ៍ក្នុងមួយថ្ងៃឲ្យបានបីរទេះ បើមិនបាន នឹងត្រូវវាយ២០រំពាត់ រីឯរបបវិញគឺអង្ករ១០កំប៉ុងសម្រាប់មួយខែ ។ ចំណែកប្រពន្ធកូននៅផ្ទះត្រូវបង្អត់អាហារព្រោះថាជាក្រុមគ្រួសារគ្រុបជ្រៀន គឺជាជនក្បត់នឹងអង្គការ ជាជនមូលធន ត្រូវតែទទួលទណ្ឌកម្មបែបនេះ ។

យប់មួយ ឪពុកខ្ញុំមានជំងឺគ្រុនចាញ់កំពុងដេកស្ដូកស្ដឹងនៅកណ្ដាលទ្រុងព្រៃ ។ គាត់បានឮសំឡេងបុរសម្នាក់ស្រែកយ៉ាងអាណោចអធ័ម ។ បុរសនោះត្រូវកងទ័ពខ្មែរក្រហមយកមកវាយសម្លាប់នៅកណ្ដាលព្រៃកូនខ្លា ពេលមេឃកំពុងភ្លៀងរលឹម ។

ពីមួយថ្ងៃទៅមួយថ្ងៃ ឪពុកខ្ញុំរស់នៅយ៉ាងសែនលំបាកវេទនា ។ ខ្មែរក្រហមបានប្រាប់ឪពុកខ្ញុំថា “មិត្តត្រូវកសាងខ្លួនឲ្យល្អឲ្យស្អាតស្អំ ព្រោះមិត្តឯងជាពួកមូលធន” ។ ក្នុងមួយថ្ងៃខ្មែរក្រហមធ្វើទារុណកម្មឪពុកខ្ញុំបីដង ។ ឪពុកខ្ញុំទ្រាំតស៊ូរស់ទាំងត្រដរ ក្រែងមានឱកាសបានជួបជុំគ្រួសារទៅថ្ងៃក្រោយ ។ ចំណែកម្ដាយខ្ញុំ អង្គការបានចាត់តាំងឲ្យគាត់មើលថែទាំដាក់បាយជ្រូកនៅក្នុងភូមិ ។

ឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមបានបញ្ជូនឪពុកខ្ញុំត្រឡប់មកភូមិតាជ្រីងវិញ ។ ម្ដាយខ្ញុំស្រឡាំងកាំងនៅពេលដែលឃើញរូបរាងកាយដ៏ស្គាំងស្គមរបស់ឪពុកខ្ញុំ ។ នៅពេលដែលឪពុកខ្ញុំសួរថា “តើកូនយើងទៅណាអស់ហើយ?” ម្ដាយខ្ញុំគ្មានចម្លើយ

ក្រៅពីបង្ហូរទឹកភ្នែកឡើយ ។

បងប្រុសទី១របស់ខ្ញុំត្រូវអង្គការបញ្ចូលទៅក្នុងកងកម្លាំងស្រួច ត្រូវបញ្ជូនទៅលើកដីជីកប្រឡាយនៅភ្នំកូនខ្វែង ខាងត្បូងខេត្តសៀមរាប ។ ភ្នំកូនខ្វែងគឺជាតំបន់ដែលហួតហែងបំផុត សូម្បីតែមើមឈើសម្រាប់រកធ្វើជាអាហារក៏គ្មានដែរ ។ បងខ្ញុំបានទទួលរបបបបរតែមួយវែកក្នុងមួយថ្ងៃ និងទឹកមួយគម្របប៊ីដុងសម្រាប់ផ្សើមបំពង់កតែប៉ុណ្ណោះ ។ របបដ៏តិចតួចបំផុតនេះធ្វើឲ្យបងប្រុសរបស់ខ្ញុំកើតការស្រេកឃ្លានយ៉ាងខ្លាំង ។ គាត់បានដើររកចំណីអាហារគ្រប់ទីកន្លែង ។ ថ្ងៃមួយបងប្រុសខ្ញុំបានពុលមើមឈើរហូតដល់ចេញឈាមតាមរោម ។ អង្គការបានបញ្ជូនបងប្រុសរបស់ខ្ញុំមកទុកចោលនៅសាលខ្មោចនៃមន្ទីរពេទ្យស្រុកសិរីសោភ័ណដោយគ្មានការផ្តល់ការជួយសង្គ្រោះសូម្បីតែបន្តិចឡើយ ។

នៅពេលទទួលដំណឹងនេះ ម្តាយខ្ញុំបានសុំអនុញ្ញាតិពីអង្គការដើម្បីទៅយកបងប្រុសត្រឡប់មកផ្ទះវិញ ប៉ុន្តែម្តាយខ្ញុំត្រូវទទួលការស្តីឲ្យថា «មីពួកមូលធន មនុស្សជិតស្លាប់ហើយយកទៅបានការអី? នៅធ្វើការវិញវាចំណេញជាង ទោះជាយកវាទៅ ក៏មិនចំណេញដែរ ។ មនុស្សដូចកូននាងឯងនេះទុកក៏មិនចំណេញដកចេញក៏មិនខាតដែរ» ។ ទោះបីជាអង្គការមិនអនុញ្ញាតឲ្យទៅក៏ដោយ ក៏ម្តាយខ្ញុំខំពុះពារលួចរត់ទៅរកកូនទាំងកណ្តាលអធ្រាត្រដើរលេចវាលចូលព្រៃនិងឡើងកាត់បង្កេះភ្នំកងវ៉ា ដើម្បីបានទៅដល់មន្ទីរពេទ្យ ។ ម្តាយខ្ញុំខ្លោចចិត្តនៅពេលឃើញបងប្រុសខ្ញុំនៅក្នុងសាលខ្មោច កំពុងតែអង្គុយត្រដោមក្បាលជង្គង់ទាំងទឹកភ្នែកហូររហាម ។ បងប្រុសដ៏កម្សត់របស់ខ្ញុំបានលូនមករកម្តាយ ។ ម្តាយខ្ញុំអៀវបងប្រុសខ្ញុំពីសាលខ្មោច ដើម្បីទៅសុំការអនុញ្ញាតពីគ្រូពេទ្យ ។ គ្រូពេទ្យបានស្តីឲ្យគាត់ថា «ន៎ែមិត្ត! មិត្តឯងយកវាចេញ មិត្តឯងទទួលខុសត្រូវណ៎ា? ព្រោះវាជាខ្មោចរបស់អង្គការ» ។ ម្តាយខ្ញុំស្លុតចិត្តនៅពេលដែលឮពាក្យថា «ខ្មោច» ព្រោះកូនរបស់គាត់មិនទាន់ស្លាប់ឯណា ។ ម្តាយខ្ញុំឆ្លើយតបទៅវិញថា «ខ្ញុំនឹងទទួលរ៉ាប់រង» ។

នៅពេលមកដល់ភូមិម្តាយខ្ញុំត្រូវមេកងបន្ទោសថា «មិត្តឯងយកវាមកនេះ មិត្តឯងមានបបរឯណាឲ្យវាស៊ី បើមិនបានទៅធ្វើការផងនោះ?» ។ ម្តាយខ្ញុំឆ្លើយទៅវិញថាគាត់សុខចិត្តប្រគល់របបរបស់គាត់ឲ្យកូនហូប ។ បងខ្ញុំមិនទាន់បានទាំងជាសះស្បើយពីជំងឺស្រួលបួលផង ស្រាប់តែមេកងហៅគាត់ទៅភ្ជួរស្រែរហូតដល់លាប់ជំងឺ ។ ទីបំផុតបងប្រុសរបស់ខ្ញុំក៏លាចាកលោកទៅ ។

ក្រោយមកអង្គការបានហៅឪពុកខ្ញុំទៅប្រជុំ ដើម្បីស្រង់ឈ្មោះគ្រូបង្រៀនដើម្បីយកទៅសម្លាប់ ។ ក្នុងរយៈពេលនោះម្តាយខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យទៅជួបឪពុកខ្ញុំទេ ។ ប៉ុន្តែសំណាងល្អនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានរួចចាកផុតពីគន្លាប់ដែកនៃរបបខ្មែរក្រហម ។ ជីវិតឪពុកនិងបងប្រុសទី២របស់ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ ។ គ្រួសាររបស់ខ្ញុំក៏បានរស់នៅជួបជុំគ្នាវិញ ។

**និល គន្ធា**


ការដ្ឋានជីកប្រឡាយមួយនៅក្នុងរបបខ្មែរក្រហម

# សំពះតែរូបថត

កាលពីរដូវភ្ជុំបិណ្ឌដែលទើបតែកន្លងទៅថ្មីៗនេះ ក្រុមគ្រួសាររបស់ខ្ញុំបានធ្វើម្ហូបអាហារយកទៅប្រគេនព្រះសង្ឃនៅវត្តតាភេម នៅក្នុងស្រុកអង្គស្នួល ខេត្តកំពង់ស្ពឺ និងវត្ត៤ទៀតនៅក្នុងខេត្តកំពង់ធំនិងកំពង់ចាម ដើម្បីឧទ្ទិសកុសលទៅឲ្យញាតិសន្តានដែលបានស្លាប់ទៅ ជាពិសេសឧទ្ទិសកុសលទៅដល់លោកតានិងពូរបស់ខ្ញុំដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនៅខេត្តព្រះវិហារកាលពីឆ្នាំ១៩៧៦ ។


ឡៅ សៀវខូវ មុនឆ្នាំ១៩៧៥

ជីតារបស់ខ្ញុំឈ្មោះ ឡៅ សៀវខូវ និងកូនប្រុស៣នាក់ បានធ្វើដំណើរទៅលេងបងប្អូននៅខេត្តកំពង់ធំ កាលពីឆ្នាំ ១៩៧០ ក្នុងខណៈពេលដែលលោកយាយរបស់ខ្ញុំរស់នៅក្នុងទីក្រុងភ្នំពេញជាមួយកូនស្រី២នាក់ទៀត ។ បន្ទាប់ពីស្នាក់នៅខេត្តកំពង់ធំបានរយៈពេល១ខែ ដោយសារក្នុងខេត្តមានការប្រយុទ្ធខ្លាំងក្លារវាងកងទ័ពរំដោះខ្មែរក្រហមនិងកងកម្លាំងសាធារណរដ្ឋខ្មែរ លោកតាបាននាំកូនប្រុសទាំង៣នាក់បន្តដំណើរទៅខេត្តព្រះវិហារ ហើយក៏ជាប់នៅទីនោះមិនអាចវិលត្រឡប់មកវិញបាន ។

នៅឆ្នាំ១៩៧២ ខេត្តព្រះវិហារ ដែលក្លាយទៅជាតំបន់រំដោះតាំងពីឆ្នាំ១៩៧០នោះ បានបែងចែកប្រជាជនឲ្យរស់នៅក្នុងសហករណ៍ហូបបាយរួមនិងធ្វើការងាររួមរួចទៅហើយ ។ ពេលនោះកូនប្រុសច្បងរបស់លោកតាខ្ញុំ (អ៊ំរបស់ខ្ញុំ) បានចូលធ្វើការនៅក្នុងក្រុមសិល្បៈនៅភូមិសុច ឃុំស្តៅ ស្រុកសង្គមថ្មី ។ លោកតាត្រូវបានអង្គការបែងចែកឲ្យធ្វើការងារជាអ្នកដាំបន្លែនៅសហករណ៍ភូមិគូលែន កូនប្រុសទី២ឃ្វាលគោ ចំណែកកូនប្រុសពៅរបស់គាត់បានបាត់បង់ជីវិតដោយសារជំងឺគ្រុនចាញ់ ។

កូនប្រុសច្បងរបស់លោកតាបានត្រឡប់មកយកឪពុកនិងប្អូនប្រុសទៅរស់នៅជួបជុំគ្នានៅភូមិសុចវិញ ។ រស់នៅភូមិសុច លោកតាត្រូវបានចាត់តាំងឲ្យធ្វើការងារជាអ្នកកើបអាចម៍គោធ្វើជី កូនប្រុសច្បងជាអ្នកធ្វើស្រែចម្ការនិងកូនប្រុសទី២ជាកុមារឃ្វាលគោ ។ នៅឆ្នាំ១៩៧៦ លោកតាបានស្លាប់ដោយសារជំងឺ ព្រោះគ្មានថ្នាំព្យាបាល និងនឹករឭកប្រពន្ធកូនដែលបានបែកគ្នាយូរឆ្នាំមកហើយ ។ នៅពេលដែលលោកតាស្លាប់ ខ្មែរក្រហមមិនអនុញ្ញាតឲ្យកូនប្រុសទាំងពីរនាក់របស់គាត់ធ្វើពិធីបុណ្យសពឡើយ គ្រាន់តែឲ្យអង្ករបន្តិចបន្តួចដើម្បីដាំបាយចែកដល់អ្នកភូមិដែលជួយយកសពទៅកប់តែប៉ុណ្ណោះ ។

ក្នុងខណៈដែលលោកតានិងកូនប្រុសរស់នៅខេត្តព្រះវិហារ លោកយាយនិងកូនស្រី២នាក់ត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅស្រុកតាំងគោក ខេត្តកំពង់ធំ ។ លោកយាយខិតខំស៊ើបសួរដំណឹងអំពីលោកតាដែរ ប៉ុន្តែគ្មានបានដំណឹងអ្វីបន្តិចសោះ ។ រហូតដល់ឆ្នាំ១៩៧៩ ក្រោយពេលដែលរបបខ្មែរក្រហមដួលរលំ លោកយាយនិងកូនស្រីទាំង២បានសម្រេចចិត្តធ្វើដំណើរទៅទីរួមខេត្តកំពង់ធំ ដើម្បីស្វែងរកលោកតានិងកូនប្រុសទាំង៣នាក់ ។ នៅពេលទៅដល់ទីរួមខេត្តកំពង់ធំ លោកយាយបានទទួលដំណឹងតាមរយៈបងប្អូននៅទីនោះថា លោកតានិងកូនប្រុសបានធ្វើដំណើរទៅខេត្តព្រះវិហារតាំងពីពេលមកដល់ខេត្តកំពង់ធំបានតែរយៈពេល១ខែម៉្លេះ ។ លោកយាយក៏សម្រេចចិត្តបន្តដំណើរទៅខេត្តព្រះវិហារទៀត ដោយនឹកសង្ឃឹមក្នុងចិត្តថានឹងបានជួបប្តីនិងកូនប្រុស ប៉ុន្តែគួរឲ្យសោកស្តាយ លោកយាយបានត្រឹមតែឃើញពំនូកដីដែលកប់សាកសពលោកតាតែប៉ុណ្ណោះ ។ ពេលនោះលោកយាយមិនទាន់យកធាតុរបស់លោកតាមកទីក្រុងភ្នំពេញភ្លាមៗទេ ពីព្រោះមិនទាន់មានផ្ទះសម្បែងត្រឹមត្រូវ ។ លោកយាយគិតថា នៅពេលមកដល់ទីក្រុងភ្នំពេញនិងរកផ្ទះសម្បែងរស់នៅបានស្រួលបួលហើយ គាត់នឹងត្រឡប់ទៅយក

ធាតុលោកតាមកធ្វើបុណ្យ ។ លោកយាយយកតែដីមួយផង់តូចជាតំណាងធាតុរបស់លោកតា ។

នៅពេលត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ លោកយាយបាននាំកូនៗ ទៅរកផ្ទះដែលគាត់ធ្លាប់រស់នៅជួបជុំជាមួយលោកតា នៅសង្កាត់ទួលគោក ប៉ុន្តែផ្ទះនោះត្រូវបានអ្នកដទៃយកធ្វើជាកម្មសិទ្ធិរួចស្រេចទៅហើយ ។ លោកយាយក៏បែរមកចាប់យកផ្ទះល្វែងនៅកណ្តាលទីក្រុងវិញ ។ បន្ទាប់ពីរៀបចំផ្ទះសម្បែងនៅស្រួលបួលហើយ លោកយាយមានបំណងវិលទៅគាស់ផ្នូរលោកតាដើម្បីយកធាតុមកធ្វើបុណ្យ ប៉ុន្តែទីនោះបានក្លាយទៅជាចម្ការមីនដែលមិនអាចឆ្លងកាត់បាន ។

នៅឆ្នាំ១៩៩៤ លោកយាយក៏ទទួលមរណភាពដោយជរាពាធ គឺស្លាប់មុនពេលដែលគាត់បានយកធាតុលោកតាមកធ្វើបុណ្យ ។ លោកយាយស្លាប់ទៅទាំងមិនអស់ចិត្ត ។ កូនចៅទាំងអស់បានយកធាតុរបស់លោកយាយ ទៅបញ្ចុះក្នុងចេតិយមួយនៅវត្តតាភេមជាមួយនឹងកោដិមួយដែលដាក់ ដីជំនួសធាតុរបស់លោកតានិងរូបថតពាក់កណ្តាលខ្លួនមួយសន្លឹក ហើយធាតុរបស់លោកតាខ្ញុំស្ថិតនៅក្នុងភូមិសុចស្រុកសង្គមថ្មី ខេត្តព្រះវិហារ នៅឡើយ ។ រហូតមកដល់បច្ចុប្បន្ន ក្រុមគ្រួសាររបស់ខ្ញុំនៅតែមិនអាចយកធាតុរបស់លោតាមកពីខេត្តព្រះវិហារដដែល ។

តាំងពីខ្ញុំកើតដឹងក្តីរហូតមកដល់បច្ចុប្បន្ននេះ ខ្ញុំមិនដែលបានស្គាល់លោកតារបស់ខ្ញុំឡើយ ។ ខ្ញុំបានឃើញតែរូបថតនិងដឹងរឿងរ៉ាវរបស់លោកតាតាមរយៈការដំណាលប្រាប់របស់លោកយាយនិងម្តាយរបស់ខ្ញុំតែប៉ុណ្ណោះ ។ កាលលោកយាយនៅរស់ គាត់តែងតែរំឭកអំពីលោកតាប្រាប់ចៅៗជារឿយៗ ។ គាត់សម្តែងការសោកស្តាយខ្លាំងណាស់ដែលមិនមានលទ្ធភាពទៅយកធាតុរបស់លោកតាមកធ្វើបុណ្យ ។

ដូចជារដូវភ្ជុំឆ្នាំមុនៗដែរ ឆ្នាំនេះក្រុមគ្រួសាររបស់ខ្ញុំបានត្រឹមតែសំពះរូបថតរបស់លោកតាដែលដាក់តាំងនៅមុខចេតិយ ហើយក៏មិនដឹងថាដល់ពេលណាទើបយើងអាចទៅយកធាតុរបស់លោកតាមកគោរពបូជាបាន ។**ប៉ាង ពីច័ន**

# សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

*សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ* **"វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ"** *ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷*

- *រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។*
- *ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការឈឺចុកចាប់ មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។*
- *ការចងចាំ គឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។*
- *ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។*

*សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។*

*សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី "ស្វែងរកការពិត" ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។*

*សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៤៣ ០៧២ និង០១២ ៩៨៤ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។*

**យូ បូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ម្តាយខ្ញុំ

ម្តាយរបស់ខ្ញុំឈ្មោះ ជុំ សារិន បច្ចុប្បន្នមានអាយុ៥២ឆ្នាំ ។ គាត់ជាអ្នកម្តាយមួយរូបដែលមានព្រហ្មវិហារធម៌ចំពោះកូនៗ ។ ទោះបីម្តាយខ្ញុំមានវ័យចំណាស់ទៅហើយក្តី ក៏គាត់នៅមានការបងចាំល្អ និងនៅតែរស់រវើកក្នុងការរករកប្រាក់កម្រៃចិញ្ចឹមកូនៗទាំងអស់ឲ្យបានរៀនបានសូត្ររហូតដល់មានការងារធ្វើគ្រប់ៗគ្នា ។

មុនការមកដល់នៃរបបខ្មែរក្រហម ក្រុមគ្រួសារម្តាយខ្ញុំជាគ្រួសារអ្នកមានជីវភាពធូរធាររមធ្យមនៅក្នុងសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ គាត់មានប្តីនិងកូនតូចៗចំនួន៤នាក់ ។ ក្នុងឆ្នាំ១៩៧៥ កូនច្បងទើបតែមានអាយុ៨ឆ្នាំ រីឯកូនតូចបង្អស់ទើបតែមានអាយុ១ខែកន្លះប៉ុណ្ណោះ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ម្តាយខ្ញុំត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ម្តាយរបស់ខ្ញុំដែលនៅសរសៃខ្ចីនៅឡើយបានធ្វើដំណើរទៅជាមួយគ្រួសារដែលមានសមាជិក១០នាក់ ក្នុងនោះមានម្តាយក្មេក ឪពុកក្មេក ព្រមទាំងក្មួយពីរនាក់ផង ឆ្ពោះទៅស្រុកកំណើតនៅភូមិសែនកៀស ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ។ នៅពេលឈប់សម្រាកម្តាយខ្ញុំបានទៅដួសទឹកអណ្តូងនៅតាមផ្លូវមកដាំបាយហូប ដោយមិនបានដឹងថានៅក្នុងអណ្តូងនោះពោរពេញដោយសាកសព រីឯទឹកដែលគាត់បានបរិភោគជាទឹកគំរង់ខ្មោចឡើយ ។ ពេលទៅដល់ស្រុកកំណើតក្រុមគ្រួសាររបស់ម្តាយខ្ញុំត្រូវមេភូមិចាត់ឲ្យរស់នៅក្នុងផ្ទះមួយដែលអង្គការរៀបចំសម្រាប់អ្នក១៧មេសា ។ សមាជិកទាំងអស់ក្នុងគ្រួសារត្រូវជីកព្រែកជីកប្រឡាយប្រព័ន្ធភ្លឺគ្មានឈប់ឈរ ។ ម្តាយខ្ញុំទុកកូនតូចៗរបស់គាត់ឲ្យជីដូនមើលថែ ហើយខ្លួនគាត់ចេញទៅធ្វើការរហូតដល់ពេលថ្ងៃត្រង់ទើបត្រឡប់មកហូបបាយថ្ងៃត្រង់ និងឆ្លៀតបំបៅកូនរួចចេញទៅធ្វើការទៀត ។ រយៈពេល៣ខែក្រោយមក កូន


ក្រុមគ្រួសារ មាស ប៊ុនថាន ក្នុងឆ្នាំ១៩៨៩



ជុំ សារិន

ប្រុសទី២ ដែលមានអាយុ ៣ឆ្នាំក៏ស្លាប់ទៅហើយ នៅចុងឆ្នាំ១៩៧៧ កូនស្រីទី៣ដែលកើតជំងឺពិស បានស្លាប់យ៉ាងទាន់ហន់ដោយសារការចាក់ថ្នាំរបស់កម្មាភិបាលពេទ្យឃុំ ។ ម្តាយរបស់ខ្ញុំដែលត្រូវបាត់បង់កូនជាទីស្រឡាញ់ជាបន្តបន្ទាប់ គ្មានធ្វើអ្វីកើតក្រៅតែពីទ្រហោយំរៀបចំសាកសពកូនស្រីដោយដាក់ទៅជាមួយនូវសំពត់អាវស្អាតៗ និងសុំឲ្យពេទ្យនៅទីនោះជួយយកកូនទៅកប់ឡើយ ។ ពេទ្យទាំងនោះមិនបានយកសពទៅកប់ឲ្យបានត្រឹមត្រូវទេ ផ្ទុយទៅវិញបែរជាយកសំពត់អាវដែលម្តាយខ្ញុំទុកដាក់ឲ្យសពទៅចែកគ្នា ហើយទុកសាកសព បងខ្ញុំឲ្យសត្វឆ្កែខាំអូសយ៉ាងអនិច្ចា ។ មិនយូរប៉ុន្មាននៅដើមឆ្នាំ១៩៧៨ កូនទី៤ដែលនៅតូចក៏ត្រូវស្លាប់ទៀតដោយសារតែខ្វះជាតិទឹកដោះ ។ ដំណាលគ្នាក្នុងឆ្នាំ១៩៧៨នោះ ឪពុកក្មេក ម្តាយក្មេក និងប្តីរបស់ម្តាយខ្ញុំ ក៏ត្រូវខ្មែរក្រហមចោទប្រកាន់ថាជាជនមានកម្មសិទ្ធិក្រាស់និងជាសេ.អ៊ី.អារបស់អាមេរិកាំង ហើយបានចាប់យកទៅសម្លាប់ចោលជាបន្តបន្ទាប់ ។ លើសពីនោះទៀត ក្នុងមូលដ្ឋានឃុំទ្រាដដែលនេះ ម្តាយខ្ញុំបានបាត់បង់បងប្អូន៥នាក់ក្នុងចំណោម១១នាក់ ព្រមទាំងឪពុកម្តាយបង្កើតដោយខ្មែរក្រហមយកទៅសម្លាប់ចោល ។ ទីបំផុត ម្តាយខ្ញុំនៅសល់តែកូនស្រីច្បងម្នាក់គត់ដែលរស់នៅជាមួយគាត់យ៉ាងត្រមង់ត្រមោច ដោយខំប្រឹងធ្វើការទាំងថ្ងៃទាំងយប់ជាថ្នូរនឹងការរស់រានមានជីវិត ។

រឿងរ៉ាវទាំងនេះសុទ្ធតែជាទុក្ខវេទនានិរាសព្រាត់ប្រាសដែលម្តាយរបស់ខ្ញុំបានទទួលរង ។ ចេញពីគ្រួសារដ៏សុខសាន្តមានជីវភាពរស់នៅសមរម្យ មកជាស្ត្រីមេម៉ាយគ្មានសេសសល់អ្វីសោះ ម្តាយខ្ញុំបានបាត់បង់ឪពុកម្តាយជាទីគោរព បងប្អូន កូន និងប្តីជាទីស្រឡាញ់របស់គាត់ ដោយគ្មានថ្ងៃជួបវិញ ។ ពេលចេញពីភ្នំពេញទៅមានគ្នាជាង១០នាក់ ពេលត្រឡប់មកវិញមានគ្នាតែ២នាក់ប៉ុណ្ណោះ ។ ទោះបីជារឿងនេះកន្លងផុតជាច្រើនឆ្នាំមកហើយក៏ដោយ ក៏ម្តាយខ្ញុំតែងតែនឹកឃើញមិនភ្លេចនូវសោកនាដកម្មដែលខ្មែរក្រហមបានធ្វើមកលើក្រុមគ្រួសាររបស់គាត់ ។ ខ្ញុំស្មានមិនដល់ថាម្តាយរបស់ខ្ញុំអាចទ្រាំទ្រនឹងភាពលំបាកវេទនាដ៏ធ្ងន់ធ្ងរនៅពេលនោះ ហើយរក្សាជីវិតរស់ដល់សព្វថ្ងៃ ។ ម្តាយខ្ញុំរស់នៅក្នុងស្រមោលនៃអតីតកាលរបស់គាត់ ។ ចុះមេដឹកនាំខ្មែរក្រហមដែលកំពុងតែរស់នៅយ៉ាងមានសេរីភាព មាននឹកឃើញដល់អំពើរបស់ខ្លួនពីអតីតកាលដែរឬទេ?

ក្នុងនាមជាកូនរបស់ជនរងគ្រោះម្នាក់ ខ្ញុំរំពឹងក្នុងចិត្តថាតុលាការឯករាជ្យមួយនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗនេះ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលជាស្ថាបនិកនៃវាលពិឃាត ដែលបានបំផ្លាញជីវិតសមាជិកក្រុមគ្រួសារម្តាយខ្ញុំនិងប្រជាជនជិត២លាននាក់ ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះខ្មែរដែលស្លាប់ទៅទាំងគ្មានកំហុស ទាំងមិនអស់ចិត្ត ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះលែងវិលវល់នៅក្នុងលោកនេះ និងទៅកាន់សុគតិភពជារៀងរហូត ។ រូបខ្ញុំផ្ទាល់និងម្តាយខ្ញុំ ក៏ដូចប្រជាជនកម្ពុជាទាំងអស់ដែលនៅរស់រានមានជីវិត មិនចង់ឲ្យរបបប្រល័យពូជសាសន៍នេះកើតមានសាជាថ្មីឡើយ ទោះជានៅកម្ពុជាឬនៅទីកន្លែងណាក៏ដោយ ។

**មាស ប៊ុនថាន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ


ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនិងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of *Searching for the Truth!*. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 46, October 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**